# សង្កេតការណ៍ ២១

## ជំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



ពីឆ្វេងទៅស្តាំ ៖ ចៅ សេង, ហ៊ូ នឹម, ហ៊ូ យន់ (ស្តាំបង្អស់) ក្នុងឆ្នាំ ១៩៧៤ ក្នុងតំបន់រំដោះខ្មែរក្រហម ។ ហ៊ូ នឹម បានផ្ញើរូបថតនេះជូន ចៅ សេង នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៤ ។ នៅខាងក្រោយរូបថតនេះ ហ៊ូ នឹម បានសរសេរថា "...កាលណារំដោះភ្នំពេញ យើងច្បាស់ជាជួបជុំគ្នាដោយសេចក្តីរីករាយជាទីបំផុត" ។

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org

ខែមិថុនា ឆ្នាំ២០១៣

# មាតិកា

ខែមិថុនា ឆ្នាំ២០១៣




## សវនាការស្តាប់សក្ខីកម្ម


៣ សាក្សី ប្រ្វង់ស្វ័រ ប៉ុងសូដ៏
១៩ សាក្សី ឈូក រីន
២៦ សាក្សី ជួន ធី
៣០ សាក្សី រស់ ស៊ុយ
៣៥ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន
៤០ សាក្សី អ៊ុំង ឆាត់
៤៣ សាក្សី លឹម សាត
៤៩ សាក្សី ហ្វីលីព ស្បុត
៦១ សាក្សី អៀង ផាន
៦៧ សាក្សី ព្រុំ ស៊ូ



ក្រុមសង្កេតការណ៍ :
ឆាយ ឈុនលី, លឹម ជ័យទ័ត្ត,
ឌី សុជាតា, និង ចាន ប្រាថ្នា

ពិនិត្យ និងផ្ទៀងផ្ទាត់ ដោយ ជី ទេវិទ្ធិ


*ប្រជាជនមកចូលរួមតាមដានកិច្ចដំណើរការជំនុំជម្រះមេដឹកនាំខ្មែរក្រហមក្នុងសាលសវនាការ (រូបថតរបស់តុលាការ)*

# ការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាល ទី១ និងទី២ និងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

## *ថ្ងៃទី៩ ខែមេសា ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣*

ចាប់ពីថ្ងៃទី៩ ខែមេសា ដល់ទី២២ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីសរុបទាំងអស់ចំនួន១០រូប ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី១ និងទី២ និងការសម្លាប់ អតីតទាហាន លន់ នល់ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង១០រូបនោះត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្មតាមលំដាប់ដោយចាប់ផ្តើមពី៖ ទី១) សាក្សី ហ្វ្រង់ស័រ ប៉ុងស្វូដ៍ ជាអាចារ្យកាតូលិក ជនជាតិបារាំង ដែលបាននិពន្ធសៀវភៅមួយក្បាលមានចំណងជើងថា«កម្ពុជាឆ្នាំសូន្យ» ។ សាក្សីបានផ្តល់សក្ខីកម្មយ៉ាងច្រើនអំពីព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកក្នុងអំឡុងពេលសង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាម ផលលំបាករបស់ប្រជាជននៅពេលខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ និងការរស់នៅរបស់ជនភៀសខ្លួនបន្ទាប់ពីបានទៅរស់នៅលើទឹកដីថៃ ។ ទី២) សាក្សី ឈូក រីន ជាអតីតមេបញ្ជាការកងទ័ពមួយរូបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានស្គាល់ថាជាមនុស្សជំនិតរបស់ ឈិត ជឿន ហៅ ម៉ុក ដែលជាលេខាភូមិភាគនិរតី ។ នៅក្នុងសវនាការសួរដេញដោលសាក្សី ឈូក រីន បានផ្តល់ព័ត៌មានយ៉ាងច្រើនទាក់ទងនឹងរចនាសម្ព័ន្ធយោធារបស់ខ្មែរក្រហម និងតួនាទីរបស់ជនជាប់ចោទ នួន ជា ទាក់ទងនឹងការធ្វើសេចក្តីសម្រេច បោសសម្អាតកម្មាភិបាល និងយោធាខ្មែរក្រហមនៅភូមិភាគបូព៌ា ។ ទី៣) សាក្សី ជួន ធី ជាអតីតមេបញ្ជាការកងវរសេនាធំលេខ១៥ នៃកងពលលេខ១ ។ គាត់បានផ្តល់សក្ខីកម្មដោយផ្តោតសំខាន់ទៅលើកិច្ចប្រជុំមួយដែលត្រូវបានធ្វើក្នុងអំឡុងឆ្នាំ១៩៧៨ នៅខេត្តកំពង់ឆ្នាំង ។ សាក្សីបានចូលរួមក្នុងកិច្ចប្រជុំនោះក្រោមអធិបតីភាពរបស់ ប៉ុល ពត ដែលបានលើកឡើងអំពីមហិច្ឆតារបស់វៀតណាមក្នុងការឈ្លានពាន និងលេបយកប្រទេសកម្ពុជា តាមរយៈការដាក់បញ្ចូលកម្ពុជាទៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន និងនិយាយអំពីផែនការបង្កើនចំនួនប្រជាជនរហូតដល់ ២០ទៅ៣០លាននាក់ ដើម្បីទប់ទល់ជាមួយវៀតណាម ។ ទី៤) សាក្សី រស់ ស៊ុយ ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សក្ខីកម្មរបស់គាត់ទាក់ទងនឹងជនជាប់ចោទ ខៀវ សំផន ដែលបានចុះទៅពិនិត្យមើលឃ្លាំងរដ្ឋផ្សេងៗដែលទទួលបន្ទុកផ្គត់ផ្គង់សំភារៈ និងចែកចាយស្បៀងអាហារទៅដល់អង្គភាពផ្សេងៗរបស់រដ្ឋ ។ ក្រៅពីនេះសក្ខីកម្មរបស់គាត់ទាក់ទងនឹងជនជាប់ចោទ នួន ជា ដែលបានយកខ្សែអាត់ថតសំឡេងរបស់ កុយ ធួន ដែលបានសារភាពអំពីសកម្មភាពក្បត់របស់ខ្លួន មកចាក់ឲ្យកម្មាភិបាលនៅក្រោមបង្គាប់របស់ កុយ ធួន ស្តាប់ ។ ទី៥) សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន អតីតអ្នកបើកបររថយន្តជូនគណៈប្រតិភូបរទេស ដែលមកធ្វើទស្សនកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីរូបនេះបានផ្តល់សក្ខីកម្មទាក់ទងនឹងកិច្ចប្រជុំមួយដែលខ្លួនបានចូលរួមក្រោមអធិបតីភាពរបស់ អៀង សារី ដែលពេលនោះ អៀង សារី បានអំពាវនាវឲ្យបញ្ញវន្តដែលនៅក្រៅប្រទេសត្រឡប់ចូលស្រុកខ្មែរវិញ ។ ទី៦) សាក្សី អ៊ុង ឆាត់ ជាអតីតយោធាខ្មែរក្រហមម្នាក់ ដែលសក្ខីកម្មរបស់គាត់ផ្តោតសំខាន់ទៅលើការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ ទី៧) សាក្សី លឹម សាត ជាអតីតយោធាខ្មែរក្រហមម្នាក់ ដែលបានផ្តល់សក្ខីកម្មទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ ទី៨) សក្ខីកម្មរបស់សាក្សី ហ្វីលីព ស្សុត ជាជនជាតិអង់គ្លេស ។ សាក្សីជាអ្នកនិពន្ធនៃសៀវភៅមួយមានចំណងជើងថា "ប៉ុល ពត ៖ ប្រវត្តិសុបិន្តអាក្រក់នៃប្រទេសកម្ពុជា" ។ សាក្សីត្រូវបានតុលាការផ្តល់ឋានៈជាសាក្សីជំនាញ និងអនុញ្ញាតឲ្យភាគីទាំងអស់មានសិទ្ធិចោទសំណួរគ្រប់អង្គហេតុទាំងអស់នៅក្នុងដីកាចោទប្រកាន់ក្នុងសំណុំរឿង

០០២ ។ ទី៩) សាក្សី អៀង ផាន អតីតប្រធានកងពលតូច២២១ របស់ខ្មែរក្រហម ។ សាក្សីរូបនេះបានផ្តល់សក្ខីកម្មយ៉ាងច្រើន ទាក់ទង នឹងរចនាសម្ព័ន្ធរបស់យោធាខ្មែរក្រហម ប្រព័ន្ធទំនាក់ទំនង ការងារក្នុងជួរកងទ័ព ព្រមទាំងការសម្រិតសម្រាំង និងការបោស សម្អាតខ្មាំងនៅក្នុងជួរកងទ័ពខ្មែរក្រហម ។ ទី១០) សាក្សី ព្រំ ស៊ូ អតីតកម្មាភិបាលខ្មែរក្រហមម្នាក់ បម្រើការងារនៅមន្ទីរពាណិជ្ជ-កម្មក្នុងតំបន់១០៣ ដែលក្រោយមកតំបន់នេះក្លាយទៅជាតំបន់ ស្វយ័ត ។ សក្ខីកម្មរបស់សាក្សីរូបនេះបានផ្តោតសំខាន់អំពីការ សម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ដែលបានកើតឡើង ភ្លាមៗបន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។

នីតិវិធីសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ មាន ការប្រែប្រួលទៅតាមប្រភេទសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្នើសុំកោះដោយភាគី ។ ជាទូទៅការសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ផ្តើមពីក្រុមមេធាវីនាំមុខតំណាងដើម បណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា និងក្រុមមេធាវីជនជាប់ ចោទ ។ សម្រាប់សាក្សីជំនាញ ឬសាក្សីធម្មតា ដែលមកផ្តល់ សក្ខីកម្មតាមសំណើរបស់ព្រះរាជអាជ្ញា ត្រូវបានសួរតាមលំដាប់ ដោយចាប់ផ្តើមពីអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា ដើមបណ្តឹង រដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទតាមលំដាប់ លំដោយ ។ ដោយឡែក សាក្សីដែលមកផ្តល់សក្ខីកម្មតាមសំណើ របស់ក្រុមមេធាវីការពារក្តី ត្រូវបានក្រុមមេធាវីការពារក្តីសួរមុន ភាគីផ្សេងៗទៀត ។ សរុបសេចក្តីមក សាក្សីដែលត្រូវបានស្នើ ឡើងដោយភាគីណា ភាគីនោះមានសិទ្ធិសួរដេញដោលសាក្សីមុន ភាគីផ្សេងៗទៀត ។



ប្រជាជនកម្ពុជាកំពុងលើកទំនប់ ១មករា ក្នុងខេត្តកំពង់ធំ ក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការសួរដេញដោលសាក្សី ហ្វ្រង់ស្វ័រ ប៉ុងសូដ៍

## ថ្ងៃទី៩-១១ ខែមេសា ឆ្នាំ២០១៣

ចាប់ពីថ្ងៃទី៩ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបន្តបើកសវនាការសួរដេញដោលសាក្សីជនជាតិបារាំងម្នាក់ឈ្មោះ ហ្វ្រង់ស៊័រ ប៉ុងសូដ៍ ខណៈពេលដែលជនជាប់ចោទ នួន ជា កំពុងតាមដានសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោមដោយសារបញ្ហាសុខភាព ។ សវនាការនេះបានប្រព្រឹត្តទៅខុសប្លែកពីសវនាការសួរដេញដោលសាក្សីផ្សេងៗទៀត ដោយសារសាក្សីរូបនេះ ត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យនិយាយភាសាខ្មែរក្នុងអំឡុងពេលនៃការសួរដេញដោល ។ ប៉ុន្តែក្រោយមក ការប្រាស្រ័យទាក់ទងគ្នាជាភាសាខ្មែររបស់សាក្សីនាំឲ្យមានការភ័ន្តច្រឡំក្នុងការបកប្រែជាភាសាបារាំង ដែលធ្វើឲ្យមានការជំទាស់ជាច្រើនដងពីមេធាវីការពារក្តី និងសាក្សីផ្ទាល់ ។ ដោយសារតែបញ្ហានេះត្រូវបានលើកឡើងច្រើនដង អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យសាក្សីនិយាយភាសាបារាំងវិញ ។ សក្ខីកម្មរបស់សាក្សីរូបនេះ បានផ្តោតសំខាន់ទៅលើព័ត៌មាននៅក្នុងសៀវភៅរបស់សាក្សីដែលមានចំណងជើងថា "កម្ពុជាឆ្នាំសូន្យ" ដែលបានរៀបរាប់អំពីស្ថានភាពទូទៅនៃប្រទេសកម្ពុជានៅក្នុងរបបលន់ នល់ ការចូលមកដល់នៃកងទ័ពខ្មែរក្រហម ការជម្លៀសប្រជាជនទៅតាមទីជនបទ ការជម្លៀសជនបរទេសឲ្យត្រឡប់ទៅប្រទេសកំណើតវិញ និងការស្វែងយល់អំពីរបបខ្មែរក្រហមតាមរយៈព័ត៌មានដែលទទួលបានពីជនភៀសខ្លួន ។

### ១) ការសួរដេញដោលសាក្សីដោយអង្គជំនុំជម្រះ

#### ក) ការសួរដេញដោលដោយចៅក្រម ហ្សង់ម៉ាក ឡាវែរីញ

ជាការចាប់ផ្តើម ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសួរសំណួរមួយចំនួនដែលទាក់ទងនឹងបុគ្គលភាព និងមុខរបរសាក្សី ។ សាក្សីបានបញ្ជាក់ថា លោកឈ្មោះ ហ្វ្រង់ស៊័រ ប៉ុងសូដ៍ កើតនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៣៩ នៅសាឡង់ ដើងភ្នំអាល់ ហើយសព្វថ្ងៃរស់នៅម្តុំបឹងត្របែកក្នុងរាជធានីភ្នំពេញ និងជាអ្នកកាន់សាសនាកាតូលិកណុងប្រែត្រ័រ ។ សាក្សីមានឪពុកឈ្មោះ លីអុង ប៉ុងសូដ៍ និងម្តាយឈ្មោះ អេឌីត៍ ហ្សារាគូ ។ បន្ទាប់មក អង្គជំនុំជម្រះបានជម្រាបសាក្សីអំពីសិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការ និងបញ្ជាក់អំពីភាសាដែលសាក្សីសម្រេចជ្រើសរើស ។ ឆ្លើយតបនឹងចំណុចនេះ សាក្សីបានបញ្ជាក់ថា ខ្លួនសម្រេចជ្រើសរើសនិយាយភាសាខ្មែរ ដោយសារតែតុលាការមានទីតាំងនៅក្នុងប្រទេសកម្ពុជា ហើយធ្វើការកាត់ទោសលើអង្គហេតុដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា ។


ហ្វ្រង់ស៊័រ ប៉ុងសូដ៍
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះអំពីមូលហេតុ ដែលនាំឲ្យលោកមករស់នៅក្នុងប្រទេសកម្ពុជា សាក្សីបានរៀបរាប់ថា ខ្លួនបានមករស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៦៥ ដោយសារតែសាក្សីជាសមាជិកនៃសមាគមក្រុមសាសនាកាតូលិក ដែលត្រូវបំពេញបេសកកម្មដឹកនាំក្រុមសាសនាកាតូលិកនៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់មក សាក្សីក៏បានរៀនសូត្រអំពីភាសាខ្មែរ និងសាសនាព្រះពុទ្ធចាប់តាំងពីពេលនោះមក ។

នៅឆ្នាំ១៩៧២ សាក្សីបានធ្វើដំណើរទៅកាន់ប្រទេសបារាំងអស់រយៈពេល៦ខែ ហើយបានត្រឡប់មករស់នៅក្នុងប្រទេសកម្ពុជាវិញរហូតដល់ឆ្នាំ១៩៧៥ ។ បន្ទាប់មក អង្គជំនុំជម្រះបាន

បន្តសួរឲ្យសាក្សីរៀបរាប់អំពីស្ថានភាពទូទៅដែលសាក្សីបានជួបប្រទះនៅក្នុងប្រទេសកម្ពុជា នៅចន្លោះឆ្នាំ១៩៦៥-១៩៧០ ។ សាក្សីបានរៀបរាប់ថា ចាប់ពីឆ្នាំ១៩៦៥ដល់ឆ្នាំ១៩៧០ នៅក្នុងប្រទេសកម្ពុជាមានរឿងរ៉ាវជាច្រើនបានកើតឡើងទាក់ទងនឹងអំពើអយុត្តិធម៌ និងភាពក្រីក្រ ប៉ុន្តែនៅពេលនោះខ្លួនពុំបានចាប់អារម្មណ៍ខ្លាំងអំពីបញ្ហាទាំងអស់នោះទេ ។ ព្រឹត្តិការណ៍ដែលលោកបានដឹងនៅពេលនោះ គឺសម្តេចព្រះ នរោត្តម សីហនុ បានដេរ ហ៊ូ នឹម និង ហ៊ូ យន់ ចលនាបះបោរនៅសំឡូតប្រឆាំងនឹងទាហានរបស់សម្តេចព្រះ នរោត្តម សីហនុ និងការប្រឆាំងគ្នារវាងសម្តេចព្រះ នរោត្តម សីហនុ និង ខៀវ សំផន ។ សាក្សីជឿជាក់ ថា ខៀវ សំផន ជាមនុស្សបរិសុទ្ធ និងជាគំរូដល់យុវជននៅជំនាន់ នោះ ។

បន្ទាប់មក សាក្សីបានបន្តរៀបរាប់អំពីស្ថានភាពច្បាំងគ្នារវាងខ្មែរក្រហម និងទាហាន លន់ នល់ ដែលបានចាប់ផ្តើមកាលពីខែឧសភា ឆ្នាំ១៩៧០ ថា ក្រោយពេលមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ប្រជាជននៅតាមខេត្តក្រចេះបានធ្វើការបះបោរជាខ្លាំង ប៉ុន្តែចលនានោះត្រូវបានលោកសូស្តែន ហ្វែណង់ដេស យកកាំភ្លើងធំ១៦៧ និង១០៧មកបាញ់បំបែកក្រុមអ្នកតវ៉ាទាំងនោះដែលបណ្តាលឲ្យមានមនុស្សស្លាប់ប្រហែល៦០នាក់ ។ នៅពេលនោះ ខ្មែរក្រហមបានជួយប្រជាជនដែលរងទុក្ខដោយសារតែការទម្លាក់គ្រាប់បែក និងជួយធ្វើការបង្កបង្កើនផលដល់កសិករ ។ តាមរយៈសកម្មភាពទាំងនោះ ប្រជាជនកម្ពុជា និងសាក្សីផ្ទាល់ មានការជឿទុកចិត្តចំពោះខ្មែរក្រហម និងចង់ឲ្យខ្មែរក្រហមឡើងកាន់អំណាចដើម្បីបញ្ចប់សង្គ្រាម ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៣មក ខ្មែរក្រហមបានក្លាយជាមនុស្សកាចសាហាវ ដោយសារមានការទម្លាក់គ្រាប់បែក ។ បន្ទាប់មក សាក្សីបានបន្តរៀបរាប់ថា មូលហេតុដែលនាំឲ្យមានការទម្លាក់គ្រាប់បែកនៅក្នុងសង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាម គឺដោយសារតែសហរដ្ឋអាមេរិកមានបំណងការពារមិនឲ្យមានការរាលដាលនៃរបបកុម្មុយនីស្តនៅក្នុងតំបន់ ។ សាក្សីបានរៀបរាប់ថា នៅពេលនោះ ខ្លួនរស់នៅម្តុំផ្សារកណ្តាល ហើយបានឃើញអណ្តាតភ្លើងពណ៌ក្រហមនៃការទម្លាក់គ្រាប់បែកក្នុងចម្ងាយប្រហែលជា៣០ទៅ៤០ម៉ែត្រតែប៉ុណ្ណោះពីកន្លែង ដែលខ្លួនរស់នៅ ។ ស្របពេលជាមួយគ្នានោះ ចំនួនប្រជាជននៅក្នុងទីក្រុងភ្នំពេញបានកើនឡើងដល់ជិតពីរលាននាក់ ហើយប្រជាជនទាំងនោះបានរស់នៅពាសពេញទីក្រុង និងតាមចិញ្ចើមថ្នល់ក្នុងស្ថានភាពលំបាកដោយសារអត់មានស្បៀងអាហារហូបចុកគ្រប់គ្រាន់ ។ សាក្សីបានបន្តថា នៅពេលនោះដែរ អង្គការកាតូលិករបស់គាត់ ក៏បានជួយផ្តល់ស្បៀងដល់ប្រជាជននៅតាមជាយក្រុងភ្នំពេញរហូតដល់ខែមករា ឆ្នាំ១៩៧៥ ទើបមានជំនួយពីសហរដ្ឋអាមេរិកតាមរយៈការដឹកអង្ករតាមកប៉ាល់វៀតណាមមកចែកជូនប្រជាជន ។ ប៉ុន្តែក្រោយមក សហរដ្ឋអាមេរិកពុំមានលទ្ធភាពដឹកស្បៀងកាត់តាមវៀត-ណាមទៀតទេ ដោយសារឥទ្ធិពលនៃសង្គ្រាមបានបំផ្លាញផ្លូវពីវៀតណាមមកកម្ពុជា ដូច្នេះ ស្បៀងត្រូវបានដឹកជញ្ជូនមកតាមយន្តហោះវិញ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ ដែលទាក់ទងនឹងស្ថានភាពនៅតាមមន្ទីរពេទ្យ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនមានតួនាទីជាអ្នកបកប្រែភាសា ដែលអាចធ្វើការងារនៅក្នុងផ្ទះបានទើបខ្លួនពុំបានដឹងអំពីស្ថានភាពនៅតាមមន្ទីរពេទ្យនានាទេ ។

## ក.១) ការចូលមកដល់នៃកងទ័ពខ្មែរក្រហម

ទាក់ទងនឹងស្ថានភាពនៅទីក្រុងភ្នំពេញ បន្ទាប់ពីមានការចូលមកដល់នៃយោធាខ្មែរក្រហម សាក្សីបានរៀបរាប់ថា នៅព្រឹកថ្ងៃទី១៧ ខែមេសា មានប្រជាជនជាច្រើននាក់បានធ្វើដំណើរចូលមកពីទិសខាងជើង រួមមានទាំងរថក្រោះមកជាមួយផង ។ នៅវេលាម៉ោងប្រហែល៦ល្ងាច សាក្សីបានឃើញរថយន្តពណ៌សជាច្រើនគ្រឿងបានឈប់នៅទល់មុខស្ថានទូតបារាំង និងមានរថក្រោះខ្មែរក្រហមឈប់នៅទល់មុខមន្ទីរពេទ្យកាល់ម៉ែត្រ ។ នៅពេលនោះ មានបុរសម្នាក់បានដើរសំដៅទៅកាន់រថក្រោះ ដើម្បីធ្វើការចរចា ។ បន្ទាប់មក ទាហានមួយចំនួនបានដាក់អាវុធចុះដើម្បីចុះចូលជាមួយខ្មែរក្រហម ។ នៅពេលរថយន្តពណ៌សទាំងនោះបានបរកាត់ផ្ទះរបស់ខ្លួន សាក្សី ប៉ុងសូដ៍ បានឃើញក្រុមយុវជនដែលពាក់ខោអាវខ្មៅបានដើរចេញមក ដោយមានកាន់ទង់ជាតិមានពណ៌ខៀវម្នាង និងម្នាងទៀតមានពណ៌ក្រហម ។ សាក្សី ប៉ុងសូដ៍ បានអះអាងថា យុវជនទាំងនោះពុំមែនជាយោធាខ្មែរក្រហមទេ ប៉ុន្តែជាក្រុមទាហានរបស់ប្អូន លន់ នល់ គឺ លន់ ណុន ដែលមានបំណងដណ្តើមយកជ័យជំនះមុនខ្មែរក្រហមទៅទៀត ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកកាសែតជាច្រើននាក់យល់ច្រឡំថា អ្នកទាំងនោះជាខ្មែរក្រហម ហើយអ្នកកាសែតខ្លះបានសរសេរថា *«ខ្មែរក្រហមបានរំដោះប្រទេស ដោយអំណរសប្បាយ»* ។ ស្របពេលជាមួយគ្នានោះដែរ ក៏មានក្រុមយុវជនមួយក្រុមទៀតមានរូបរាងតូចៗ និងហាក់ដូចជាពុំសូវមានកម្លាំងកំហែង បានចូលមកដល់ទីក្រុងភ្នំពេញនៅម៉ោងប្រហែល៩ព្រឹក ។ សាក្សីបានបន្តថា នៅពេលនោះ សម្តេចសង្ឃ ហួត តាត បានមានសង្ឃដីកាថា *«ឥឡូវនេះ សូមញោមចូលរួមកសាងប្រទេសជាមួយគ្នា ។ យើងសុទ្ធតែជាបងប្អូនគ្នា ដូច្នេះ សូមទទួលអ្នកដែលមានជ័យជម្នះ សូមកុំរើតទៅមុខទៀត»* ។ បន្តិចក្រោយមក សាក្សីបានឃើញអ្នកជំងឺជាច្រើននាក់ចាកចេញពីមន្ទីរពេទ្យ ហើយមានជនពិការម្នាក់បានចូលមកសុំជ្រកនៅក្នុងផ្ទះរបស់ខ្លួន ប៉ុន្តែសាក្សីបានបដិសេធដោយមានការបារម្ភខ្លាចខ្មែរក្រហមចូលមកសម្លាប់ ។ សាក្សីបានបន្តរៀបរាប់ថា នៅម៉ោងប្រហែល១២ថ្ងៃត្រង់ ខ្មែរក្រហមបានបណ្តេញជនជាតិចាមឲ្យចេញពីក្រុង ហើយនៅម៉ោងប្រហែល២រសៀលខ្មែរក្រហម ដែលស្លៀកពាក់ខោអាវខ្មៅបានប្រកាសថា *«មិត្ត! សូមចេញភ្លាម! បន្តិចទៀតអាមេរិកកាំងនឹងទម្លាក់គ្រាប់បែក»* ។ ដោយការភ័យខ្លាច ប្រជាជននៅក្នុងទីក្រុងបានធ្វើដំណើរចេញទៅទិសខាងជើងតាមការបញ្ជារបស់ខ្មែរក្រហម ។ សាក្សី ប៉ុងសូដ៍ បានបន្តថា ពេលកំពុងជម្លៀសនោះ ខ្មែរក្រហមពុំមានការបាញ់កាំភ្លើងអ្វីទេ ដែលចំណុចនេះផ្ទុយគ្នាពីព្រឹត្តិការណ៍នៅក្នុងវីដេអូរបស់ រ៉ូឡង់ ហ្យូហ្វេ ដែលមានចំណងជើងថា *«វាលពិឃាត»* ។ ភាពពិតខ្មែរក្រហមបានគំរាមប្រជាជន ដោយប្រើក្រសែភ្នែកដ៏កាចសាហាវរបស់គេតែប៉ុណ្ណោះ ។ សាក្សីបានបន្តថា នៅយប់ថ្ងៃទី១៧ ខែមេសា ខ្មែរក្រហមមួយក្រុមបានធ្វើដំណើរមកកាន់ផ្ទះរបស់ខ្លួន ដែលមានទីតាំងនៅសាលាក្រុងសព្វថ្ងៃ ។ ពេលនោះ ខ្មែរក្រហមបានមកសួររកប្រពន្ធរបស់ ហ្វ្រង់ស្វ័រ បីហ្សូ ហើយសាក្សីបានប្រាប់ខ្មែរក្រហមទាំងនោះថា ប្រពន្ធរបស់ ហ្វ្រង់ស្វ័រ បីហ្សូ ស្ថិតនៅចម្ងាយ២០០ម៉ែត្រពីទីតាំងរបស់ខ្លួន ហើយមិនអាចដើរចេញមកក្រៅបាន ដោយសារខ្មែរក្រហមមិនអនុញ្ញាតឲ្យដើរនៅពេលយប់ ។ ដោយសារតែសាក្សីអាចនិយាយភាសាខ្មែរបានខ្មែរក្រហមទាំងនោះ ពុំបានបញ្ចេញចរិតគួរឲ្យខ្លាចនោះឡើយ ។ ផ្ទុយទៅវិញ យោធាខ្មែរក្រហមទាំងនោះបានឲ្យសាក្សីនិងមិត្តភក្តិរបស់គាត់ម្នាក់ទៀតបង្រៀនពួកគេឲ្យបើកឡានទាំងយប់នោះទៀតផង ។ លុះព្រឹកឡើងថ្ងៃទី១៨ មេសា ក្រុមខ្មែរក្រហមទាំងនោះ បានមកហៅឲ្យសាក្សីបើកឡានជូនទៅប្រជុំនៅស្ថានីយរទេះភ្លើង ។ ខណៈពេលធ្វើដំណើរនោះ សាក្សីបានណែនាំអំពីទីតាំងខ្លះៗដល់យោធាទាំងនោះដូចជា ទីតាំងផ្ទះរបស់ឡុង បូរ៉េត និងនៅមុំវិមានឯករាជ្យជាដើម ។ បន្ទាប់មក ខ្មែរក្រហមបានសួររកអាមេរិកកាំងដែលនៅសេសសល់នៅក្នុងទីក្រុង ប៉ុន្តែសាក្សីបានប្រាប់ខ្មែរក្រហមទាំងនោះថា គ្មានអាមេរិកកាំងនៅក្នុងប្រទេសកម្ពុជាទៀតទេ ។ បន្ទាប់មក សាក្សីបានបើករថយន្តកាត់ទៅតាមផ្លូវក្រមួនសរ ក៏ប្រទះឃើញមានទាហាន លន់ នល់ ដែលនៅសេសសល់កំពុងប្រយុទ្ធគ្នាជាមួយខ្មែរក្រហមនៅឡើយ ។ សំណួរបន្ទាប់របស់ប្រធានអង្គជំនុំជម្រះគឺទាក់ទងនឹងរបៀបនៃការបញ្ជាឲ្យប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញថា តើនៅពេលនោះខ្មែរក្រហមបានប្រើអាវុធដើម្បីបណ្តេញប្រជាជនដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ លោក ប៉ុងសូដ៍ បានបញ្ជាក់ថា ពេលនោះ ខ្មែរក្រហមបានប្រាប់ឲ្យប្រជាជនចាកចេញក្នុងរយៈពេលបីថ្ងៃ ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិក និងប្រាប់មិនឲ្យប្រជាជនយកឥវ៉ាន់ និងមិនឲ្យចាក់សោផ្ទះ ។ សាក្សីបានបន្តថា នៅកន្លែងដែលខ្លួនបានឃើញនោះ ខ្មែរក្រហមពុំបានប្រើអាវុធក្នុងការគំរាមប្រជាជនឡើយ ប៉ុន្តែ ប្រជាជនដែលធ្វើដំណើរចាកចេញនោះមានទឹកមុខក្រៀមក្រំជាខ្លាំង ហើយធ្វើដំណើរទៅតាមទិសដៅដែលបានបង្ហាញ ។ សាក្សីបានបន្ថែមថា ខណៈពេលដែលខ្លួនបើកឡានជូនខ្មែរក្រហមកាត់តាមវិមានឯករាជ្យនោះ ខ្លួនពុំបានឃើញសាកសពអ្វីនោះទេ មានតែទាហាន លន់ នល់ ដែលនៅបន្តបាញ់គ្នាជាមួយខ្មែរក្រហមតែប៉ុណ្ណោះ ។

នៅថ្ងៃនោះដែរ សាក្សីត្រូវបានបញ្ជូនឲ្យទៅស្នាក់នៅក្នុងស្ថានទូតបារាំងជាមួយជនបរទេសជាច្រើននាក់ទៀត ។ បួនថ្ងៃក្រោយមក សាក្សីបានធ្វើដំណើរចេញពីស្ថានទូតបារាំងដើម្បីតាមដានសភាពការណ៍នៅខាងក្រៅ ហើយខ្លួនពុំបានឃើញប្រជាជននៅក្នុងទីក្រុងទៀតទេ មានតែនារីខ្មែរក្រហមដែលមានទឹកមុខកាចសាហាវតែប៉ុណ្ណោះ ។ មួយរយៈក្រោយមក សាក្សីបានចេញ

ទៅតាមរកជនជាតិបារាំងដែលបានជម្លៀសចេញជាមួយប្រជាជនរហូតទៅដល់ព្រែកញ្ញោ ប៉ុន្តែខ្លួនពុំអាចរកឃើញទេ សូម្បីតែសាកសពរបស់ប្រជាជនម្នាក់ក៏គ្មាននៅទីនោះដែរ ។

**ក.២) ស្ថានភាពនៅក្នុងស្ថានទូតបារាំង**

បន្ទាប់មក អង្គជំនុំជម្រះបានបន្តសួរសាក្សី ប៉ុងសូដ៍ អំពីស្ថានភាពនៅក្នុងស្ថានទូតបារាំងដែលសាក្សីបានស្នាក់នៅ ។ សាក្សីបានរៀបរាប់ថា លោកបានមកស្នាក់នៅក្នុងស្ថានទូតបារាំងនៅថ្ងៃទី១៨ ខែមេសា ហើយនៅទីនោះមានជនជាតិបរទេសប្រហែលប្រាំរយនាក់ដូចជាមេដឹកនាំ សេ.អ៊ី.អា ជនជាតិ អាមេរិក ជនជាតិឡាវ និងជាតិសាសន៍ផ្សេងៗទៀត ។ នៅក្នុងនោះដែរក៏មានមេដឹកនាំធំៗនៅក្នុងរបប លន់ នល់ ដែលបានគេចខ្លួនពីខ្មែរក្រហម ។ នៅថ្ងៃទី២០ ខែមេសា មានបុគ្គលម្នាក់បានមកប្រកាសនៅស្ថានទូតបារាំងថា «មិត្ត ខៀវ សំផន ចង់មកជួបបងប្អូន ចង់ជួបមិត្តទាំងឡាយ ក៏ប៉ុន្តែលោកជាប់នឹងកិច្ចការចាត់ចែងបដិវត្តន៍ឡើងវិញ ។ ដូច្នេះ លោកសូមទោសដែលគ្មានពេលមកជម្រាបសួរមិត្តទាំងឡាយ» ។

បន្ទាប់មក សាក្សីបានរៀបរាប់អំពីព្រឹត្តិការណ៍មួយដែលខ្មែរក្រហមបានបំបែកក្រុមគ្រួសារដែលមានប្រពន្ធជាជនជាតិបារាំង និងប្តីជនជាតិខ្មែរ ។ នៅពេលនោះ ខ្មែរក្រហមបានឲ្យប្រពន្ធជាជនជាតិបារាំងជាង២០នាក់ត្រឡប់ទៅស្រុកកំណើតវិញ ចំណែកប្តីជាជនជាតិខ្មែរត្រូវជម្លៀសទៅនៅតាមជនបទជាមួយប្រជាជនខ្មែរផ្សេងៗទៀតដែលបានមកស្នាក់នៅក្នុងស្ថានទូតបារាំងប្រហែលប្រាំរយនាក់ ។ សាក្សីបានរៀបរាប់ទៀតថា នៅថ្ងៃទី១៩ ខែមេសា មានកងទ័ពខ្មែរក្រហមបានមកដល់មុខស្ថានទូតបារាំង ដើម្បីតាមចាប់ខ្លួនជនក្បត់ទាំង៧នាក់ ដោយគំរាមថា ប្រសិនបើមិនប្រគល់ជនក្បត់ទាំងនោះមកទេ កងទ័ពខ្មែរក្រហមទាំងនោះ នឹងបាញ់សម្លាប់អ្នកផ្សេងៗទៀតដែលស្នាក់នៅក្នុងស្ថានទូតជាមិនខាន ។ ស្ថិតនៅក្នុងស្ថានភាពដូច្នោះ ទ្រង់ ស៊ីសុវត្ថិ សិរិមតៈ បានចាកចេញពីស្ថានទូតដោយបាននិយាយលាគ្នាជាមួយអនុកុងស៊ុល លោក ហ្សង់ ឌីរាក់ ។ ចៅក្រម និល ណុន បានបន្តសួរឲ្យសាក្សីបញ្ជាក់ឡើងវិញទាក់ទងនឹងជនជាតិបរទេសដែលស្នាក់នៅក្នុងស្ថានទូតបារាំង ។ លោក ហ្រ្វង់ស្វ័រ ប៉ុងសូដ៍ បានរៀបរាប់ថា ជនជាតិបរទេសទាំងនោះរួមមាន ជនជាតិអាមេរិក ជនជាតិឡាវ និងជនជាតិវៀតណាមខាងត្បូង ។ សាក្សីបានបន្តថា បន្ទាប់ពីមានការចាប់ខ្លួនជនក្បត់ និងប្រជាជនខ្មែរដែលបានគេចខ្លួនចូលទៅនៅក្នុងស្ថានទូតបារាំងនោះ នៅមានជនជាតិខ្មែរ និងជនជាតិបរទេសប្រហែល៥រយនាក់ ហើយក្រោយមកទើបមានជនជាតិប៉ាគីស្ថានប្រហែល៥រយនាក់ទៀតបានមកស្នាក់នៅទីនោះ ។

**ក.៣) ការបញ្ជូនជនបរទេសដែលស្នាក់នៅក្នុងស្ថានទូតបារាំងចេញពីប្រទេសកម្ពុជា**

សាក្សី ហ្រ្វង់ស្វ័រ ប៉ុងសូដ៍ បានរៀបរាប់ថា នៅថ្ងៃទី៣០


យោធាខ្មែរក្រហមត្រៀមវាយចូលទីក្រុង

ខែមេសា ឆ្នាំ១៩៧៥ អ្នកដែលបានស្នាក់នៅក្នុងស្ថានទូតបារាំងចាប់ផ្តើមភៀសខ្លួនទៅកាន់ព្រំដែនថៃ ដោយធ្វើដំណើរកាត់តាមខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។ លោកបានបញ្ជាក់ថា មុនពេលចាកចេញ លោក ហ្រ្វង់ស្វ័រ ប៊ីសូ បានទៅចរចាជាមួយកម្មាភិបាលថ្នាក់ខ្ពស់ខ្មែរក្រហមម្នាក់អំពីការធ្វើដំណើរចាកចេញនោះថា «រដ្ឋាភិបាលនៃប្រទេសបារាំងសុខចិត្តយកយន្តហោះ ដើម្បីមកទទួលជនជាតិបរទេសទាំងអស់ត្រឡប់ទៅ

ប្រទេសកំណើតវិញ» ។

ក្រោយមក ខ្មែរក្រហមបានចាត់ចែងរថយន្តក្បួនពីរ ក្បួនទី១ ចេញដំណើរនៅថ្ងៃទី៣០ មេសា ដែលក្នុងនោះមានប្រធាន សេ.អ៊ី.អា ស្រ្តីមានផ្ទៃពោះ និងមនុស្សចាស់ ។ ចំណែកក្បួនទី២ បានចេញដំណើរនៅថ្ងៃទី៧ ខែឧសភា ដែលមានសាក្សីនៅក្នុងនោះដែរ ។ សាក្សីបានបន្តថា ក្នុងពេលធ្វើដំណើរនោះមានយោធាខ្មែរក្រហមពីរបីនាក់បានរួមដំណើរជាមួយទៅដល់ព្រំដែនថៃ ទើបយោធាទាំងនោះត្រឡប់មកវិញ ។

សំណួរចុងក្រោយរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការចចាររវាងមន្រ្តីនៅក្នុងរបបសាធារណៈរដ្ឋខ្មែរ និងកម្មាភិបាលខ្មែរ


...ភ្នំពេញ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រហមខណៈពេលខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញដំបូង ។ សាក្សីបានបញ្ជាក់ថា នៅ ពេលខ្មែរក្រហមចូលមកដល់ភ្លាម ខ្លួនបានទទួលដំណឹងថា ឡុង បូរ៉េត ជាអតីតនាយករដ្ឋមន្រ្តីនៅក្នុងរបប លន់ នល់ បានទៅចចារជាមួយខ្មែរក្រហម ប៉ុន្តែខ្មែរក្រហមមិនព្រមចចារឡើយ ហើយក្រោយមក ឡុង បូរ៉េត ត្រូវបានខ្មែរក្រហមចាប់ខ្លួន ហើយយកទៅសម្លាប់ចោល ។

**១) ការសួរដេញដោលដោយចៅក្រម ហ្សង់ម៉ាក ឡាវីញ**

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយប្រធានអង្គជំនុំជម្រះ ចៅក្រម ហ្សង់ម៉ាក ឡាវីញ បានចាប់ផ្តើមដោយសួរបញ្ជាក់ឡើងវិញអំពីប្រវត្តិសាវតាររបស់សាក្សី ។ សាក្សីបានរៀបរាប់ថា ខ្លួនជាអតីតទាហានលោតឆ័ត្រយោងនៅប្រទេសបារាំង ហើយក្រោយមកបានទៅរៀនសូត្រដើម្បីធ្វើជាអាចារ្យសាសនាកាតូលិក ។ សាក្សីបានបន្តថា នៅឆ្នាំ១៩៦៦-១៩៦៧ ខ្លួនបានទៅរស់នៅក្នុងខេត្តស្ទឹងត្រែង និងខេត្តបាត់ដំបង ដើម្បីបង្រៀននិស្សិតដែលនៅតាមស្រុកស្រែ និងបកប្រែឯកសារផ្សេងៗ ។ នៅខែសីហា ឆ្នាំ១៩៧០ សាក្សីបានទៅរស់នៅខេត្តកំពង់ចាម ខណៈពេលដែលសង្រ្គាមកំពុងតែកើតឡើងរវាងទាហាន លន់ នល់ និងអ្នកដែលបានគាំទ្រសម្តេចព្រះ នរោត្តម សីហនុ ។ ទាក់ទងនឹងព្រឹត្តិការណ៍ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ សាក្សីបានបញ្ជាក់ថា នៅពេលនោះមានប្រជាជនខ្លះបានគាំទ្រ ចំពោះការទម្លាក់សម្តេច ប៉ុន្តែប្រជាជនខ្លះក៏បានប្រឆាំងនឹងព្រឹត្តិការណ៍នោះដែរ ។ បញ្ញវន្តជាច្រើននាក់នៅក្នុងទីក្រុងមិនពេញចិត្តនឹងការដឹកនាំរបស់សម្តេច ជាពិសេសនៅឆ្នាំ១៩៦៧ ដោយសារតែសម្តេចព្រះ នរោត្តម សីហនុ បានផ្សព្វផ្សាយភាពយន្តអប្សរា ដែលបង្ហាញអំពីអាកប្បកិរិយាមិនល្អដូចជាការប្រព្រឹត្តល្បែងស៊ីសងរបស់អ្នកមានអំណាចនៅជំនាន់នោះជាដើម ។ ផ្ទុយទៅវិញ ប្រជាជននៅតាមជនបទមានការពេញចិត្តចំពោះការដឹកនាំរបស់ទ្រង់ ដោយសារតែនៅក្នុងរបប លន់ នល់ ប្រជាជន មានការលំបាកមិនអាចបង្កបង្កើនផលចិញ្ចឹមជីវិត និងមានអំពើពុករលួយកើតឡើង ។

បន្ទាប់មក ចៅក្រម ហ្សង់ម៉ាក ឡាវីញ បានបន្តសួរឲ្យសាក្សីបញ្ជាក់អំពីទស្សនៈរបស់ប្រជាជនចំពោះរបប លន់ នល់ និងការចូលរួមគាំទ្រសម្តេចព្រះ នរោត្តម សីហនុ ។ ប៉ុន្តែភ្លាមនោះ មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានក្រោកឈរជំទាស់ចំពោះសំណួររបស់ចៅក្រម ឡាវីញ ដោយអះអាងថា សាក្សីពុំមែនជាអ្នកជំនាញទេ ដូច្នេះសាក្សីមិនអាចឆ្លើយដោយប្រើការវិភាគរបស់ខ្លួនបានឡើយ ។ ផ្ទុយទៅវិញ តំណាងសហព្រះរាជអាជ្ញា អន្តរជាតិ វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល បានបដិសេធការជំទាស់របស់មេធាវីការពារក្តី ដោយលើកឡើងថា សាក្សីជាអ្នកដែលបាន

ឃើញផ្ទាល់នូវព្រឹត្តិការណ៍ដែលបានកើតឡើងរហូតដល់ ខែឧសភា ឆ្នាំ១៩៧៥ ។ ម្យ៉ាងទៀត សាក្សី ជាអ្នកវិភាគរាល់ព័ត៌មានដែលទទួលបានពីជនភៀសខ្លួនដោយផ្ទាល់ ។ ចំពោះបញ្ហានេះ ចៅក្រម ស៊ីលវៀ ខាតវ៉្រាយតី បានផ្តល់ជាយោបល់ថា បញ្ហានេះ អង្គជំនុំជម្រះនឹងធ្វើការសម្រេចនៅពេលចុងបញ្ចប់នៃការសួរដេញដោលសាក្សី ។ បន្ទាប់មក ចៅក្រមឡាវ៉ែញ បានបន្តសំណួរទាក់ទងនឹងស្ថានភាពនៃការជម្លៀសប្រជាជន ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនពុំបានឃើញខ្មែរក្រហមប្រើអាវុធដើម្បីបង្ខំឲ្យប្រជាជនឲ្យចាកចេញនោះទេ ដោយយោធាទាំងនោះគ្រាន់តែប្រើក្រសែភ្នែកធ្វើឲ្យប្រជាជនមានការភ័យខ្លាចតែប៉ុណ្ណោះ ។ បន្ទាប់មក ចៅក្រម ឡាវ៉ែញ បានបន្តសួរឲ្យសាក្សីបញ្ជាក់អំពីការចចាររវាងខ្មែរក្រហម និងកុងស៊ុលនៅក្នុងស្ថានទូតបារាំង ។ សាក្សីបានរៀបរាប់ថា នៅពេលនោះ លោកបានស្គាល់ ញ៉ែម ដែលជាអ្នកមើលថែ និងយកចិត្តទុកដាក់ជាមួយជនភៀសខ្លួននៅក្នុងស្ថានទូតបារាំង ចំណែកអ្នកដែលចចារជាមួយខ្មែរក្រហម គឺលោក ហ្សាក់ ឌីរាក់ ។

ចៅក្រម ឡាវ៉ែញ បានលើកយកសៀវភៅរបស់លោក ហ្វ្រង់ស៊័រ ប៊ីហ្សូ ដែលបានសរសេរថា «នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ ប្រីក្សាហ្គ្រុង (រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា) បានលើកឡើងយ៉ាងដូច្នេះ ដោយសារទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរនេះមិនទាន់អនុវត្តនៅឡើយ ។ ដោយហេតុថា ហ្គ្រុង ...រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមិនទាន់បង្កស្ថានភាពស្ថិរភាព បានដូច្នេះសូមអញ្ជើញអនិកជនបរទេសទាំងអស់ឲ្យចេញពីប្រទេសកម្ពុជានៅថ្ងៃទី៣០មេសា ឆ្នាំ១៩៧៥ ហើយនៅពេលដែលស្ថានភាពមានលំនឹងមានស្ថិរភាព រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានឹងពិចារណាលើស្ថានភាពទំនាក់ទំនងអន្តរជាតិនេះ ។ រាជរដ្ឋាភិបាលបង្រួមបង្រៀនជាតិកម្ពុជា នឹងបញ្ជូនអនិកជនបរទេសទាំងអស់នេះទៅព្រំប្រទល់តាមផ្លូវដីនៅប៉ោយប៉ែត និងទទួលបន្ទុកក្នុងការ...ហើយបន្តមកទៀតនឹងមានអ្នកបន្តយកចេញពីប៉ោយប៉ែតនេះទៅទៀត» ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា លោកធ្លាប់បានឮពាក្យចចាមអារ៉ាមទាំងនេះមែន ប៉ុន្តែលោកពុំបានឃើញដោយផ្ទាល់ភ្នែកនោះទេ ។ ចៅក្រម ឡាវ៉ែញ បានបន្តសួរទាក់ទងនឹងការចាប់ខ្លួនជនក្បត់ដែលស្នាក់នៅក្នុងស្ថានទូត ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះពុំមានការចចារជាមួយខ្មែរក្រហមឡើយ ហើយមានយោធាខ្មែរក្រហមស្ពាយកាំភ្លើងអាកា ៤៧ បានមកហៅជនក្បត់ទាំងប្រាំពីរនាក់ចេញពីក្នុងស្ថានទូត ។

បន្ទាប់មក ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ បានបន្តសួរទាក់ទងនឹងសំណើរសុំផ្តល់សម្ភារៈមនុស្សធម៌ដល់ប្រទេសកម្ពុជា ។ ឆ្លើយតបនឹងសំណួរនេះ លោក ប៉ុងសូដ៍ បានបញ្ជាក់ថានៅពេលនោះ មានយន្តហោះដឹកជំនួយថ្នាំពេទ្យមកពីបរទេសមកដល់បាងកក ដើម្បីផ្តល់ឲ្យខ្មែរក្រហម ប៉ុន្តែខ្មែរក្រហមបានបដិសេធដោយអះអាងថា «យើងជាអង្គការ យើងមានឯករាជ្យ យើងមិនត្រូវការរបស់អាណានិគមនិយមតទៅទៀត» ។ លោកបានឆ្លើយតបនឹងសំណួរបន្ទាប់ថា នៅពេលធ្វើដំណើរភៀសខ្លួនទៅប្រទេសថៃ លោកពុំឃើញមានប្រជាជននៅតាមផ្លូវទេ ហើយលោកក៏បាននឹកឃើញដល់សំដីរបស់កម្មាភិបាលខ្មែរក្រហមម្នាក់ដែលបាននិយាយនៅថ្ងៃទី១៧មេសាថា«ទីក្រុងជាកន្លែងអាក្រក់ ។ នៅទីក្រុង អ្នកស្រុកគ្រាន់តែដាំអ្វីៗដែលគេហូប ដូច្នេះចូលទៅធ្វើស្រែ ទៅកាប់ឆ្ការព្រៃ ទៅដាំ ទៅស្ទូង ទៅប្រូតនោះ ខ្មែរនឹងស្គាល់តម្លៃនៃអ្វីទាំងអស់ ។ ត្រូវឲ្យខ្មែរដឹងថា គេកើតពីគ្រាប់ស្រូវ» ។ លោកបានបន្តថា អៀង សារី បានពន្យល់ជាច្រើននៅស្រុកបារាំងអំពីការជម្លៀសប្រជាជននៅភ្នំពេញ ប៉ុន្តែ ប្រជាជនពិតជាចង់ចាកចេញពីទីក្រុងភ្នំពេញពិតមែន ដោយសារភាពអន្តិសុខនៅក្នុងទីក្រុង ។ ទោះបីជា យ៉ាងណាក៏ដោយ លោកបានបន្ថែមថា មូលហេតុដែលពិតប្រាកដនៃការជម្លៀស ដោយសារតែមនោគមវិជ្ជា ហើយម្យ៉ាងទៀត អង្គការចង់ឲ្យខ្មែរត្រឡប់ទៅស្រុកវិញដើម្បីឲ្យទៅជាខ្មែរពិតប្រាកដ ពីព្រោះខ្មែរដែលរស់នៅភ្នំពេញជាខ្មែរក្លែងក្លាយ ។ ជាងនេះទៅទៀត លោកបានលើកឡើងអំពីការសរសេររបស់ ប៉ុល ពត ថា «ខ្មែរដែលពិតប្រាកដ គឺជាខ្មែរដែលនៅស្រុកស្រែ ដូច្នេះពេលត្រឡប់ទៅនៅស្រុកស្រែ ប្រជាជននឹងក្លាយទៅជាខ្មែរសុទ្ធសាធ» ។ ពាក់ព័ន្ធនឹងព័ត៌មាននៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីបានរៀបរាប់ថា លោកព្យាយាមស្វែងយល់អំពីអ្វី ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៧៥មកម្ល៉េះ ហើយខ្លួនធ្លាប់បានស្តាប់សន្ទរកថារបស់

អៀង សារី នៅម៉ូប៉ែ-មុតេលីតេ ប្រទេសបារាំងដែលបាននិយាយថា ស្ថានភាពនៅក្នុងប្រទេសកម្ពុជាមិនមានការលំបាកអ្វីទេ ហើយមាននិស្សិតជាច្រើនបានធ្វើមាតុភូមិនិវត្តន៍តាមការអំពាវនាវរបស់ អៀង សារី ។ ពាក់ព័ន្ធនឹងព័ត៌មានដែលផ្សព្វផ្សាយអំពីការជម្លៀសជនបរទេស និងការសម្លាប់មនុស្សនៅក្នុងប្រទេសកម្ពុជា លោកបានរៀបរាប់ថា នៅឆ្នាំ១៩៧៧ លោកបានសរសេរសៀវភៅមួយ ក្បាលដែលមានចំណងជើងថា "កម្ពុជាឆ្នាំសូន្យ" ។ បន្ទាប់មក ចៅក្រម ហ្សង់ម៉ាក ឡាវីញ បានបន្តសួរទាក់ទងនឹងប្រភពព័ត៌មានផ្សេងៗទាក់ទងនឹងការសម្លាប់ប្រជាជនដែលសាក្សីបានដឹងឮ ។ សាក្សី ប៉ុងសូដ៍ បានពន្យល់ថា គាត់ចាត់ទុកព័ត៌មានដែលប្រមូលបានពីជនភៀសខ្លួនជាប្រភេទព័ត៌មានផ្សេងៗ ដោយសារតែជនភៀសខ្លួនភាគច្រើនផ្តល់ព័ត៌មានដែលលើសពីការពិត ។ ប៉ុន្តែ ក្រោយពេលទទួលបានព័ត៌មានដូចគ្នា ឬប្រហាក់ប្រហែលគ្នារួចមកទើបគាត់យល់ថា ព័ត៌មានទាំងនោះអាចប្រើប្រាស់បាន ។ សាក្សីបានបន្តថា ដំបូងឡើយគាត់មានការទុកចិត្តចំពោះអង្គការ ដោយសារដែរមេដឹកនាំធំៗសុទ្ធតែជាអ្នកចេះដឹងនិងបានទៅរៀនសូត្រនៅប្រទេសបារាំង ។ ជាងនេះទៅទៀត ខ្មែរក្រហមមានផែនការល្អ មិនមែនជាការកាប់សម្លាប់ប្រជាជននោះទេ ។ ដូច្នេះ សាក្សីបានព្យាយាមស្តាប់ព័ត៌មានតាមវិទ្យុរបស់ខ្មែរក្រហមដែលផ្សព្វផ្សាយអំពីមនោគមវិជ្ជារបស់អង្គការ ។ ចំណែកព័ត៌មានដែលទទួលបានពីជនភៀសខ្លួន ជាព័ត៌មានដែលបង្ហាញអំពីស្ថានភាពរស់នៅក្រោមការអនុវត្តមនោគមវិជ្ជារបស់អង្គការ ។ ទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មានទៅក្រៅប្រទេសអំពីព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា សាក្សីបានបញ្ជាក់ថា ការដែលខ្លួនបានផ្សព្វផ្សាយព័ត៌មានទាំងនោះ ដោយសារតែខ្លួនចង់ចែករំលែកនូវទុក្ខលំបាកវេទនារបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបខ្មែរក្រហម ។ លោកបានបន្តថា ហេតុការណ៍នោះបានកើតឡើងដោយសារតែវាជាដំណាក់កាលនៃសង្គ្រាមត្រជាក់រវាងសហរដ្ឋអាមេរិក សូវៀត និងចិន ។ ចិនបានប្រើប្រាស់ខ្មែរក្រហមដើម្បីប្រឆាំងនឹងសូវៀត ដូច្នេះ អង្គការសហប្រជាជាតិបានដឹងច្បាស់អំពីការកាប់សម្លាប់ និងទុក្ខវេទនារបស់ប្រជាជនខ្មែរ ប៉ុន្តែក្រោយមកអង្គការសហប្រជាជាតិនៅតែទទួលស្គាល់ខ្មែរក្រហមថែមទៀត ។ ចៅក្រមក៏បានបន្តដកស្រង់នៅក្នុងសៀវភៅរបស់សាក្សីដែលមានចំណងជើងថា "កម្ពុជាឆ្នាំសូន្យ" ត្រង់ចំណុចដែលនិយាយអំពីស្ថានភាពកាប់សម្លាប់មន្ត្រីបុគ្គលិក យោធា គយ និងអ្នកស៊ើបការណ៍ផ្សេងៗនៅក្នុងរបបលន់ នល់ នៅក្រោយថ្ងៃ១៧មេសា ដើម្បីឲ្យសាក្សីពន្យល់ ។ ខណៈនោះ ក៏មានការលើកឡើងជំទាស់របស់មេធាវីការពារក្តីអាកទួរ វ៉ែកកែន និងមេធាវី វិចទ័រ កុបប៉េ ដោយមេធាវីទាំងពីររូបបានអះអាងថា ការលើកឡើងរបស់ចៅក្រម ឡាវីញ ប្រាសចាកពីវិសាលភាពនៃអង្គហេតុ ។ម្យ៉ាងទៀត សាក្សី ប៉ុងសូដ៍ ជាសាក្សីធម្មតាតែប៉ុណ្ណោះ មិនមែនជាសាក្សីជំនាញឡើយ ។ ទោះបីជាមានការជំទាស់យ៉ាងនេះក្តី ចៅក្រម និល ណុន បានបដិសេធការជំទាស់នេះ ដោយផ្តល់ហេតុផលថា សំណួរនេះអាចទទួលយកបានដោយសារសំណួរនេះ ត្រូវបានសួរឡើងដោយអង្គជំនុំជម្រះ ។ ចំពោះព័ត៌មានទាំងនោះ សាក្សីបានទទួលពីជនភៀសខ្លួន ជាច្រើននាក់ និងច្រើនកន្លែងខុសៗគ្នា ។ សាក្សី ប៉ុងសូដ៍ បានបន្តថា ការសរសេរសៀវភៅរបស់គាត់ ក៏បានទទួលរងនូវការរិះគន់ពីសំណាក់លោក ម៉ៃឃើល វីកក័រី ប៉ុន្តែទោះបីជាយ៉ាងណា គាត់ទទួលស្គាល់ការរិះគន់ទាំងនោះ ដោយសារតែគាត់មានការភ័ន្តច្រឡំថា ស្ថានភាពកាប់សម្លាប់នៅក្នុងប្រទេសកម្ពុជានៅពេលនោះបានកើតឡើងដូចគ្នានៅគ្រប់ទីកន្លែង ។

## ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

### ក) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ដឺវ៉ាយ ដេស្មាឯលបានចាប់ផ្តើមសំណួរដោយស្នើឲ្យសាក្សីបញ្ជាក់លើចម្លើយរបស់ខ្លួនដែលនិយាយថា នៅចន្លោះឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមដែលនៅតាមតំបន់រំដោះមានសភាពកាចសាហាវ ។ ទាក់ទងនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា ខ្លួនបានទទួលព័ត៌មានទាំងនេះមកពីខេត្តកំពង់ចាម និងនៅកែបដែលបញ្ជាក់ថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានដុតបំផ្លាញផ្ទះប្រជាជន សម្លាប់មេភូមិ និងកៀរប្រជាជនឲ្យចូលទៅក្នុងព្រៃ ។ ករណីស្រដៀងគ្នានេះ លោកទទួលព័ត៌មានពីក្រុមលោកសង្ឃកាតូលិកដែលរស់នៅខេត្តកំពង់ធំនៅឆ្នាំ១៩៧៣ ។ សាក្សីបានបន្តថា នៅក្នុង

ផ្នែកអារម្ភកថានៃសៀវភៅរបស់ខ្លួន សាក្សីបានគាំទ្រចំពោះខ្មែរក្រហមក្នុងការឡើងកាន់អំណាចដោយសារតែនៅក្នុងរបបលន់ នល់ មានការធ្វើបាប និងកាប់សម្លាប់ប្រជាជនជាច្រើននាក់ ។ ដូច្នេះ មានតែខ្មែរក្រហមទេដែលអាចនាំសេចក្ដីសុខជូនប្រជាជនបាន ។ ប៉ុន្តែ ក្រោយមកសាក្សីបានផ្លាស់ប្ដូរការគិតបែបនេះវិញ ក្រោយពេលខ្មែរក្រហមបានជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ដោយសារសាក្សីយល់ថា ការជម្លៀសនេះត្រូវបានធ្វើឡើងទីក្រុង ត្រឡប់ទៅស្រុកស្រែ ទៅឆ្ការព្រៃ ទៅស្ទូងស្រូវ ទៅច្រូតស្រូវ គេស្គាល់តម្លៃដ៏ពិតប្រាកដនៃអ្វីៗដែលគេហូប ។ ជនជាតិខ្មែរត្រូវដឹងថា គេកើតមកពីគ្រាប់ស្រូវ» ។ «ចិន ជាខ្មាំងសត្រូវរបស់ខ្មែរ ពីព្រោះនេះចូលក្នុងការតស៊ូវណ្ណៈចិនកាន់លុយ» ។ ចំណែកនៅក្នុងនិក្ខេបបទរបស់ ខៀវ សំផន ក៏បានពន្យល់អំពីការតស៊ូវណ្ណៈដោយមានសរសេរថា«កុំប្រាដ័រ» សំដៅទៅលើចិនដែលយកផលិតផលរបស់អ្នកស្រែទៅលក់ឲ្យជនជាតិបរទេស ។



កម្មាភិបាលខ្មែរក្រហម និងអ្នកជំនាញចិន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយមានការគ្រោងទុកច្បាស់លាស់ និងយកគំរូតាមការជម្លៀសប្រជាជនជា ប្រព័ន្ធនៅតាមបណ្ដាខេត្តផ្សេងៗតាំងពីឆ្នាំ១៩៧២មកម្ល៉េះ ។ បន្ទាប់មក ចៅក្រម ហ្សង់ម៉ាក ឡាវីញ បានបន្តសួរទាក់ទងនឹងទស្សនៈរបស់ខ្មែរក្រហមចំពោះអ្នកដែលរស់នៅទីក្រុង ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា លោកបានជួបខ្មែរក្រហមម្នាក់ដែលចូលមកដល់ទីក្រុងភ្នំពេញបាននិយាយថា «ទីក្រុង គឺជាកន្លែងដែលអាក្រក់ និងពោរពេញទៅដោយអំពើពុករលួយ ។ មិត្តមិនបានហូបបាយដែលខ្លួនដាំ ប្រសិនបើមិត្តនៅ

### ក.១) ការចូលមកដល់នៃយោធាខ្មែរក្រហម

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាយ៍ ដេស្មាឯល បានសួរទាក់ទងនឹងយោធាខ្មែរក្រហមដែលមានស្ថានភាពអស់កម្លាំង ខណៈពេលដែលប្រជាជនមានការអបអរដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សី ហ្វ្រង់ស័រ ប៉ុងសូដ៍ បានរៀបរាប់ថា នៅថ្ងៃដំបូងដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញមានយោធាមួយក្រុមដែលមនុស្សគ្រប់គ្នាមានការយល់ច្រឡំថា ជាខ្មែរក្រហម ប៉ុន្តែភាពពិតអ្នកទាំងនោះ ជាទាហាន លន់ នល់ ដែលចូលមកចរចា

ជាមួយខ្មែរក្រហមតែប៉ុណ្ណោះ ។ ចំណែកយោធាខ្មែរក្រហមពិតប្រាកដវិញ បានប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងដើម្បីបោសសម្អាតទីក្រុង ។ សាក្សីបានពន្យល់ថា នៅពេលពាក្យ "បោសសម្អាតទីក្រុង" ខ្ញុំយល់ឃើញថា សកម្មភាពនោះជាការបោសសម្អាតបុគ្គលិកនៃរបបសាធារណៈរដ្ឋខ្មែរ ។

### ក.២) ការសម្លាប់ទាហាន លន់ នល់

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ ។ សាក្សី ប៉ុងសូជ៏ បានរៀបរាប់ថា ខណៈពេលស្នាក់នៅក្នុងស្ថានទូតបារាំង គាត់បានជួបបុរសម្នាក់មកពីស្រុកកៀនស្វាយ ហើយបានរៀបរាប់ប្រាប់គាត់ថា "អង្គការសូមឲ្យរាជការជាន់ខ្ពស់ និងឲ្យទាហានសរសេរឈ្មោះរបស់ខ្លួនលើក្ដារខៀននៅក្នុងវត្តកៀនស្វាយ ។ នៅពេលល្ងាច អង្គការបានប្រមូលអ្នកទាំងនោះទៅសម្លាប់ចោលនៅក្នុងបឹង" ។ ជាងនេះទៅទៀត គាត់បានទទួលដំណឹងអំពីការសម្លាប់ទាហាន លន់ នល់ ជាងបីរយនាក់នៅភ្នំធិបតីពីសាក្សីបួននាក់ ដែលនៅរួចជីវិតពីការសម្លាប់នៅទីនោះ ។ ប៉ុន្តែទោះបីជាយ៉ាងណា សាក្សីបានបន្ថែមថា គាត់ពុំធ្លាប់ឃើញខ្មែរក្រហមធ្វើបាបប្រជាជន ឬកាប់សម្លាប់ទាហាន លន់ នល់ នៅពេលមានការជម្លៀសចេញពីទីក្រុងភ្នំពេញនោះឡើយ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរឲ្យសាក្សីបញ្ជាក់អំពីចម្លើយរបស់ខ្លួន ដែលបានឆ្លើយតបនឹងសំណួររបស់ចៅក្រម ឡាវើញ ទាក់ទងនឹងស្ថានភាពក្នុងពេលជម្លៀសប្រជាជន ។ ជាការឆ្លើយតបសាក្សី ប៉ុងសូជ៏ បានលើកយកសម្ដីរបស់លោក អ៊ូ ណាល់ ជាគ្រូពេទ្យនៅឯមន្ទីរពេទ្យព្រះកេតុមាលា ដែលនិយាយថា "ចំពោះអ្នកជំងឺ និងជនពិការត្រូវបានបណ្ដេញចេញពីមន្ទីរពេទ្យ" ។ ពាក់ព័ន្ធនឹងមូលហេតុនៃការជម្លៀសប្រជាជនវិញ សាក្សីបានបញ្ជាក់ថា មូលហេតុតែមួយគត់ដែលខ្មែរក្រហមបានប្រើប្រាស់នៅពេលនោះ គឺជាការប្រើមនោគមវិជ្ជា ដើម្បីបោកបញ្ឆោតតែប៉ុណ្ណោះដោយសារសហរដ្ឋអាមេរិក បានចាកចេញពីប្រទេសកម្ពុជាតាំងពីថ្ងៃទី១២ ខែមេសា មកម្ល៉េះ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វាំងសង់ បានបន្តលើកឡើងនូវបទសម្ភាសន៍របស់ ចេមស៍ ព្រីងហ្គល ជាមួយ អៀង សារី កាលពីខែកញ្ញា ឆ្នាំ១៩៧៥ ទាក់ទងនឹងការជម្លៀសប្រជាជន ដែលនៅក្នុង បទសម្ភាសន៍នោះ អៀង សារី បាននិយាយថា "នៅភ្នំពេញ មានមនុស្សប្រហែលដប់ម៉ឺននាក់បានត្រឡប់មកវិញ ហើយអ្នកផ្សេងទៀតមកបន្តិចម្ដងៗ ហើយអ្នកណាចង់មកភ្នំពេញអាចមកវិញបាន បើមិនចង់ទេ អាចនៅស្រុកស្រែបាន ។ ប្រជាជនយើងទាំងអស់គ្នាធ្វើការទាំងថ្ងៃទាំងយប់ ដើម្បីកសាងប្រទេសកម្ពុជាដូចជារោងជាងមួយដ៏មហាសាលអ៊ីចឹង" ។ ឆ្លើយតបនឹងការលើកឡើងនេះ សាក្សីបានបដិសេធថា ចម្លើយរបស់ អៀង សារី ជាការភូតកុហកតែប៉ុណ្ណោះ ដោយអះអាងថា នៅទីក្រុងពុំមានមនុស្សរស់នៅឡើយ ហើយព័ត៌មាននេះលោកបានមកពីការសម្ភាសន៍ជាមួយជនភៀសខ្លួនដែលមកពីតំបន់ខុសៗគ្នា ។ សាក្សីបានបន្តថា នៅចុងខែមេសា គាត់បានជួបស្ត្រីមួយក្រុមដែលមានសមាជិក១០នាក់ជាភរិយារបស់ទាហាន លន់ នល់ បានធ្វើដំណើរត្រឡប់មកកាន់ស្ថានទូតបារាំងវិញ ដោយសារអង្គការបានហៅអ្នកទាំងនោះឲ្យមកធ្វើការបំរើជាតិ ប៉ុន្តែនេះសុទ្ធតែជាការបោកប្រាស់របស់អង្គការ ដើម្បីយកអ្នកទាំងនោះមកសម្លាប់តែប៉ុណ្ណោះ ។ សាក្សីបានបន្ថែមថា លោកធ្លាប់សម្ភាសន៍ជាមួយជនរងគ្រោះបួននាក់ជាអតីតទាហាន លន់ នល់ ដែលបានរួចជីវិតពីការបាញ់សម្លាប់ដោយខ្មែរក្រហមនៅភ្នំធិបតីថា មានទាហាន លន់ នល់ ជាងបីរយនាក់បានស្លាប់នៅទីនោះ ដោយខ្មែរក្រហមបោកបញ្ឆោតឲ្យទាហានទាំងនោះទៅទទួលសម្ដេចឪ ។

ទាក់ទងនឹងចលនាបដិវត្តន៍ សាក្សី ប៉ុងសូជ៏ បានពន្យល់ថា ការធ្វើបដិវត្តន៍របស់ខ្មែរក្រហមមានបីដំណាក់កាលផ្សេងៗគ្នា ។ ដំណាក់កាលទី១ នៅឆ្នាំ១៩៧៥ ដែលខ្មែរក្រហមមានបំណងបំផ្លាញឬកម្ទេច អ្នកដែលបានបម្រើឲ្យអាមេរិកាំង ឬរដ្ឋាភិបាល លន់ នល់ ដែលខ្មែរក្រហមចាត់ទុកថាជាជនក្បត់ជាតិ ។ ដំណាក់កាលទី២ ជាដំណាក់កាលបដិវត្តន៍ប្រជាធិបតេយ្យនៅឆ្នាំ១៩៧៦ ដែលបង្ខំឲ្យគ្រប់វណ្ណៈចូលនៅក្នុងវណ្ណៈកសិករក្រថ្នាក់កណ្ដាលក្រោម ។ ដំណាក់កាលទី៣ ជាបដិវត្តន៍សង្គមនិយមនៅឆ្នាំ១៩៧៧ដែលមានការបង្កើតសហករណ៍កម្រិតខ្ពស់ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឲ្យសាក្សីពន្យល់អំពី

ទស្សនៈស្អាតស្អំ និងពាក្យស្លោករបស់ខ្មែរក្រហមដែលសាក្សីបានសរសេរនៅក្នុងសៀវភៅ "កម្ពុជាឆ្នាំសូន្យ" ថា "ដីកស្មៅត្រូវតែដីកទាំងឫស" ប៉ុន្តែត្រង់ចំណុចនេះ សាក្សីគ្រាន់តែបានបញ្ជាក់ថា "ឋានៈនៅក្នុងសង្គមខ្មែរ ប្រជាជនពិតប្រាកដ គឺជាអ្នកស្រែ អ្នកក្រថ្នាក់កណ្តាលក្រោមដែលមិនគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន មិនស្លូនត្លូ មិនគិតអំពីប្រយោជន៍ផ្ទាល់ខ្លួន ទៅជាមានកិត្តិយស ទៅជាគ្រឿងមួយក្នុងកណ្តាប់ដៃរបស់អង្គការនោះទេ តាមទស្សនៈនេះ"។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិក៏បានបន្តលើកឡើងនូវប្រធានបទមួយទៀតចេញពីសៀវភៅ "កម្ពុជាឆ្នាំសូន្យ" ទាក់ទងនឹងសន្ទរកថារបស់ ខៀវ សំផន ដែលបានចាក់ផ្សាយនៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ ដែលនិយាយអំពីការទទួលជ័យជំនះរបស់ខ្មែរក្រហម ។ ទាក់ទងនឹងចំណុចនេះ សាក្សីបានបញ្ជាក់យ៉ាងខ្លីថា នៅក្នុងសន្ទរកថានោះ គ្រាន់តែសង្កត់ធ្ងន់ទៅលើការប្រើប្រាស់អាវុធពីបុរាណក្នុងការទទួលបានជ័យជម្នះ ។ ទាក់ទងនឹងពាក្យ "ប្រុងប្រយ័ត្នបដិវត្តន៍" ដែល ខៀវ សំផន បានលើកឡើងនៅក្នុងសន្ទរកថាដដែលនោះ សាក្សីបានពន្យល់ថា ពាក្យឃោសនារបស់ខ្មែរក្រហមជាការផ្សព្វផ្សាយឲ្យមានការរួមគ្នារបស់ប្រជាជនកម្ពុជា ជាពិសេសប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយក្រៅពីនោះក៏មានពាក្យប្លែកៗមួយចំនួនទៀតដែលអង្គការបានប្រើដូចជាពាក្យ ឯករាជ្យម្ចាស់ការ ស្លូនត្លូ និងពាក្យថា ឈរលើគោលជំហរសតិអារម្មណ៍ និងចាត់តាំង ។ ចំណែកពាក្យថា "ឈ្លើយសឹក" លោកបានបញ្ជាក់ថា ពាក្យនេះ សំដៅទៅលើប្រជាជន ១៧មេសា ឬប្រជាជនថ្មីដែលខ្មែរក្រហមរំដោះបាន ហើយប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ សំដៅទៅលើប្រជាជនដែលរស់នៅតាមស្រុកស្រែ ។ លោកបានបន្តថា ដំបូងមានតែប្រជាជន ១៧ មេសា ទេដែលពុំមានសិទ្ធិសេរីភាពអ្វីទាំងអស់ ប៉ុន្តែរហូតដល់ឆ្នាំ ១៩៧៧ ខ្មែរក្រហមបានផ្លាស់ប្តូរគោលនយោបាយដោយធ្វើការរឹតត្បិតសិទ្ធិសេរីភាពរបស់ប្រជាជនមូលដ្ឋានដែរ ។ មុនពេលបញ្ចប់តំណាងសហព្រះរាជអាជ្ញាបានលើកយកសម្តីរបស់ អៀង សារី ដែលបានផ្តល់បទសម្ភាសន៍ជាមួយលោក ចេមស៍ ព្រីងហ្គុល ដែលនិយាយថា "កម្ពុជា គឺជាការដ្ឋានដ៏ធំ ដោយសារតែប្រជាជនពុំមានសិទ្ធិសេរីភាពចាប់ពីថ្ងៃទី១៧ ខែមេសា និងថ្ងៃបន្តបន្ទាប់ទៀត" ។ សាក្សីបានបញ្ជាក់ថា ករណីនេះខ្លួនធ្លាប់ឮជនភៀសខ្លួននិយាយថា កម្ពុជាជាគុកឥតជញ្ជាំង ប៉ុន្តែចំពោះពាក្យឃោសនារបស់ខ្មែរក្រហមវិញ កម្ពុជាជាការដ្ឋាន ដ៏ធំដែលប្រជាជនត្រូវធ្វើការទាំងថ្ងៃទាំងយប់ និងពោរពេញដោយការលំបាក ។

## ២) តំណាងសហព្រះរាជអាជ្ញាជាតិ

តំណាងសហព្រះរាជអាជ្ញាជាតិ ចាន់ តារាស្មី បានចាប់ផ្តើមសួរសាក្សីថា តើនៅក្នុងស្ថានភាពដែលខ្មែរក្រហមបានមកចាប់ជនក្បត់ទាំងប្រាំពីរនាក់ និងបំបែកគ្រួសារជនជាតិបារាំង និងជនជាតិខ្មែរនោះ ខ្មែរក្រហមបានគំរាមកំហែងអ្នកទាំងនោះយ៉ាងដូចម្តេចខ្លះ? ឆ្លើយតបនឹងសំណួរនេះ សាក្សី ប៉ុងសូដ៍ បានបញ្ជាក់ថា នៅពេលនោះខ្មែរក្រហមពុំបានគំរាមដោយប្រើអាវុធអ្វីឡើយ ប៉ុន្តែបុគ្គលទាំងនោះមានការភ័យខ្លាចជាខ្លាំង ហើយត្រូវតែធ្វើតាមបញ្ជារបស់ខ្មែរក្រហម ។ នៅពេលចាកចេញពីប្រទេសកម្ពុជា សាក្សី បានរៀបរាប់ថា ខ្លួនមានការរន្ធត់ជាខ្លាំង ដោយសារតែនៅតាមផ្លូវលោកពុំឃើញមានប្រជាជនសូម្បីតែម្នាក់ មានតែវាលស្រែនៅឆ្ងាយៗតែប៉ុណ្ណោះ ។ ទាក់ទងនឹងការបំបែកសមាជិកគ្រួសារ នៅពេលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សី ប៉ុងសូដ៍ បានបញ្ជាក់ថា ខ្លួនពុំបានឃើញផ្ទាល់ភ្នែកនូវព្រឹត្តិការណ៍នោះទេ ។ ប៉ុន្តែ សាក្សីបានពន្យល់ដោយយោងទៅលើការសម្ភាសន៍ជាមួយជនភៀសខ្លួនថា នៅពេលធ្វើដំណើរសមាជិកគ្រួសារបានដើរបែកគ្នាពិតមែន ។ ទោះបីជាយ៉ាងណាសាក្សីបានបញ្ជាក់ថា ការបំបែកសមាជិកគ្រួសារពុំមែនជាគោលបំណងពិតប្រាកដរបស់ខ្មែរក្រហមឡើយ ។

## ៣) ការសួរដេញដោលដោយសហមេធាវីដើមតំណាងបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយសហព្រះរាជអាជ្ញារួច សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី បានបន្តសួរបញ្ជាក់នូវចំណុចមួយចំនួនដែលសាក្សីបានឆ្លើយចំពោះអង្គជំនុំជម្រះ និងតំណាងសហព្រះរាជអាជ្ញា ព្រមទាំងព័ត៌មានមួយចំនួនដែលសាក្សីទទួលបានពីជនភៀសខ្លួន ។ សំណួរដំបូងរបស់មេធាវីជាតិ ទាក់ទងនឹងការសន្ទនារវាងសាក្សី និងយោធា

ខ្មែរក្រហមមួយក្រុមដែលសាក្សី បានជួបនៅយប់ថ្ងៃទី១៨ ខែមេសា ។ ជាការឆ្លើយតប សាក្សី ហ្វ្រង់ស្វ័រ ប៉ុងសូជ៍ បានរៀបរាប់ថា យោធា ដែលគាត់បានជួបនៅពេលនោះ គ្រាន់តែបាននិយាយប្រាប់អំពីគោលបំណងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញតែប៉ុណ្ណោះ ហើយគាត់ក៏ពុំបានសួរសំណួរអ្វីផ្សេងទៀតដែរ ដោយសារគាត់មានការភ័យខ្លាចចំពោះខ្មែរក្រហមទាំងនោះ ។ សាក្សីបានបន្តថា នៅថ្ងៃបន្ទាប់ គាត់បានជូនយោធាទាំងនោះទៅប្រជុំនៅស្ថានីយរទេះភ្លើង ប៉ុន្តែគាត់ក៏ពុំបានដឹងអំពីខ្លឹមសារនៃកិច្ចប្រជុំនោះដែរ ។ ទាក់ទងនឹងឋានៈរបស់កម្មាភិបាលថ្នាក់ខ្ពស់វិញ សាក្សីគ្រាន់តែពន្យល់ថា តាមការសម្ភាសន៍ជាមួយលោក ពេជ្រ លឹមគួន ដែលជាអ្នកបើកបរឧត្តម្ភាគចក្រឲ្យមេដឹកនាំខ្មែរក្រហម បានបញ្ជាក់ថា មេដឹកនាំធំៗនៅពេលនោះមានដូចជា ពត ហែម វ៉ាន់ និង ហាន ។ មេធាវីបានបន្តសំណួរដោយស្នើឲ្យសាក្សីបញ្ជាក់សាជាថ្មីនូវចម្លើយរបស់ខ្លួន ដែលនិយាយថា «អង្គការពូកែកុហក» ។ ចំពោះករណីនេះ សាក្សី ហ្វ្រង់ស្វ័រ ប៉ុងសូជ៍ បានរៀបរាប់ថា អង្គការបានប្រើពាក្យកុហកដើម្បីជាមធ្យោបាយត្រួតត្រាប្រទេសចាប់ពីពេលដែលមានការជម្លៀសប្រជាជនចេញពីទីក្រុង ហើយពាក្យឃោសនារបស់ខ្មែរក្រហមមានលក្ខណៈប្លែកៗ ដូចជាពាក្យថា មហាលោតផ្លោះ មហាអស្ចារ្យជាដើម ។

បន្ទាប់មក សហមេធាវីជាតិបានបន្តសួរទាក់ទងនឹងព័ត៌មានដែលសាក្សីបានសរសេរនៅក្នុងអត្ថបទមួយមានចំណងជើងថា «ប្រទេសកម្ពុជាប្រាំបួនខែក្រោយ» ដែលនៅក្នុងនោះសាក្សីបានរៀបរាប់ថា«តាមរបៀបនេះ ប្រទេសកម្ពុជាទាំងមូលបានក្លាយជាការដ្ឋានដ៏ធំទូលាយ ហើយដែលម្នាក់ៗលែងគិតអំពីយប់ ឬថ្ងៃទៀតហើយ ។ ពួកគេគិតតែសម្រុកធ្វើការឥតឈប់ឈរ ដោយគ្មានខ្លាចនឿយហត់ ក្នុងអារម្មណ៍រីករាយ និងមោទនភាព» ។ ចំពោះព័ត៌មាននេះ សាក្សីបានស្តាប់ឮតាមវិទ្យុដោយផ្ទាល់ ប៉ុន្តែអ្វីដែលគាត់បានសម្ភាសន៍ជាមួយជនរងគ្រោះ មានលក្ខណៈផ្ទុយគ្នាស្រឡះពីការផ្សព្វផ្សាយទាំងនោះ ។

សំណួរចុងក្រោយទាក់ទងនឹងសំណេរដែលសាក្សីបានសរសេរថា «បើតាមសម្តីរបស់ជនភៀសខ្លួនទាំងឡាយដែលបានមកដល់ប្រទេសថៃបានឲ្យដឹងថា នៅក្នុងខែមករា ការជម្លៀសប្រជាជនបានបណ្តាលឲ្យមានមនុស្សស្លាប់បាត់បង់ជីវិតច្រើនជាងការជម្លៀសប្រជាជនទ្រង់ទ្រាយធំ ដែលបានធ្វើឡើងកាលពីខែមេសា និងខែឧសភា ឆ្នាំ១៩៧៥ទៅទៀត ដោយសារការបាក់កម្លាំង ខ្វះចំណីអាហារបរិភោគ និងរស់នៅក្នុងស្ថានភាពខ្វះអនាម័យជាខ្លាំង» សាក្សីបានបន្តរៀបរាប់ថា មូលហេតុដែលនាំឲ្យគាត់សរសេរអត្ថបទនេះគឺ ដោយសារបានទទួលព័ត៌មានពីជនភៀសខ្លួនដែលរៀបរាប់អំពីទុក្ខវេទនាក្នុងពេលជម្លៀសជាលើកទី២ទៅកាន់ព្រៃដែនដោយពុំមានទឹក និងចំណីបរិភោគ ព្រមទាំងគ្មានកន្លែងសម្រាប់បន្ទោរបង់ ។ ជាងនេះទៅទៀត ដោយសារចំនួនមនុស្សស្លាប់បានកើនឡើងកាន់តែច្រើនឡើង ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយសហមេធាវីជាតិ សហមេធាវីអន្តរជាតិ អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វត បានចាប់ផ្តើមសំណួរទាក់ទងនឹងប្រភពព័ត៌មានដែលសាក្សីបានសរសេរផ្ញើទៅកាន់អង្គការសហ ប្រជាជាតិស្តីអំពីសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៨ និងអត្ថបទដែលចុះនៅក្នុងកាសែតកាលពីឆ្នាំ១៩៧៦ដែលនិយាយអំពីការជម្លៀសប្រជាជន និងស្ថានភាពរស់នៅរបស់ប្រជាជន ។ សាក្សី ប៉ុងសូជ៍ បានរៀបរាប់ថា ចំពោះការជម្លៀសប្រជាជន គាត់បានឃើញដោយផ្ទាល់ភ្នែក ប៉ុន្តែក្រោយពេលដែលគាត់ចាកចេញពីប្រទេសកម្ពុជា គាត់ពឹងផ្អែកទៅលើព័ត៌មានដែលផ្សាយតាមវិទ្យុខ្មែរក្រហម និងព័ត៌មានដែលទទួលបានពីជនភៀសខ្លួន ដែលក្នុងនោះ ជនរងគ្រោះបានរៀបរាប់អំពីការលុបបំបាត់សាសន៍ផ្សេងៗ ការរៀបអាពាហ៍ពិពាហ៍ការសម្លាប់មនុស្ស និងការធ្វើទុក្ខបុកម្នេញដល់ជនជាតិចាម និងវៀតណាម ។

## ៤) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តី

### ក) សហមេធាវីការពារក្តី ខៀវ សំផន

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីជាតិ គង់ សំអុន បានចាប់ផ្តើមសួរអំពីព័ត៌មានមួយចំនួនដែលពាក់ព័ន្ធនឹង ខៀវ សំផន ។ សាក្សី ប៉ុងសូជ៍ បានបញ្ជាក់ថា ខ្លួនបានស្គាល់ ខៀវ សំផន ដំបូងនៅក្នុងសម័យសង្គមរាស្ត្រនិយមក្នុងឆ្នាំ១៩៦៦ ។ ខៀវ សំផន ជាមនុស្សដែលស្អាតស្អំ មិនពុករលួយ និងហ៊ានស្វែងរកយុត្តិធម៌

ប្រឆាំងនឹងរបបសង្គមរាស្ត្រនិយមរបស់សម្តេចព្រះ នរោត្តម សីហនុ ។ សាក្សីបានបន្តថា នៅឆ្នាំ១៩៦៧ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ បានរត់គេចខ្លួនទៅខេត្តកំពតចេញពីការធ្វើបាបដោយមន្ត្រីនៅក្នុងរបបនោះ ដោយសារតែមានព្រឹត្តិការណ៍បះបោរពីប្រជាជននៅសំឡូត ប៉ុន្តែភាពពិតសកម្មភាពនោះពុំមានពាក់ព័ន្ធនឹង ខៀវ សំផន ឡើយ ។ នៅពេលនោះដែរ ក៏មានការឃោសនាពីសំណាក់រដ្ឋាភិបាលរបស់សម្តេចព្រះ នរោត្តម សីហនុ ថា បុគ្គលទាំងបីត្រូវបានគេយកទៅសម្លាប់ ប៉ុន្តែនៅឆ្នាំ១៩៧៣ ខៀវ សំផន បានលេចមុខសាជាថ្មី ។

សហមេធាវីអន្តរជាតិ អាកទួរ វែរកែន បានបន្តសំណួរដោយឲ្យសាក្សីបញ្ជាក់អំពីមូលហេតុដែលធ្វើឲ្យក្រុមនិស្សិតគាំទ្ររបបកុម្មុយនីស្តមកពីប្រទេសបារាំង មិនពេញចិត្តនឹងការដឹកនាំរបស់សម្តេច ព្រះ នរោត្តម សីហនុ ។ ពាក់ព័ន្ធនឹងបញ្ហានេះ សាក្សី ប៉ុងសូដ៍ បានរៀបរាប់ថា ក្រុមនិស្សិតទាំងនោះមានបំណងចង់បានអំណាចពីសម្តេចព្រះ នរោត្តម សីហនុ ប៉ុន្តែ សម្តេចពុំយល់ព្រម ទើបធ្វើឲ្យក្រុមនិស្សិតទាំងនោះមិនពេញចិត្ត ។ ម្យ៉ាងទៀត សាក្សីបានបន្តពន្យល់ទាក់ទងនឹងកុនអប្សរាថា ជាកុនមួយដែលឆ្លុះបញ្ចាំងឲ្យឃើញអំពីជីវិតរស់នៅក្នុងទីក្រុងភ្នំពេញ ដែលពោរពេញទៅដោយការប្រព្រឹត្តអំពើពាលាអាវ៉ាសែ ល្បែងស៊ីសងដោយមន្ត្រីធំៗជាហេតុធ្វើឲ្យកសិករនៅតាមជនបទមានការខឹងសម្បារ ។ ខណៈពេលដែលសាក្សីកំពុងរៀបរាប់នោះ មេធាវីការពារក្តីបានស្នើសុំឲ្យសាក្សីនិយាយជាភាសាបារាំងវិញ ដោយសារតែមេធាវីអះអាងថា ការបកប្រែជាភាសាបារាំងមិនបានត្រឹមត្រូវដូចដែលសាក្សីបានរៀបរាប់នោះទេ ។ ឆ្លើយតបនឹងសំណើនេះ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា ការជ្រើសរើសក្នុងការនិយាយភាសាខ្មែរជាជម្រើសរបស់សាក្សី ។ ម្យ៉ាងទៀត ដោយសារតែការនិយាយរបស់សាក្សីច្បាស់លាស់ត្រូវតាមពាក្យពេចន៍ខ្មែរ ដូច្នេះអង្គជំនុំជម្រះសម្រេចឲ្យសាក្សីនិយាយភាសាខ្មែរដដែល ។

បន្ទាប់មក មេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងស្ថានភាពនៅក្នុងស្ថានទូតបារាំងនៅពេលដែលមានកម្មាភិបាលម្នាក់មកប្រាប់ថា ខៀវ សំផន នឹងមកជួបមិត្តទាំងអស់នៅក្នុងស្ថានទូត ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះ បើយោងតាមអ្វីដែលខ្លួនបានដឹង ខៀវ សំផន ជាមេដឹកនាំខ្មែរក្រហមម្នាក់ក្នុងចំណោមថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ ប៉ុន្តែលោកមិនដឹងអំពីតួនាទីពិតប្រាកដនោះទេ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានបញ្ជាក់ថា ខ្លួនបានជួបលោក ពេជ លឹមគួន នៅឯប្រទេសថៃក្នុងឆ្នាំ១៩៧៦ ហើយពេលនោះខ្លួនបានសួរ ពេជ លឹមគួន ថា តើអ្វីជាអង្គការ? នៅពេលនោះ ពេជ លឹមគួន បានឆ្លើយថា អង្គការមានដូចជា ប៉ុល ពត ឬ សាឡុត ស, សមមិត្ត ហែម និងសមមិត្ត វ៉ាន់ ហើយក្រោយមកទើបខ្លួនបានដឹងថា ហែម គឺ សំដៅទៅលើ ខៀវ សំផន ហើយ វ៉ាន់ សំដៅទៅលើ អៀង សារី ។ សាក្សីបានបន្តថា ពេជ លឹមគួន បានភៀសខ្លួនទៅកាន់ប្រទេសថៃនៅពេលនោះ ដោយសារតែអង្គការបានចាត់តាំងឲ្យទៅបង្រៀនយុវជននៅតាមជនបទ ។ បន្ទាប់មក សហមេធាវីអន្តរជាតិបានបន្តសួរសាក្សីទាក់ទងនឹងការស្វែងរកជនជាតិអាមេរិកកាំង ខណៈពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ។ បញ្ហានេះ សាក្សី ប៉ុងសូដ៍ បានបញ្ជាក់ដូចអ្វីដែលគាត់បានឆ្លើយនឹងសំណួររបស់ចៅក្រម ឡាវែញ ថា ខ្មែរក្រហមបានស្វែងរកជនជាតិអាមេរិក ប៉ុន្តែអ្នកទាំងនោះបានចាកចេញពីប្រទេសកម្ពុជាតាំងពីថ្ងៃទី១២ ខែមេសា មកម៉្លេះ ហើយមានតែប្រធានក្រុម សេ.អ៊ី.អា ម្នាក់ប៉ុណ្ណោះ ដែលបានទៅស្នាក់នៅក្នុងស្ថានទូតបារាំង ។ សហមេធាវីអន្តរជាតិ អាកទួរ វែរកែន បានសួរដេញដោលបន្តទាក់ទងនឹងគោលជំហររបស់ប្រទេសថៃក្នុងការទទួលយកជនភៀសខ្លួនឲ្យទៅស្នាក់នៅក្នុងជំរំចាប់ពីឆ្នាំ១៩៧៥មក ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានរៀបរាប់ថា ថៃមានបំណងត្រួតត្រាលើជនភៀសខ្លួនដើម្បីទទួលយកផលប្រយោជន៍នយោបាយ ដោយបើកឲ្យមានជនភៀសខ្លួនរហូតដល់ទៅប្រាំម៉ឺននាក់រស់នៅទីនោះ ។ ពេលខ្លះ ថៃបានអនុញ្ញាតឲ្យប្រជាជនខ្មែរដែលប្រឆាំងនឹងខ្មែរក្រហមចូលមកច្បាំងជាមួយខ្មែរក្រហម ប៉ុន្តែពេលខ្លះ ថៃបានសម្លាប់ជនភៀសខ្លួន និងអ្នកដែលប្រឆាំងនឹងខ្មែរក្រហម ទៅវិញ ។ សាក្សីបានបន្តថា នៅឆ្នាំ១៩៧៩ ប្រជាជនខ្មែររាប់សែននាក់បានចូលទៅរស់នៅក្នុងប្រទេសថៃ ប៉ុន្តែ ថៃពុំព្រមទទួលយកជនភៀសខ្លួនគេទៀតទេ ។ ដូច្នេះ ថៃបានយកជនភៀសខ្លួនប្រមាណបីម៉ឺននាក់ទៅទម្លាក់ចោលនៅខេត្តព្រះវិហារតាមជួរភ្នំដងរែក ហើយពេលនោះ បុគ្គលិករបស់

អង្គការសហប្រជាជាតិបានយកជំនួយទៅចែកជូនជនភៀសខ្លួនទាំងនោះ ។

**បញ្ជាក់ ៖** ខណៈពេលឆ្លើយតបនឹងសំណួរនេះ សាក្សី ប៉ុងសូដ បានខឹងច្រឡោតជាខ្លាំង ដោយអះអាងថា មានបញ្ហាខាងបកប្រែភាសាយ៉ាងពិតប្រាកដ ដោយសារតែខ្លឹមសារមានភាពផ្ទុយគ្នាពីអ្វីដែលខ្លួនបាននិយាយទាំងស្រុង ។ បន្ទាប់មក សាក្សីបានបញ្ជាក់ថា ដំបូងឡើយខ្លួនបានជ្រើសរើសនិយាយភាសាខ្មែរដោយសារមិនចង់ឲ្យតំណាងសហព្រះរាជអាជ្ញាយល់ច្រឡំថា ខ្លួនលំអៀងទូតបារាំង ខ្លួនបានឃើញក្មេងៗអាយុប្រហែល១៣-១៤ឆ្នាំសូត្រវិន័យនោះរាល់ថ្ងៃ ហើយអ្នកទាំងនោះគោរពវិន័យនេះបានល្អ ។ មេធាវីអន្តរជាតិបានលើកយកនូវបទសម្ភាសន៍របស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ដែលទាក់ទងនឹងមូលហេតុនៃការជម្លៀសប្រជាជនដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សីបានបញ្ជាក់ថា ការជម្លៀសជាការអនុវត្តមនោគមវិជ្ជារបស់ខ្មែរក្រហមដែលចង់បង្កើតសង្គមមួយដែលគ្មានទីក្រុង គ្មានកុំប្រាឌ័រ គ្មាននាយទុន ដូចនឹងអ្វីដែល ខៀវ សំផន បានសរសេរនៅក្នុងនិក្ខេបបទ



យោធាខ្មែរក្រហមក្នុងពិធីរំឭកខួបកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យនៅពហុកីឡាដ្ឋានជាតិអូឡាំពិក ឆ្នាំ១៩៧៥ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅខាងមេធាវីការពារក្តី ។ ដូច្នេះ សាក្សីបានស្នើសុំដល់អង្គជំនុំជម្រះដើម្បីនិយាយភាសាបារាំងវិញ ។ ដោយយល់ឃើញថាស្ថានភាពបែបនេះបានកើតឡើងសាជាថ្មី អង្គជំនុំជម្រះបានសម្រេចឲ្យសាក្សីនិយាយភាសាបារាំងចាប់ពីពេលនោះតទៅដើម្បីចៀសវាងកុំឲ្យមានបញ្ហាបែបនេះកើតឡើងបន្តទៀត ។

បន្ទាប់មក មេធាវីអន្តរជាតិ អាកទួរ វែកគែន បានលើកឡើងអំពីវិន័យទាំង១២ប្រការរបស់ខ្មែរក្រហមដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សី ប៉ុងសូដ បានបញ្ជាក់ថា ខ្លួនគាំទ្រចំពោះវិន័យទាំង១២ប្រការនោះ ដោយសារខណៈពេលដែលខ្លួនស្នាក់នៅក្នុងស្ថានថ្នាក់បណ្ឌិតរបស់ខ្លួន ។ បន្ទាប់មក មេធាវីអន្តរជាតិបានបន្តសួរសាក្សីថា តើស្ថានភាពដែលប្រជាជនពុំមានស្បៀងហូបគ្រប់គ្រាន់នោះ ដោយសារតែខ្មែរក្រហមបានយកស្រូវទៅសងបំណុលសង្គ្រាមឬយ៉ាងណា? ឆ្លើយតបនឹងសំណួរនេះ សាក្សី ហ្វ្រង់ស្វ័រ ប៉ុងសូដ បានពន្យល់ថា ខ្លួនធ្លាប់បានសម្ភាសន៍ជាមួយប្រជាជនមួយចំនួនដែលបង្ហាញថា នៅក្នុងរបបខ្មែរក្រហមមានការបង្កបង្កើនផលស្រូវបានច្រើន ប៉ុន្តែមូលហេតុដែលធ្វើឲ្យប្រជាជនខ្វះខាតរបបអាហារ ដោយសារតែខ្មែរក្រហមបានយកផលស្រូវនោះទៅសងបំណុលសង្គ្រាមជាមួយវៀតណាមខាងជើង និង

នាំយកទៅប្រទេសចិនមួយផ្នែកទៀត ។

សំណួរបន្ទាប់ ទាក់ទងនឹងការកម្រិតសិទ្ធិអំណាចរបស់កម្មាភិបាលថ្នាក់ក្រោមដូចជា មេឃុំ មេស្រុក និងប្រធានសហករណ៍ ។ សាក្សីបានពន្យល់ថា ខ្លួនបានមើលខ្សែភាពយន្តរបស់ ប្រ៊ុយណូ ការេត ដែលក្នុងនោះ ខៀវ សំផន បានទទួលស្គាល់ចំណុចខ្សោយនៅក្នុងរបបខ្មែរក្រហម ដែលបានផ្ដល់ទំនុកចិត្តលឿនពេកទៅលើកម្មាភិបាលថ្នាក់ក្រោម ។ ចំពោះមូលហេតុមួយទៀត អង្គការពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីបង្ហាត់បង្រៀន ទើបបណ្ដាលឲ្យកម្មាភិបាលទាំងនោះអនុវត្តបញ្ជាដោយភាពឆោតល្ងង់របស់ខ្លួន ហើយបានក្លាយទៅជាឃាតករយ៉ាងពិតប្រាកដ ។ ម្យ៉ាងទៀត ការអនុវត្តការងារនៅតាមសហករណ៍នីមួយៗមានលក្ខណៈខុសៗគ្នា ។ ប្រធានសហករណ៍ខ្លះចិត្តល្អ ប៉ុន្តែមួយចំនួនទៀត ព្យាយាមផ្គាប់ចិត្តថ្នាក់លើខ្លាំងពេក ដោយកាត់បន្ថយស្បៀងសម្រាប់ផ្គត់ផ្គង់ប្រជាជនដើម្បីយកទៅបង្ហាញថ្នាក់លើថា សហករណ៍របស់ខ្លួនអាចផលិតទិន្នផលបានច្រើន ។

**បញ្ជាក់** ៖ បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយក្រុមមេធាវីការពារក្ដីរបស់ ខៀវ សំផន សាក្សី ប៉ុងសូជ៍ បានស្នើសុំអង្គជំនុំជម្រះដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់ ខៀវ សំផន ប៉ុន្តែការនោះត្រូវបានប្រធានអង្គជំនុំជម្រះបដិសេធដោយអះអាងថា ក្នុងនាមជាសាក្សី លោក ប៉ុងសូជ៍ មានសិទ្ធិត្រឹមតែឆ្លើយតបនឹងសំណួររបស់ភាគីតាមអ្វីដែលខ្លួនបានដឹងដោយផ្ទាល់ ឬដោយប្រយោលតែប៉ុណ្ណោះ ។ ចំណែកតម្លៃនៃភស្តុតាងដែលចេញពីសក្ខីកម្មរបស់សាក្សីមានតែអង្គជំនុំជម្រះតែប៉ុណ្ណោះជាអ្នកមានសិទ្ធិសម្រេច ។

បន្ទាប់មក លោកប្រធានបានផ្ទេរវេទិកាជូនក្រុមមេធាវីការពារក្ដី នួន ជា ដើម្បីសួរដេញដោលសាក្សី ។

### ១) ក្រុមមេធាវីការពារក្ដី នួន ជា

### ១.១) ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក

ក្នុងការសួរដេញដោលនេះ សហមេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានបន្តការសួរដេញដោលដោយផ្ដោតសំខាន់ទៅលើស្ថានភាពនៃការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាក្នុងអំឡុងពេលសង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាម ស្ថានភាពរបស់ជនភៀសខ្លួនដែលបានទៅរស់នៅក្នុងជំរំនៅប្រទេសថៃ និងព័ត៌មានមួយចំនួនទៀតទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ នួន ជា ។

សហមេធាវីបានចាប់ផ្ដើម ដោយសួរបញ្ជាក់លើចម្លើយរបស់សាក្សីទាក់ទងនឹងស្ថានភាពនៃការទម្លាក់គ្រាប់បែកនៅពេលមានសង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាម ។ សាក្សីបានបញ្ជាក់ថា បញ្ហានេះធ្វើឲ្យប្រជាជនកម្ពុជាទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំង ។ ម្យ៉ាងទៀត ហេតុការណ៍ជានេះជារឿងដ៏អាម៉ាស់មួយរបស់សហរដ្ឋអាមេរិក ដែលបានបង្កសង្គ្រាមជាមួយវៀតណាមខាងជើង ។ ដើម្បីបញ្ចប់សង្គ្រាមសហរដ្ឋអាមេរិកបានដាក់សម្ពាធមកលើខ្មែរក្រហមឲ្យធ្វើជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាម ប៉ុន្តែពេលនោះ ខ្មែរក្រហមបានបដិសេធដោយអះអាងថា ខ្លួនបានធ្វើសង្គ្រាមជាមួយនឹង លន់ នល់ ដោយមិនពាក់ព័ន្ធជាមួយសហរដ្ឋអាមេរិក និងវៀតណាមទេ ។ លោក ប៉ុងសូជ៍ បានបញ្ជាក់ថា ជាលទ្ធផល សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាយ៉ាងដំណំនៅក្នុងឆ្នាំ១៩៧៣ ដែលបណ្ដាលឲ្យមានមនុស្សស្លាប់ប្រហែលបួនម៉ឺននាក់ ព្រមទាំងប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់កម្ពុជា ។ ដូច្នេះ តុលាការគួរតែធ្វើការកាត់ទោស ឃីសស៊ីងជ័រ ដែលនាំឲ្យខ្មែរក្រហមមានកំហឹងតបតនឹងការទម្លាក់គ្រាប់បែកនេះ ។ សាក្សីបានបន្តរៀបរាប់ថា តំបន់ដែលទទួលរងការទម្លាក់គ្រាប់បែកខ្លាំង គឺនៅចំការកៅស៊ូក្នុងខេត្តកំពង់ចាម ។ ដោយសារតែការទម្លាក់គ្រាប់បែកនេះ កំណើនប្រជាជននៅទីក្រុងភ្នំពេញបានកើនឡើងជាលំដាប់ ។ ចំណែកប្រជាជនដែលរស់នៅទីក្រុងវិញ ក៏គ្មានអង្ករគ្រប់គ្រាន់សម្រាប់បរិភោគដែរ ។ ក្រោយមក សហរដ្ឋអាមេរិកបានយកស្បៀងមកចែកដល់ប្រជាជនដោយដឹកជញ្ជូនតាមយន្តហោះ រហូតដល់ដើមឆ្នាំ១៩៧៥ ។ តាមរយៈរូបភាពទាំងនេះ សាក្សី ប៉ុងសូជ៍ បានស្វែងយល់អំពីការលំបាករបស់ប្រជាជនកម្ពុជាដែលបានតស៊ូរស់នៅក្នុងសង្គ្រាម ។ ទាក់ទងនឹងព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកដ៏សាហាវនៃសង្គ្រាមរវាងវៀតណាម និងសហរដ្ឋអាមេរិក សាក្សីបានរៀបរាប់ថា ក្រោយពេលមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ ពីតំណែង លន់ នល់ បានបញ្ជាឲ្យវៀតណាមខាងជើងដែលនៅតាមព្រំដែនត្រឡប់ទៅវៀតណាមវិញ ។ ផ្ទុយ

ទៅវិញ វៀតណាមកុម្មុយនីស្តបានចូលមកឈ្លានពានប្រទេសកម្ពុជា ដែលធ្វើឲ្យ លន់ នល់ ផ្លាស់ប្តូរគំនិតអំពាវនាវដល់ប្រជាជនខ្មែរ ដែលមិនពេញចិត្តនឹងវៀតណាម ឲ្យចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាមអស់ប្រហែល២ពាន់នាក់រួមទាំងខ្មែរកម្ពុជាក្រោមដែរ ។ ម្យ៉ាងទៀត ដោយសារវៀតណាមខាងជើង និងវៀតកុងបានចូលមកឈ្លានពាន និងដណ្តើមយកទីក្រុងភ្នំពេញ លន់ នល់ បានស្នើសុំជំនួយទ័ពពីវៀតណាមខាងត្បូង ។ នៅពេលនោះ សហរដ្ឋអាមេរិកក៏បានចូលមកទម្លាក់គ្រាប់បែកអមជាមួយវៀតណាមខាងត្បូងលើទីស្នាក់ការរបស់វៀតណាមខាងជើង ដែលមានចម្ងាយ៤០គីឡូម៉ែត្រក្នុងទឹកដីកម្ពុជា ។ បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងពាក្យ“ប្រល័យពូជសាសន៍” ទៅលើជនជាតិវៀតណាមដោយរបប លន់ នល់ ក្នុងពេលមានការទម្លាក់គ្រាប់បែកដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានបញ្ជាក់ថា ខ្លួនចាត់ទុកការសម្លាប់វៀតណាមជាអំពើប្រល័យពូជសាសន៍ ដោយសារមានមនុស្សស្លាប់ជាច្រើននាក់នៅពេលនោះ ។ ករណីនេះមានភាពខុសគ្នាជាមួយនឹងរបបខ្មែរក្រហម ដោយសារតែនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជូនវៀតណាមឲ្យត្រឡប់ទៅស្រុកវិញ ប៉ុន្តែស្ថានភាពនេះមានការផ្លាស់ប្តូរវិញចាប់ពីឆ្នាំ១៩៧៨ ដោយសារតែខ្មែរក្រហមបានធ្វើសង្គ្រាម និងសម្លាប់ជនជាតិវៀតណាម ។ ទោះបីជាយ៉ាងណា សាក្សីពុំបានបញ្ជាក់ថា សកម្មភាពសម្លាប់នោះជាការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬយ៉ាងណាឡើយ ។ សាក្សី ប៊ុងសូដ បានបន្តរៀបរាប់ថា នៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ពុំមានការធ្វើទុក្ខបុកម្នេញមកលើសាសនាឡើយទោះបីជាសាសនានោះជាសាសនាគ្រិស្ត សាសនាឥស្លាម ឬសាសនាព្រះពុទ្ធក៏ដោយ ។ ម្យ៉ាងទៀត បើយោងទៅលើការសម្ភាសន៍របស់ខ្លួនជាមួយជនជាតិចាមមួយចំនួនហាក់បីដូចជាពុំមានចម្លើយណាច្បាស់លាស់ ដើម្បីបង្ហាញថាមានអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមនោះទេ ។

សំណួរបន្ទាប់ ទាក់ទងនឹងទិដ្ឋភាពនៅថ្ងៃ១៧មេសា ដែលមានការបែងចែកទាហានជាច្រើនក្រុម និងមានលក្ខណៈខុសៗគ្នា ។ សាក្សីបានរៀបរាប់ថា នៅថ្ងៃទី១៧មេសា មានយោធាជាច្រើនខុសគ្នា ទាំងការស្លៀកពាក់ ការប្រើប្រាស់ភាសា និងអាកប្បកិរិយាជាដើម ប៉ុន្តែខ្លួនមិនបានដឹងថា យោធាទាំងនោះមកទីតំបន់ណាជាក់លាក់ទេ ។ ប៉ុន្តែក្រោយមក ខ្លួនបានស្វែងយល់ថា យោធាទាំងអស់មាន៦ក្រុមដែលបានទៅប្រជុំគ្នានៅស្តាទីយរថភ្លើង ។

### ១.២) ព័ត៌មានដែលទទួលបានពីជនភៀសខ្លួន

មេធាវីអន្តរជាតិបានបន្តសំណួរដើម្បីឲ្យសាក្សីបញ្ជាក់ឡើងវិញ អំពីការសរសេរសៀវភៅរបស់លោក ម៉ៃខល វិកឃើរី ដែលមានភាពមិនស៊ីសង្វាក់គ្នានឹងការសរសេររបស់សាក្សី ទាក់ទងនឹងការអនុវត្តគោលនយោបាយរបស់ខ្មែរក្រហមក្នុងការសម្លាប់មនុស្ស ។ ពាក់ព័ន្ធនឹងបញ្ហានេះ សាក្សី ប៊ុងសូដ បានបញ្ជាក់ថា ខ្លួនបានបញ្ចប់ការសរសេរសៀវភៅ “កម្ពុជាឆ្នាំសូន្យ” នៅឆ្នាំ១៩៧៦ ដូច្នេះ ខ្លួនពុំមានលទ្ធភាពទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយពីប្រជាជនដែលមកពីតាមបណ្តាខេត្តផ្សេងៗដូចជាខេត្តក្រចេះ កំពង់ចាម ស្វាយរៀង តាកែវ ទេ ។ ព័ត៌មានភាគច្រើនខ្លួនបានទទួលពីប្រជាជនដែលភៀសខ្លួនមកពីខេត្តបាត់ដំបង និងភ្នំពេញតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាសាក្សីបានបញ្ជាក់ថា សាក្សីពុំជឿតាមការរៀបរាប់របស់ជនភៀសខ្លួនដែលខ្លួនបានសម្ភាសន៍នោះទាំងស្រុងឡើយ អ្នកដែលធ្លាប់ធ្វើជាខ្មែរក្រហមមានមួយចំនួនតូចប៉ុណ្ណោះដែលបានផ្តល់ព័ត៌មានពិត ។ ម្យ៉ាងទៀត ខ្លួនបានជ្រើសរើសបទសម្ភាសន៍ដែលប្រមូលបានយ៉ាងប្រុងប្រយ័ត្នបំផុត និងពិនិត្យទៅលើស្លាកស្នាមដែលបានបន្សល់ទុកនៅលើរាងកាយរបស់ជនរងគ្រោះដើម្បីជៀសវាងនូវព័ត៌មានដែលមានលក្ខណៈបំផ្លើស ។ ជាងនេះទៅទៀត ខ្លួនបានព្យាយាមស្វែងរកព័ត៌មានផ្សេងៗតាមរយៈការស្តាប់វិទ្យុខ្មែរក្រហមបន្ថែមទៀត ដើម្បីយល់ដឹងអំពីគោលនយោបាយរបស់ខ្មែរក្រហមដែលអាចឲ្យលោកធ្វើការ វិភាគតាមបែបវិទ្យាសាស្ត្របាន ។

បន្ទាប់មក មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានបន្តសួរទាក់ទងនឹងការអនុវត្តរបស់កម្មាភិបាលថ្នាក់ក្រោម និងអ្នកដែលត្រូវទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយរបស់ខ្មែរក្រហម ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនតែងតែសួរសំណួរនេះទៅកាន់ខ្លួនឯង ហើយបញ្ហានេះពាក់ព័ន្ធនឹងតុលាការផ្ទាល់តែម្តងដែលថា តើតុលាការកាត់ទោសចំពោះបុគ្គល

ឬកាត់ទោសចំពោះមនោគមន៍វិជ្ជា?

បន្ទាប់មក សាក្សីបានលើកជាឧទាហរណ៍បន្ថែមថា "ដូច លោក ខៀវ សំផន នៅទីនេះ គឺមានអ្នកដែលមានចេតនាល្អ ហើយ ក្រោយមកទៀត ដោយសារតែការបត់បែនតាមមនោគមន៍វិជ្ជា មិនទាន់ ដែលនាំទៅរកផ្លូវខុសទាំងស្រុង និងពោរពេញដោយ ការស្រមើស្រមៃ ពីព្រោះអ្នកទាំងអស់នោះសុទ្ធតែស្រមើស្រមៃ ចង់បានពិភពមួយដែលប្រសើរជាងពិភពដែលខ្លួនកំពុងរស់នៅសព្វ ថ្ងៃ ។ ជាការពិតណាស់ដែលមានសេចក្តីណែនាំពីថ្នាក់លើប្រហែល ជាសេចក្តីណែនាំដ៏ឆោតល្ងង់ដែរ ដែលសន្និដ្ឋានមនុស្សថាសុទ្ធតែ ល្អ ។ នេះជាគំនិតរបស់ខ្មែរក្រហមដែលថា មនុស្សកើតមកសុទ្ធតែ ល្អ ប៉ុន្តែសង្គមធ្វើឲ្យគេពុករលួយ ។ ខ្មែរក្រហមបានណែនាំកម្មា ភិបាលថ្នាក់ក្រោមនូវអ្វីដែលខ្លួនយល់ថា ជាការត្រឹមត្រូវដោយ ពុំមានសរសេរជាលាយលក្ខណ៍អក្សរនោះទេ ។ ចំណែកធម្មជាតិ របស់មនុស្សវិញ គឺនៅពេលដែលកម្មាភិបាលថ្នាក់តូចមានអំណាច អ្នកទាំងនោះមិនបានរឹតត្បិតអំណាចរបស់ខ្លួនទេ ផ្ទុយទៅវិញ គេ ចង់ប្រើអំណាចនោះឲ្យអស់តែម្តង" ។

មេធាវីអន្តរជាតិបានបន្តសួរសាក្សីអំពីការផ្តល់ព័ត៌មាន របស់ជនភៀសខ្លួនថា តើជនភៀសខ្លួន ទាំងនោះមានបំណង ចង់មកផ្តល់ព័ត៌មានទាក់ទងនឹងការលំបាករបស់ខ្លួនដោយស្ម័គ្រចិត្ត ឬយ៉ាងណា? សាក្សី ប៉ុងសូដ៍ បានអះអាងថា ពេលដែលខ្លួន ស្នាក់នៅក្នុងប្រទេសបារាំងចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ដល់ខែមីនា ឆ្នាំ១៩៧៦ មានជនភៀសខ្លួនច្រើននាក់បានមកជួបខ្លួនដោយ ស្ម័គ្រចិត្ត ហើយមានពេលខ្លះទៀត សាក្សីបានទៅសម្ភាសន៍នៅក្នុង ជំរំបណ្តោះអាសន្ន ។ ក្រោយមកចាប់ពីខែមិថុនា ឆ្នាំ១៩៧៦ ខ្លួនបានត្រឡប់មកប្រទេសថៃដើម្បីសម្ភាសន៍ប្រជាជនផ្សេង ទៀត ។ ប៉ុន្តែនៅឆ្នាំ១៩៧៩ សាក្សីបានបញ្ជាក់ថា ខ្លួនជួបការ លំបាកច្រើនក្នុងការសម្ភាសន៍ជនភៀសខ្លួន ដោយសារតែនៅ ពេលនោះ ចំនួនជនភៀសខ្លួនបានកើនឡើងប្រហែល ៥ម៉ឺននាក់ ។ ដូច្នេះ នៅពេលទៅសម្ភាសន៍ តែងតែមានអ្នកផ្សេងទៀតបាន មកចូលរួម ដែលជាហេតុធ្វើឲ្យអ្នកផ្តល់បទសម្ភាសន៍នោះពុំហ៊ាន ផ្តល់ព័ត៌មានត្រង់ៗនោះទេ ។ ទាក់ទងនឹងស្ថានភាព និងចំនួនជន ភៀសខ្លួននៅតាមព្រំដែនថៃ សាក្សីបានបន្តរៀបរាប់ថា នៅឆ្នាំ ១៩៧៩ មានប្រជាជនច្រើននាក់បានរត់ទៅនៅតាមព្រំដែន ជាមួយខ្មែរក្រហម ប៉ុន្តែនៅពេលនោះ ប្រទេសថៃបានប្រឹក្សា យោបល់ជាមួយប្រទេសចិន ដើម្បីបើកជំរំជនភៀសខ្លួនក្រោម ជំនួយរបស់កាកបាទក្រហម ដូចជា ជំរំខៅអ៊ីដាងដែលជាជំរំ ដ៏ល្បីមួយមានមនុស្សស្នាក់នៅប្រហែលជា ១សែន៥ម៉ឺននាក់ ។ ក្រោយមក ប្រទេសថៃបានជ្រើសរើសទាហានក្នុងចំណោមជន ភៀសខ្លួនទាំងនោះដើម្បីបណ្តេញកងទ័ពវៀតណាមពីប្រទេស កម្ពុជា ។ នៅឆ្នាំ១៩៨៤ ជនភៀសខ្លួនជាច្រើននាក់បានចូលទៅ រស់នៅក្នុងប្រទេសថៃក្នុងជំរំសាយធូ សាយអេច សាយសុខសាន្ត និងសាយប៊ីជាដើម ។

សំណួរចុងក្រោយ មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានផ្តោត សំខាន់ទៅលើព័ត៌មានដែលទាក់ទងនឹងជនជាប់ចោទ នួន ជា ។ សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់ឮឈ្មោះរបស់ នួន ជា តាមរយៈវិទ្យុ ប៉ុន្តែ ខ្លួនពុំបានដឹងអំពីតួនាទីរបស់ នួន ជា ទេ ។ សាក្សីបានបន្ត "ការកាត់ក្តីដែលធ្វើដោយកងទ័ពវៀតណាមនៅខែសីហា ឆ្នាំ ១៩៧៩ កាលនោះ នួន ជា អត់មានគេកាត់ក្តីអីទេ អត់មានឈ្មោះ នួន ជា ទេ ។ កាលនោះ គេកាត់ក្តីតែ បន ប៉ុល ពត, អៀង សារី... តាមសៀវភៅចុងក្រោយរបស់លោក ហិនរី ឡូកា, នួន ជា ជាអ្នក តំណាងឲ្យមនុស្សទាំងឡាយដែលទទួលការបណ្តុះបណ្តាលពី វៀតណាមដើម្បីសួរចម្លើយ ហើយនៅឆ្នាំ១៩៧៩ វៀតណាម ប្រហែលជាគិតថា នួន ជា ជាមនុស្សដែលគាត់អាចប្រើប្រាស់ បាន ។ អ៊ីចឹង ហើយទើបមិនមានឈ្មោះ នួន ជា នៅក្នុងសាលក្រម ១៩៧៩ ខែសីហា" ។ ត្រង់ចំណុចនេះ ចៅក្រម និល ណុន បាន កាត់សម្តីរបស់សាក្សីដោយអះអាងថា ការរៀបរាប់របស់សាក្សី បានចាកឆ្ងាយពីសំណួររបស់មេធាវី ។

មុនពេលបញ្ចប់ សាក្សីបានសម្តែងនូវការបារម្ភចំពោះមុខ អង្គជំនុំជម្រះអំពីសក្ខីកម្មរបស់ខ្លួន ដែលបានផ្តល់កន្លងមកដោយ សារមានបញ្ហាក្នុងការបកប្រែភាសា ។ ទោះបីជាយ៉ាងណា អង្គ ជំនុំជម្រះបានបញ្ជាក់ថា រាល់ការយោងទៅលើសក្ខីកម្មរបស់ សាក្សី អង្គជំនុំជម្រះនឹងពិនិត្យទៅលើការប្រើប្រាស់ភាសាដើម របស់សាក្សី និងមានការផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់មុនពេលអង្គ ជំនុំជម្រះធ្វើសេចក្តីសម្រេចណាមួយ ។

# សវនាការស្ដីពីការសាកសួរដេញដោលសាក្សី ឈូក រិន

## ថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ២០១៣

នៅថ្ងៃទី២២ និង២៣ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្ដីខ្មែរក្រហម បានកោះហៅសាក្សីមួយរូបទៀត ដែលមានឈ្មោះ ឈូក រិន ដើម្បីស្ដាប់សក្ខីកម្មទាក់ទងនឹងអង្គហេតុស្ដីពីប្រព័ន្ធទំនាក់ទំនងផ្នែកយោធារវាងថ្នាក់មូលដ្ឋាន និងថ្នាក់មជ្ឈិមអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឈូក រិន ជាអតីតមេបញ្ជាការខ្មែរក្រហមទទួលបន្ទុកផ្នែកយោធានៅកៀកនឹងតាមុក ហើយក្រោយមកត្រូវបានចាប់ខ្លួនដោយរាជរដ្ឋាភិបាលកម្ពុជា ដោយសារពាក់ព័ន្ធនឹងការសម្លាប់ជនបរទេស



ឈូក រិន
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

បីនាក់នៅតំបន់ភ្នំវល្លិ៍ក្នុងខេត្តកំពត នៅអំឡុងឆ្នាំ១៩៩៤ និងត្រូវបានតុលាការសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជាសម្រេចផ្ដន្ទាទោសដាក់គុកអស់មួយជីវិត។ នេះជាករណីទី២ ហើយដែលអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្ដីខ្មែរក្រហម កោះហៅទណ្ឌិតដែលត្រូវបានដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតមកធ្វើជាសាក្សីក្នុងសំណុំរឿង០០២ បន្ទាប់ពីការកោះហៅទណ្ឌិត កាំង ហ្កេកអ៊ាវ ហៅ ឌុច មកធ្វើជាសាក្សីនៅក្នុងខែមីនា និងខែមេសា ឆ្នាំ២០១២កន្លងទៅ។ បច្ចុប្បន្ន ឈូក រិន កំពុងអនុវត្តទោសរបស់គាត់នៅក្នុងមណ្ឌលអប់រំកែប្រែទី១ ឬហៅម្យ៉ាងទៀតថា គុកព្រៃស។

នៅពេលប្រធានអង្គជំនុំជម្រះចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីសួរដេញដោលបានបន្តិច សាក្សី ឈូក រិន បានបដិសេធពុំព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ និងភាគី ដោយសំអាងលើហេតុផលសុខភាពទ្រុឌទ្រោមរបស់គាត់ និងបានស្នើឲ្យអង្គជំនុំជម្រះពន្យាពេលសវនាការ ដើម្បីអាចឲ្យគាត់ជួបជាមួយវេជ្ជបណ្ឌិតត្រួតពិនិត្យសុខភាពជាមុនសិន។ ប៉ុន្ដែ សំណើនេះត្រូវបានអង្គជំនុំជម្រះបដិសេធ ហើយស្នើឲ្យ ឈូក រិន ឆ្លើយតបនឹងសំណួរដែលភាគីចោទសួរ។ ឈូក រិន នៅតែពុំព្រមឆ្លើយតបនឹងសំណួររបស់ភាគីដែលបានចោទសួរមកលើខ្លួន រហូតធ្វើឲ្យកិច្ចដំណើរការនីតិវិធីចំណាយពេលអស់មួយព្រឹកដោយពុំទទួលបានលទ្ធផល។ ទីបំផុត ដំណោះស្រាយត្រូវបានរកឃើញ ដោយអង្គជំនុំជម្រះអនុញ្ញាតឲ្យវេជ្ជបណ្ឌិតប្រចាំការនៅសាលាក្ដីខ្មែរក្រហមត្រួតពិនិត្យសុខភាពឲ្យសាក្សីរូបនេះនៅអំឡុងពេលនៃការឈប់សម្រាកពេលរសៀល។ បន្ទាប់មក នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលរសៀល សាក្សី ឈូក រិន បានសម្រេចចិត្តឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាយ៉ាងក្បោះក្បាយ និងបានសហការឆ្លើយតបគ្រប់សំណួររបស់ភាគីរហូតដល់ទីបញ្ចប់នៃសវនាការស្ដាប់សក្ខីកម្មរបស់គាត់។

ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្ម សាក្សី ឈូក រិន ហាក់បីដូចជាបានឆ្លើយចោទប្រកាន់ចំៗលើរូបជនជាប់ចោទ នួន ជា ថាជាអ្នកបញ្ជាឲ្យមានការកាប់សម្លាប់ និងបានកោតសរសើរ ខៀវ សំផន ថាជាមេដឹកនាំស្អាតស្អំ ពុំបានដឹងអំពីការបញ្ជាឲ្យមានការសម្លាប់មនុស្ស ហើយថែមទាំងបានស្នើសុំឲ្យតុលាការដោះលែងជនជាប់ចោទ ខៀវ សំផន ឲ្យមានសេរីភាពឡើងវិញ។ ជនជាប់ចោទ នួន ជា ពុំបានចូលរួមស្ដាប់សវនាការនេះដោយផ្ទាល់ទេ ដោយសារមានបញ្ហាសុខភាពពិបាកអង្គុយ ហេតុនេះអង្គជំនុំជម្រះបានអនុញ្ញាតឲ្យ នួន ជា ចូលរួមតាមដាននីតិវិធីសវនាការពីបន្ទប់

ឃុំខ្លួននៅខាងក្រោមសាលសវនាការតាមរយៈប្រព័ន្ធវីដេអូ ។

ដូចជាសាក្សីមុនៗដែរ ការសួរដេញដោលសាក្សី ឈូក រីន បានចាប់ផ្តើមដោយសហព្រះរាជអាជ្ញា បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយគឺមេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម ។

ការផ្តល់សក្ខីកម្មរបស់សាក្សី ឈូក រីន បានចំណាយពេល ២ថ្ងៃ គឺនៅថ្ងៃទី២២ និង២៣ ខែមេសា ឆ្នាំ២០១៣ ដោយមានការចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ប្រជាជន សិស្សនិស្សិត និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិអំពីកិច្ចដំណើរការនីតិវិធីប្រមាណ៧០០នាក់ មកពីរាជធានីភ្នំពេញ ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង ។

## ១) ប្រវត្តិសាវតារសាក្សី ឈូក រីន

ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជាមួយនឹងការសាកសួរអំពីប្រវត្តិសាវតាររបស់សាក្សី ឈូក រីន ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះ សាក្សី ឈូក រីន បានពិពណ៌នាថា កាលពីក្មេង គាត់មានឈ្មោះ សុខ ប៉ុន្តែក្រោយមកក៏ប្តូរមកជាឈ្មោះ រីន រហូតដល់ពេលបច្ចុប្បន្ន ។ សព្វថ្ងៃមានអាយុ៦០ឆ្នាំ មានទីលំនៅ នៅភូមិចម្ការព ឃុំពង៍ទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ ជាង និងម្តាយ ញ៉ែត លុយ និងមានកូន៥នាក់ ។

សាក្សី ឈូក រីន បានបញ្ជាក់ថា នៅក្នុងឆ្នាំ២០០៨ និង ២០០៩ គាត់ធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតចំនួនបីដង នៅក្នុងគុកព្រៃស ជាទីដែលគាត់ត្រូវបានដាក់ឲ្យអនុវត្តទោសតាមអំណាចនៃសាលដីការបស់សាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដោយសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតពាក់ព័ន្ធនឹងការសម្លាប់ជនបរទេសនៅភ្នំវល្លិ៍ខេត្តកំពត ។

### ការជាប់គាំងនៃកិច្ចដំណើរការនីតិវិធីដោយសារសាក្សីពុំឆ្លើយតបនឹងសំណួរ

ដោយពុំទាន់បានបញ្ចប់ការសួរដេញដោលទាក់ទងនឹងប្រវត្តិសាវតារដោយប្រធានអង្គជំនុំជម្រះនៅឡើយផង ស្រាប់តែសាក្សី ឈូក រីន បានស្នើសុំអង្គជំនុំជម្រះពន្យាពេលសវនាការ (ដូចបានលើកឡើងខាងលើនេះ) ។ សវនាការបានជួបប្រទះនឹងភាពជាប់គាំង ដោយសារអង្គជំនុំជម្រះបានបដិសេធ សំណើរបស់ ឈូក រីន ហើយ ឈូក រីន ក៏បានបដិសេធពុំព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ ។ បន្ទាប់មក អង្គជំនុំជម្រះក៏បានប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាដើម្បីចោទសួរលើ ឈូក រីន ប៉ុន្តែ សាក្សីរូបនេះនៅតែបដិសេធពុំព្រមឆ្លើយតបរាល់សំណួរទាំងអស់របស់សហព្រះរាជអាជ្ញា ដោយអះអាងថា គាត់មានបញ្ហាសុខភាព ពុំអាចឆ្លើយតបចំពោះសំណួរទាំងឡាយដែលចោទសួរមកលើគាត់ទេ ។ ឈូក រីន បានអះអាងថា គាត់នឹងឆ្លើយសំណួរទាំងអស់ នៅពេលណាដែលសុខភាពរបស់គាត់មានលក្ខណៈល្អប្រសើរ និងបន្ថែមទៀតថា *“សម័យខ្មែរក្រហម ប៉ុល ពត និង នួន ជា ប្រើទាំងឈឺក៏ខ្ញុំធ្វើដែរ ព្រោះខ្លាចស្លាប់ ។ ប៉ុន្តែ ពេលនេះខ្ញុំស្នើសុំឲ្យតុលាការចាត់តាំងពេទ្យឲ្យពិនិត្យរូបខ្ញុំសិន”* ។ ឈូក រីន បានបញ្ជាក់ថា ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ សុខភាពរបស់គាត់មានការធ្លាក់ចុះយ៉ាងខ្លាំង ព្រោះនៅក្នុងមន្ទីរឃុំឃាំង គាត់ពុំទទួលបានអាហារគ្រប់គ្រាន់ ដែលបណ្តាលឲ្យខ្សោយ និងឈឺក្បាលខ្លាំង ។ ភ្នែកទាំងពីរមានភាពក្រហាយ និងហូរទឹកភ្នែកនៅពេលបើកភ្នែកម្តងៗ ដូច្នេះពុំអាចមើលអក្សរបានច្បាស់ទេ ។

អង្គជំនុំជម្រះបានបដិសេធសំណើរបស់ ឈូក រីន និងបានបង្គាប់ឲ្យសាក្សីរូបនេះឆ្លើយតបចំពោះសំណួររបស់សហព្រះរាជអាជ្ញា ដើម្បីកុំឲ្យមានការចំណាយពេលវេលាខ្ជះខ្ជាយ នៅខណៈពេលដែលតុលាការកំពុងខិតខំប្រឹងប្រែងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ និងធ្វើការជំនុំជម្រះឲ្យបានឆាប់រហ័ស ។ ឈូក រីន បានឆ្លើយតបចំពោះការលើកឡើងរបស់អង្គជំនុំជម្រះថា ពុំមែនគាត់ជាអ្នកធ្វើឲ្យខ្ជះខ្ជាយពេលវេលាទេ អង្គជំនុំជម្រះខ្លួនឯងជាអ្នកធ្វើឲ្យខ្ជះខ្ជាយពេលវេលា ដោយសារខ្លួនបានសរសេរលិខិតស្នើសុំអង្គជំនុំជម្រះ ដើម្បីពន្យាពេលសវនាការរួចហើយ ប៉ុន្តែអង្គជំនុំជម្រះពុំបានឆ្លើយតបនឹងសំណើរបស់ខ្លួន និងថាអង្គជំនុំជម្រះហាក់បីដូចជាពុំមានក្តីមេត្តាចំពោះគាត់ ដែលកំពុងមានជំងឺទាល់តែសោះ ។

ដោយមើលឃើញភាពជាប់គាំង ទំនងជាពុំអាចដោះស្រាយបានដោយសារសាក្សី ឈូក រីន ពុំព្រមឆ្លើយតបនឹងសំណួរ អង្គ

ជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអានកំណត់ហេតុស្តាប់ចម្លើយរបស់ ឈូក រីន ដែលធ្លាប់បានឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងឆ្នាំ២០០៨ និង ២០០៩ ដោយពុំចាំបាច់មានការឆ្លើយបញ្ជាក់ពីសាក្សី ហើយកំណត់ហេតុស្តាប់ចម្លើយនោះនៅតែមានតម្លៃជាភស្តុតាង ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រេន័រ បានប្រើប្រាស់វិធីសាស្ត្រនេះ ដោយបានអានកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងបានឆ្លៀតសួរបញ្ជាក់សាក្សីម្តងម្កាលថា តើសាក្សីពិតជាបានឆ្លើយដូច្នោះមែនដែរឬយ៉ាងណា ។

បន្ទាប់ពីសម្រាកពិសារអាហារពេលរសៀល សាក្សី ឈូក រីន ហាក់បីដូចជាបានប្តូរគោលជំហររបស់ ខ្លួន ដោយបានសម្រេចចិត្តឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា និងបានបញ្ជាក់យ៉ាងក្បោះក្បាយ ។ ការផ្លាស់ប្តូរជំហរបែបនេះ ទំនងជាដោយសារអង្គជំនុំជម្រះបានយល់ស្របតាមសំណើរបស់សាក្សីដែលស្នើសុំឲ្យមានវេជ្ជបណ្ឌិតពិនិត្យសុខភាពរបស់ខ្លួនជាមុន ដើម្បីដឹងអំពីស្ថានភាពជំងឺរបស់ខ្លួន និងប្រហែលជាមានការផ្តល់ប្រឹក្សាពីជំនាញផ្នែកចិត្តសាស្ត្រនៅក្នុងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ។

## ២) ការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

មុនពេលសាក្សី ឈូក រីន យល់ព្រមឆ្លើយតបចំពោះសំណួររបស់សហព្រះរាជអាជ្ញា មានសំណួរជាច្រើនទាក់ទងនឹងប្រវត្តិនៃការចូលរួមក្នុងបដិវត្ត និងការបញ្ជាឲ្យបោសសម្អាតខ្មាំងនៅភូមិភាគបូព៌ា ពុំទទួលបានការបញ្ជាក់ពីសាក្សីរូបនេះទេ ។

ក្រោយពេលសាក្សី ឈូក រីន យល់ព្រមឆ្លើយតបសំណួរតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងាររវាងថ្នាក់មូលដ្ឋាន និងថ្នាក់មជ្ឈិម ជាពិសេស តួនាទីរបស់ជនជាប់ចោទ នួន ជា និងគោលនយោបាយបោសសម្អាតខ្មាំង ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រេន័រ បានអានសម្រង់ដែលយកចេញពីកំណត់ហេតុ ស្តាប់ចម្លើយរបស់សាក្សី ឈូក រីន ហើយស្នើឲ្យសាក្សីរូបនេះធ្វើការបញ្ជាក់ ។ សម្រង់នោះបានសរសេរថា "មុនឆ្នាំ១៩៧៥ នៅមុនពេលដែលខ្ញុំចូលបក្ស តាម៉ុក បានខទ្មេសនាមឈ្មោះ នួន ជា ។ ខ្ញុំដឹងថា ប៉ុល ពត ជាលេខាបក្ស ហើយ នួន ជា ជាអនុលេខាបក្សតាំងពីឆ្នាំ១៩៧៣ មកម្ល៉េះ ។ អ្នកចូលរួមបក្ស ត្រូវស្គាល់តួនាទីរបស់បក្ស និងតួនាទីរបស់ថ្នាក់ដឹកនាំបក្ស" ។ "ខ្ញុំបានជួប នួន ជា ជាលើកដំបូងក្នុងឆ្នាំ ១៩៧៧ នៅក្នុងកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំរបស់បក្ស" ។ ឈូក រីន បានបញ្ជាក់ថា គាត់ពិតជាបាន ឆ្លើយចម្លើយដូច្នេះមែន ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ សាក្សី ឈូក រីន ធ្លាប់បានអះអាងថា មេបញ្ជាការវរសេនាធំទាំងអស់ត្រូវបាន ប៉ុល ពត បញ្ជាឲ្យចាប់ខ្លួននៅចន្លោះពីឆ្នាំ១៩៧៦ ទៅ១៩៧៧ ដោយមាន ប៉ុល ពត និង នួន ជា ប្រកាសអំពីការចាប់ខ្លួននេះ ។ រីឯ កង ចាប ត្រូវបានប្រកាសថា ចាប់ខ្លួននៅចុងឆ្នាំ១៩៧៧ ។ នៅមុនពេលមានការបោសសម្អាតកម្មាភិបាលនៅភូមិភាគបូព៌ា សាក្សី និងមេបញ្ជាការកងទ័ពផ្សេងទៀត ត្រូវបានកោះហៅឲ្យទៅផ្ទះ តាម៉ុក នៅខេត្តតាកែវជាបន្ទាន់បំផុត ។ នៅពេលនោះ មានកងទ័ពមកពីខេត្តកំពតចំនួន៧០០នាក់ ខេត្តតាកែវ១០០០នាក់ និងមកពីខេត្តកណ្តាលពី ៧០០ទៅ៨០០នាក់ ត្រូវបានបញ្ជូនទៅភូមិភាគបូព៌ា ។

នៅពេលដែលតំណាងសហព្រះរាជអាជ្ញាបានសួរពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា សាក្សី ឈូក រីន បានបង្ហាញពីការប្រងើយកន្តើយរបស់គាត់ចំពោះសំណួរទាំងនោះ ហើយបាននិយាយថា គាត់ពុំធ្លាប់បានជួប ខៀវ សំផន នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែបានឮ តាម៉ុក ប្រាប់ថា ខៀវ សំផន ជាបញ្ញវន្ត និងមិនយល់ដឹងស៊ីជម្រៅអំពីកិច្ចការទូទៅនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទេ ។ បន្ទាប់មក ឈូក រីន បានស្នើទៅអង្គជំនុំជម្រះថាគួរតែដោះលែង ខៀវ សំផន ឲ្យមានសេរីភាពឡើងវិញ ព្រោះ ខៀវ សំផន គ្រាន់តែជាមេដឹកនាំមានតែឈ្មោះ រីឯការសម្រេចផ្សេងៗគឺនៅក្រោមការទទួលខុសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឈូក រីន បានបន្តទៀតថា នៅក្រោយពេលដែលគាត់បានចូលរៀនសូត្រវគ្គសិក្សានយោបាយក្នុងបក្សកុម្មុយនីស្តកម្ពុជាទើបគាត់បានដឹងថា បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកសម្តេចព្រះ នរោត្តម សីហនុ និង ខៀវ សំផន គ្រាន់តែជាកម្លាំងរណសិរ្ស

ដោយពុំបានចាត់ទុកអ្នកទាំងពីរជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ ។ ដូច្នេះ ទាំងសម្តេចព្រះ នរោត្តម សីហនុ និង ខៀវ សំផន សុទ្ធសឹងតែជាបុគ្គលដែលបានចាញ់បោក ប៉ុល ពត និង នួន ជា ។ បន្ថែមពីលើនេះ ឈូក រីន បានកត់សម្គាល់ថា ប៉ុល ពត នៅពេលក្រោយមក ដូចជា“ខ្លាកញ្ជាស់មួយក្បាលដែលអត់មានចំណី” ។ ឈូក រីន បានរៀបរាប់ថា *“ខ្ញុំជម្រាបថា ប៉ុល ពត ដូចខ្លាកញ្ជាស់មួយក្បាលអត់ចំណីអីចឹង ។ មូលហេតុអីបានជាខ្ញុំលើកអីចឹង? កាលពឆ្នាំនោះ វៃតែកូនចៅឯង វៃតែកងទ័ពឯងអ្នកច្បាំងខ្លាំងៗ ហ្នឹង វៃសាប់សឹងទាំងអស់ ។ ហើយរឿងនេះ គឺរឿងពិត ។”*

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងប្រជាជន១៧មេសា ឈូក រីន បានបញ្ជាក់ថា គាត់ពុំធ្លាប់បានទទួលបញ្ជាពីថ្នាក់លើឲ្យចាត់ទុកប្រជាជន១៧មេសាថាជាខ្មាំងឡើយ ។ ប៉ុន្តែ បានទទួលស្គាល់ថា ទាំងប្រជាជនសាមញ្ញ និងកងទ័ពបានស្ថិតនៅក្រោមភាពភ័យខ្លាច ដោយសារតែមានការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមដែលធ្វើការជាមួយខ្លួនជាបន្តបន្ទាប់ ដោយជាប់ចោទពីបទទាក់ទងនឹងភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាម ។ អ្នកដែលត្រូវបានចាប់ខ្លួនទាំងអស់ រងការចោទប្រកាន់ថាជាខ្សែក្បត់ ដោយអ្នកខ្លះត្រូវបានបញ្ជូនមកទីក្រុងភ្នំពេញ និងអ្នកខ្លះទៀតត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខខេត្តកំពតក្នុងតំបន់៣៥ ហើយមន្ទីរនោះសម្រាប់ដាក់តែអ្នកទោសជាកងទ័ពតែប៉ុណ្ណោះ ពុំមែនសម្រាប់ដាក់អ្នកទោសស៊ីវិលទេ ។ ប៉ុន្តែខ្លួនពុំដឹងថា មន្ទីរសន្តិសុខនោះមានទីតាំងនៅកន្លែងណាពិតប្រាដកទេ ។

ពាក់ព័ន្ធនឹងអ្នកសរសេរទង់បដិវត្ត សាក្សី ឈូក រីន បានសន្និដ្ឋានថា អ្នកដែលសរសេរ និងដាក់ចេញនយោបាយដែលមានរៀបរាប់នៅក្នុងទស្សនាវដ្តីទង់បដិវត្ត គឺគណៈមជ្ឈិមដែលមាន ប៉ុល ពត, នួន ជា និង អៀង សារី ដែលបានចម្លងគំនិតពីបក្សកុម្មុយនីស្តរុស្ស៊ី និងចិន ។ ការដែលគាត់សន្និដ្ឋានដូច្នេះ ដោយសារតែអ្នកទាំងនោះជាមេដឹកនាំបក្ស ហើយការដាក់ចេញគោលនយោបាយដើម្បីយកមកអនុវត្តនៅទូទាំងប្រទេសបានលុះត្រាតែមានការយល់ស្របគ្នាក្នុងចំណោមមេដឹកនាំទាំងនោះជាមុនសិន ។



គណៈប្រតិភូក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ធ្វើទស្សនកិច្ចទៅកាន់ប្រទេសអាល់បានី គណៈប្រតិភូកម្ពុជាពីឆ្វេងទៅស្តាំគឺ ហ៊ួត សម្បត្តិ, ហាក់ សៀងឡាយនី និង សារិន ឆាក (រូបខាងស្តាំជួរក្រោយ) ។ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាលយោធានៅខេត្តកំពតក្នុងអំឡុងឆ្នាំ១៩៧៦ សាក្សី ឈូក រីន បានអត្ថាធិប្បាយថា នៅក្នុងខេត្តកំពត មានកងវរសេនាតូចចំនួន៣ ។ ទី១ គ្រប់គ្រងដោយឈ្មោះ ជ័យ ហៅ សុខន ទី២គ្រប់គ្រងដោយឈ្មោះ ជន ដែលត្រូវជាប្អូនរបស់ នួន ប៉ែត និងទី៣ឈ្មោះ ចន ។ អ្នកទាំងនេះ បានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៥ ឬ១៩៧៦ ដែលធ្វើឲ្យខ្លួនសន្និដ្ឋានថាប្រហែលជាអាចត្រូវបានចាប់ខ្លួនយកទៅសម្លាប់ ។ ចំពោះការចាប់ខ្លួន ជូ ជេត គាត់បានដឹងពីការនិយាយតៗ គ្នានៅក្នុងជួរបក្ស ប៉ុន្តែពុំបានដឹងអំពីមូលហេតុដែលនាំឲ្យមានការចាប់ខ្លួននោះទេ ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការវាយប្រយុទ្ធរវាងទាហាន លន់ នល់ និង យោធាខ្មែរក្រហមនៅក្នុងខេត្តកំពត ឈូក រីន បានរៀបរាប់ថា នៅក្នុងឆ្នាំ១៩៧៣ មានការប្រយុទ្ធគ្នាខ្លាំង នៅទូទាំងខេត្តកំពត ជាពិសេសការធ្វើសង្គ្រាម២០០យប់ ២០០ថ្ងៃ ដោយមានការទម្លាក់គ្រាប់បែកបេ៥២ ពីយន្តហោះអាមេរិក ដែលបានបណ្តាលឲ្យមានការខូចខាត និងមានរណ្តៅគ្រាប់ស្ទើរគ្រប់ទីកន្លែង ។ ការទម្លាក់គ្រាប់បែកនេះ

បានបំផ្លិចបំផ្លាញវត្តដែលខ្លួនធ្លាប់បួសរៀននៅក្នុងខេត្តកំពត និង បានសម្លាប់ព្រះសង្ឃអស់មួយចំនួន ។ ដោយសារហេតុការណ៍នេះ ទើបប្រជាជននៅទីនោះត្រូវបង្ខំចិត្តចូលរួមជាមួយខ្មែរក្រហម ហើយសូម្បីតែព្រះសង្ឃក៏សុខចិត្តផ្សឹកដើម្បីចូលរួមជាមួយនឹង ចលនាខ្មែរក្រហមដែរ ។ សាក្សី ឈូក រីន បានបន្តទៀតថា ការប្រយុទ្ធគ្នារវាងខ្មែរក្រហម និងទាហាន លន់ នល់ បានបន្តរហូតដល់ឆ្នាំ១៩៧៥ ។

ទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហម ដែលធ្លាប់បានសិក្សានៅហាណូយ ឈូក រីន បានអះអាងថា នៅក្នុងខេត្តកំពតធ្លាប់មានកម្មាភិបាលដែលធ្លាប់បានទៅរៀនសូត្រនៅហាណូយក្នុងសម័យជំនាន់ខ្មែរឥស្សរៈ ក្រោយមកចូលមកក្នុងជួរខ្មែរក្រហម ក្រោយពីថ្ងៃរំដោះ ១៧ មេសា ១៩៧៥ អ្នកទាំងនោះ ត្រូវបានចាប់ខ្លួន និងអ្នកខ្លះទៀតបានបាត់ខ្លួន ក្នុងនោះមានដូចជា មាស ក្រូច និង មាស សំណាង រួមជាមួយនឹងអ្នកផ្សេងទៀតជាច្រើន ។

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីរួមខេត្តកំពត នៅក្រោយពេលខ្មែរក្រហមទទួលបានជ័យជម្នះ សាក្សី ឈូក រីន បានអះអាងថា នៅពេលនោះខ្មែរក្រហមបានស្នើសុំឲ្យប្រជាជនចាកចេញពីផ្ទះ ដោយពុំមានការគំរាមកំហែងដោយអាវុធឡើយ ហើយប្រជាជនទាំងអស់ពុំមានការជំទាស់នឹងសំណើនេះទេ និងយល់ព្រមចាកចេញទាំងអស់គ្នា ។ ឈូក រីន បន្តទៀតថា ខ្មែរក្រហមបានប្រាប់ប្រជាជនពីមូលហេតុ ដែលនាំឲ្យមានការជម្លៀសថាដើម្បីសុវត្ថិភាពរបស់ប្រជាជន ព្រោះសង្គ្រាមនៅពុំទាន់បញ្ចប់ទាំងស្រុងនៅឡើយទេ ។ ការជម្លៀសនេះ ធ្វើឡើងនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ នៅមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមួយថ្ងៃ ។

នៅមុនពេលបញ្ចប់ការសួរដេញដោលដោយសហព្រះរាជអាជ្ញា សាក្សី ឈូក រីន បានទម្លាក់ការទទួលខុសត្រូវទាំងអស់លើជនជាប់ចោទ នួន ជា ដោយបញ្ជាក់ថា ដោយសារតែគោលមាគ៌ាក្រហមឆ្អិនឆ្អៅ ដែលមានសរសេរក្នុងសៀវភៅទង់បដិវត្តនោះហើយ ទើបធ្វើឲ្យប្រជារាស្ត្រត្រូវរងទុក្ខវេទនា សង្គមជាតិទាំងមូលត្រូវបែកបាក់គ្នា ។

### ៣) ការសួរសាក្សីដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី បានចាប់ផ្តើមសំណួររបស់គាត់ដោយផ្តោតសំខាន់លើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឈូក រីន ទាក់ទងនឹងគោលនយោបាយផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតា ។ ឈូក រីន បានអះអាងថា អង្គការបានដាក់ចេញគោលនយោបាយនេះ មិនត្រឹមតែបង្ខំឲ្យប្រជាជនខិតខំធ្វើការប៉ុណ្ណោះទេ សូម្បីតែកងទ័ពក៏ត្រូវបានបង្ខំឲ្យធ្វើការ និងធ្វើស្រែដើម្បីផលិតស្រូវឲ្យបាន៣តោនក្នុង១ហិចតាដែរ ។ សាក្សីរូបនេះបានសន្និដ្ឋានថា គោលនយោបាយនេះប្រហែលជាត្រូវបានយកទៅអនុវត្តនៅទូទាំងប្រទេស ។

ឆ្លើយតបនឹងសំណួរមេធាវីដែលសួរថា ហេតុអ្វីបានជាសាក្សីមានការភ័យខ្លាចចំពោះ នួន ជា នៅពេលដែលខ្លួនមករៀននៅភ្នំពេញ? សាក្សី ឈូក រីន បានបញ្ជាក់ថា ខ្លួនពុំមែនភ័យខ្លាចចំពោះតែ នួន ជា ម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែភ័យខ្លាចចំពោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាតែម្តង ដោយសារនៅក្នុងទស្សនាវដ្តីទង់បដិវត្តរបស់បក្សបានសរសេរថា បាក់ចបមួយត្រូវមានទោស ចិញ្ចឹមសេះស្គមក៏មានទោស ។ បន្ថែមពីលើនេះ ភាគច្រើននៃអ្នកដែលបានមករៀនសូត្រតែងតែត្រូវបានចាប់ខ្លួន ដូច្នេះទើបធ្វើឲ្យខ្លួនមានការភ័យខ្លាច ។

ទាក់ទងនឹងការផ្សឹកព្រះសង្ឃ ឈូក រីន បានអត្ថាធិប្បាយថា នៅក្នុងឆ្នាំ១៩៧៣ មានការផ្សឹកព្រះសង្ឃនៅក្នុងខេត្តកំពត ដើម្បីយកមកធ្វើជាកងទ័ពច្បាំងជាមួយនឹងទាហានរដ្ឋាភិបាល លន់ នល់ ប៉ុន្តែខ្លួនពុំបានដឹងថានេះជាគោលនយោបាយរបស់បក្ស ឬក៏នយោបាយរបស់ថ្នាក់ដឹកនាំខ្មែរក្រហមនៅក្នុងខេត្តកំពតទេ ។ នៅពេលនោះ កង ចាប ជាមេដឹកនាំប្រចាំខេត្តកំពត ដែលបានបញ្ជាឲ្យមានការផ្សឹកព្រះសង្ឃធ្វើជាទាហាន ។ ការលើកឡើងរបស់ ឈូក រីន នៅត្រង់ចំណុចនេះ ហាក់បីដូចជាមានភាពផ្ទុយគ្នាទៅនឹងការអះអាងចំពោះសំណួររបស់សហព្រះរាជអាជ្ញា ដែលថាព្រះសង្ឃបានសម្រេចចិត្តសឹកដើម្បីចូលរួមជាមួយខ្មែរក្រហម ដោយសារតែការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ ប៉ុន្តែពុំមានភាគីណាសួរបញ្ជាក់អំពីចំណុចមិនស៊ីចង្វាក់នេះទេ ។

ទាក់ទងនឹងសេចក្តីសម្រេចរៀបចំរចនាសម្ព័ន្ធយោធាឡើង

វិញ ក្រោយពីមានការចាប់ខ្លួន កង ចាប ឈូក រីន បានបញ្ជាក់ថា សំ បិត ត្រូវបានតែងតាំងឲ្យកាន់ដំណែងជាប្រធានភូមិភាគនិរតីជំនួស កង ចាប ប៉ុន្តែខ្លួនពុំបានដឹងថាសេចក្ដីសម្រេចនោះចេញពីថ្នាក់ណាទេ ដោយសារតែការងារទាំងអស់ត្រូវបានលាក់ការណ៍យ៉ាងសម្ងាត់ខ្លាំងណាស់ ។

សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត បានបន្តចោទសំណួរបន្ទាប់ពីសហភាតារបស់ខ្លួន ដោយផ្ដោតលើចម្លើយសាក្សីបានឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា ដើម្បីឲ្យសាក្សីធ្វើការបញ្ជាក់លម្អិតបន្ថែមសារជាថ្មីឡើងវិញ ទាក់ទងនឹងការជម្លៀសប្រជាជន ការផ្សឹកព្រះសង្ឃ និងការចាប់ខ្លួនកម្មាភិបាលនៅក្នុងខេត្តកំពត ។

នៅក្នុងការរៀបរាប់របស់ខ្លួន សាក្សី ឈូក រីន បានបន្ថែមថា ក្រោយពេលរបបខ្មែរក្រហមដួលរលំ ទើបខ្លួនបានដឹងថា មានសមាជិកក្រុមគ្រួសាររបស់ខ្លួនត្រូវបានចាប់យកទៅសម្លាប់ដូចប្រជាជនផ្សេងទៀតដែរ ។ ឈូក រីន បានពន្យល់ពីអត្ថន័យដែលខ្លួននិយាយ *“ប៉ុល ពត ដូចជាខ្លាចាស់ដែលអត់មានចំណី ដែលអត់មានអ៊ីស៊ី គឺស៊ីកូនឯង”* ថា អ្នកដែលនៅជិតមេដឹកនាំខ្មែរក្រហមទាំងអស់ មិនយូរមិនឆាប់គង់នឹងត្រូវមេដឹកនាំរបស់ខ្លួនយកទៅសម្លាប់ជាមិនខាន ។ បន្ថែមពីលើនេះ ឈូក រីន បានសរសើររាជរដ្ឋាភិបាលបច្ចុប្បន្នថា ទោះបីជាខ្លួនត្រូវជាប់ពន្ធនាគារដោយសារតែធ្វើតាមបញ្ជាមេរបស់ខ្លួនក៏ដោយ ក៏ខ្លួននៅមានឱកាសបានជួបមុខភរិយានិងកូនៗរបស់ខ្លួន មិនដូចជានៅក្នុងសម័យខ្មែរក្រហម ។ ម្យ៉ាងវិញទៀត នៅក្នុងពន្ធនាគារបានធ្វើឲ្យខ្លួនមានឱកាសទទួលបានការលត់ដំខ្លួន និងមានពេលវេលាអានសៀវភៅបានយ៉ាងច្រើន ព្រោះនៅក្នុងពន្ធនាគារនោះមានបណ្ណាល័យ និងមានសៀវភៅគ្រប់ប្រភេទ ។

## ៤) ការសួរដេញដោលដោយមេធាវីការពារក្ដីជនជាប់ចោទ

### ក) ក្រុមមេធាវីការពារក្ដី នួន ជា

មេធាវីជាតិការពារក្ដីជនជាប់ចោទ នួន ជា គឺលោក សុន អរុណ បានចាប់ផ្ដើមសំណួររបស់ខ្លួន ដោយផ្ដោតសំខាន់លើប្រវត្តិសាវតារ ប្រវត្តិនៃការសិក្សា និងតួនាទីនៅក្នុងជួរយោធារបស់សាក្សី ឈូក រីន សាជាថ្មីឡើងវិញ ។ បន្ទាប់មកដូចជាសាក្សីមុនៗដែរ មេធាវី សុន អរុណ តែងតែចោទសួរអំពីទស្សនាវដ្ដីទង់បដិវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា និងថា តើសាក្សីធ្លាប់បានទទួលបានទស្សនាវដ្ដីទាំងនោះដែរឬទេ? តើទស្សនាវដ្ដីនោះត្រូវបានបោះពុម្ពដោយរបៀបណា ហើយមានអត្ថន័យយ៉ាងដូចម្ដេច? ឆ្លើយតបនឹងសំណួរទាំងនេះ សាក្សី ឈូក រីន បានបញ្ជាក់ថា ខ្លួនធ្លាប់បានទទួលទស្សនាវដ្ដីទង់បដិវត្ត និងស្គាល់ទស្សនាវដ្ដីនេះយ៉ាងច្បាស់ ។ ទស្សនាវដ្ដីនោះត្រូវបានបោះពុម្ពដោយដាក់ទីឡូ ឬក៏អង្គុលីលេខ ហើយនៅលើក្របនៃទស្សនាវដ្ដីនោះមានកម្រងក្ងួរស្រូវ ញញួរ កណ្ដៀវ និងសញ្ញារបស់បក្សកុម្មុយនីស្តកម្ពុជា ។

ឆ្លើយតបនឹងសំណួរពាក់ព័ន្ធនឹងប្រព័ន្ធទំនាក់ទំនងផ្នែកយោធា ឈូក រីន បានបញ្ជាក់ថា ការបញ្ជាកងទ័ពនៅភូមិភាគបូព៌ាអំឡុងពេលមានសង្គ្រាមជាមួយវៀតណាម មានកូនប្រសាររបស់ តាម៉ុក ឈ្មោះ រ៉ែន ជាអ្នកបញ្ជាទ័ព ហើយក្រោយពីនោះក៏មាន សុន សេន ជាអ្នកបញ្ជាកងទ័ពប្រយុទ្ធជាមួយវៀតណាមនៅពេលនោះដែរ ។ ឈូក រីន បានបន្តថា តាម៉ុក ជាបុគ្គលម្នាក់ដែលមានឥទ្ធិពលខ្លាំងនៅខាងផ្នែកយោធា ដោយសារតែ តាម៉ុក អាចបញ្ជាកងទ័ពបានគ្រប់ទិសទី ទោះបីជាតួនាទីជាក់ស្ដែង តាម៉ុក ត្រឹមតែជាលេខាភូមិភាគនិរតីក៏ដោយ ។ ម្យ៉ាងវិញទៀត តាម៉ុក ធ្លាប់បាននិយាយដដែលៗថា *“នៅលើក្បាល ម៉ុក មានមួក នៅលើមួកមានមេឃ”* ។ ប៉ុន្តែ ឈូក រីន ពុំបានបញ្ជាក់អំពីអត្ថន័យច្បាស់លាស់ចំពោះការលើកឡើងដូច្នេះរបស់ តាម៉ុក ឡើយ ។

ចំពោះការបញ្ជាឲ្យចាប់ខ្លួននរណាម្នាក់ ឈូក រីន បានធ្វើការសន្និដ្ឋានថា បញ្ជាដូច្នេះអាចចេញមកពី នួន ជា ឬ សុន សេនៗ សាក្សីរូបនេះបានអះអាងទៀតថា ខ្លួនបានដឹងតាមរយៈវិទ្យុថា នួន ជា មានតួនាទីជាប្រធានសភាកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួររបស់មេធាវី សុន អរុណ ដែលសួរថា ហេតុអ្វី បានសាក្សីនិយាយថា ខ្លួនខឹងនឹង នួន ជា សាក្សី ឈូក រីន បានបញ្ជាក់ថា ដោយសារតែ នួន ជា ពុំព្រមទទួលស្គាល់នៅចំពោះមុខប្រវត្តិសាស្ត្រ ។ ម្យ៉ាងវិញទៀត នួន ជា ជាប្រធានសភា ដែលជាស្ថាប័នតាក់តែងច្បាប់សម្រាប់គ្រប់គ្រងប្រទេស ដូច្នេះមានន័យថា នួន ជា ជាអ្នកតាក់តែងគោលនយោបាយ ទាំងអស់របស់បក្សកុម្មុយនីស្ត

កម្ពុជា ប៉ុន្តែ នួន ជា បែរជាបដិសេធពុំព្រមទទួលខុសត្រូវទៅវិញ ។

ឈូក រីន បានបញ្ជាក់ថា ខ្លួនពុំដែលដឹងសោះឡើយថានៅតំបន់ដែលខ្លួនឈរជើងនោះមានមន្ទីរសន្តិសុខ ហើយខ្លួនក៏ពុំដែលបានដឹងថា មានមន្ទីរសន្តិសុខស-២១ នៅទីក្រុងភ្នំពេញក្នុងពេលនោះដែរ ។ ខ្លួនទើបតែបានដឹងអំពីអត្ថិភាពនៃមន្ទីរស-២១ នៅពេលដែលតុលាការកាត់ទោស ឌុច តែប៉ុណ្ណោះ ហើយរហូតមកដល់ពេលនេះ ខ្លួននៅតែពុំទាន់ស្គាល់ទីក្រុងភ្នំពេញច្បាស់នៅឡើយ ។

### ១) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន លោក គង់ សំអុន បានអានកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ឈូក រីន ដែលធ្លាប់បានផ្តល់សម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតទាក់ទងនឹង ខៀវ សំផន និងបន្ទាប់មកបានស្នើឲ្យសាក្សី ឈូក រីន បញ្ជាក់លម្អិតនៅត្រង់ផ្នែកដែលខ្លួនបាននិយាយនៅពេលនោះ ។ ឃ្លាដែលសាក្សី ឈូក រីន បាននិយាយនៅពេលនោះមានអត្ថន័យដូច្នេះថា៖ «*ខ្ញុំមិនដែលជួប ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ ឬ ឌុច ទេ ។ បក្សកុម្មុយនីស្តកម្ពុជាមានជនចម្រើនសម្ព័ន្ធយុវកក និងបក្ខជន ។ បក្ខជនមានពីរប្រភេទ បក្ខជនត្រៀម និងបក្ខជនពេញសិទ្ធិ ។ ខៀវ សំផន ជាសមាជិករណសិរ្សជាមួយ សម្តេច សីហនុ ។ បក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់សមាជិករណសិរ្សជាអ្នកការទូតសម្រាប់ទំនាក់ទំនងជាមួយប្រទេសនានាលើពិភពលោក*» ។ បន្ទាប់មកមេធាវី គង់ សំអុន បានស្នើឲ្យសាក្សី ឈូក រីន បញ្ជាក់អំពីពាក្យថា ជនចម្រើន និង បក្ខជន។ ឈូក រីន បានបញ្ជាក់ថា ជនចម្រើន ជាជនដែលត្រៀមបញ្ចូលទៅក្នុងសម្ព័ន្ធយុវកក និងជាជនដែលសកម្ម និងចេញពីវណ្ណៈកសិករក្រីក្រ ។ ប៉ុន្តែ សាក្សីពុំបានបញ្ជាក់អំពីពាក្យ«បក្ខជន» ទេ ។

ចំពោះអត្ថន័យនៃពាក្យថា *រណសិរ្ស* សាក្សី ឈូក រីន បានបញ្ជាក់ថា គឺជាការប្រមូលនូវកម្លាំងគ្រប់ស្រទាប់វណ្ណៈ ដូចជា អ្នកមាន អ្នកក្រ បញ្ញាជន បញ្ញវន្ត ឥស្សរជន សក្តិភូមិ ជាដើម ។ ឈូក រីន បានបន្ថែមទៀតថា ប្រសិនបើមេធាវីចង់ដឹងលម្អិតបន្ថែមទៀតអំពីរណសិរ្សអាចសួរ ខៀវ សំផន បាន ពីព្រោះ ខៀវ សំផន ប្រហែលជាដឹងស៊ីជម្រៅអំពីពាក្យនេះ ។ សាក្សី ឈូក រីន បានបញ្ជាក់ទៀតថា ខ្លួនធ្លាប់បានដឹងតាមរយៈថ្នាក់លើរបស់ខ្លួនដែលនៅកៀកនឹង តាម៉ុក ថា ខៀវ សំផន គឺគ្រាន់តែជាបញ្ញាជន ដូច្នេះ ខៀវ សំផន មិនស្ថិតនៅក្រុមអ្នកប្រយុទ្ធទេ នៅមុនពេលភ្នំពេញត្រូវបានរំដោះ ។ ប៉ុន្តែក្រោយឆ្នាំ១៩៧៥ ខ្លួនពុំបានដឹងថា ខៀវ សំផន មានតួនាទីជាអ្វីឡើយ ។ ឈូក រីន បានបន្ថែមថា ខ្លួនស្គាល់ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ ដោយសារអ្នកទាំងបីរូបបានរត់ទៅលាក់ខ្លួននៅតំបន់របស់ខ្លួន ហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនមិនគិតថា ខៀវ សំផន នៅមានជីវិតរហូតដល់សព្វថ្ងៃនេះទេ ដោយសារតែខ្លួនបានដឹងថា ហ៊ូ នឹម និង ហ៊ូ យន់ ដែលជាមិត្តជិតស្និទរបស់ ខៀវ សំផន ត្រូវបានបក្សកុម្មុយនីស្តកម្ពុជាចាប់យកទៅសម្លាប់ ។ សាក្សីបានបញ្ជាក់ថា ក្នុងអំឡុងពេលនៃសម័យសង្គមរាស្ត្រនិយម ខ្លួនធ្លាប់ជួយផ្តល់កន្លែងលាក់ខ្លួន និងផ្តល់អាហារដល់ ហ៊ូ នឹម និង ហ៊ូ យន់ ដោយសារអ្នកទាំងពីររូបនេះ បានរត់ទៅលាក់ខ្លួននៅខេត្តកំពត រីឯ ខៀវ សំផន លាក់ខ្លួននៅកំពង់ស្ពឺជាមួយ តាម៉ុក ។

ឆ្លើយតបនឹងសំណួរដែលសួរថា តើហេតុអ្វីបានជា ខៀវ សំផន ពុំអាចលាក់ប្រវត្តិរូបរបស់ខ្លួនជិត នៅមុនពេល និងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ? សាក្សី ឈូក រីន បានអះអាងថា មូលហេតុដែល ខៀវ សំផន មិនអាចលាក់បាំងប្រវត្តិរូបរបស់ខ្លួនបានគឺដោយសារតែ ខៀវ សំផន ជាបញ្ញវន្ត ដែលមានឈ្មោះល្បី ធ្លាប់ធ្វើជារដ្ឋមន្ត្រី និងជាតំណាងរាស្ត្រ ជាបុគ្គលស្អាតស្អំ មិនពុករលួយ និងជាគំរូ ដែលធ្វើឲ្យប្រជាជនគោរព ។ ម្យ៉ាងវិញទៀត ខៀវ សំផន ជាតំណាងរាស្ត្រដែលពុំមានឡានជិះ គឺជិះកង់ទៅធ្វើការ ដោយសារតែខ្លួនស្រឡាញ់រាស្ត្រ ។ ឈូក រីន បន្ថែមថា នៅពេលនោះ ទោះបីជាខ្លួននៅមានវ័យក្មេងនៅឡើយ ក៏ខ្លួនស្គាល់ ខៀវ សំផន ដែរ ។

នៅពេលមេធាវីចាប់ផ្តើមអំពីសមាជិកនៃគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម សាក្សី ឈូក រីន បានបញ្ជាក់ថា ខ្លួនពុំមានសមត្ថភាពឆ្លើយតបចំពោះសំណួរទាំងនេះឡើយ ដោយសារតែនៅពេលនោះខ្លួនគ្រាន់ តែជាទាហានដែលមានឋានៈទាប ដូច្នេះពុំអាចដឹងលម្អិតបានអំពីថ្នាក់លើឡើយ ។ សាក្សីរូបនេះគ្រាន់តែបញ្ជាក់ថា ខៀវ សំផន ពុំមានអំណាចក្នុងការបញ្ជាកងទ័ពទេ ។

# សវនាការសួរដេញដោលសាក្សី ជួន ធី

## ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបន្តបើកសវនាការសួរដេញដោលសាក្សីម្នាក់ទៀត បន្ទាប់ពីសក្ខីកម្មរបស់សាក្សី ឈូក រីន ត្រូវបានបញ្ចប់ ។ នីតិវិធីនៅក្នុងសវនាការសួរដេញដោលនេះ ត្រូវបានធ្វើឡើងដោយមានលក្ខណៈខុសប្លែកពីនីតិវិធីមុនៗ ដោយសារសាក្សីដែលត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មត្រូវបានស្នើសុំដោយក្រុមមេធាវីការពារក្តី ។ ដូច្នេះ អង្គជំនុំជម្រះបានផ្តល់វេទិកាសួរដេញដោលនេះទៅឲ្យក្រុមមេធាវីការពារក្តីមុនសហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

សូមបញ្ជាក់ថា មុនពេលចាប់ផ្តើមនីតិវិធីសួរដេញដោលនេះ មេធាវីអន្តរជាតិ អង់តា ហ្គីសសេ បានស្នើសុំសួរដេញដោលសាក្សីបន្ទាប់ពីភាគីផ្សេងៗទៀត ដោយផ្តល់ហេតុផលថា នេះគឺជាការអនុវត្តនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ។ អង្គជំនុំជម្រះសម្រេចតាមសំណើសុំនេះ ។ ដោយឡែក មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ ការពារក្តី នួន ជា បញ្ជាក់ថា ខ្លួននឹងអនុវត្តតាមការសម្រេចរបស់អង្គជំនុំជម្រះ គាត់នឹងសួរដេញដោលសាក្សីរូបនេះមុនភាគីផ្សេងទៀត ។ ប៉ុន្តែ ចំពោះសាក្សីនៅថ្ងៃបន្ទាប់នឹងត្រូវបានសួរដេញដោលដំបូង ដោយមេធាវីរបស់ ខៀវ សំផន នោះ គាត់នឹងសួរបន្ទាប់ពីភាគីផ្សេងៗទៀតវិញម្តង ។

ការលើកឡើងបែបនេះ នាំឲ្យមានការដោះស្រាយពីអង្គជំនុំជម្រះថា ជាគោលការណ៍តុលាការការអនុវត្តន៍នីតិវិធីសួរដេញដោល ដោយយោងទៅលើមាត្រា៩១ស្ទួននៃវិធានផ្ទៃក្នុងរបស់តុលាការ ដែលចែងថា “ប្រធានអង្គជំនុំជម្រះសាលាដំបូង ត្រូវកំណត់លំដាប់លំដោយដែលចៅក្រម សហព្រះរាជអាជ្ញា មេធាវី និងភាគីនានាដទៃទៀតមានសិទ្ធិសួរសំណួរទៅកាន់ជនជាប់ចោទ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី” ។ អង្គជំនុំជម្រះបានផ្តល់ហេតុផលថា ការអនុវត្តន៍បែបនេះ គឺដោយសារតែតុលាការនេះជាតុលាការវិសាមញ្ញ ដែលពុំអនុវត្តន៍តាមច្បាប់ជាតិទាំងស្រុងនោះទេ ដូច្នេះទើបធ្វើឲ្យការអនុវត្តន៍នេះ មានលក្ខណៈខុសគ្នាពីការអនុវត្តន៍នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

បន្ទាប់ពីបញ្ចប់ការលើកឡើងរបស់ភាគីទាក់ទងនឹងនីតិវិធីនៃការសួរដេញដោលសាក្សី ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានចាប់ផ្តើមសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី ។ សាក្សីបានបញ្ជាក់ថា គាត់មានឈ្មោះ ជួន ធី អាយុ៦៨ឆ្នាំ មានមុខរបរធ្វើចម្ការ និងមានទីលំនៅក្នុងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ ឪពុករបស់គាត់ឈ្មោះ



ជួន ធី
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆេ ម្តាយឈ្មោះ ហ៊ី និងប្រពន្ធមានឈ្មោះ សៅ ហេង ព្រមទាំងមានកូនបីនាក់ ។ បន្ទាប់មក ចៅក្រម និល ណុន បានបញ្ជាក់អំពីសិទ្ធិ និងករណីកិច្ចមួយចំនួនដល់សាក្សីក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីនៃការសួរដេញដោលនេះ ។

### ២) ការសួរដេញដោលសាក្សីដោយមេធាវីការពារក្តី នួន ជា

មេធាវី សុន អរុណ បានចាប់ផ្តើមសំណួរដោយឲ្យសាក្សីបញ្ជាក់អំពីប្រវត្តិនៃការសិក្សាអប់រំរបស់គាត់ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបញ្ជាក់ថា គាត់បានរៀនត្រឹមថ្នាក់ទី៣ ពីជំនាន់

មុន ក្រោយមកនៅឆ្នាំ១៩៧០ គាត់ចូលរួមក្នុងចលនាបដិវត្តន៍នៅក្នុងអង្គភាពទី១ នៃកងអនុសេនាតូចលេខ៣៥ ។ មូលហេតុ ដែលគាត់ចូលបម្រើកងទ័ពនោះ ដោយសារគាត់ចង់ចូលរួមទាមទារឲ្យសម្តេចព្រះ នរោត្តម សីហនុ ត្រឡប់មកដឹកនាំប្រទេសវិញ បន្ទាប់ពីមានរដ្ឋប្រហារដោយលោកសេនាប្រមុខ លន់ នល់ ។ មេធាវី សុន អរុណ បានបន្តសួរទាក់ទងនឹងការចូលរួមប្រជុំរបស់សាក្សីនៅខេត្តកំពង់ឆ្នាំងជាមួយ ប៉ុល ពត ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា គាត់បានចូលរួមការប្រជុំមួយស្តីអំពីការរៀបចំទ័ព ដើម្បីច្បាំងជាមួយវៀតណាម ដែលមកឈ្លានពានប្រទេសកម្ពុជា ។ កិច្ចប្រជុំនេះធ្វើនៅឆ្នាំ១៩៧៨ ក្នុងខេត្តកំពង់ឆ្នាំង ដោយមាន ប៉ុល ពត ធ្វើជាអធិបតី ។ ពេលត្រលប់មកវិញ គាត់បានទទួលបញ្ជាពីប្រធានកងពលដើម្បីរៀបចំកងទ័ព ៣វរៈសេនាតូច ដែលមានយោធាជាង ១ពាន់នាក់ ដើម្បីទៅវាយជាមួយកងទ័ពរបស់វៀតណាមនៅតាមព្រំដែន ។

ទាក់ទងនឹងការប្រជុំនោះដែរ សាក្សីបានបញ្ជាក់ថា ប៉ុល ពត បានលើកឡើងថា *"...វៀតណាមមានបំណងឈ្លានពានលើទឹកដីខ្មែរ ដើម្បីដាក់បញ្ចូលទៅក្នុងសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន"* ។ បន្ទាប់មក លោក សុន អរុណ បានដកស្រង់សម្តីរបស់សាក្សីដែលនិយាយថា *"...ប៉ុល ពត គាត់តម្រូវថា ឲ្យមានការរៀបចំអាពាហ៍ពិពាហ៍ ដើម្បីបង្កើនចំនួនប្រជាជន ដោយឲ្យថ្នាក់ក្រោមជាអ្នករៀបចំអាពាហ៍ពិពាហ៍របស់ប្រជាជន..."* ។ ទាក់ទងនឹងការលើកឡើងនេះ សាក្សីបានបញ្ជាក់ថា អាពាហ៍ពិពាហ៍នៅពេលនោះពុំត្រូវបានហាមឃាត់ឡើយ ហើយអង្គការគ្រាន់តែណែនាំថា "កុំឲ្យទុំមុនស្រគាល" ហើយត្រូវរៀបការដោយមានការស្នើសុំត្រឹមត្រូវ ។ ដូចរូបគាត់ផ្ទាល់ អង្គការអនុញ្ញាតឲ្យរៀបការតាមការស្នើសុំដោយពុំមានការបង្ខិតបង្ខំអ្វីឡើយ ។ ខ្មែរក្រហមបានរៀបចំផែនការថា *"...ចាប់ពី ១០ ទៅ២០ឆ្នាំទៀត កម្ពុជានឹងមានប្រជាជនរហូតដល់ទៅ២០ ទៅ៣០លាននាក់ ដែលអាចជួយការពារទឹកដីបាន"* ។

ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងទីតាំងកងទ័ព នៅពេលប្រយុទ្ធជាមួយកងទ័ពរបស់វៀតណាម សាក្សីបានរៀបរាប់ថា គាត់បានទៅឈរជើងនៅក្នុងខេត្តស្វាយរៀង ។ នៅទីនោះ គាត់បានជួប សុន សេន ដែលជារដ្ឋមន្ត្រីការពារប្រទេសចំនួន ២-៣ដង ។

បន្ទាប់មក មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានបន្តសួរដេញដោល ដោយផ្តោតទៅលើស្ថានភាពក្នុងពេលទម្លាក់គ្រាប់បែកនៅចន្លោះឆ្នាំ១៩៧០-១៩៧៥ ។ សាក្សីបានរៀបរាប់ថា រយៈពេលនៃការទម្លាក់គ្រាប់បែកមានចំនួន៣០០យប់ និង៣០០ថ្ងៃ ។ នៅពេលនោះមានប្រជាជនស្លាប់អស់ជាច្រើននាក់ ហើយបន្សល់ទុកនូវរណ្តៅធំៗជាច្រើន ។ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញវិញ សាក្សីបញ្ជាក់ថា គាត់ពុំបានដឹងពីគម្រោងនៃការជម្លៀសប្រជាជននោះទេ ។ គាត់គ្រាន់តែបានឃើញព្រឹត្តិការណ៍នៃការជម្លៀសនេះ នៅពេលដែលគាត់មកដល់ភ្នំពេញនៅចំណុចដម្លូវីនតែប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវីទាក់ទងនឹងតួនាទីរបស់សាក្សី បន្ទាប់ពីខ្មែរក្រហមបានចូលមកដល់នោះ សាក្សីបានបញ្ជាក់ថា គាត់មានឋានៈជាមេបញ្ជាការកងវរសេនាធំលេខ១១៥ នៃកងពលលេខ១១ ។ នៅពេលនោះ គាត់ត្រូវបានកោះហៅឲ្យទៅប្រជុំជាមួយប្រធានកងពលឈ្មោះ ពៅ សឿង ដោយសារតែមេកងទ័ពផ្សេងបានចេញទៅការពារនៅតាមកោះ និងតាមព្រៃ ។

បន្ទាប់មក មេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងសមាសភាពនៃគណៈមជ្ឈិមដើម្បីឲ្យសាក្សីបញ្ជាក់ ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា គាត់ពុំបានដឹងអំពីកិច្ចការនៅថ្នាក់លើទេ ព្រោះគាត់គ្រាន់តែជាកងទ័ពតូចតាច ។ ម្យ៉ាងទៀត នៅជំនាន់នោះ ពុំមានការផ្សាយព័ត៌មានដែលពាក់ព័ន្ធនឹងថ្នាក់លើឡើយ ហើយអ្វីដែលគាត់បានដឹងនៅពេលនោះ មានតែផែនការយុទ្ធសាស្ត្រក្នុងការកសាងប្រទេសប៉ុណ្ណោះ ។ ទាក់ទងនឹងកិច្ចប្រជុំជាមួយ ប៉ុល ពត ក្នុងការកំណត់មុខសញ្ញាខ្មាំងវិញ សាក្សីបានរៀបរាប់ថា ខ្មាំងនៅពេលនោះមានដូចជា គិញអាមេរិក សេ.អ៊ី.អា និងគិញរបស់សូវៀត និងវៀតណាម ។ សំណួរចុងក្រោយរបស់មេធាវីទាក់ទងនឹងខ្លឹមសារនៃកិច្ចប្រជុំដែលគាត់បានចូលរួមជាមួយ ប៉ុល ពត នៅឆ្នាំ១៩៧៨ ប៉ុន្តែសាក្សី នៅតែបញ្ជាក់ជាច្រើនលើកច្រើនសារថា គាត់ពុំដែលបានទទួលបញ្ជាអ្វីក្រៅពីកិច្ចការការពារព្រំដែនកុំឲ្យមានការឈ្លានពានពីបរទេសតែប៉ុណ្ណោះ ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់មេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះបានផ្ទេរវេទិកាសួរដេញដោលនេះជូនតំណាងសហព្រះរាជអាជ្ញាដើម្បីសួរសាក្សីបន្ត ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌែល លីសាក់ បានចាប់ផ្តើមសួរឲ្យសាក្សីបញ្ជាក់ឡើងវិញទាក់ទងនឹងតួនាទី និងទីតាំងដែលគាត់បានឈរជើង នៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ។ សាក្សីបានរៀបរាប់ថា នៅពេលនោះគាត់បានទៅប្រចាំការនៅទួលលៀប នៅម្តុំផ្លូវបំបែករវាងផ្លូវជាតិលេខ៣ និងលេខ៤ ហើយនៅពេលនោះ គាត់បានឃើញប្រជាជនជាច្រើនត្រូវជម្លៀស ។ ប៉ុន្តែគាត់ពុំបានដឹងអំពីគម្រោងការណ៍នៃការជម្លៀសនោះពីមុន ឬទទួលការចាត់តាំងអ្វីទេ ហើយក្រោយមកទៀត គាត់ក៏ពុំបានដឹងអំពីទិសដៅនៃការជម្លៀសប្រជាជននោះដែរ ។ សាក្សីបានបន្ថែមថា បន្ទាប់ពីមានការជម្លៀសប្រជាជនរួចមក អង្គភាពរបស់គាត់ត្រូវបានចាត់តាំងឲ្យទៅជួសជុលផ្លូវជាតិលេខ៣ ដែលបានទទួលរងការខូចខាតដោយសារសង្គ្រាមកន្លងមក ។ បន្ទាប់មកទៀត កងទ័ពនៅក្នុងអង្គភាពត្រូវបានចាត់តាំងឲ្យទៅធ្វើស្រែនៅលង្វែករហូតដល់ឆ្នាំ១៩៧៨ ទើបគាត់ត្រូវបានផ្លាស់ទៅនៅស្វាយរៀងវិញ ។

សំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញា ទាក់ទងនឹងការរាយការណ៍នៅក្នុងជួរយោធាខ្មែរក្រហម ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា ការរាយការណ៍ត្រូវធ្វើឡើងតាមរយៈនីសារ ហើយពេលខ្លះ គាត់រាយការណ៍តាមវិទ្យុទាក់ទង សេ-២៥ (របស់អាមេរិក) ទៅកាន់មេបញ្ជាការកងពល ឈ្មោះ សឿន ដែលមានទីតាំងនៅលង្វែក ដោយពុំមានចម្លងជូនអ្នកផ្សេងទៀតឡើយ ។ បន្ទាប់មក សឿន ជាអ្នករាយការណ៍បន្តទៅថ្នាក់លើ ។ តំណាងសហព្រះរាជអាជ្ញាបានអាននូវសារទូរលេខចំនួន ៣ ដែលនិយាយអំពីការចាប់ខ្លួនអ្នកបើកយន្តហោះកាត់ខេត្តកោះកុង និងខ្មាំងដែលបើកទូកនេសាទចូលមកក្នុងទឹកដីខ្មែរ ។ ឯកសារទូរលេខនោះផ្ញើពី តាសឿន និងមានចម្លងជូនដល់មេដឹកនាំថ្នាក់លើមួយចំនួនដូចជា អ៊ីនួន និង បងវ៉ាន់ ជាដើម ។ ទាក់ទងនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា សារទូរលេខប្រភេទនេះ ជាសមត្ថកិច្ចរបស់អង្គភាពផ្សេងទៀត ចំណែកទូរលេខដែលគាត់ផ្ញើនោះ គ្រាន់តែជារបាយការណ៍នៅថ្នាក់ខាងក្រោមត្រឹមប្រធានកងពលប៉ុណ្ណោះ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានសួរទាក់ទងនឹងការអប់រំនយោបាយដល់កងទ័ពតាមរយៈការចែកចាយសៀវភៅទង់បដិវត្តន៍ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានឆ្លើយថា គាត់បានទទួលទង់បដិវត្តន៍នៅពេលនោះដែលបានចែកចាយឲ្យកងទ័ពផ្សេងៗទៀត ។ តំណាងសហព្រះរាជអាជ្ញាក៏បានអានសេចក្តីដកស្រង់នៅក្នុងទង់បដិវត្តន៍ទាក់ទងនឹងខ្មាំង សេ.អ៊ី.អា និង កា.ហ្សេ.បេ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា គាត់មិនដែលយល់ និងស្គាល់ខ្មាំងទាំងនោះទេ ព្រោះថ្នាក់លើមិនដែលបានប្រាប់អំពីបញ្ហានេះឡើយ ។ សំណួរមួយចំនួនទៀតត្រូវបានតំណាងសហព្រះរាជអាជ្ញាសួរឲ្យសាក្សីបញ្ជាក់ទាក់ទងនឹងឈ្មោះ កម្មាភិបាលមួយចំនួនដែលត្រូវបានចាប់ខ្លួន ដោយសារអង្គការចោទថា ជាគិញរបស់អាមេរិក និងវៀតណាម ប៉ុន្តែសាក្សីនៅតែបញ្ជាក់ម្តងហើយម្តងទៀតថា គាត់ពុំដែលស្គាល់បុគ្គលទាំងនោះឡើយ ។ ចំពោះឈ្មោះ ចាន់ ស៊ី អតីតប្រធានភូមិភាគបស្ចិម ដែលត្រូវបានចាប់ខ្លួនដោយសារធ្វើសកម្មភាពក្បត់នោះ សាក្សីបានបញ្ជាក់ថា លោកគ្រាន់តែធ្លាប់បានឮថា ចាន់ ស៊ី នោះត្រូវបានចាប់ខ្លួនតែប៉ុណ្ណោះ ហើយក្រោយមក គាត់ពុំដែលទទួលបានព័ត៌មានផ្សេងទៀតឡើយ ។

### ៤) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ជាដំបូង សហមេធាវីជាតិ ពេជ អង្គ បានចាប់ផ្តើមដោយស្នើឲ្យសាក្សីបញ្ជាក់ឡើងវិញអំពីអង្គភាពផ្សេងៗដែលបានវាយចូលមកទីក្រុងភ្នំពេញ ។ ទាក់ទងនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា គាត់ពុំបានដឹងច្បាស់ថា មានអង្គភាពណាខ្លះដែលបានវាយចូលទីក្រុងនោះទេ គឺគ្រាន់តែបានទទួលបញ្ជាពីថ្នាក់លើថា គ្រប់កងទ័ពត្រូវតែចូលមកទីក្រុងភ្នំពេញ ហើយនៅពេលនោះគាត់បានឃើញប្រជាជនទាំងចាស់ទាំងក្មេងត្រូវជម្លៀសចេញពីទីក្រុង ប៉ុន្តែគាត់មិនបានដឹងថា នៅពេលនោះប្រជាជនកំពុងតែមានការលំបាកនោះទេ ព្រោះគាត់បានឃើញប្រជាជនខ្លះនាំគ្នាសើចក្អាកក្អាយទៅវិញ ។ ចំណែកសំណួរបន្ទាប់ទាក់ទងនឹងទាហាន លន់ នល់ វិញ សាក្សីបានបញ្ជាក់ថា គាត់បានឃើញទាហាន និងប្រជាជនជិះ

រថយន្តចេញពីទីក្រុងជាមួយគ្នា ប៉ុន្តែពុំមានកាន់កាំភ្លើងអ្វីនោះទេ ។ សហមេធាវីជាតិ ពេជ អង្គ បានបន្តសួរទាក់ទងនឹងគោលនយោបាយរៀបការរបស់ខ្មែរក្រហមដើម្បីបង្កើនចំនួនប្រជាជនដែលមានការបិទផ្សាយឲ្យសាក្សីពន្យល់ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានឆ្លើយតបថា ការរៀបការជាផ្នែកមួយនៃគោលនយោបាយរបស់ខ្មែរក្រហម ហើយពាក្យស្លោកនោះមានអត្ថន័យថា *“កសាងប្រជាជនពី១៥...ពី២០ទៅ៣០លានក្នុងរយៈពេលពី១០ទៅ២០ឆ្នាំ”*, *“កសាងសកិកម្មអន់ថយឲ្យទៅជាកសិកម្មជឿនលឿន”* ហើយពាក្យស្លោកទាំងនោះត្រូវបានបិទផ្សាយនៅកន្លែងធ្វើការនៅតាមដងផ្លូវថែមទៀត ។ ចំពោះការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុវិញ សាក្សីបានបញ្ជាក់ថា ក្រោយពេលរំដោះបានទីក្រុងភ្នំពេញ វិទ្យុស្ទឹងមានជ័យនៅមានដំណើរការនៅឡើយ ។ ដូច្នេះប្រជាជននៅតាមជនបទអាចស្តាប់ព័ត៌មានបាន ព្រោះវិទ្យុនោះត្រូវបានចាក់ផ្សាយនៅតាមវាលស្រែ និងការដ្ឋាននានា ។ ព័ត៌មានទាំងនោះ និយាយអំពីការបង្កបង្កើនផល និងការធ្វើស្រែឲ្យបាន៣តោនក្នុង១ហិចតា ។ ជាងនេះទៅទៀត គាត់ធ្លាប់ឮការផ្សាយអំពីឈ្មោះរបស់មេដឹកនាំមួយចំនួនដូចជា ខៀវ សំផន, ប៉ុល ពត និង នួន ជា ជាដើម ប៉ុន្តែគាត់ពុំដែលដឹងពីតួនាទីរបស់មេដឹកនាំទាំងនោះទេ ។

សហមេធាវីអន្តរជាតិ អេម៉ានូអ៊ែល ហ្សាកូមី បានបន្តសំណួរទាក់ទងនឹងស្ថានភាពនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅពេលចូលមកទីក្រុងភ្នំពេញ គាត់បានឃើញប្រជាជនសើចសប្បាយដែលហាក់ដូចជាពុំមានទុក្ខសោកអ្វីទាំងអស់ ម្យ៉ាងទៀតគាត់ ក៏មិនដែលឃើញមានសាកសពប្រជាជននៅតាមដងផ្លូវក្នុងពេលជម្លៀសនោះដែរ ។ បន្ទាប់មក មេធាវីបានអានសេចក្តីដកស្រង់មួយនៅក្នុងបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនិយាយអំពីការចាប់ខ្លួនប្រជាជនដោយយោធាខ្មែរក្រហម ខណៈពេលដែលលោកឈរជើងនៅតំបន់៣៧ ប៉ុន្តែសាក្សីបានបដិសេធថា គាត់ពុំដែលដឹងថាមានករណីបែបនេះកើតឡើងទេ ជាពិសេសនៅតំបន់ដែលគាត់រស់នៅ ដោយសារតែលោកនៅខាងកងទ័ពមិនមានតួនាទីខាងសន្តិសុខនោះទេ ។

## ៥) ការសួរដេញដោលដោយមេធាវីការពារក្តី ខៀវ សំផន

មេធាវីជាតិ គង់ សំអុន បានចាប់ផ្តើមសួរបញ្ជាក់ឡើងវិញអំពីតួនាទីរបស់សាក្សីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបានរៀបរាប់ថា គាត់មាននាទីជាសមាជិកវរសេនាធំ១៥ដែលមាន រ៉ុម ជា ប្រធាន ។ មេធាវីបានបន្តសួរថា តើសាក្សីបានស្គាល់ ប៉ុល ពត ច្បាស់ដែរឬទេនៅពេលដែលគាត់បានជួប ប៉ុល ពត នៅកំពង់ឆ្នាំងនោះ ។ ឆ្លើយតបនឹងសំណួរនេះ លោក ជួន ធី បានបញ្ជាក់ថា នៅពេលនោះគាត់ បានឃើញ ប៉ុល ពត មានមាឌធាត់សម្បុរស និងមានចរិកគួរឲ្យចង់រាប់អាន ។ បន្ទាប់មក មេធាវីបានលើកឡើងនូវសម្តីរបស់ ប៉ុល ពត ថា *“ស្រូវអង្ករដែលនៅសល់ពីប្រជាជនត្រូវយកទៅដោះដូរឧបករណ៍កសិកម្ម ដើម្បីយកមកធ្វើនៅស្រុកយើង...”* ហើយសាក្សីបញ្ជាក់ថា គាត់ពិតជាធ្លាប់បានឮនៅពេលគាត់ទៅឈរជើងនៅខេត្តស្វាយរៀង និងពេលទៅប្រជុំនៅកងពល ។

បន្ទាប់មកមេធាវីអន្តរជាតិ អង់តា ហ្គីសសេ បានបន្តសំណួរពីសហភាគារបស់គាត់ទាក់ទងនឹងភារកិច្ចរបស់កងទ័ពបន្ទាប់ពីទទួលបានជ័យជំនះ ។ ជាការឆ្លើយតប សាក្សីបានអះអាងថា កងទ័ពនៅក្នុងអង្គភាពរបស់គាត់បានទៅធ្វើស្រែចំការនៅលន្លែកដើម្បីហូបចុកដោយខ្លួនឯង និងអង្គភាព ហើយក្រៅពីនោះយោធានៅក្នុងអង្គភាពរបស់គាត់មានតួនាទីក្នុងការការពារសន្តិសុខដែរ ។ ទាក់ទងនឹងការប្រជុំជាមួយ ប៉ុល ពត វិញ សាក្សីបានបញ្ជាក់ជាថ្មីថា គាត់បានទទួលដំណឹងពី ពេទ្យ សឿន ដែលបានមកប្រាប់ដល់ទ័ពនៅក្នុងកងពលរបស់គាត់ឲ្យទៅចូលរួមប្រជុំនៅពេលនោះ ។ ឆ្លើយតបនឹងសំណួរចុងក្រោយទាក់ទងនឹងអាវុធដែលប្រើប្រាស់នៅពេលកងទ័ពវៀតណាមចូលមកផ្តួលរបបខ្មែរក្រហមនោះ សាក្សីបានបញ្ជាក់ថា នៅក្រោយថ្ងៃ១៧ ខែមេសា កងទ័ពទាំងអស់ត្រូវទៅធ្វើស្រែ ដូច្នេះអាវុធទាំងអស់ត្រូវបញ្ជូនទៅដាក់នៅក្នុងឃ្លាំង ។ អស់រយៈពេលប្រហែលបីឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៨ ពេលដែលទាហានវៀតណាម ចូលមកនោះ កងទ័ពខ្មែរក្រហមកំពុងតែរស់នៅរាយប៉ាយនៅតាមតំបន់ផ្សេងៗ និងពុំមានការរៀបចំកាំភ្លើងឲ្យបានគ្រប់គ្រាន់ទេ ដូច្នេះហើយទើបធ្វើឲ្យទ័ពវៀតណាមចូលមកផ្តួលរលំរបបកម្ពុជាប្រជាធិបតេយ្យបានយ៉ាងលឿន ។

# សវនាការស្ដីពីការស្ដាប់សក្ខីកម្មសាក្សី រស់ ស៊ីុយ

## ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តបើកសវនាការស្ដាប់សក្ខីកម្មសាក្សីថ្មីមួយរូបទៀត ។ ការបើកសវនាការនេះ បានធ្វើឡើងបន្ទាប់ពីបញ្ចប់ការសួរដេញដោលសាក្សី ជួន ធី ។ សាធារណៈជនដែលជាគរុសិស្សចំនួន ២៧៧នាក់ មកពីខេត្តកំពង់ធំ បានចូលរួមទស្សនាការសួរដេញដោលសាក្សីនៅក្នុងសវនាការនេះ ។ គួររំឭកថា សាក្សីថ្មីនេះ ត្រូវបានកោះអញ្ជើញដោយក្រុមមេធាវីការពារក្ដី ខៀវ សំផន ដូច្នេះក្រុមមេធាវីការពារក្ដី ខៀវ សំផន បានធ្វើការតាំងសំណួរបន្ទាប់ពីអង្គជំនុំជម្រះ ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

សាក្សីមានឈ្មោះ រស់ ស៊ីុយ មានទីលំនៅក្នុងភូមិពាមប្រជុំ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ។ សាក្សីមានអាយុ ៦០ ឆ្នាំ និងប្រកបមុខរបរធ្វើស្រែចម្ការ ។ ឪពុករបស់សាក្សីឈ្មោះ រស់ ព្រាម និងម្ដាយឈ្មោះ ហ៊ឹម ផុក ។ ប្រពន្ធរបស់សាក្សីឈ្មោះ សុខ សិ ដែលមានកូន៦នាក់ កូនប្រុស៤នាក់ និងកូនស្រី២នាក់ ។ សាក្សីពុំមានញាតិលោហិត និងញាតិពន្ធជាមួយជនជាប់ចោទ និងបុគ្គលទាំងឡាយដែលត្រូវទទួលជាដើមបណ្ដឹងរដ្ឋប្បវេណីនៃរឿងក្ដីនេះទេ ។ សាក្សីធ្លាប់ផ្ដល់បទសម្ភាសន៍ចំនួន២ដងកន្លងមក នៅឆ្នាំ២០០២ និង២០០៨ ។ សាក្សីក៏បានពិនិត្យនូវបទសម្ភាសន៍ទាំងនោះមុនពេលមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការនេះរួចរាល់ បទសម្ភាសន៍ទាំងនោះមានលក្ខណៈសមស្រប ។

### ២) ការសួរដេញដោលដោយមេធាវីការពារក្ដី ខៀវ សំផន

ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានធ្វើការតាំងសំណួរមុនភាគីផ្សេងទៀតនៃរឿងក្ដី ។ មេធាវីអន្តរជាតិ អង់គា ហ្គីសេ បានចាប់ផ្ដើមតាំងសំណួរទៅកាន់សាក្សី ទាក់ទងនឹងការផ្ដល់សម្ភាសន៍ចំនួនពីរលើកកន្លងមក ។ សាក្សីបានបញ្ជាក់ជូនមេធាវីថា បទសម្ភាសន៍លើកទី១ ខ្លួនបានផ្ដល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា និងលើកទី២ ផ្ដល់ជូនចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយសារខ្លួនពុំអាចចងចាំនូវកាលបរិច្ឆេទជាក់លាក់នៃបទសម្ភាសន៍ទាំងពីរលើក សាក្សីគ្រាន់តែអាចរំឭកថា ខ្លួនបានផ្ដល់បទសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយជនជាតិខ្មែរ មុនពេលផ្ដល់បទសម្ភាសន៍ជាមួយចៅក្រមស៊ើបអង្កេត ហើយខ្លួនបានដឹងថា មានការថតសម្លេងនៅពេលកំពុងសម្ភាសន៍ថែមទៀត ។

ចំពោះប្រវត្តិសិក្សារបស់សាក្សី បានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៧ ដែលអាចសរសេរ និងអានភាសាខ្មែរបានខ្លះ ។ សាក្សីបានចូលរួមតស៊ូជាមួយកងទ័ពវៀតណាម ដែលមកជួយរំដោះកម្ពុជានៅអំឡុងឆ្នាំ១៩៧០ ក្រោយមកសាក្សីចូលរួមជាមួយ ចលនាខ្មែរក្រហមវិញ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៣ ។ សម្រាប់មូលហេតុដែលសាក្សីចូលរួមជាមួយខ្មែរក្រហម ដោយ



រស់ ស៊ីុយ
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

សារខ្លួនយល់ថា មានតែខ្មែរដូចគ្នាទេទើបអាចយោគយល់គ្នា និងអាចរកសន្តិភាពបាន ។ ចំណែកការចូលរួមជាមួយកងទ័ពវៀតណាមវិញពេលវាយម្តង១ កងទ័ពវៀតណាម តែងតែដកថយចោលកងទ័ពខ្មែរ ព្រមទាំងបានបែងចែកក្រុមរវាងខ្មែរនឹងវៀតណាមដាច់ពីគ្នា ។ ក្រោយពេលចាកចេញពីកងទ័ពវៀតណាម សាក្សីបានទៅស្រុកស្វាយចេក ដើម្បីបម្រើកងទ័ពក្រោយមកខ្មែរក្រហមបានចាត់តាំងឲ្យសាក្សីធ្វើជាមេក្រុមសេដ្ឋកិច្ច ដែលមានសមាជិកប្រហែល៥០នាក់ ហើយចំនួនសមាជិកនេះ អាចប្រែប្រួលនៅពេលខ្លះ ។ សមាជិកទាំងនោះរួមមានព្រះសង្ឃ ដែលត្រូវបានផ្សឹកជាដើម ហើយក្រោយមកព្រះសង្ឃទាំងនោះ ត្រូវបានបញ្ជូនទៅសមរភូមិ ។

មុនពេលចូលភ្នំពេញ សាក្សីបានបម្រើការងារផ្នែកសេដ្ឋកិច្ចជាប្រធានផ្នែកតូចមួយ ដែលមានតួនាទី ផ្តល់ស្បៀងជូនសមរភូមិនៅក្រោមបញ្ជារបស់ថ្នាក់លើជាច្រើននាក់ទៀត ។ ក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះ នៅឆ្នាំ១៩៧៥ អង្គភាពសេដ្ឋកិច្ចបានបញ្ជូនសាក្សីទៅភ្នំពេញ ដោយរៀបចំជាមន្ទីរ៣១១ ហើយសាក្សីទទួលបន្ទុកនៅឃ្លាំងកំពង់ទឹកកក ដែលមានទីតាំងនៅទល់មុខផ្សារធំថ្មីបច្ចុប្បន្ន ។ អង្គភាពរបស់សាក្សីទទួលបន្ទុកផ្នែកគ្រប់គ្រងឃ្លាំងដែលមានពីរកងវរសេនាធំ ហើយសាក្សីមានមុខងារជាប្រធានកងហា ។ សាក្សីបានធ្វើការនៅក្នុងឃ្លាំងកំពង់ទឹកកក ក្នុងឆ្នាំ១៩៧៥ លុះដល់ចុងឆ្នាំ១៩៧៦ សាក្សីបាន ប្តូរទៅគីឡូម៉ែត្រលេខ៦ ដែលជាសាខាមួយក្នុងចំណោមឃ្លាំងទាំងអស់ ដែលរួមមានឃ្លាំងជ្រោយចង្វា ឃ្លាំងលេខ៦ និងឃ្លាំងកំពង់ទឹកកក ។ សាក្សីថា គាត់ពុំដឹងពីគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តឡើយ ដោយសារវាជាបញ្ជារបស់ថ្នាក់លើ ចំណែកការងាររបស់គណៈមជ្ឈិមបក្សទើបតែដឹងខ្លះនៅពេលដែលបក្សប្រកាសថា ប៉ុល ពត ជារដ្ឋមន្ត្រីទីមួយ ។ សាក្សីបានឆ្លើយថាខ្លួនពុំស្គាល់មន្ទីរក-១ មន្ទីរក-៣ មន្ទីរក-៧ មន្ទីរ៨៧០ និងមន្ទីរសន្តិសុខស-២១ទេ ។ សាក្សីពុំធ្លាប់ធ្វើការជាមួយគណៈពាណិជ្ជកម្មទេ ចំណែកខាងឧស្សាហកម្មវិញសាក្សីបានត្រឹមតែការទំនាក់ទំនងផ្នែកដឹកជញ្ជូនអីវ៉ាន់មកដាក់ក្នុងឃ្លាំងប៉ុណ្ណោះ ។ មេធាវីបានសួរដេញដោលសាក្សីពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយបុគ្គលមួយចំនួន ដូចជាឈ្មោះ តេង, វឿង, វ៉ាន់, រិត (នៅខាងពាណិជ្ជកម្ម) និង កុយ ធួន ។ សាក្សីបានបញ្ជាក់ថា ខណៈដែលខ្លួននៅឃ្លាំងកំពង់ទឹកកក ខ្លួនមាននាទីមើលការខុសត្រូវត្រឹមតែអង្គភាពឃ្លាំងតែប៉ុណ្ណោះ ពោលគឺដឹកអីវ៉ាន់ដាក់ឃ្លាំង ។ ចំណែកតួនាទីនៅឃ្លាំងគីឡូលេខ៦ សាក្សីចាំទទួលបញ្ជាពីខាងលើរួមមានការចែកចាយអីវ៉ាន់ និងធ្វើការសរុបបញ្ជី នៅរៀងរាល់ចុងខែ ។ សាក្សីជម្រាបជូនអង្គជំនុំជម្រះថា នៅក្នុងឃ្លាំងដែលខ្លួនគ្រប់គ្រង មានផលិតផលចំនួនពីរប្រភេទ សម្រាប់នាំចេញទៅក្រៅប្រទេសផលិតផលទាំងពីរប្រភេទនេះ រួមមានផលិតផលកៅស៊ូ និងអង្ករ ។ ប៉ុន្តែសាក្សីពុំបានដឹងអំពីចំនួនត្រូវនាំចេញជាក់លាក់នោះឡើយ ។ ស្រូវ និងអង្ករមួយចំនួនមិនត្រូវបានបញ្ជូនទៅតាមភូមិភាគទេ គឺទុកសម្រាប់ផ្គត់ផ្គង់ការចែកចាយនៅតាមក្រសួង និងមន្ទីរក្នុងទីក្រុងភ្នំពេញប៉ុណ្ណោះ ។ សាក្សី រស់ ស៊ុយ បានបញ្ជាក់ជូនតុលាការថា នៅអំឡុងឆ្នាំ១៩៧៣-៧៥ ខ្លួនពុំទាន់ស្គាល់មុខ ខៀវ សំផន នោះទេ រហូតដល់ពេលសម្តេច នរោត្តម សីហនុ ប្រកាសឲ្យប្រជាជនតស៊ូរំដោះជាតិ ទើបសាក្សីដឹងថាពុំមែនមានតែ ខៀវ សំផន ទេ មានទាំង ហ៊ូ យន់ និង ហ៊ូ នឹម ទៀតផង ។ លុះដល់ឆ្នាំ១៩៧៥ នៅពេលដែលមានការប្រកាសអំពីឋានៈរបស់ ប៉ុល ពត ជានាយករដ្ឋមន្ត្រីទីមួយ ទើបសាក្សីដឹងថា ខៀវ សំផន ពុំមែនជាមេដឹកនាំធំជាងគេទេ ។ សាក្សីបានឃើញ ខៀវ សំផន នៅពេលចូលរួមប្រជុំម្តង១ និងដឹងត្រឹមថា ខៀវ សំផន មកពិនិត្យឃ្លាំង តែខ្លួនពុំបានជួបដោយផ្ទាល់នោះទេ ។

មេធាវីបានអាននូវបទសម្ភាសន៍មួយចំនួន ដែលសាក្សីបានធ្វើជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលនៅពេលនោះសាក្សីបានលើកឡើងថា *"ខ្ញុំដឹងថា ខៀវ សំផន មានការភ្ញាក់ផ្អើលនៅពេលគាត់ដឹងថា កម្មាភិបាលហូបតែបបរ មិនហូបបាយ"* ។ ឆ្លើយតបនឹងការលើកឡើងនេះ សាក្សីបញ្ជាក់ថា នៅពេលមានកិច្ចប្រជុំម្តង១ ខៀវ សំផន បានណែនាំពីការទុកដាក់សម្ភារកុំឲ្យខូចខាត ហើយមានការសំណេះសំណាលនៅក្រៅអង្គប្រជុំ ។ សាក្សីបានធ្វើការសន្និដ្ឋានដោយខ្លួនឯងប៉ុណ្ណោះ ដែលថា ខៀវ សំផន អាចមានការភ្ញាក់ផ្អើលនៅពេលឮក្រុមផ្សេងហូបតែបបរ ហើយក្រុមការងាររបស់សាក្សីហូបបាយចំហុយ ។ សាក្សី បានជម្រាបជូនអង្គជំនុំជម្រះថា គាត់មិនយល់ពីប្រធានបទ និងខ្លឹមសារដែល ខៀវ

សំផន ហៅទៅប្រជុំនោះទេ គ្រាន់តែចាំថា មានការណែនាំឲ្យមើលថែសម្ភារនៅក្នុងឃ្លាំងឲ្យបានល្អ ។ ខៀវ សំផន បានពន្យល់ពីទស្សនៈសភាពការណ៍របស់ប្រជាពលរដ្ឋដែលគាត់ខំធ្វើការ ហើយឲ្យសាក្សីនៅមើលថែរក្សារបស់របរ ប៉ុន្តែពុំបានពន្យល់ពីនយោបាយទេ ។ សាក្សីថា ខណៈដែល នួន ជា បានចាក់ខ្សែអាត់សម្ភាសន៍ កុយ ធួន ឲ្យខ្លួននិងសមាជិកប្រជុំផ្សេងទៀតបានស្តាប់ នោះ មានតែ នួន ជា ទេដែលនៅស្តាប់ ហើយ ខៀវ សំផន ពុំមានវត្តមាននៅទីនោះទេ ។

មេធាវី គង់ សំអុន បានសួរទាក់ទងនឹងសំណើពីមន្ទីរក-២៥ ។ សាក្សីឆ្លើយថា ខ្លួនពុំបានដឹងថា ក-២៥ ជាមន្ទីរសម្រាប់ទទួលបន្ទុកផ្នែកអ្វីនោះទេ គ្រាន់តែឃើញលិខិតអនុញ្ញាតឲ្យបើកឥវ៉ាន់ បានចារថា មកពីមន្ទីរក-២៥ ។ មេធាវីបានសួរសាក្សីទាក់ទងនឹងឈ្មោះ ខៀវ នៅ ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនាពេលកន្លងមក ប៉ុន្តែសាក្សីថា ខ្លួនពុំស្គាល់បុគ្គលនោះទេ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីស្តីពីបុគ្គលដែលមកទទួលសម្ភារៈទៅតាមភូមិភាគ សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បើកសំភារៈជូនភូមិភាគនិរតី ប៉ុន្តែមនុស្សដែលមកទទួលប្លែកៗពីគ្នា ដូច្នេះខ្លួនពុំអាចស្គាល់បុគ្គលណាមួយបាននោះទេ ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដារីក អាប់ឌុលហាក់ បានចាប់ផ្តើមសំណួរមួយចំនួនទាក់ទងនឹងកិច្ចប្រជុំ នៅថ្ងៃទី៩ ខែមករា ដោយលើកយកចម្លើយដែលសាក្សីផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចោទសួរ ។ ឆ្លើយតបនឹងការដកស្រង់នោះ សាក្សីបានបញ្ជាក់ថា ថ្នាក់ដឹកនាំដែលបានចូលរួមនៅក្នុងការប្រជុំនោះមានតែ ខៀវ សំផន ម្នាក់ប៉ុណ្ណោះ ដែលបានកោះហៅអ្នកចូលរួមមកពីក្រសួង និងមន្ទីរផ្សេងៗដូចជាថ្នាក់ដឹកនាំកងទ័ព ឧស្សាហកម្ម ពាណិជ្ជកម្ម និងឃ្លាំងរដ្ឋ ។ ប៉ុន្តែសាក្សីពុំអាចកំណត់អត្តសញ្ញាណរបស់បុគ្គលទាំងនោះ និងឋានៈរបស់ពួកគេបានទេ ។ សាក្សីបានឆ្លើយថាការកោះហៅសមាជិកចូលរួមប្រជុំម្តងៗ ធ្វើឡើងតាមរយៈឈ្មោះ វឿន ដែលជាអ្នកចាត់ចែងចំនួនមនុស្សត្រូវចូលរួម ។ សាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះថា នៅក្នុងកិច្ចប្រជុំវគ្គសិក្សារៀនសូត្រនោះ ខៀវ សំផន ពិតជាបានលើកឡើងទាក់ទងនឹងពាក្យ "ខ្មាំងស៊ីរូងផ្ទៃក្នុង" ថា "យោងតាមស្ថានភាពបច្ចុប្បន្នប្រហែលជាបណ្តាលមកពីបញ្ហាផ្ទៃក្នុង ហើយបើពុំមានបញ្ហាផ្ទៃក្នុង គឺខ្មាំងខាងក្រៅមិនអាចវាយប្រហារយើងបានទេ" ។

តំណាងសហព្រះរាជអាជ្ញាបានអានអត្ថបទដកស្រង់ដោយលើកឡើងអំពីវគ្គរៀនសូត្រ ដែលសាក្សីបានចូលរួមជាមួយ ខៀវ សំផន និង នួន ជា ។ ក្រោយពីការរំឭកឡើងវិញ សាក្សីបានបំភ្លឺថា កន្លែងរៀនសូត្រទាំងនោះរួមមាន វត្តខណ្ឌលោម បុរីកីឡា និងនៅស្តាតអូឡាំពិកជាដើម ដែលមាន នួន ជា និង ខៀវ សំផន ជាអ្នកបង្រៀនដោយផ្ទាល់ ។ ទាក់ទងនឹងការងាររបស់គាត់ សាក្សី រស់ ស៊ុយ បានរៀបរាប់ជូនអង្គជំនុំជម្រះថា ម៉ាស៊ីនកិនស្រូវនៅគីឡូម៉ែត្រលេខ៦ អាចធ្វើការកែសម្រួល ឬក៏អាចវេចខ្ចប់ដោយស្វ័យប្រវត្តិ ដែលអាចវេចខ្ចប់អង្ករក្នុងមួយបាវមានចំណុះមួយរយគីឡូក្រាមបានមួយពាន់ប្រាំមួយរយដល់មួយពាន់ប្រាំពីររយបាវក្នុងមួយថ្ងៃ ។ សាក្សីក៏បានបញ្ជាក់ទៀតថា មន្ទីរមួយចំនួននៅទីក្រុងភ្នំពេញទទួលការផ្គត់ផ្គង់អង្ករពីឃ្លាំងគីឡូម៉ែត្រលេខ៦ ហើយរាល់ការចែកចាយអង្ករចេញពីឃ្លាំងនេះធ្វើតាមបញ្ជាពីមន្ទីរក-២៥មួយប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញា សាក្សីបានបញ្ជាក់ថា ខៀវ សំផន ធ្លាប់មកពិនិត្យឃ្លាំងរបស់គាត់ និងថា ខៀវ សំផន ពុំមានយានជំនិះទំនើបនោះទេ ព្រមទាំងពាក់ស្បែកជើងផ្ទាត់នៅពេលចុះត្រួតពិនិត្យម្តងៗ ។ ចំណែក នួន ជា ក៏ធ្លាប់ចុះពិនិត្យឃ្លាំងដែរ ប៉ុន្តែពិនិត្យនៅពេលផ្សេងគ្នាពី ខៀវ សំផន ។ សាក្សីបានបន្ថែមថា បើប្រៀបធៀបពីឋានៈឃ្លាំងរដ្ឋ មានលក្ខណៈតូចជាងក្រសួងពាណិជ្ជកម្ម ។

ពាក់ព័ន្ធនឹងការចាប់ខ្លួន សាក្សីបានបញ្ជាក់ថា បើមានការឆ្លើយដាក់បុគ្គលណាមួយ ចាប់ពី២-៣នាក់ បុគ្គលនោះនឹងត្រូវចាប់ខ្លួន បើទោះបីជាគ្មានកំហុសក៏ដោយ ហើយការចាប់ខ្លួនពុំបានធ្វើដោយហឹង្សានោះទេ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាជាថ្មី ទាក់ទងនឹងការចាក់ចម្លើយសារភាពរបស់ កុយ ធួន នៅពេលប្រជុំរៀនសូត្រនោះ សាក្សីបានបំភ្លឺជូនអង្គជំនុំជម្រះថា មានវត្តមាន នួន ជា ម្នាក់ប៉ុណ្ណោះនៅពេលចាក់ខ្សែអាត់ថតសម្លេងនោះ ។ ការចាក់នេះ ដើម្បីឲ្យក្រុមរបស់សាក្សី

ស្ដាប់ក្នុងគោលបំណងអប់រំអំពីបញ្ហាជនក្បត់ ។ សាក្សីនៅតែរក្សាចម្លើយរបស់គាត់ដដែលថា ខណៈពេលនោះ ពុំមានវត្តមានរបស់ ខៀវ សំផន ទេ ។ សាក្សីក៏បានបន្ថែមទៀតថា ទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានដឹងត្រឹមថា ខៀវ សំផន មានមុខងារជាប្រធានគណៈប្រធានរដ្ឋប៉ុណ្ណោះ និងពុំបានដឹងថា ខៀវ សំផន ជាសមាជិកអចិន្ត្រៃយ៍ ឬយ៉ាងណានោះទេ ។ ខណៈដែល ខៀវ សំផន ចុះទៅពិនិត្យនរណាទេ នៅពេលឃើញអ្នកទាំងនោះត្រូវបញ្ជូនមកដល់ដីរំរបស់ខ្លួន ដែលជាកន្លែងសម្រាប់ពួកគេស្នាក់បណ្ដោះអាសន្ន តែប៉ុណ្ណោះ ។ សាក្សីគ្រាន់តែសន្មតដោយខ្លួនឯង ថាមនុស្សទាំងនោះអាចជាលោកសង្ឃ ដោយសារឃើញសក់របស់ពួកគេទើបតែដុះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សាក្សីពុំបាន រក្សាឯកសារណាមួយ ឬសោររបស់ឃ្លាំងទុកនោះទេ ។ សាក្សីបានចាកចេញ



ខៀវ សំផន (ស្ដាំ) អំឡុងពេលជូនដំណើរគណៈប្រតិភូនៃប្រទេសភូមា ដឹកនាំដោយប្រធានាធិបតី ណេវីន នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃ្លាំងម្ដងៗ ខ្លួនពុំបានទទួលការបញ្ជា ឬសេចក្ដីសម្រេចណាមួយទាក់ទងនឹងឃ្លាំងរដ្ឋពី ខៀវ សំផន ឡើយ ។

## ៤) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អេលីហ្សាប៉ែត ស៊ីម៉ុនណូហ្វុត បានចាប់ផ្ដើមសំណួរទាក់ទងនឹងលោកសង្ឃដែលត្រូវបានផ្សឹករួចបញ្ជូនឲ្យទៅធ្វើជាកងទ័ព ។ សាក្សីបានលើកឡើងថា គាត់ពុំបានដឹងថាកងទ័ពចូលថ្មីនោះ ជាដោយពុំបាននាំយកអ្វីទៅជាមួយឡើយ ។ សាក្សីបានជម្រាបទៀតថា បងស្រីរបស់គាត់ត្រូវបានចាប់ខ្លួន និងសម្លាប់នៅគុកទួលស្លែង ។ ក្រោយមក គាត់បានដឹងអំពីព័ត៌មានបន្ថែមទាក់ទងនឹងបងស្រី និងក្រុមគ្រួសារ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សាក្សីបានទទួលស្គាល់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលសាច់ញាតិត្រូវចាប់ខ្លួន គាត់មានការភ័យខ្លាចជាខ្លាំងរហូតដល់លាក់បាំងទំនាក់ទំនងសាច់ញាតិដើម្បីការពារខ្លួនទៀតផង ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពេជ អង្គ

បានបន្តសំណួរពីសហភាគារបស់ខ្លួន ពាក់ព័ន្ធនឹងទិដ្ឋភាពជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ ក្នុងអំឡុងឆ្នាំ១៩៧៥ ។ សាក្សីថាខ្លួនបានរៀបរាប់ថា គាត់បានឃើញប្រជាពលរដ្ឋចាកចេញពីភ្នំពេញយ៉ាងពពាក់ពពូនគ្នា ហើយពេលសាក្សីចូលមកដល់ទីក្រុងភ្នំពេញ បានឃើញទីក្រុងមានសភាពស្ងាត់ជ្រងំ ។ មេធាវី ពេជ អង្គ បានសួរឲ្យសាក្សីបញ្ជាក់ពីសភាពប្រជាជនដែលជម្លៀសពីទីក្រុង និងការបែងចែករវាងប្រជាជន១៧មេសា (ប្រជាជនថ្មី) និងប្រជាជនមូលដ្ឋាន (ប្រជាជនចាស់) ។ បន្ទាប់មកមេធាវីបានសួរទាក់ទងនឹងកិច្ចការនៅក្នុងឃ្លាំងរដ្ឋ ។ សាក្សីបានឆ្លើយថា សម្ភារចេញពីរោងចក្រត្រូវបានចែកជូនប្រជាពលរដ្ឋមួយសប្តាហ៍ម្តងយ៉ាងជាក់លាក់ ដែលមានជាច្រើនប្រភេទ ប៉ុន្តែសាក្សីពុំអាចដឹងថាសម្ភារទាំងនោះ បានដល់ដៃប្រជាពលរដ្ឋ ឬអត់នោះទេ ។

## ៥) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី

### ក) មេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានចាប់ផ្តើមសំណួរដោយផ្តោតលើការចាក់ខ្សែអាត់សម្លេងចម្លើយសារភាពរបស់ កុយ ធួន ដោយ នួន ជា ។ សាក្សីបានឆ្លើយថា នៅក្នុងចម្លើយសារភាពនោះ សាក្សីបានឮការលើកឡើងអំពីការប៉ុនប៉ងសម្លាប់ ប៉ុល ពត ប៉ុន្តែផែនការសម្លាប់នោះ ពុំបានទទួលជោគជ័យ ដូច្នេះហើយទើបមានការចាប់ខ្លួន និងការសារភាព ។ សាក្សីបានបន្តថា ការចាក់ខ្សែអាត់សម្លេងនេះ ធ្វើនៅពេលប្រជុំដែលមានអ្នកចូលរួមមិនលើសពីមួយពាន់នាក់នោះឡើយ ។ ការប្រជុំរបៀបនេះធ្វើឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៦-៧៧ មានប្រមាណ២-៣លើកតែប៉ុណ្ណោះ ។ សាក្សីបានបញ្ជាក់ថា នួន ជា បានលើកពីបញ្ហាក្បត់របស់ កុយ ធួន ប្រាប់ទៅអ្នកចូលរួមប្រជុំទាំងអស់ ។ ទាក់ទងនឹង សោ ភឹម សាក្សីបានបំភ្លឺថា ខ្លួនពុំបានឮ ឬសន្និដ្ឋានថា នួន ជា ជាអ្នកលើកឡើងថា សោ ភឹម ជាជនក្បត់នោះទេ ។ ក្រោយមកទើបខ្លួនបានឮការពិភាក្សាគ្នាៗគ្នាថា សោ ភឹម ក៏ជាជនក្បត់ដែរ ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងសម្ភារៈនៅក្នុងឃ្លាំង សាក្សីបានជម្រាបថា នៅក្នុងឃ្លាំងកំពង់ទឹកកក ក្រៅពីស្រូវ និងអង្ករ មានសម្ភារៈផ្សេងទៀតដូចជា ក្រណាត់ ស្បែកជើង អំបោះ មុង ភួយ ដែកគោល ថ្មដែកកេះ ព្រមទាំងគ្រឿងបន្លាស់ម៉ាស៊ីនមកពីបរទេសទៀតផង ។ ចំណែកនៅឃ្លាំងគីឡូលេខ៦ មានដូចជាស្រូវ អង្ករ ស៊ីម៉ង់ត៍ កៅស៊ូ និងកន្ទក់ជាដើម ។ សាក្សីក៏បានធ្វើការកែតម្រូវនូវអ្វី ដែលខ្លួនបានឆ្លើយកន្លងមកថា តាមពិតស្រូវពុំត្រូវនាំចេញនោះទេ គឺមានតែអង្ករប៉ុណ្ណោះ ដែលត្រូវនាំចេញទៅក្រៅប្រទេស ។ សាក្សីបានទទួលស្គាល់ថា ខ្លួនពុំធ្លាប់បានជួប នួន ជា ដោយផ្ទាល់ទេ ។

គួរបញ្ជាក់ថា ក្នុងអំឡុងពេលមេធាវីសួរសាក្សី រស់ ស៊ុយ ពាក់ព័ន្ធនឹងចម្លើយសារភាពរបស់ កុយ ធួន លោកចៅក្រមឡាវ៉ែញ បានរំឭកដល់មេធាវីថា ប្រសិនបើមេធាវីមានចេតនាយកខ្លឹមសារនៃចម្លើយសារភាពរបស់ កុយ ធួន មកសួរជាការមិនត្រឹមត្រូវទេ ដោយសារចម្លើយសារភាពរបស់ កុយ ធួន ទទួលបានពីការធ្វើទារុណកម្ម ។



ហ៊ូ នឹម (ឆ្វេង) ហ៊ូ យន់ (កណ្តាល) និង ខៀវ សំផន នៅតំបន់រំ

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ស សារិន

## ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបឈ្មោះ ស សារិន អតីតអ្នកបើកបររថយន្តជូនគណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន កើតថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៥៧ នៅភូមិត្រពាំងក្រពើ ឃុំរៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ បច្ចុប្បន្នរស់នៅផ្ទះលេខ ៤៩ ភូមិទី៥ សង្កាត់វាលវង់ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ស សេន ម្តាយឈ្មោះ សាន សារឿន ប្រពន្ធឈ្មោះ ម៉ម សារ៉ុន មានកូនចំនួន៥នាក់ ។



ដោះខ្មែរក្រហម មុនឆ្នាំ១៩៧៥ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

សវនាការសួរដេញដោល ស សារិន បានប្រព្រឹត្តទៅជាងកន្លះថ្ងៃ ដោយមានប្រជាជនកម្ពុជាចូលរួមតាមដានដោយផ្ទាល់ប្រមាណជាង ៤០០នាក់ លើកលែងតែជនជាប់ចោទ នួន ជា តែប៉ុណ្ណោះ ដែលមានបញ្ហាសុខភាព ហើយស្នើសុំអង្គជំនុំជម្រះតាមដានកិច្ចដំណើរការនីតិវិធីពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ដែលត្រូវបានរៀបចំទុកនៅបន្ទប់រង់ចាំនៅក្រោមសាលសវនាការ ។ សវនាការស្តាប់សក្ខីកម្មរបស់ សារិន អង្គជំនុំជម្រះគ្រោងធ្វើមួយថ្ងៃពេញ ដោយផ្តល់ពេលវេលាកន្លះថ្ងៃសម្រាប់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងកន្លះថ្ងៃទៀតសម្រាប់មេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម ដើម្បីសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ ប៉ុន្តែ ការប្រព្រឹត្តទៅពុំដូចការគ្រោងទុកទេ ។ សវនាការត្រូវបានបិទបញ្ចប់ពាក់កណ្តាលទី ដោយសារដើមបណ្តឹងរដ្ឋប្បវេណីរូបនេះពុំយល់ព្រមផ្តល់សក្ខីកម្មបន្ត ដោយផ្តល់ហេតុផលថា គាត់មានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន ។

មុននឹងអនុញ្ញាតឲ្យភាគីទាំងអស់សួរដេញដោល ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានប្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន អំពីសិទ្ធិក្នុងការថ្លែងទុក្ខសោក និងការខូចខាតទាំងឡាយដែលគាត់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលការខូចខាតនេះ បណ្តាលមកពីអង្គហេតុដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទទាំងពីររូប ។ នីតិវិធីក្នុងការសួរដេញដោល ចាប់ផ្តើមពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយឡែក តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងពីររូប ពុំបានចោទសួរ ស សារិន ឡើយ ដោយសារតែអង្គជំនុំជម្រះសម្រេចបញ្ចប់ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនការគ្រោងទុក ។

### ១) សក្ខីកម្មរបស់ ស សារិន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

ស សារិន បានចូលរួមក្នុងចលនាបដិវត្តនៅអាយុ ១៣ឆ្នាំ ចំពេលដែលសម្តេចព្រះ នរោត្តម សីហនុ ប្រកាសអំពាវនាវឲ្យ

ចូលព្រៃដើម្បីប្រឆាំងនឹងរបប លន់ នល់ បន្ទាប់ពីព្រះអង្គត្រូវបាន លោកសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ សារិន បានចូលរួមក្នុងចលនានេះតាមការ ណែនាំរបស់ ទន់ គ្រី ជាមេបញ្ជាការយោធាតំបន់២១ ហើយ បានចូលពេញសិទ្ធិ នៅក្នុងខែសីហា ឆ្នាំ១៩៧៣ ពេលដែល មានការអំពាវនាវឲ្យយុវជនទាំងអស់ចូលរួមវាយផ្តាច់យកទីក្រុង ភ្នំពេញ ។ នៅពេលចូលដំបូង សារិន មានតួនាទីជាអ្នកសំដែង សិល្បៈ ដោយទទួលបន្ទុកផ្សព្វផ្សាយមាគ៌ា និងគោលនយោបាយ របស់រណសិរ្សរួបរួមជាតិ ។ សារិន បានបញ្ជាក់ថា មុននឹងសិល្បៈ ចាប់ផ្តើមសម្តែងម្តងៗ គាត់តែងឡើងអានអំពីមាគ៌ានយោបាយ របស់រណសិរ្សរួបរួមជាតិដែលបានសរសេរនៅក្នុងសៀវភៅ តូចមួយ ដើម្បីឲ្យអ្នកមកមើលសិល្បៈបានស្តាប់ ។ ខ្លឹមសារដែល គាត់បានអានជាប្រចាំនោះ *«រណសិរ្សរួបរួមជាតិកម្ពុជា រួបរួម រាល់អង្គការ សាសនា ព្រះមហាក្សត្រ រាជវង្សានុវង្ស ដោយមិន ប្រកាន់ពូជសាសន៍ និងពណ៌សម្បុរឡើយ»* ។ ក្រៅពីនេះ មានអ្នក ផ្សេងមួយចំនួនទៀតឡើងថ្លែងអំពីប្រវត្តិតស៊ូរបស់ អាចារ្យស្មា, អាចារ្យពោធិ៍កំបោរ, អាចារ្យ ហែម ចៀវ ជាដើម ។ នៅក្នុង សិល្បៈនោះ មានការច្រៀងចម្រៀង«ត្រុដិ» ដែលជាចម្រៀង មួយធ្វើឲ្យយុវជនចង់ចូលរួមបម្រើកងទ័ពជាខ្លាំង ។ សារិន បាន រៀបរាប់ថា «ចម្រៀង ត្រុដិ ហ្នឹង គេធ្វើឲ្យមនុស្សដែលជាកងទ័ព បដិវត្តយ៉ាងម៉េចឲ្យមានភាពក្លាហាន សម្បុរ ទោះបីធ្វើពលិកម្ម យ៉ាងម៉េចក៏នៅតែសម្បុរកងទ័ព ។ ...គ្រាន់តែច្រៀងចម្រៀង ត្រុដិ ហ្នឹង មនុស្សចូលបម្រើកងទ័ពច្រើនណាស់ ហើយព្រះសង្ឃ ខ្លះបានស្មុគ្រចិត្តផ្សឹក... ។ ចម្រៀងហ្នឹងគឺគេវាយលុបបំបាត់នូវ វណ្ណៈនាយ ទុន វណ្ណៈសក្តិភូមិ និងធ្វើឲ្យស្អប់ដល់និស្សិតដល់បញ្ញវន្ត អ្នកណាដែលមានសញ្ញាបត្រគេមិនចូលចិត្តទេ ។ មិត្តនារីហ្នឹងគេមិន ស្រឡាញ់ទេ ទាល់តែចូលបម្រើកងទ័ព ឬចុះជនបទ កែប្រែជីវភាព ប្រជាជនអីបានគេស្រឡាញ់ ។ នេះគឺ ខ្លឹមសារជាសង្ខេបនៅក្នុង ចម្រៀងហ្នឹង» ។

នៅពេលចូលរួមក្នុងចលនាបដិវត្តជាលើកដំបូង សារិន ត្រូវ តម្រូវឲ្យរៀនយុទ្ធសាស្ត្រប្រយុទ្ធចំនួន ៣ខែ ដើម្បីត្រៀមប្រយុទ្ធ ជាមួយទាហាន លន់ នល់ ។ ប៉ុន្តែដោយពេលនោះ គាត់នៅតូចពេក ដូច្នេះ គាត់ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកប្រមូលស្បៀងនៅតាម មូលដ្ឋាន ដើម្បីផ្គត់ផ្គង់កងទ័ព ហើយបន្ទាប់ពីវាយបែក ទីក្រុង ភ្នំពេញ គាត់ទទួលបន្ទុកជាអ្នកយកបាយឲ្យទាហាន លន់ នល់ ។ បន្តមក គាត់ត្រូវបានបញ្ជូនទៅមន្ទីរក-៧ នៅជាមួយ តាគី ដើម្បី ដាំបន្លែមួយរយៈ ។ ក្រោយមក សារិន ធ្វើការនៅមន្ទីរក-១២ ដែលជាមន្ទីរបើកបរស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ ៨៧០ ។ ដំបូងឡើយ សារិន មានតួនាទីជាអ្នកដើរប្រមូលរថយន្ត ដែលប្រជាជនជិះទុកចោលនៅតាមផ្លូវក្នុងអំឡុងពេលដែលពួក គាត់ត្រូវបានខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ។ រថយន្ត ដែលប្រមូលបានយកមកទុកនៅក្នុងមន្ទីរក-១២ លើកលែងតែ រថយន្តល្អៗដែលត្រូវយកមកទុកនៅមន្ទីរក-៣ ។ មន្ទីរក-១២ មានទីតាំងជាច្រើនកន្លែង ហើយត្រូវបានបែងចែកជាផ្នែកបើកបរ ផ្នែកជួសជុល ផ្នែកដាំបន្លែ ។ល ។ ដែលមានបុគ្គលិកបម្រើការងារ ប្រមាណជាង៣០០នាក់ ដោយមានឈ្មោះ មៀល ជាអ្នកទទួល ខុសត្រូវរួម ។

ក្រោយមក សារិន ត្រូវបានបង្រៀនឲ្យបេះបើកបររថយន្ត ដើម្បីដឹកសំភារៈផ្សេងៗ និងសម្រាមជាដើម ។ សារិន បញ្ជាក់ថា គាត់ធ្លាប់បានដឹកកម្មាភិបាលមកតាមភូមិភាគផ្សេងៗ ទៅធ្វើ ទស្សនកិច្ច នៅតាមស្រុកគំរូចំនួន៣ ដែលក្នុងនោះមាន ស្រុក ប្រសូត ស្រុកកំពុងត្រឡាច និងស្រុកត្រាំកក់ ។ ស្រុកទាំងនេះ ត្រូវបានបក្សប្រគល់ទង់ឲ្យម្នាក់មួយៗដើម្បីជាការលើកទឹកចិត្ត និងឲ្យស្រុកផ្សេងៗទៀតយកគំរូតាម ។ លើសពីនេះទៀត គាត់ ធ្លាប់បានដឹកភ្ញៀវបរទេសជាច្រើន មកពីប្រទេសភូមា ឡាវ និង លេខាបក្សកុម្មុយនីស្តចិន ។ មុនពេលទៅដឹកគណៈប្រតិភូទាំងនោះ អៀង សារី កោះហៅ ក្រុមរបស់គាត់រួមមានផ្នែកបើកបររថយន្ត ផ្នែកការពារសន្តិសុខ ផ្នែកម្ហូប មកប្រជុំនៅមន្ទីរប-១ ដើម្បីពន្យល់ ណែនាំអំពីរៀបទទួលគណៈប្រតិភូបរទេស ។ នៅពេលប្រជុំនោះ អៀង សារី បានលើកឡើងថា *«...ប្រទេសកម្ពុជារាល់ថ្ងៃហ្នឹង គឺ មានឈ្មោះបោះសំឡេង នៅលើពិភពលោកយ៉ាងខ្លាំងក្រោយពី បានទទួលមហាជ័យជម្នះ១៧មេសាហ្នឹង ហើយមានប្រទេស ជាច្រើនចង់មកចងស្ពានមេត្រីជាមួយយើងដាក់ការទូត ។ តែ ប្រទេសខ្លះក៏យើងទទួលយកតែ ប្រទេសខ្លះទៀតក៏យើងមិនទទួល*

យកដែរ" ។ អៀង សារី បានបន្ថែមថា "ក្រោយពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប្រហែលជា៣លាននាក់ហ្នឹង ដូច្នេះប្រជាជនយើងកំពុងតែប្រឈមមុខនឹងការខ្វះខាតស្បៀង ។ ប្រជាជនយើងសព្វថ្ងៃហ្នឹង មិនមែនសប្បូរសប្បាយ សប្បូររុងរឿងដូចរ៉ាដូផ្សាយនោះទេ សមមិត្ត គឺកំពុងតែប្រឈមមុខនឹងការអត់ឃ្លាន ខ្វះស្បៀង ខ្វះថ្នាំសង្កូវ ខ្វះទីជម្រក ។ រួចចំពោះការរ៉ាដូផ្សាយនេះ ជានយោបាយយើងទៅបរទេស ដើម្បីឲ្យគេមានជំនឿទៅលើកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យអ្នកនៅបរទេស ចូលមកជួយកសាងប្រទេសឲ្យមានភាពជឿនលឿន" ។ ចុងក្រោយ អៀង សារី បានណែនាំឲ្យអ្នកចូលរួមប្រជុំទាំងអស់នោះ កាត់សម្លៀកបំពាក់ថ្មីៗ ដើម្បីទទួលគណៈប្រតិភូបរទេស ។

បន្ទាប់ពីបញ្ចប់ការប្រជុំនេះ សារិន ត្រូវបានចាត់ឲ្យបើករថយន្តទៅទទួលគណៈប្រតិភូមកពីប្រទេសភូមា ដែលមានប្រធានាធិបតី អ៊ូណេវិន ជាអ្នកដឹកនាំ ។ គណៈប្រតិភូនេះត្រូវបានទទួលដំណើរដោយ ខៀវ សំផន (ក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ) នួន ជា (ជាប្រធានសភាតំណាងប្រជាជន) អៀង សារី (ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស) វ៉ន វេត (ខាងឧស្សាហកម្ម) ម៉ី ប្រាង (ខាងគមនាគមន៍ផ្លូវដែក) អៀង ធីរិទ្ធ (ខាងសង្គមកិច្ច) សុន សេន (ជាឧបនាយករដ្ឋមន្ត្រីក្រសួងការពារប្រទេស) ។ លើកលែងតែ ប៉ុល ពត ប៉ុណ្ណោះដែលពុំបានទៅទទួល ។ គណៈប្រតិភូនេះបានសម្រាកនៅវិមានរដ្ឋាភិបាលនៅមុខវត្តភ្នំ ហើយបន្ទាប់មកត្រូវបាននាំទៅធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ និងប្រាសាទអង្គរវត្ត ។ ចំពោះគណៈប្រតិភូមកពីប្រទេសឡាវដឹកនាំដោយព្រះអង្គម្ចាស់ សុផានុវង្ស ។ គណៈប្រតិភូនេះក៏ត្រូវបានទទួលដំណើរដោយ ខៀវ សំផន, នួន ជា, អៀង សារី និងមេដឹកនាំផ្សេងៗទៀត ដែលសុទ្ធតែមានឋានៈជារដ្ឋមន្ត្រី ។ ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូនេះ មានលក្ខណៈដូចគ្នានឹងគណៈប្រតិភូមកពីប្រទេសភូមាដែរ ។ ក្រៅពីនេះ មានគណៈប្រតិភូមកពីប្រទេសចិន ដែលដឹកនាំដោយលេខាបក្សកុម្មុនីស្តចិន មានឈ្មោះថា ឆឹងយឹងគួយ ហៅ គានឆាយ ។ សារិន បញ្ជាក់ថា មានតែគណៈប្រតិភូនេះប៉ុណ្ណោះ ដែលបានធ្វើទស្សនកិច្ចនៅកម្ពុជាបានយូរជាងគេរយៈពេល១៦ថ្ងៃ ។ គណៈប្រតិភូនេះត្រូវបានទទួលស្វាគមន៍ដោយ ប៉ុល ពត ផ្ទាល់នៅឯព្រលានយន្តហោះ ។ លើសពីនេះទៀត មានអ្នករង់ចាំទទួលរាប់ម៉ឺននាក់ឈរតម្រៀបគ្នាចាប់ពីព្រលានយន្តហោះ រហូតមកដល់វិមានរដ្ឋាភិបាល ដែលមានទីតាំងនៅជិតវត្តភ្នំ ។


ស សារិន
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

សំណួរចុងក្រោយរបស់មេធាវី វ៉ែន ពៅ ពាក់ព័ន្ធនឹងចំនួនស្ថានទូតបរទេសដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួរនេះ សារិន បញ្ជាក់ថា នៅពេលនោះមានស្ថានទូត ចិន និងកូរ៉េខាងជើង ធំជាងគេ ។ ក្រៅពីនោះមានស្ថានទូតវៀតណាម អាល់បានី រ៉ូម៉ានី គុយបា យូហ្គោស្លាវី អេហ្ស៊ីប ស៊ុយអែត ។ល ។

បន្ទាប់ពីមេធាវី វ៉ែន ពៅ បញ្ចប់សំណួររបស់គាត់ លោក ពេជ អង្គ ដែលជាសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបន្តសួរសំណួរមួយចំនួនទាក់ទងនឹងការរៀនសូត្រនយោបាយដែល សារិន បានចូលរួម ដោយមាន នួន ជា និង ខៀវ សំផន ជាអ្នកបង្រៀន ។ សារិន បានបញ្ជាក់ថា វគ្គបង្រៀននោះ

ត្រូវបានធ្វើឡើងនៅស្តាតអូឡាំពិក ដោយមានកម្មាភិបាលជាច្រើនបានមកចូលរួម ។ នៅក្នុងបន្ទប់បង្រៀននោះមានពាក្យស្លោកជាច្រើន ដូចជា "ជយោ! បក្សកុម្មុយនីស្តដ៏មហិមា មហាអស្ចារ្យ" "កម្ទេច សេ.អ៊ី.អា អាមេរិក និងបរិវារ" "កម្ទេច និងបោសសម្អាត សេ.អ៊ី.អា កា.ហ្សេ.បេ និងខ្មាំងយួនវាតទីលេបទឹកដី" ។ ក្រៅពីពាក្យស្លោកទាំងនេះ មានការច្រៀងចម្រៀងមួយបទដែលមានខ្លឹមសារ "ក្រោកឡើងអស់អ្នកក្រខ្ញុំគេទាំងប៉ុន្មាន ក្រោកឡើងអស់អ្នកក្រតោកយ៉ាករាល់ប្រាណក្តៅណាស់ស្មើរប្រេះដើមទ្រូងឆ្ងាយចេញ គ្រានេះមួងស្លាប់រស់មិនស្តាយ ។ របបចាស់យើងកម្ទេចឲ្យអស់ចេញ មិនទោរម្មេញ ប្តេជ្ញាបូជាចិត្តកាយ អាំងទៃរណាស្បូណាល់ គឺជាសង្គមអនាគត" ។ សារិន បញ្ជាក់បន្ថែមថា បន្ទាប់ពីច្រៀងចម្រៀងនេះចប់ នួន ជា បានចូលមកដល់ ហើយបានពោលថា "នេះជាសំឡេងបក្សកុម្មុយនីស្តកម្ពុជា..." ។ ពេលនោះ នួន ជា បាននិយាយអំពីថ្ងៃមហាជ័យជម្នះរបស់បក្សមហាជ័យជម្នះចាស់ និងមហាជ័យជម្នះថ្មី ។ មហាជ័យជម្នះចាស់ និយាយអំពីថ្ងៃ១៧ មេសា ដែលជាថ្ងៃវាយឈ្នះចក្រពត្តិអាមេរិក និងបរិវារ ដែលមាននៅភ្នំពេញ បាត់កក និងព្រៃនគរ ។ ចំណែកជ័យជម្នះថ្មីនិយាយអំពីការលើកទំនប់ ជីកប្រឡាយពាសពេញផ្ទៃប្រទេស ។ លើសពីនេះទៀត ការរកឃើញខ្មាំងស៊ីរូងផ្ទៃក្នុង ដែលមានបំណងបំផ្លាញបក្ស ប៉ុន្តែត្រូវបានទប់ស្កាត់ទាន់ពេលវេលា ។

### ២) ការបដិសេធចោលនូវសំណើសុំវិធានការការពាររបស់ដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សំណួររបស់គាត់ ប្រធានអង្គជំនុំជម្រះក៏ប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាដើម្បីសួរដេញដោល ស សារិន បន្ត ។ បន្ទាប់ពីទទួលបានការអនុញ្ញាតពីនេះ តំណាងសហព្រះរាជអាជ្ញា លោក ឃីត វ៉ារ៉េន់ មានបំណងដាក់បង្ហាញឯកសារប្រតិចារិកនៃបទសម្ភាសន៍ដែល សារិន ធ្លាប់បានធ្វើជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីចោទសំណួរពាក់ព័ន្ធនឹងខ្លឹមសារនៃកិច្ចប្រជុំរៀនសូត្រនយោបាយដែលគាត់បានចូលរួមរៀនជាមួយ នួន ជា និង ខៀវ សំផន ។ ប៉ុន្តែជាការឆ្លើយតប សារិន បញ្ជាក់ថា គាត់ពុំមានបំណងផ្តល់សក្ខីកម្មអំពីកិច្ចប្រជុំនោះទៀតឡើយ ព្រោះទី១) គាត់ធ្លាប់បានផ្តល់បទសម្ភាសន៍អំពីបញ្ហានេះជូនមជ្ឈមណ្ឌលឯកសារកម្ពុជាម្តងរួចមកហើយ ។ ទី២) គាត់មានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់គាត់នៅពេលដែលគាត់និយាយអំពីកិច្ចប្រជុំរៀនសូត្រនេះ ព្រោះព័ត៌មានទាំងនោះអាចធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ នួន ជា និង ខៀវ សំផន ព្រោះគាត់បានចងចាំស្ទើរតែទាំងអស់ នូវពាក្យពេចន៍ដែលអ្នកទាំងពីររូបនេះនិយាយនៅក្នុងកិច្ចប្រជុំរៀននយោបាយនោះ ។ សារិន អះអាងថា អតីតខ្មែរក្រហមជាច្រើនពុំសប្បាយឡើយ នៅពេលនាំមេដឹកនាំរបស់ពួកគេមកកាត់ទោស ដូច្នេះហើយពួកគេអាចនឹងមិនសប្បាយចិត្តនៅពេលដែលគាត់ផ្តល់សក្ខីកម្មប្រឆាំង នឹងមេដឹកនាំខ្មែរក្រហមទាំងនោះ ។ ចុងក្រោយ សារិន បញ្ជាក់ថា ប្រសិនបើអង្គជំនុំជម្រះនៅតែមានបំណងឲ្យគាត់ផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងកិច្ចប្រជុំនោះទៀត គាត់ស្នើសុំរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិចាត់វិធានការការពារសន្តិសុខសម្រាប់រូបគាត់រហូតអស់មួយជីវិត បើពុំនោះសោតគាត់នឹងមិនបន្តផ្តល់សក្ខីកម្មទៀតឡើយ ។ ភ្លាមៗនោះ មេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន លោក គង់ សំអុន បានលើកឡើងថា វិធានផ្ទៃក្នុងរបស់តុលាការពុំបានចាប់បង្ខំឲ្យដើមបណ្តឹងរដ្ឋប្បវេណីឲ្យត្រូវតែនិយាយឡើយ ដូច្នេះតុលាការត្រូវពិចារណាអំពីបញ្ហានេះ ។ ក្រុមមេធាវីរបស់ នួន ជា បានគាំទ្រចំពោះការលើក



ឡើងក្រុមមេធាវី ខៀវ សំផន ។ ចំណែកតំណាងសហព្រះរាជអាជ្ញាបានផ្ដល់ដំណោះស្រាយជូនអង្គជំនុំជម្រះ ដោយបានលើកឡើងនូវវិធាន២៩ នៃវិធានផ្ទៃក្នុងរបស់តុលាការមកធ្វើជាមូលដ្ឋាន ។ វិធាននេះអនុញ្ញាតឲ្យតុលាការស្ដាប់សក្ខីកម្មរបស់ សារិន ជាអសាធារណៈ ប្រសិនបើគាត់មានការភ័យខ្លាច ។ គួររំឭកថា សារិន ធ្លាប់ត្រូវបាន អង្គភាពគាំពារសាក្សីសួរបញ្ជាក់ពីការសម្រេចយក ឬមិនយកវិធានការការពារតាមរយៈការផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់ដែលបិទ ដោយកញ្ចក់មិនអាចមើលឃើញមុខ និងបំលែងសំឡេងដែលមិនអាចស្គាល់បាន ។ ប៉ុន្តែ សារិន សម្រេចមិនយកដោយផ្ដល់ហេតុផលថា គាត់ចង់មកផ្ដល់សក្ខីកម្មដោយផ្ទាល់តែម្ដង ដើម្បីជៀសវាងការមានមន្ទិលសង្ស័យអំពីភាពត្រឹមត្រូវនៃសក្ខីកម្មរបស់គាត់ ។

បន្ទាប់ពីសវនាការត្រូវបានប្រកាសផ្អាកមុនម៉ោងកំណត់ និងចូលវិញយឺតជាងកន្លះម៉ោង សហមេធាវីជាតិនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី លោក ពេជ អង្គ បានបញ្ជាក់ជូនអង្គជំនុំជម្រះថា គាត់បានបញ្ចុះបញ្ចូល សារិន ឲ្យផ្លាស់ប្ដូរគោលជំហររួចហើយ ដោយពន្យល់អំពីសារៈសំខាន់នៃសក្ខីកម្ម និងតំលៃភស្ដុតាងទាក់ទងនឹងអង្គហេតុនេះ ប៉ុន្តែ សារិន នៅតែទទូចសុំវិធានការការពារដដែល ។ សារិន ស្នើសុំកងកម្លាំងប្រដាប់អាវុធចំនួន៤នាក់ការពាររហូតដល់គាត់អស់ជីវិត ហើយរាល់ការចំណាយផ្សេងៗ ដូចជាប្រាក់បៀវត្សរ៍ បាយទឹក ។ល ។ សម្រាប់អ្នកការពារទាំងនោះជាបន្ទុករបស់រដ្ឋ ។ ជាការឆ្លើយតបអង្គជំនុំជម្រះបញ្ជាក់ថា «...សំណើរបស់លោកដែលបានសុំឲ្យអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាផ្ដល់កិច្ចការពារសន្តិសុខសម្រាប់រូបលោកចាប់ពីពេលនេះ រហូតដល់អស់មួយជីវិតនោះ មិនមានហេតុផលសមស្របទេ ។ អង្គជំនុំជម្រះសូមជម្រាបផងដែរថា អង្គជំនុំជម្រះគ្មានយុត្តាធិការសម្រេចតាមសំណើរបស់លោកបែបនេះទេ ។ អង្គជំនុំជម្រះក៏មិនសម្រេចផ្ដល់នូវវិធានការផ្សេងៗទៀតជូនលោកដែរ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបញ្ចប់ការស្ដាប់សក្ខីកម្មរបស់លោកត្រឹមនេះ...» ។ គួរបញ្ជាក់ថាមុននឹងចេញសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះបានសួរ សារិន បញ្ជាក់អំពីភាពត្រឹមត្រូវនៃប្រតិចារិកដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចម្លងចេញពីខ្សែអាត់ថតសំឡេងដែលបានថតនៅពេលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការសម្ភាសន៍ជាមួយ ស សារិន ។ សារិន បញ្ជាក់ថាប្រតិចារិកនោះពិតជាត្រឹមត្រូវតាមអ្វីដែលគាត់បានផ្ដល់បទសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាងនេះទៅទៀតគាត់មានជំនឿជាក់ទៅលើការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។



ប្រជាជនកម្ពុជាវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ក្នុងឆ្នាំ១៩៧៩ (រូបថតមជ្ឈមណ្ឌលឯកសារ)

# សវនាការស្តាប់សក្ខីកម្មសាក្សី អ៊ុង ឆាត់

## ថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ២០១៣

*នៅរសៀលថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហម បានកោះហៅសាក្សីមួយរូបទៀត ដែលមានឈ្មោះ អ៊ុង ឆាត់ ដើម្បីស្តាប់សក្ខីកម្មទាក់ទងនឹងអង្គហេតុស្តីពីការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសួរដេញដោលនេះធ្វើឡើងបន្ទាប់ពីអង្គជំនុំជម្រះបានបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សី ស សារិន ។ សាក្សី អ៊ុង ឆាត់ ជាអតីតយោធាខ្មែរក្រហមដែលបានឈរជើងប្រចាំនៅខេត្តពោធិ៍សាត់ ។ ក្នុងអំឡុងពេលនៃសវនាការ សាក្សី អ៊ុង ឆាត់ ត្រូវបានភាគីសាកសួរសំណួរជាច្រើនទាក់ទងនឹងការនាំយកអតីតទាហាន លន់ នល់ ចេញពីសាលាខេត្តពោធិ៍សាត់ យកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ក្រោយពីមានការប្រជុំមួយដែលរៀបចំឡើងដោយខ្មែរក្រហមនៅក្នុងសាលាខេត្តពោធិ៍សាត់ ។ សាក្សី អ៊ុង ឆាត់ ជាកម្មាភិបាលខ្មែរក្រហមមួយរូបក្នុងចំណោមកម្មាភិបាលខ្មែរក្រហមជាច្រើនរូបផ្សេងទៀត ដែលបានទទួលភារកិច្ចប្រចាំការនៅក្លោងទ្វារច្រកចូលក្នុងសាលាខេត្តពោធិ៍សាត់ក្នុងអំឡុងពេលនៃកិច្ចប្រជុំនោះ ។*

*នីតិវិធីក្នុងការសួរដេញដោលសាក្សី អ៊ុង ឆាត់ ត្រូវចាប់ផ្តើមដោយតំណាងសហព្រះរាជអាជ្ញា បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយ មេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម ។ ប៉ុន្តែ ក្រុមមេធាវីការពារក្តី ខៀវ សំផន ពុំបានចោទសំណួរលើសាក្សីរូបនេះទេ ហើយមានតែក្រុមមេធាវីការពារក្តី នួន ជា មួយប៉ុណ្ណោះ ។*

*សវនាការស្តាប់សក្ខីកម្មសាក្សី អ៊ុង ឆាត់ បានបញ្ចប់នៅត្រឹមព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៣ ។ អំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការសួរដេញដោលសាក្សី អ៊ុង ឆាត់ ទាំង២ថ្ងៃ មានការចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ប្រជាជន សិស្សនិស្សិត និងអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ អំពីកិច្ចដំណើរការនីតិវិធីប្រមាណ៤០០នាក់ មកពីរាជធានីភ្នំពេញ ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំង ។*

### ១) ប្រវត្តិសាវតាររបស់សាក្សី អ៊ុង ឆាត់

*នៅមុនពេលប្រគល់វេទិកាសួរដេញដោលសាក្សីជូនភាគី ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសាកសួរសាក្សីអំពីប្រវត្តិសាវតារ និងជូនដំណឹងអំពីសិទ្ធិ និងកាតព្វកិច្ចដែលសាក្សីមាន ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះ សាក្សី អ៊ុង ឆាត់ បានបញ្ជាក់ថា សព្វថ្ងៃលោកមានអាយុ៦២ឆ្នាំ រស់នៅខេត្តពោធិ៍សាត់ និងប្រកបរបរធ្វើស្រែ ។ ឪពុកឈ្មោះ ម៉ៅ ឈិត និងម្តាយឈ្មោះ គាត ប៊ិន និងប្រពន្ធឈ្មោះ មិត្ត សែម មានកូន៥នាក់ ។ បន្ទាប់មក អង្គជំនុំជម្រះបានជម្រាបសាក្សីអំពីសិទ្ធិក្នុងការមិន ធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ប៉ុន្តែសាក្សីមានករណីកិច្ចត្រូវឆ្លើយតបនឹងសំណួររបស់ភាគី លើកលែងតែសំណួរនោះនាំឲ្យដាក់បន្ទុកលើខ្លួនឯង ។ សាក្សី អ៊ុង ឆាត់ បានបញ្ជាក់ថា ខ្លួនធ្លាប់ផ្តល់សម្ភាសន៍ជូន ការិយាល័យសហចៅក្រមស៊ើបអង្កេតចំនួនពីរដងរួចមកហើយ ។*



អ៊ុង ឆាត់
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

*តំណាងសហព្រះរាជអាជ្ញាជាតិ ស៊ុង ឆវីន្ត ត្រូវបានផ្តល់វេទិកាជូនដើម្បីចោទសួរសាក្សីទាក់ទងនឹងការសម្លាប់អតីតទាហាន*

នៃរដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ សំណួរដំបូង បានផ្តោតជាសំខាន់លើប្រវត្តិនៃការចូលរួមក្នុងបដិវត្តរបស់សាក្សីជាមួយនឹងចលនាខ្មែរក្រហម ។ សាក្សី អ៊ុង ឆាត់ បានរៀបរាប់ថា លោកបានចូលធ្វើបដិវត្តន៍ជាមួយចលនាខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧២ ឬ១៩៧៣ នៅក្នុងខេត្តពោធិ៍សាត់ ។ ក្រោយពីខេត្តពោធិ៍សាត់ត្រូវបានរំដោះនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ សាក្សីត្រូវបានចាត់តាំងឲ្យយាមកាមនៅចំណុចសាលាខេត្តពោធិ៍សាត់ និងមានភារកិច្ចរុះរើផ្សារ ដោយទទួលបញ្ជាពីឈ្មោះ ធើយ និង សារីម កាន់អនុសេនាធំ ។ ការរុះរើផ្សារធ្វើឡើងមួយថ្ងៃ បន្ទាប់ពីខ្មែរក្រហមរំដោះបានក្រុងពោធិ៍សាត់ ហើយប្រជាជនត្រូវបានស្នើឲ្យចាកចេញទីក្រុងដោយសន្តិវិធី ដោយពុំមានការប្រើប្រាស់អាវុធគំរាមកំហែងឡើយ ។ ប៉ុន្តែសម្រាប់ប្រជាជនដែលមិនព្រមចាកចេញ អាចនឹងមានការចាត់វិធានការដោយឡែកពីសំណាក់ក្រុមផ្សេងមួយទៀត ។

ឆ្លើយតបនឹងសំណួរដែលសួរថា តើមានការចាប់ខ្លួនអតីតទាហាន លន់ នល់ ដែរឬយ៉ាងណា? សាក្សីបានអះអាងថា នៅពេលដែលខ្លួនត្រូវបានចាត់តាំងឲ្យយាមកាមនៅច្រកទ្វារសាលាខេត្ត ខ្លួនបានឃើញអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ ស្លៀកពាក់ជាស៊ីវិល ត្រូវបានដឹកតាមឡានតូច ធំ ដើម្បីមកចូលរួមប្រជុំនៅសាលាខេត្តពោធិ៍សាត់ ១០ថ្ងៃបន្ទាប់ពីរំដោះបានទីក្រុងពោធិ៍សាត់ ។ សាក្សី អ៊ុង ឆាត់ បានបន្តទៀតថា ក្រោយពេលប្រជុំរួច អ្នកទាំងនោះត្រូវបានដឹកចេញទៅរៀនសូត្រនៅទួលពោធិ៍ជ្រៃ ប៉ុន្តែពុំដែលឃើញត្រឡប់មកវិញឡើយ ។ សាក្សីបានបញ្ជាក់ថា ការដែលខ្លួនដឹងថា អតីតទាហាន លន់ នល់ ទាំងនោះត្រូវបានដឹកយកទៅទួលពោធិ៍ជ្រៃដើម្បីរៀនសូត្រ ដឹងបានតាមរយៈការនិយាយតៗគ្នា ព្រោះខ្លួនពុំបានដឹងថា ឡានដឹកយកទៅទីណាពិតប្រាកដ ។ សាក្សីគ្រាន់តែបានឃើញនៅពេលចាកចេញពីសាលាខេត្តប៉ុណ្ណោះ ។ សាក្សី អ៊ុង ឆាត់ បានធ្វើការសន្និដ្ឋានថា អ្នកដែលបានចូលរួមក្នុងកិច្ចប្រជុំនោះមានចំនួនប្រហែល២០០នាក់ ។ ការសន្និដ្ឋានដូច្នេះ ត្រូវបានសាក្សីផ្តល់ហេតុផលថា ដោយសារទំហំនៃសាលប្រជុំនៅក្នុងសាលាខេត្តនោះអាចដាក់មនុស្សបានប្រ-មាណតែ២០០នាក់ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វ៉ែន័រ បានបន្តពីសហភាគាជាតិរបស់ខ្លួន ដើម្បីចោទសួរសាក្សីទាក់ទងនឹងការនាំយកទាហាន លន់ នល់ មកសម្លាប់នៅទួលពោធិ៍ជ្រៃ ។ នៅត្រង់ចំណុចនេះ សាក្សី អ៊ុង ឆាត់ បានអះអាងថា ខ្លួនធ្លាប់បានឮពីការនិយាយតៗគ្នាថា ឈ្មោះ ប៉ិល ដែលជាអតីតមេបញ្ជាការទាហាននៅបន្ទាយភូមិពោធិ៍ក្នុងរដ្ឋការ លន់ នល់ ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំនៅសាលាខេត្តពោធិ៍សាត់ដែរ ។ បន្ទាប់មក ប៉ិល ត្រូវបាននាំយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ។ សាក្សី អ៊ុង ឆាត់ បានបន្តទៀតថា អ្នកទាំងនោះត្រូវបានដឹកយកទៅរៀនសូត្រម្តងមួយឡានៗ ហើយយោធាខ្មែរក្រហមរង់ចាំរហូតទាល់តែឃើញឡានទីមួយត្រឡប់មកវិញជាមុនសិន ទើបដឹកយកចេញទៅមួយឡានថ្មីទៀត ។ ក្រោយមកខ្លួនបានឮប្រជាជននៅទីនោះនិយាយថា មានឆ្អឹងខ្មោចជាច្រើន ដែលត្រូវបានចងដៃមកក្រោយ មានខ្លះត្រូវរបួសត្រង់ក្បាល និងខ្លះត្រូវរបួសនៅដងខ្លួន ដែលត្រូវបានសម្លាប់ ប៉ុន្តែសាក្សីពុំធ្លាប់បានឃើញឆ្អឹងទាំងនោះផ្ទាល់ភ្នែកទេ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា វ៉ែន័រ បានបង្ហាញខ្សែភាពយន្តឯកសារមួយរបស់លោក ថេត សម្បត្តិ ដែលមានចំណងជើងថា "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ" ទាក់ទងនឹងការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ នៅក្នុងខ្សែភាពយន្តឯកសារនោះ ប្រជាជននៅក្នុងខេត្តពោធិ៍សាត់បានរៀបរាប់ថា នៅក្រោយពេលចាកចេញពីការប្រជុំនៅសាលាខេត្តពោធិ៍សាត់ ឈ្មោះ ប៉ិល និង ឈ្មោះ សារុន ត្រូវបានខ្មែរក្រហមកាត់ក្បាល ហើយដោតជាមួយនឹងឈើនៅទួលពោធិ៍ជ្រៃ ។

### ៣) ការសួរដេញដោលសាក្សីដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ចេត វ៉ាន់លី បានត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាជូនដើម្បីបន្តសួរដេញដោលសាក្សី អ៊ុង ឆាត់ ។ មេធាវី វ៉ាន់លី បានចាប់ផ្តើមសំណួរដំបូងរបស់ខ្លួនដោយផ្តោតជាសំខាន់លើផែនការប្រមូលអតីតទាហាន លន់ នល់ មកប្រជុំនៅក្នុងសាលាខេត្តពោធិ៍សាត់ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី អ៊ុង ឆាត់ បានបញ្ជាក់ថា ខ្លួនពុំបានដឹងថានរណាជាអ្នក ដាក់ចេញផែនការនោះទេ ព្រោះខ្លួនគ្រាន់តែធ្វើ

តាមថ្នាក់លើនៅឈរយាមមុខសាលាខេត្តប៉ុណ្ណោះ ។ សាក្សី អ៊ុង ឆាត់ បានបន្តទៀតថា បន្ទាប់ពីកិច្ចប្រជុំបានបញ្ចប់ ខ្លួនបានឮអ្នកចូលរួមដែលឈររង់ចាំឡាន ដើម្បីជិះចាកចេញពីសាលាខេត្តជជែកគ្នាថា កិច្ចប្រជុំនៅពេលនោះនិយាយអំពីការទៅរៀនសូត្រនៅទន្លេសាប និងត្រៀមទៅទទួលសម្តេចព្រះ នរោត្តម សីហនុ ។

បន្ទាប់មក មេធាវី ចេត វ៉ាន់លី បានប្រគល់វេទិកាបន្តជូនសហភាគាអន្តរជាតិរបស់ខ្លួនដើម្បីបន្តសួរដេញដោល ។ សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត បានស្នើឲ្យសាក្សីបញ្ជាក់សារជាថ្មីអំពីការពុំបានចូលរួមសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ដោយចោទសួរថា *"លោកសាក្សី លោកបានស្បថរួចហើយ ។ ដូច្នេះ តើលោកអាចធានា នៅចំពោះមុខអង្គជំនុំជម្រះបានទេថា លោកពុំត្រូវបានបង្ខំដោយថ្នាក់លើរបស់លោកឲ្យចូលរួមក្នុងអំពីសម្លាប់មនុស្សដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ"?* ឆ្លើយតបនឹងសំណួរនេះ សាក្សីអះអាងថា ខ្លួនបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយ និងថា ប្រសិនបើខ្លួនទទួលបញ្ជាឲ្យសម្លាប់មនុស្សមែន សុំឲ្យខ្លួនស្លាប់ ប៉ុន្តែប្រសិនបើខ្លួនពុំបានទទួលបញ្ជាឲ្យសម្លាប់មនុស្សនៅពេលនោះទេ សុំឲ្យខ្លួនរស់នៅដោយសេចក្តីសុខ និងសុភមង្គលតទៅ ។

### ៤) ការសួរដេញដោលសាក្សីដោយមេធាវីការពារក្តី នួន ជា

បន្ទាប់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការចោទសួរសំណួរ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីការពារក្តី នួន ជា ដើម្បីបន្តចោទសំណួរចំពោះសាក្សី អ៊ុង ឆាត់ ។ ការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា បានផ្តោតជាសំខាន់លើការដឹងឮ និងមើលឃើញផ្ទាល់ភ្នែករបស់សាក្សីពាក់ព័ន្ធការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ ក្រុមមេធាវីការពារក្តី នួន ជា បានសួរសំណួរជាច្រើនពាក់ព័ន្ធនឹងចំនួនអ្នកចូលរួមប្រជុំនៅក្នុងសាលាខេត្ត និងការដឹកជញ្ជូនមនុស្សចេញពីសាលាខេត្ត ដើម្បីដឹងថា តើសាក្សីបានដឹង និងឃើញដោយផ្ទាល់ភ្នែកថា អ្នកទាំងនោះត្រូវបានដឹកយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ មែនឬយ៉ាងណា ។ នៅក្នុងការឆ្លើយតបចំពោះសំណួររបស់មេធាវីការពារក្តី នួន ជា សាក្សីបានបញ្ជាក់អះអាងថា ការដឹងរបស់ខ្លួនភាគច្រើនឮតាមរយៈការនិយាយប្រាប់តៗគ្នា ហើយចំពោះចំនួនអ្នកចូលរួមនៅក្នុងការប្រជុំនៅក្នុងសាលាខេត្តពោធិ៍សាត់នៅពេលនោះ គ្រាន់តែជាការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួនតែប៉ុណ្ណោះ ហើយខ្លួនពុំបានឃើញការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ផ្ទាល់ភ្នែកទេ ។ ទោះបីជាយ៉ាងណាក្តី សាក្សីបានអះអាងថា ខ្លួនបានឃើញផ្ទាល់ភ្នែកអំពីទិដ្ឋភាពដឹកមនុស្ស ចាកចេញពីសាលាខេត្តតាមរយៈរថយន្តតូចធំដែលខ្មែរក្រហមបានត្រៀមទុក ព្រោះខ្លួនជាអ្នកយាមនៅច្រកទ្វារសាលាខេត្តនាពេលនោះ ។

សម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន ពុំមានសំណួរចោទសួរចំពោះសាក្សីរូបនេះឡើយ ។ សវនាការសួរដេញដោលសាក្សី អ៊ុង ឆាត់ បានបញ្ចប់នៅរសៀលថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០១៣ ។



ប្រជាជនកម្ពុជាវិលត្រលប់មកមាតុភូមិកំណើតវិញ ក្រោយរបបខ្មែរក្រហមដួលរំលំក្នុងឆ្នាំ១៩៧៩ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការសួរដេញដោលសាក្សី លឹម សាត

## *ថ្ងៃទី២-៣ ខែឧសភា ឆ្នាំ២០១៣*

នៅថ្ងៃទី២-៣ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានបើកសវនាការសួរដេញដោលសាក្សី លឹម សាត ។ នៅក្នុងដំណាក់កាលសួរដេញដោលនេះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសាក្សីមានមេធាវីជំនួយម្នាក់ឈ្មោះ ម៉ម រិទ្ធា ដើម្បីជួយសម្រួល និងប្រឹក្សាយោបល់ជៀសវាងសំណួរទាំងឡាយណាដែលនាំឲ្យមានការដាក់បន្ទុកមកលើសាក្សី ។ ការសួរដេញដោលសាក្សីរូបនេះ បានផ្ដោតសំខាន់ទៅលើអង្គហេតុ រចនាសម្ព័ន្ធយោធា ការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ និងការជម្លៀសប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ ។ ជាដំបូង ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសួរសំណួរមួយចំនួន ដែលទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី ព្រមទាំងណែនាំអំពីសិទ្ធិ និងករណីកិច្ចមួយចំនួនរបស់សាក្សីក្នុងការចូលរួមកិច្ចដំណើរការសវនាការនេះ ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

ឆ្លើយតបនឹងសំណួរមួយចំនួនរបស់ប្រធានអង្គជំនុំជម្រះ សាក្សីបានបញ្ជាក់ថា គាត់មានឈ្មោះ លឹម សាត អាយុ៥៨ឆ្នាំ មានទីលំនៅក្នុងស្រុកបាកាន ឃុំបឹងបត់កណ្ដាល ខេត្តពោធិ៍សាត់ ។ សព្វថ្ងៃមានមុខរបរជាអ្នកធ្វើស្រែ ។ សាក្សីមានឪពុកឈ្មោះ ទា ម្ដាយឈ្មោះ ណាំ និងភរិយាឈ្មោះ ចិន ព្រមទាំងមានកូនចំនួន ៧នាក់ ។ បន្ទាប់មក អង្គជំនុំជម្រះបានបន្តសួរទាក់ទងនឹងចំនួនបទសម្ភាសន៍ ដែលសាក្សីបានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតកន្លងមក ។ សាក្សីបញ្ជាក់ថា ខ្លួនធ្លាប់បានផ្ដល់បទសម្ភាសន៍ពីរដងជាមួយសហចៅក្រមស៊ើបអង្កេត ហើយមុនពេលចូលរួមនៅក្នុងសវនាការនៅពេលនេះ ខ្លួនបានអានឯកសារសម្ភាសន៍ទាំងនោះខ្លះៗ ដើម្បីជាការរំឭកដល់ការចងចាំ ។

### ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

#### ក) ព្រឹត្តិការណ៍មុនថ្ងៃជម្លៀស ១៧មេសា

ជាការចាប់ផ្ដើម តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានសួរឲ្យសាក្សីបញ្ជាក់អំពីទីតាំង ដែលកងទ័ពរបស់គាត់បានឈរជើងចាប់តាំងពីឆ្នាំ១៩៧១-១៩៧៥ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី បានបញ្ជាក់ថា ក្នុងអំឡុងពេលនោះ ខ្លួនបានទៅឈរជើងនៅសមរភូមិមុខដែលស្ថិតក្នុងតំបន់អំពិល រួមជាមួយខាងភូមិភាគ ហើយខ្លួនបានប្រយុទ្ធជាមួយទាហាន លន់ នល់ ចាប់ពីឆ្នាំ១៩៧២រហូតដល់ឆ្នាំ១៩៧៥ ។ សាក្សីបានបន្តថា នៅក្នុងអង្គភាពរបស់ខ្លួនពុំធ្លាប់មានការសម្លាប់ទាហាន លន់ នល់ ទេ ។ ម្យ៉ាងទៀត ទាហានដែលត្រូវយោធាខ្មែរក្រហមចាប់ខ្លួនបានគ្រាន់តែត្រូវបានបញ្ជូនទៅដាក់នៅឯសមរភូមិក្រោយតែប៉ុណ្ណោះ ។ តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានបន្តសួរទាក់ទងនឹងបែបបទនៃការទទួលបញ្ជាផ្សេងៗ នៅក្នុងជួរកងទ័ពដើម្បីឲ្យសាក្សីបញ្ជាក់ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា រាល់ការអនុវត្តត្រូវធ្វើតាមផែនការរបស់ថ្នាក់លើដែលមានថ្នាក់តំបន់ និងថ្នាក់ភូមិភាគ ហើយថ្នាក់ដឹកនាំជាន់ខ្ពស់ដែលកាន់ខាងទ័ពនៅពេលនោះគឺ ខៀវ សំផន ចាប់តាំងពីឆ្នាំ១៩៧១មក ។ ទាក់ទងនឹងទីតាំង ដែលខ្មែរក្រហមវាយយកបានពីការកាន់កាប់នៃរបប លន់ នល់ នៅចន្លោះឆ្នាំ១៩៧០ដល់១៩៧៥ សាក្សីបានបញ្ជាក់ថា ខ្មែរក្រហមបានវាយដណ្ដើមយកតំបន់មួយចំនួនដូចជានៅលាច



លឹម សាត
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

(ក្នុងខេត្តពោធិ៍សាត់) កោះក្រឡ និងតំបន់ផ្សេងទៀតនៅខេត្តបាត់ដំបង ។ ក្រោយមក ផ្សារដែលនៅតាមតំបន់ទាំងនោះ ត្រូវខ្មែរក្រហមបិទមិនឲ្យដំណើរការ ។

### ខ) ការជម្លៀសប្រជាជននៅខេត្តពោធិ៍សាត់

ទាក់ទងនឹងការជម្លៀសប្រជាជននៅក្នុងខេត្តពោធិ៍សាត់ សាក្សីបានបន្តរៀបរាប់ថា បន្ទាប់ពីខ្មែរក្រហមបានចូលកាន់កាប់ទីប្រជុំជននៅខេត្តពោធិ៍សាត់បានប្រហែលបីសប្តាហ៍ ប្រជាជននៅទីនោះត្រូវបានខ្មែរក្រហមជម្លៀសចេញទៅតាមទីជនបទក្រោមបញ្ជារបស់ តាសុត នៅថ្នាក់ភូមិភាគ និង តាកន នៅថ្នាក់តំបន់ ពីព្រោះខ្មែរក្រហមចង់លុបបំបាត់គិញបង្កប់ សេ.អ៊ី.អា របស់សហរដ្ឋអាមេរិក ។ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនពុំបានដឹងអំពីផែនការជម្លៀសនេះជាមុនទេ មានតែថ្នាក់លើតែប៉ុណ្ណោះដែលបានដឹង ។ សាក្សីបានបញ្ជាក់បន្ថែមថា កងទ័ពដែលវាយចូលខេត្តពោធិ៍សាត់នៅពេលនោះមានពីរវរសេនាតូច គឺវរសេនាតូចលេខ២០១ និងវរសេនាតូចលេខ២០២ក្រោមការបញ្ជារបស់មេបញ្ជាការកងទ័ពភូមិភាគឈ្មោះ តាខ្វែង ។ ទាក់ទងនឹងបន្ទាយនៅទួលពោធិ៍ជ្រៃ សាក្សីបានបញ្ជាក់ថា ទួលពោធិ៍ជ្រៃជាសមរភូមិប្រយុទ្ធដែលខ្លួនជាអ្នកទទួលខុសត្រូវក្នុងការវាយប្រឆាំងនឹងទាហាន លន់ នល់ ដែលកំពុងឈរជើងនៅទីនោះជាង ១០០នាក់ ។

### គ) ការចាប់ខ្លួនទាហាន លន់ នល់ ទៅសម្លាប់នៅទួលពោធិ៍ជ្រៃ

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរ ដោយលើកយកបទសម្ភាសន៍របស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងកិច្ចប្រជុំមួយនៅខេត្តពោធិ៍សាត់ ដែលមានការចូលរួមពីគណៈតំបន់ និងភូមិភាគ ។ បទសម្ភាសន៍នោះមានខ្លឹមសារថា “ប្រធានវរសេនាតូច ប្រធានវរសេនាធំ និងប្រធានកងពលផ្សេងៗ នៅក្នុងកងទ័ពខ្មែរក្រហមត្រូវបានអញ្ជើញឲ្យចូលរួមប្រជុំដែលដឹកនាំដោយ តាញឹម ជាគណៈភូមិភាគ និង តាសុត ជាគណៈតំបន់” ។ សាក្សីក៏បានរៀបរាប់នៅក្នុងបទសម្ភាសន៍នោះដែរថា “ខ្លឹមសារនៅក្នុងកិច្ចប្រជុំនោះគឺ អ្នកដែលមានបុណ្យស័ក្តិទាំងអស់ត្រូវតែទៅរៀនសូត្រសិន ហើយពេលត្រឡប់ពីរៀនសូត្រវិញ អង្គការនឹងឲ្យចូលធ្វើការវិញដដែល អ្នកណាមានស័ក្តិប៉ុន្មាន អង្គការឲ្យពាក់ស័ក្តិប៉ុណ្ណឹងវិញ” ។ ឆ្លើយតបនឹងលើកឡើងនេះសាក្សីបញ្ជាក់ថា នៅពេលនោះខ្លួនបានទទួលបញ្ជាពីថ្នាក់វរៈឲ្យជូនដំណឹងទៅតាមអង្គភាពរបស់ ទាហាន លន់ នល់ ទាំងអស់ ដើម្បីឲ្យមកប្រជុំនៅឯសាលាខេត្តពោធិ៍សាត់ ។ ក្រោយពេលប្រជុំរួច ទាហាន លន់ នល់ ប្រហែលជាង១០ឡានត្រូវបានបញ្ជូនយកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ ។ សាក្សីបានបន្ថែមថា នៅពេលនោះ ខ្លួនមិនបានចូលរួមប្រជុំទេ ប៉ុន្តែបានទទួលដំណឹងពីអ្នកផ្សេងទៀត ព្រោះគាត់ត្រូវបានចាត់តាំងឲ្យទៅចាំមើលឡានដែលដឹកជញ្ជូនទាហានទាំងនោះ ។ តំណាងសហព្រះរាជអាជ្ញាជាតិបានបន្តសួរទាក់ទងនឹងអង្គភាពដែលសាក្សីបានឈរជើងខណៈពេលមានការចាប់ខ្លួនទាហាន លន់ នល់ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា អង្គភាពរបស់គាត់មានទីតាំងនៅក្នុងស្រុកកណ្ដៀង មានចម្ងាយប្រហែល១០គីឡូម៉ែត្រពីទួលពោធិ៍ជ្រៃ ។ លឹម សាត បានបន្ថែមថា នៅទួលពោធិ៍ជ្រៃមានយោធាខ្មែរក្រហមប្រហែល ៦០នាក់ ហើយ តាខ្វែង ដែលជាមេបញ្ជាការភូមិភាគក៏បានចុះទៅឈរជើងនៅទីនោះ ដើម្បីដាក់ចេញបញ្ជាដល់បញ្ជាការវរៈក្នុងការចាប់ខ្លួនទាហានទាំងនោះ ។ សាក្សីបានទទួលដំណឹងថា ក្នុងចំណោមទាហាន លន់ នល់ ទាំងនោះ មានទាហានម្នាក់បានលួចរត់ពីការបាញ់សម្លាប់នៅទួលពោធិ៍ជ្រៃ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាជាតិបន្តសួរទាក់ទងនឹងការចាប់ខ្លួនមន្ត្រីរាជការផ្សេងៗទៀត ក្រៅពីការចាប់ខ្លួនទាហាន លន់ នល់ ។ សាក្សីបានបញ្ជាក់ថា ក្រៅពីការចាប់ខ្លួនទាហាន លន់ នល់ ខ្មែរក្រហមបានឲ្យប្រជាជន និងកងទ័ពរបស់ខ្លួនធ្វើប្រវត្តិរូបដើម្បីស្វែងរកសាច់ញាតិរបស់ទាហាន លន់ នល់ មន្ត្រីរាជការ និងសិស្សនិស្សិតដើម្បីយកទៅរៀនសូត្រ ។

### ឃ) ការជម្លៀសប្រជាជននៅដំណាក់កាលលើកទី២

តំណាងសហព្រះរាជអាជ្ញា សេង ប៊ុនឃាង បានបន្តសួរទាក់ទងនឹងការជម្លៀសប្រជាជននៅដំណាក់កាលទី២ នៅឆ្នាំ ១៩៧៥-១៩៧៦ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងត្រឹមតែការជម្លៀសពីភ្នំពេញនៅឆ្នាំ១៩៧៦ និងប្រជាជនមកពីស្វាយរៀងទៅដាក់នៅតាមសហករណ៍នៅភូមិភាគពាយ័ព្យនៅឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ហើយខ្លួនក៏ពុំបានដឹងអំពីមូលហេតុដែលនាំឲ្យមានការជម្លៀសប្រជាជនដែរ ។

### ង) ការអប់រំនយោបាយ

តំណាងសហព្រះរាជអាជ្ញា ប៊ុនយាង បានបន្តសួរសាក្សីទាក់ទងនឹងការចូលរួមប្រជុំដើម្បីអប់រំនយោបាយ ។ សាក្សីបានបញ្ជាក់ថា គាត់បានទៅចូលរួមប្រជុំត្រឹមថ្នាក់ស្រុកដែលធ្វើឡើងនៅក្នុងសាលារៀនស្វាយលួងស្ថិតនៅក្នុងស្រុកកណ្តៀងអស់រយៈពេលបីថ្ងៃ ដោយមាន នួន ជា ជាអ្នកដឹកនាំប្រជុំ ។ កិច្ចប្រជុំនេះ មានការចូលរួមពីយោធាកម្មាភិបាលនៅថ្នាក់តំបន់ អនុតំបន់ និងភូមិភាគផ្សេងៗទៀត ។ ខ្លឹមសារនៅក្នុងកិច្ចប្រជុំនោះ ទាក់ទងនឹងការរៀនសូត្រនយោបាយនៅសាលាខេត្តពោធិ៍សាត់ ដែលបានធ្វើឡើងនៅឆ្នាំ១៩៧៦ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តលើកយកឯកសារបទសម្ភាសន៍របស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេតដែលមានខ្លឹមសារថា នួន ជា បានដឹកនាំការប្រជុំ២ទៅ៣ដងនៅឆ្នាំ១៩៧៦ អំពីផែនការបោសសំអាតខ្មាំង ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនពុំបានចូលរួមប្រជុំទេ ប៉ុន្តែបានដឹងដោយសារថ្នាក់ស្រុកបាននិយាយប្រាប់ ។ តំណាងសហព្រះរាជអាជ្ញាជាតិបានបន្តសួរទាក់ទងនឹងតួនាទីរបស់សាក្សីចាប់ពីឆ្នាំ១៩៧៦មក ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៦ខ្លួនត្រូវបានចាត់តាំងឲ្យទៅធ្វើប្រធានកងចល័តនៅឃុំស្វារ ស្ថិតនៅក្នុងស្រុកកណ្តៀង ។

ឆ្លើយតបនឹងសំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងគោលនយោបាយ សិទ្ធិអំណាច របបរាយការណ៍ និងប្រព័ន្ធទំនាក់ទំនងនៅក្នុងឃុំ និងស្រុកវិញ សាក្សីបានរៀបរាប់ថា ឃុំស្វារស្ថិតនៅក្នុងតំបន់៧នៃភូមិភាគពាយ័ព្យ ហើយនៅទីនោះមានសហករណ៍ចំនួនប្រាំ ។ ប្រជាជនដែលនៅឃុំនោះ មានទាំងប្រជាជនថ្មី ឬប្រជាជន១៧មេសា និងប្រជាជនចាស់ ។ ប្រជាជននៅទីនោះ តម្រូវឲ្យធ្វើការងារជីកប្រឡាយ និងលើកភ្លឺស្រែជាដើម ។ ទាក់ទងនឹងការរាយការណ៍វិញ សាក្សីបានបញ្ជាក់ថា នៅពេលនោះ គាត់បានរាយការណ៍ទៅត្រឹមថ្នាក់ស្រុកប៉ុណ្ណោះ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានបន្តសួរពីសហការីរបស់ខ្លួន ទាក់ទងនឹងចំនួនយោធាខ្មែរក្រហមនៅក្នុងកងវរសេនាតូច និងអនុសេនាធំ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា កងអនុសេនាតូចនៅពេលនោះមានកងទ័ព៣០នាក់ កងអនុសេនាធំមានទ័ព១០០នាក់ ហើយខ្លួនមានតួនាទីជាប្រធានអនុសេនាតូចនៅឆ្នាំ១៩៧៥ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបានអានសេចក្តីថ្លែងការណ៍របស់សាក្សីដែលនិយាយរៀបរាប់អំពីផែនការសម្លាប់ទាហាន លន់ នល់ ដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំនៅសាលាខេត្តពោធិ៍សាត់ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះគាត់ពុំបានចូលរួមប្រជុំទេ ប៉ុន្តែបន្ទាប់ពីថ្នាក់លើបានទៅប្រជុំរួច គណៈបញ្ជាការរបស់ខ្លួនបានប្រាប់អំពីផែនការនោះខណៈពេលដែលខ្លួនកំពុងតែឈរជើងនៅស្រុកកណ្តៀង ។ តំណាងសហព្រះរាជអាជ្ញាបានសួរបន្តទាក់ទងនឹងសមាសភាពកងទ័ពដែលចូលរួមសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ សាក្សីបានបញ្ជាក់ថា កងទ័ពដែលសម្លាប់ទាហានទាំងនោះ ជាកងទ័ពដែលមកពីភូមិភាគពាយ័ព្យ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាចាក់បញ្ចាំងខ្សែវីដេអូរបស់លោក ថេត សម្បត្តិ ដែលមានចំណងជើងថា "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ" ដែលនៅក្នុងនោះ មានការរៀបរាប់របស់យោធាបីនាក់អំពីការដឹកជញ្ជូនទាហាន លន់ នល់ យកទៅសម្លាប់ដូចតទៅ ៖

...គេប្រាប់ទៅពីរថ្ងៃ គេប្រជុំប្រាប់ថា យើងក្រោកពីងងឹតម៉ោង៤ជួបជុំគ្នា ។ ឆាប់ក្រោកជួបជុំគ្នាឡើងឡានទៅវិពាមជ្រៃ អីចឹងណា! ។ ...ងើបទៅជុំគ្នាទាំងអស់គេឲ្យឡើងឡាន ជិះពីពោធិ៍-សាត់មកដល់ពាមជ្រៃ ភ្លឺស្រាងៗ ។

កាលនោះ តាប៉ិ ខ្លឹម គេឡើងប្រកាសមេក្រូ ។ ...តា ប៉ិ ខ្លឹម ហ្នឹងគេវរសេនាធំអង្គាលហ្នឹង ។ ...គេនិយាយប្រកាសយកទ័ពមកតម្រៀប ទាំងយើងផង ទាំងតំបន់ផង វាជាប់១៨ផង ១៩ផង វាចូល១០០០នាក់មកការពារ ហើយពួកខ្ញុំគេឲ្យរៀប គេប្រជុំហើយគេហៅកងការពារ គេហៅពួកខ្ញុំថា កងការពារ ។ ពួកកងការពារហ្នឹង បើសិនជាមានការធ្វេសប្រហែសហ្នឹង គេប្រាប់ត្រង់ថា បើសិនជាអ្នកកម្មេចរួច យើងអ្នកការពារធ្វើម៉េចកុំឲ្យរួច តែរួច វាបែកការ ខូចផែនការរបស់យើង ។ ស្រាប់ដល់ម៉ោង៧ ឮស្នូរឡានមក ។ ឡានធំមកមុន...ឮសូឡានអីចឹង គេប្រាប់ថា "កងពិសេសប្រុងប្រៀប!" ។ ថ្ងៃទី៣ហ្នឹងត្រូវដឹកមនុស្សចេញទៅ ទៅទួលពោធិ៍ជ្រៃហើយ ។ ប៉ុន្តែយើងដឹងស្ថានការណ៍ហើយថា យកទៅមិនមែនយកទៅធ្វើអីទេ ពីព្រោះយើងដឹងផែនការថា គេយកទៅ

កម្ទេចហើយ ព្រោះសុទ្ធតែអ្នកសំខាន់ៗ...។ ក្រោយពីបានជួបសម្តេចឪ ហើយមកកាន់ការងាររៀងៗខ្លួន ។ អាហ្នឹងគេនិយាយអីចឹង គេអត់មានព្រួយបារម្ភពីបញ្ហាថា យ៉ាងណាៗអីអត់ទេ ហើយគេនិយាយលេងធម្មតា លលេងគ្នា គេហ្នឹងៗ... ចៅហ្វាយខេត្តតីនុយ ស្លៀកសពាក់ស ពាក់មួកស្លឹកត្នោត ធ្វើរបៀបសាមញ្ញណាំ ។ ខ្មែរក្រហមស្លៀកពាក់ ខោអាវខ្មៅ បង់កន្សែងនៅលើក ។ អីចឹងគេអាររបៀបកសិករដែរ ។...លេងសើចធម្មតាទៅនៅក្នុងឡានហ្នឹងបង្កើតបរិយាកាសរីករាយ ដូចអត់មានអីគេហៅថា នៅខាងមុខនឹងមានវិបត្តិយ៉ាងម៉េចៗអត់ដឹងទេ ។

ចុះពីលើឡានគេភ្លុងមក គេប្រកាស ។ គ្រាន់តែឡានឈប់មក គេប្រកាសតាមមេក្រូថា ឲ្យសមមិត្តយើងកុំភិតកុំភ័យអី ប្រាប់ទាហានហ្នឹងណា៎ះ ។ ទៅជួបអគ្គការ អគ្គការយើងអត់ទុកចិត្តទេ ព្រោះអីយើងនៅជាប់សមាសភាព ទៅជួបសម្តេច គេថាអីចឹងណា៎ះ! ទាល់តែចង ។ ឡានមួយៗចងអស់ បណ្តើរទៅ ចងអស់មួយឡាន បណ្តើរទៅ ។

បន្ទាប់ពីបញ្ចប់ការដាក់បង្ហាញនេះ តំណាងសហព្រះរាជអាជ្ញាបានសួរពីអត្តសញ្ញាណរបស់កងទ័ពទាំងបីនាក់នោះ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនពុំស្គាល់អ្នកទាំងនោះទេ ព្រោះកងទ័ពទាំងនោះនៅក្នុងវរៈផ្សេងពីខ្លួន ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីជាតិ គឹម ម៉េងឃី បានសួរទាក់ទងនឹងឈ្មោះសហករណ៍ទាំង៥ ដែលសាក្សីបានគ្រប់គ្រង ប៉ុន្តែសាក្សីបានបញ្ជាក់ថា គាត់គ្រប់គ្រងតែមួយសហករណ៍ទេ ដែលនៅក្នុងនោះមានភូមិច្រើនដូចជា ភូមិស្បារ ភូមិព្រៃដក្តិ ភូមិកញ្ជរ ភូមិផ្ទះយួន ភូមិចារឹក ភូមិធ្នូក និងភូមិក្បាលឈើពុក ។ បន្ទាប់មកមេធាវីជាតិបានសួរទាក់ទងនឹងការគ្រប់គ្រងរវាងប្រជាជនចាស់ និងប្រជាជនថ្មីនៅសហករណ៍ស្បារ ។ សាក្សីបានរៀបរាប់ថា នៅទីនោះទោះបីជាមានប្រជាជន១៧ និង១៨មេសាក៏ដោយ ប៉ុន្តែការរស់នៅដូចគ្នាទាំងអស់ ដោយពុំមានការរើសអើងអ្វីឡើយ ។ ម្យ៉ាងទៀតការគ្រប់គ្រងនៅទីនោះ ខ្លួនបានទទួលបញ្ជាតែពីថ្នាក់លើប៉ុណ្ណោះ ។ សាក្សីបានបន្តថា នៅឆ្នាំ១៩៧៩ មានការចាប់បញ្ជូនប្រជាជនមកពីខេត្តស្វាយរៀងឲ្យទៅនៅក្នុងសហករណ៍របស់ខ្លួន ។ ប្រជាជនទាំងនោះស្លៀកពាក់ដូចប្រជាជនផ្សេងទៀតដែរ ប៉ុន្តែខុសគ្នាត្រង់ក្រមារ ដោយសារតែប្រជាជននៅស្វាយរៀងតម្រូវឲ្យបង់កក្រមារពណ៌ខៀវ ចំណែកការនិយាយក៏មានភាពខុសគ្នាបន្តិចបន្តួចដែរ ។ ចំពោះការងារវិញ ត្រូវបែងចែកដូចប្រជាជនដែលរស់នៅទីនោះស្រាប់ដែរ ។

បន្ទាប់មក សហមេធាវីអន្តរជាតិ ប៉ែននី យេ បានបន្តសំណួរពីសហភាគារបស់ខ្លួនទាក់ទងនឹងក្រុមគ្រួសាររបស់ទាហាន និងមន្ត្រីរាជការ លន់ នល់ ដែលត្រូវបញ្ជូនទៅសម្លាប់នៅទួលពោធិ៍-ជ្រៃ ។ សាក្សីបានបញ្ជាក់ថា គាត់ពុំបានដឹងអំពីហេតុការណ៍ផ្សេងៗ ដែលកើតឡើងចំពោះគ្រួសារទាហានទាំងនោះទេ ប៉ុន្តែ



កងអាវុធហត្ថរបស់ លន់ នល់ ក្នុងអំឡុងពេលសមយុទ្ធនៅទីក្រុងភ្នំពេញ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

គ្រាន់តែដឹងថា គ្រួសាររបស់ទាហានទាំងនោះបានទទួលដំណឹងពីការស្លាប់នោះប្រហែល ៤ថ្ងៃក្រោយមកតែប៉ុណ្ណោះ ។ សហមេធាវីអន្តរជាតិបានសួរបន្តទាក់ទងនឹងមន្ទីរសន្តិសុខថ្កូល ។ សាក្សីបានរៀបរាប់ថា មន្ទីរសន្តិសុខនោះត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៧៦ សម្រាប់ដាក់អ្នកទោសគ្រប់ប្រភេទ ដោយពុំមានការបែងចែកប្រជាជនចាស់ថ្មី ឬកម្រិតទោសធ្ងន់ស្រាលនោះទេ ។ ទាក់ទងនឹងសំណួរនេះ សហមេធាវីអន្តរជាតិ អង់តា ហ្គីសសេ បានជំទាស់នឹងការតាំងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ដោយអះអាងថា សំណួរនេះចាកឆ្ងាយពីអង្គហេតុដែលត្រូវពិភាក្សា ពីព្រោះអង្គហេតុនេះ និយាយអំពីការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ ។ ឆ្លើយតបនឹងការជំទាស់នេះ អង្គជំនុំជម្រះបានយល់ស្រប និងបង្គាប់ឲ្យមេធាវីសួរសំណួរណាដែលពាក់ព័ន្ធនឹងអង្គហេតុនៅដំណាក់កាលនេះ ។ សំណួរចុងក្រោយរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ផ្តោតទៅលើជោគវាសនារបស់ប្រជាជនដែលត្រូវជម្លៀសពីទីក្រុងភ្នំពេញ ។ សាក្សីបានបញ្ជាក់ថា ប្រជាជនទាំងនោះមិនត្រូវបានខ្មែរក្រហមសម្លាប់ទេ ដោយគ្រាន់តែរស់នៅ និងធ្វើការជាមួយប្រជាជនចាស់ដែរ ។

## ៤) ការសួរដេញដោលដោយមេធាវីការពារក្តីទាំងពីរក្រុម

### ក) សហមេធាវីការពារក្តី នួន ជា

ជាដំបូង សហមេធាវីជាតិ សុន អរុណ បានចាប់ផ្តើមសួរដោយឲ្យសាក្សីបញ្ជាក់ឡើងវិញអំពីឆ្នាំកំណើតរបស់គាត់ដែលបានឆ្លើយផ្ទុយគ្នាពីរដងក្នុងពេលសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ។ សាក្សីបានបញ្ជាក់ថា ខ្លួនកើតនៅឆ្នាំ១៩៥៥ ។ បន្ទាប់មក មេធាវីបានបន្តសួរឲ្យសាក្សីបញ្ជាក់ឡើងវិញអំពីតួនាទីរបស់សាក្សីនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីក៏បានសួរបញ្ជាក់ឡើងវិញទាក់ទងនឹងចំនួនទាហានលន់នល់ដែលត្រូវបានយកទៅសម្លាប់ ។ សាក្សីបានបញ្ជាក់ថា ចំនួនទាហាននៅពេលនោះ មានប្រហែលជាពាន់នាក់ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវីទាក់ទងនឹងការចាប់ខ្លួនយោធាខ្មែរក្រហមនៅភូមិភាគពាយ័ព្យមកដាក់នៅមន្ទីរសន្តិសុខទួលស្លែងវិញ សាក្សីបានបញ្ជាក់ថា ខ្លួនបានទទួលដំណឹងនេះនៅឆ្នាំ១៩៧៧ ដែលមាន នួន ជា ជាអ្នកបញ្ជាឲ្យសម្លាប់យោធាទាំងនោះ ។ បន្ទាប់មក មេធាវីការពារក្តីបានសួរឲ្យសាក្សីបញ្ជាក់អំពីព័ត៌មានរបស់ នួន ជា ខណៈពេលដែលសាក្សីបានឃើញ នួន ជា ចុះទៅបង្រៀននៅខេត្តបាត់ដំបង ។ សាក្សីបានបញ្ជាក់ថា គាត់បានឃើញ នួន ជា ដំបូងនៅពេលដែល នួន ជា កំពុងធ្វើដំណើរទៅខេត្តបាត់ដំបង ហើយនៅពេលនោះមានកងទ័ពផ្សេងទៀតដែលស្គាល់ នួន ជា បានប្រាប់ខ្លួនតែប៉ុណ្ណោះ ។ សំណួរចុងក្រោយរបស់មេធាវីទាក់ទងសំខាន់នឹងរចនាសម្ព័ន្ធយោធា ហើយសាក្សីបានពន្យល់ថា ជាទូទៅក្នុងមួយកងពលមានបីវរសេនាធំ, មួយកងវរសេនាធំមានបីវរសេនាតូច, មួយវរសេនាតូចមានបីអនុសេនាធំ, មួយអនុសេនាធំមានបីអនុសេនាតូច, មួយអនុសេនាតូចមានបីក្រុម ហើយមួយក្រុមមានទ័ព១២នាក់ ។

សហមេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានបន្តការសួរដេញដោលបន្ទាប់ពីសហភាគីរបស់ខ្លួន ដោយស្នើសុំឲ្យសាក្សីបញ្ជាក់ពីអាយុរបស់គាត់ឡើងវិញ ។ សាក្សី លឹម សាត បានបញ្ជាក់សាជាថ្មីថា ខ្លួនកើតនៅឆ្នាំ១៩៥៥ ហើយបានចូលរួមក្នុងចលនាបដិវត្តន៍នៅពេលខ្លួនមានអាយុ២២ឆ្នាំ ។ ទាក់ទងនឹងចំនួនទាហាន និងនគបាលដែលត្រូវបានបញ្ជូនទៅសម្លាប់នោះ សាក្សីបានបញ្ជាក់ថា ខ្លួនពុំបានដឹងពីចំនួនច្បាស់លាស់ទេ ពីព្រោះពេលនោះ ខ្លួនជាអ្នកយាមឡានតែប៉ុណ្ណោះ ។ ទាក់ទងនឹងការប្រយុទ្ធនៅក្នុងរបប លន់ នល់ វិញ សាក្សីបានបញ្ជាក់ថា ចាប់ពីឆ្នាំ១៩៧១ដល់១៩៧៣ មានការប្រកាសឲ្យកងទ័ពបើកការប្រយុទ្ធរហូតដល់ឆ្នាំ១៩៧៣ ទើបមានការវាយប្រយុទ្ធកាន់តែខ្លាំងបន្តទៅដល់ឆ្នាំ១៩៧៥ ។ នៅពេលនោះ ខ្លួនមានតួនាទីជាកងទ័ពនៅតំបន់ពោធិ៍សាត់ ដូច្នេះខ្លួន និងកងទ័ពដ៏ទៃទៀតបានចូលរួមប្រយុទ្ធជាមួយទាហាន លន់ នល់ ដែរ ។ នៅពេលនោះ ទាហាន លន់ នល់ ឈរជើងក្នុងខេត្តពោធិ៍សាត់រាប់ម៉ឺននាក់រួមទាំងទាហានមកពីតាមស្រុក និងតាមព្រំដែនផង ។

សហមេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងព្រឹត្តិការណ៍នៃការប្រយុទ្ធគ្នារវាងខ្មែរក្រហម និង ទាហាន លន់ នល់ នៅទួល-ពោធិ៍ជ្រៃ ។ ពាក់ព័ន្ធនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ទួល-ពោធិ៍ជ្រៃជាតំបន់ចុងក្រោយដែលខ្លួនបានប្រយុទ្ធនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមបានរំដោះភ្នំពេញបានប្រហែលមួយម៉ោងតែប៉ុណ្ណោះ ។ នៅពេលនោះ គ្រប់បន្ទាយរបស់ លន់ នល់ បានលើកទង់ជ័យសដើម្បីជាសញ្ញាសុំចុះចាញ់ ហើយទាហាននៅទួលពោធិ៍ជ្រៃមានចំនួនប្រហែល១០០នាក់ រួមទាំងកងកម្លាំងផ្សេងៗទៀត ។ សាក្សីបានបញ្ជាក់បន្ថែមថា ទាហានទាំងនោះស្លៀកពាក់ជាឯកសណ្ឋាន ចំណែកកងកម្លាំងផ្សេងស្លៀកពាក់ជាស៊ីវិល ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជំនះមក ទាហាន លន់ នល់ បានរស់នៅជាមួយខ្មែរក្រហម ប៉ុន្តែនៅតែមានការបែងចែកទៅតាមក្រុមដដែល ។ ក្រោយមក សាក្សីបានទទួល

បញ្ជាពីបញ្ជាការវរៈ ដើម្បីរៀបចំដឹកជញ្ជូនទាហានទាំងនោះយកទៅរៀនសូត្រ បន្ទាប់ពីថ្នាក់លើបានប្រជុំរៀបចំផែនការនៅសាលាខេត្តពោធិ៍សាត់រួចមក ។ សាក្សីបានបន្តថា ទាហានទាំងនោះមានគ្នាប្រហែលជាង១០ឡានដែលក្នុងមួយឡានមានចំនួនពី៣០ទៅ៤០នាក់ និងស្លៀកឯកសណ្ឋានទាហានទាំងអស់ ។ នៅពេលទៅដល់ទួលពោធិ៍ជ្រៃ ទាហានទាំងនោះត្រូវបានចាប់ចង និងបាញ់សម្លាប់ ។ បន្ទាប់មក ខ្មែរក្រហមបានប្រមូលយកវ៉ាលី និងសម្ភារៈរបស់ទាហានទាំងនោះមកទុក លើកលែងតែឯកសណ្ឋានតែប៉ុណ្ណោះ ។ ជាថ្មីម្តងទៀត មេធាវីបានសួរឲ្យសាក្សីបញ្ជាក់អំពីចំនួនឡានដែលដឹកជញ្ជូនទាហានទៅទួលពោធិ៍ជ្រៃ ប៉ុន្តែសំណួរនេះត្រូវបានជំទាស់ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ ដោយហេតុថា សំណួរដែលលើកឡើងនេះ ជាសំណួរច្រំដែល ។ អង្គជំនុំជម្រះបានគាំទ្រចំពោះសេចក្តីជំទាស់នេះ ព្រមទាំងបង្គាប់មិនឲ្យសាក្សីឆ្លើយសំណួរនេះទេ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវីការពារក្តីទាក់ទងនឹងទាហាន លន់ នល់ ដែលត្រូវយកទៅសម្លាប់នោះ សាក្សីបានបញ្ជាក់ថា ទាហានទាំងនោះសុទ្ធតែជាទាហានដែលប្រមូលមកពីបន្ទាយផ្សេងៗនៅក្នុងខេត្តពោធិ៍សាត់ដូចជា បន្ទាយនៅស្រុកក្រគរជាដើម ។

មេធាវីអន្តរជាតិ វ៉ិចទ័រ កុបប៉េ បានបន្តសំណួរទាក់ទងនឹងពេលដែលសាក្សីបានជួបជាមួយ នួន ជា ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានជួប នួនជា ពីរដង ។ លើកទី១ នៅពេលគាត់បានទៅចូលរួមប្រជុំក្នុងឆ្នាំ១៩៧៦ ហើយលើកទីពីរនៅពេលដែល នួន ជា ធ្វើដំណើរកាត់ខេត្តពោធិ៍សាត់នៅក្នុងឆ្នាំ១៩៧៩ ។ សាក្សីបានបន្តថា ការប្រជុំនៅពេលនោះ មានការចូលរួមពីប្រជាជនដែលនៅតាមសហករណ៍ផ្សេងៗជាច្រើននាក់ ហើយខ្លឹមសារក្នុងពេលប្រជុំផ្តោតទៅលើការធ្វើការងារបង្កបង្កើនផល ។ ទោះជាយ៉ាងណាក៏ពុំមានប្រជាជនណាហ៊ានតវ៉ាក្នុងពេលប្រជុំឡើយ ។ សំណួរបន្ទាប់របស់មេធាវីទាក់ទងនឹងតួនាទីរបស់ នួន ជា នៅក្នុងឆ្នាំ១៩៧៦ ។ សាក្សីបានបញ្ជាក់ថា ខ្លួនពុំបានដឹងពីតួនាទីរបស់ នួនជា ទេ ហើយនៅឆ្នាំដដែលនោះ ខ្លួនក៏ពុំដែលឃើញ នួន ជា ចូលរួមប្រជុំនៅក្នុងខេត្តពោធិ៍សាត់ដែរ ។ សូមបញ្ជាក់ថា សំណួរចុងក្រោយ ដែលសាក្សីបានឆ្លើយនេះ សាក្សីហាក់បីដូចជាមានការភាន់ច្រឡំ ព្រោះសាក្សីធ្លាប់បានឆ្លើយនឹងសំណួររបស់សហព្រះរាជអាជ្ញាថា ខ្លួនពិតជាបានចូលរួមប្រជុំជាមួយ នួន ជា នៅឆ្នាំ១៩៧៦ នៅក្នុងបរិវេណនៃសាលារៀនស្វាយលុងដែលស្ថិតនៅក្នុងស្រុកកណ្តៀង ។

### ១) សហមេធាវីការពារក្តី ខៀវ សំផន

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់មេធាវីការពារក្តី នួន ជា មេធាវីជាតិការពារក្តី ខៀវ សំផន បានបន្តសួរដេញដោលសាក្សី ។ សហមេធាវីជាតិ គង់ សំអុន បានផ្តើមសំណួរទាក់ទងនឹងចម្លើយរបស់សាក្សីដែលថា ខៀវ សំផន ជាអ្នកបញ្ជាទ័ពនៅចន្លោះឆ្នាំ១៩៧១-១៩៧៥ ។ សាក្សីបញ្ជាក់ថា នៅពេលនោះ ខៀវ សំផន ជាអ្នកទទួលខុសត្រូវ និងរៀបចំផែនការទ័ពពិតមែន ប៉ុន្តែខ្លួនពុំបានដឹងពីតួនាទីរបស់ ខៀវ សំផន ច្បាស់លាស់ទេ ។ ទាក់ទងនឹងតួនាទីរបស់ខ្លួននៅឆ្នាំ១៩៧៥វិញ សាក្សីបានបញ្ជាក់ថា ខ្លួនជាប្រធានកងអនុសេនាតូចដែលគ្រប់គ្រងកងទ័ព៣០នាក់ ហើយថ្នាក់លើរបស់ខ្លួន គឺអនុសេនាធំ ។ បន្ទាប់មក មេធាវីបានសួរឲ្យសាក្សីរៀបរាប់ឡើងវិញអំពីរចនាសម្ព័ន្ធយោធាចាប់ពីថ្នាក់អនុសេនាតូចរហូតដល់ថ្នាក់កងពលដូចដែលខ្លួនបានបញ្ជាក់ជូនមេធាវីការពារក្តី នួន ជា ។ សាក្សីបញ្ជាក់បានបន្ថែមថា នៅឆ្នាំ១៩៧១ មេបញ្ជាការរបស់ខ្លួនបានប្រាប់ថា ខៀវ សំផន ជាមេបញ្ជាការកងពលខណៈពេលដែលមានកិច្ចប្រជុំឲ្យកងទ័ពរៀបចំស្បៀងដើម្បីទៅប្រយុទ្ធជាមួយខ្មាំង ។

បន្ទាប់មក សហមេធាវីអន្តរជាតិ អង់តា ហ្គីសសេ បានបន្តពីរសំណួរចុងក្រោយដែលទាក់ទងនឹងរចនាសម្ព័នរដ្ឋបាល និងការគ្រប់គ្រងស្បៀងនៅក្នុងសហករណ៍ដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សីបានបញ្ជាក់ថា នៅក្នុងរបបនោះមានការបែងចែកជា គណៈភូមិភាគ គណៈតំបន់ គណៈស្រុក គណៈឃុំ និងសហករណ៍ ដែលជាថ្នាក់ទាបជាងគេ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានពន្យល់ថា ចំពោះស្បៀងមានការបែងចែកទៅតាមការដ្ឋានដែលនៅក្នុងនោះសហករណ៍មួយមានការដ្ឋានច្រើនផ្សេងៗគ្នា ហើយការដ្ឋានទាំងអស់ ត្រូវទៅបើកស្បៀងពីខាងពាណិជ្ជ ដែលជាអ្នកទទួលខុសត្រូវខាងដឹកជញ្ជូនអង្ករ និងស្បៀងផ្សេងៗទៀតសម្រាប់ផ្គត់ផ្គង់តាមសហករណ៍ និងអង្គភាពផ្សេងៗ ។

# សវនាការស្ដាប់សក្ខីកម្មសាក្សីជំនាញ ហ្វីលីព ស្យត

## ថ្ងៃទី៦-៩ ខែឧសភា ឆ្នាំ២០១៣

នៅព្រឹកថ្ងៃទី៦ ដល់ទី៩ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការដើម្បីស្ដាប់សក្ខីកម្មសាក្សីជំនាញឈ្មោះ ហ្វីលីព ស្យត ។ សវនាការស្ដាប់សក្ខីកម្មសាក្សីជំនាញរូបនេះ បានធ្វើឡើងបន្ទាប់ពីការបញ្ចប់សក្ខីកម្មសាក្សី លឹម សាត ។ នៅក្នុងសវនាការរយៈពេលបួនថ្ងៃនេះ អង្គជំនុំជម្រះបានធ្វើការបែងចែកពេលវេលាដើម្បីផ្ដល់ឱកាសដល់ភាគីទាំងអស់ ក្នុងការសួរដេញដោលសាក្សី ដោយផ្ដល់រយៈពេលរួមគ្នាជូនអង្គជំនុំជម្រះចំនួនមួយថ្ងៃ ភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីរយៈពេលមួយថ្ងៃកន្លះ និងមេធាវីការពារក្ដី នួន ជា និង ខៀវ សំផន ចំនួនមួយថ្ងៃកន្លះរួមគ្នាដែរ ។ នៅក្នុងការសួរដេញដោលសាក្សី បានផ្ដោតសំខាន់លើអត្ថន័យ នៅក្នុងសៀវភៅដែលមានចំណងជើងជាភាសាអង់គ្លេស “Pol Pot: Anatomy of a Nightmare” ឬជាភាសាខ្មែរ “ប៉ុល ពត ៖ ប្រវត្តិសុបិន្តអាក្រក់នៃប្រទេសកម្ពុជា” ដែលនិពន្ធដោយសាក្សីផ្ទាល់ ការយល់ឃើញរបស់សាក្សីចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ព្រឹត្តការណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការយល់ដឹងរបស់សាក្សី ចំពោះឥរិយាបថរបស់ជនជាប់ចោទ ក៏ដូចជាតួនាទី និងការទទួលខុសត្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

### ១) ប្រវត្តិសាវតាររបស់សាក្សីជំនាញ

សាក្សី ហ្វីលីព ស្យត មានអាយុ៦៨ឆ្នាំ មានសញ្ជាតិអង់គ្លេស សព្វថ្ងៃសាក្សីរស់នៅប្រទេសបារាំង ។ លោក ហ្វីលីព ស្យត បច្ចុប្បន្នជាអ្នកនិពន្ធប្រវត្តិសាស្ត្រ និងប្រវត្តិរូបបុគ្គលផ្សេងៗ ។ ប្រវត្តិសិក្សារបស់សាក្សីធ្លាប់សិក្សានៅប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិក ផ្នែកធម្មជាតិវិទ្យា និងអក្សរសាស្ត្រអង់គ្លេស ។ សាក្សីធ្លាប់បម្រើការងារជាអ្នកសារព័ត៌មានជូនបណ្ដាញផ្សព្វផ្សាយរបស់ចក្រភពអង់គ្លេស ប៊ីប៊ីស៊ី (BBC) និងធ្វើជាអ្នកឆ្លើយឆ្លងព័ត៌មានបរទេសប្រចាំទីក្រុងមួយចំនួន ដូចជាទីក្រុងមូស្គូ ទីក្រុងប៉េកាំង ទីក្រុងប៉ារីស ទីក្រុងតូក្យូ និងទីក្រុងវ៉ាស៊ីនតោន ។ ទន្ទឹមគ្នានោះដែរ សាក្សីក៏មានអាជីពជាអ្នកសរសេរប្រវត្តិសាស្ត្រ និងប្រវត្តិរូបរបស់អ្នកនយោបាយ និងអ្នកប្រាជ្ញជាដើមចាប់តាំងពីឆ្នាំ១៩៦៨ គឺប្រហែល៤០-៤៥ឆ្នាំមកហើយ ។ បន្ទាប់ពីចូលនិវត្តន៍ពីការងារសាក្សីបានចំណាយពេល ១ឆ្នាំ ដើម្បីបង្រៀនមុខវិជ្ជាប្រៀបធៀបនយោបាយនៅសាកលវិទ្យាល័យអាយអូវ៉ា ក្នុងអំឡុងឆ្នាំ១៩៩៧-១៩៩៨ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា មូលហេតុដែលខ្លួនមានចំណាប់



ហ្វីលីព ស្យត
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

អារម្មណ៍សរសេរប្រវត្តិរូបមេដឹកនាំខ្មែរក្រហម ដោយសារខ្លួនបានធ្វើជាអ្នករាយការណ៍ព័ត៌មាននៅទីក្រុងប៉េកាំង ក្នុងអំឡុងឆ្នាំ ១៩៧០ ។ នៅពេលនោះ សាក្សីបានស្គាល់អ្នកការទូតនៃរបបកម្ពុជាប្រជាធិតេយ្យ លោក ពេជ ឈាង ហើយបន្ទាប់មកខ្លួនបានចាប់អារម្មណ៍ ចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ នៅខែកញ្ញា ឆ្នាំ ១៩៧៧ ប៉ុល ពត, អៀង សារី, វន វ៉េត, និង ជួន ជឿន បានទៅទស្សនកិច្ចនៅទីក្រុងប៉េកាំង ។ សាក្សីបានចាប់ផ្ដើមសរសេរប្រវត្តិរបស់ ប៉ុល ពត ក្រោយពេល

សរសេរជីវប្រវត្តិរបស់ម៉ៅ (មេដឹកនាំកុម្មុយនីស្តចិន) ហើយសាក្សីពុំបានទទួលទិដ្ឋាការឲ្យចូលក្នុងប្រទេសកម្ពុជានោះទេ នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបន្ថែមថា ចំពោះការសរសេរជីវប្រវត្តិរបស់មេដឹកនាំ ប៉ុល ពត ត្រូវចំណាយពេលប្រហែល៥-៦ឆ្នាំ ដើម្បីធ្វើការស្រាវជ្រាវប្រវត្តិរបស់ ប៉ុល ពត នៅក្នុងសៀវភៅដែលមានចំណងជើងថា "ប្រវត្តិសុបិន្តអាក្រក់" បោះពុម្ពនៅឆ្នាំ២០០៤ នៅចក្រភពអង់គ្លេស ។

**២) ការសួរដេញដោលដោយអង្គជំនុំជម្រះ**

លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ និងលោកចៅក្រម ហ្សង់ម៉ាក ឡាវែ៉ញ បានធ្វើការតាំងសំណួរមួយចំនួនទៅសាក្សី ជំនាញ ហ្វីលីព ស្សុត ។ ចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បានចាប់ផ្តើមសំណួរដោយការបញ្ជាក់ពីលទ្ធភាព ដែលសាក្សីធ្លាប់បានជួបសម្ភាសន៍ផ្ទាល់ជាមួយ ប៉ុល ពត នៅទីក្រុងប៉េកាំង នៅឆ្នាំ១៩៧៧ ។ សាក្សីបានឆ្លើយតបថា ខ្លួនធ្លាប់ជួបសម្ភាសន៍ដោយផ្ទាល់ជាមួយ ប៉ុល ពត, អៀង សារី និង ខៀវ សំផន ប៉ុន្តែពុំធ្លាប់សម្ភាសន៍ នួន ជា ទេ ។ ការជួបសម្ភាសន៍ជាមួយ ខៀវ សំផន បានឆ្លងកាត់ការបញ្ជូនពាក្យស្នើសុំទៅ ខៀវ សំផន ចំនួន ៦ដង នៅប៉ៃលិន ។

ចៅក្រមបានសួរដេញដោលសាក្សី ទាក់ទងនឹងស្ថានភាពក្នុងទីក្រុងភ្នំពេញនៅអំឡុងពេលមុនឆ្នាំ១៩៧៥ ។ សាក្សីថា ចំនួនប្រជាជននៅភ្នំពេញ មានការកើនឡើងខុសពីធម្មតា ដោយមូលហេតុការទម្លាក់គ្រាប់បែក នៅតាមទីជនបទ និងហេតុផលសង្គ្រាម ។ សាក្សីបានរំឭកទៀតថា នៅដើមឆ្នាំ១៩៧៥ ហ៊ូ យន់ បាននិយាយនៅក្នុងការផ្សព្វផ្សាយមួយស្តីពីការអំពាវនាវឲ្យប្រជាជនធ្វើការសម្រេចចិត្តក្នុងការចូលរួមបដិវត្ត ឬក៏ជ្រើសរើសចូលរួមជាមួយរបប លន់ នល់ ដោយការរស់នៅក្នុងទីក្រុងភ្នំពេញបន្តទៀត ។ សាក្សីបន្តថា ដូច្នេះហើយទើបក្រោយមកនៅក្នុងដំណាក់កាលរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនថ្មីត្រូវគេប្រព្រឹត្តផ្សេងពីប្រជាជននៅតាមមូលដ្ឋាន ព្រោះតែអ្នកទាំងនោះជ្រើសរើសយក លន់ នល់ ដោយពុំព្រមចាកចេញពីទីក្រុងភ្នំពេញរហូតដល់ថ្ងៃខ្មែរក្រហមធ្វើការជម្លៀស ។

**ការពិភាក្សាលើអត្ថបទដកស្រង់ចេញពីសៀវភៅដែលនិពន្ធដោយសាក្សី**

សាក្សីបានបញ្ជាក់ថា ប្រភពឯកសារដែលខ្លួនប្រើប្រាស់ដើម្បីចងក្រងជាសៀវភៅ ស្តីអំពីជីវប្រវត្តិរបស់ ប៉ុល ពត កើតឡើងពីការសន្ទ្រាព័ត៌មានដូចជាគ្រាប់ល្ង ដែលទទួលពីបុគ្គលផ្សេងៗគ្នាដូចជា ភ្នាក់ងារអាមេរិក អតីតកម្មាភិបាលខ្មែរក្រហម ជនជាប់ចោទ ខៀវ សំផន និង អៀង សារី និងមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម ។ ឆ្លើយតបនឹងការដកស្រង់អត្ថបទ សាក្សីបានផ្តល់នូវមតិយោបល់ខ្លះៗ ទាក់ទងនឹងការណែនាំរបស់ខ្មែរក្រហមដើម្បីឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ ក្នុងពេលជម្លៀសនោះថា ខ្មែរក្រហម ផ្ទាល់យល់ថា តាមពិតពុំមានការទម្លាក់គ្រាប់បែកនោះទេ ខ្មែរក្រហមលើកឡើងអំពីការទម្លាក់គ្រាប់បែក ដោយការឲ្យប្រជាជនចាកចេញពីលំនៅដ្ឋានរបស់ខ្លួនក្នុងរយៈពេលពីរឬបីថ្ងៃក្នុងគោលបំណងបញ្ចុះបញ្ចូលប្រជាជនឲ្យយល់ព្រមចាកចេញដោយពុំមានយករបស់របរជាប់ខ្លួនច្រើនតែប៉ុណ្ណោះ ។ ចៅក្រមបានបន្តសំណួរចំពោះសាក្សីស្តីពីការយល់ដឹងរបស់ ខៀវ សំផន ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ សាក្សីបានឆ្លើយតបថា ខៀវ សំផន បានរៀបរាប់ពីភាពស៊ីសង្វាក់គ្នានៃព្រឹត្តិការណ៍ទាំងឡាយ និងអត្ថន័យ ដែលមាននៅក្នុងសៀវភៅរបស់ ខៀវ សំផន ផ្ទាល់ ដែលថា ខៀវ សំផន ពុំបានចូលរួមនៅក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទេ ។ ចៅក្រមបានអាននូវអ្វីដែល ខៀវ សំផន បានលើកឡើង ទាក់ទងនឹងមូលហេតុនៃការជម្លៀសដោយសារការគ្រប់គ្រង ការបះបោរ និងទុរ្ភិក្ស ប៉ុន្តែសាក្សី ហ្វីលីព ស្សុត ថា ការលើកពីហេតុផលបះបោរនោះគ្រាន់តែជាលេសប៉ុណ្ណោះ ។

ចៅក្រមអន្តរជាតិ ស៊ីលវៀ ខាតវ៉្រាយត៍ បានដកស្រង់អត្ថន័យនៅក្នុងសៀវភៅរបស់សាក្សីថា "គោលបំណងនៃការជម្លៀស គឺពុំមែនដើម្បីកម្ទេចទេ ប៉ុន្តែដើម្បីបំប្លែង ។ ប៉ុល ពត បាននិយាយពេលក្រោយថា ការជម្លៀស គឺជាវិធានការពិសេសដែលយើងពុំបានឃើញនៅក្នុងកុម្មុយនីស្តផ្សេងទៀតទេ ។ នេះគឺជាយុទ្ធសាស្ត្ររបស់សេដ្ឋកិច្ច យុទ្ធសាស្ត្ររបស់បក្ស ដើម្បីធ្វើការងារនេះ ហើយសម្រេចនៅក្នុងកិច្ច ប្រជុំគណៈអចិន្ត្រៃយ៍ធ្វើនៅស្ថានីយរថភ្លើង ព្រមទាំងកិច្ចប្រជុំផ្សេងទៀត" ។ សាក្សីបាន

ផ្តល់យោបល់នៅក្នុងការដកស្រង់នេះថានៅពេលដែលខ្លួនសរសេរសៀវភៅនៅក្នុងផ្នែកនេះ សាក្សីគិតថា ជាការចាំបាច់ក្នុងការបញ្ជាក់ឲ្យច្បាស់អំពីគោលដៅរបស់ខ្មែរក្រហម ដែលពុំមានគំនិតបំផ្លាញប្រជាជនទាំងមូល ប៉ុន្តែ ក្នុងគោលបំណងផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជន ។ សាក្សីបន្ថែមថា ប៉ុល ពត មានមោទនភាពចំពោះបក្សកុម្មុយនីស្តកម្ពុជា ដែលបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយសកម្មភាពនេះបក្សកុម្មុយនីស្ត នៅប្រទេសផ្សេងពុំបានធ្វើដូចកម្ពុជាឡើយ ។ ទាក់ទងនឹងចំណុចដែលថា បុគ្គលដែលត្រូវជម្លៀសខ្លួន ត្រូវមានភារកិច្ចរាយការណ៍អំពីប្រវត្តិរូបរបស់ខ្លួន សាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះថា នេះគឺជាបច្ចេកទេសរបស់ខ្មែរក្រហម ដែលបានរៀនសូត្រពីបក្សកុម្មុយនីស្តវៀតណាម និងបក្សកុម្មុយនីស្តចិន ។ គោលបំណងដំបូងខ្មែរក្រហមចង់ដឹងពីប្រវត្តិរូបអ្នកដែលចាកចេញពីទីក្រុងភ្នំពេញ ។ ប្រជាជនដែលត្រូវគេនាំខ្លួនទៅពុំឃើញត្រឡប់មកវិញ សន្មតថាត្រូវគេយកទៅសម្លាប់ចោល ។ ការសន្មតនេះឆ្លុះបញ្ចាំងពីការយល់ឃើញរបស់ប្រជាជនចំពោះគោលនយោបាយរបបខ្មែរក្រហមមកលើពួកគាត់ ។ កម្មករជំនាញត្រូវបានគេបញ្ជូនមកទីក្រុងភ្នំពេញ ដើម្បីធ្វើការនៅក្នុងរោងចក្រផ្សេងៗ អ្នកខ្លះបញ្ជូនទៅធ្វើជាកម្មកររថភ្លើង និងនៅតាមកំពង់ផែ ជាដើម ។ សាក្សីថាការកាប់សម្លាប់ធ្វើឡើងមិនដូចគ្នាទេ អាស្រ័យទៅលើកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមបន្តបន្ទាប់ ។ ដូច្នេះហើយទើបមន្ត្រីរាជការឬក្រុមព្រះរាជវង្សានុវង្សខ្លះនៅរស់រានមានជីវិត ។ សាក្សីបានបន្តថា ជាទូទៅយើងអាចនិយាយបានថា ប្រសិនបើប្រវត្តិរូបនោះមិនអាចយោគយល់ ឬអនុគ្រោះបានទេ ត្រូវតែសម្លាប់ចោលតែម្តង ។ ចៅក្រមបានបន្តសំណួរទាក់ទងនឹងការសម្លាប់កងទ័ព លន់ នល់ ក៏ដូចជាមន្ត្រីរដ្ឋការនៅទួលពោធិ៍ជ្រៃ ។ សាក្សីឆ្លើយថា ចំពោះមន្ត្រីយោធាជាន់ខ្ពស់ លន់ នល់ ត្រូវគេសម្លាប់ចោលនៅទីកន្លែងផ្សេងៗ នៅក្នុងដំណាក់កាលមួយនៃពេលជម្លៀសប្រជាជនសម្លាប់នៅភ្នំពេញ និងខ្លះសម្លាប់នៅ ដំណាក់កាលក្រោយតាមដងផ្លូវពេលធ្វើដំណើរ ។ ចំណែកប្រជាជនមួយក្រុមទៀតដូចជាវេជ្ជបណ្ឌិត វិស្វករ គ្រូពេទ្យ ក៏ត្រូវនាំយកទៅរៀនសូត្រដែរ ។ គោលការណ៍បញ្ជូនមនុស្សទៅរៀនសូត្រ នេះបានអនុវត្តតាំងពីដំណាក់កាលដំបូងនៃការជម្លៀស ដែលជាស្ថានភាពដ៏លំបាកវេទនាសម្រាប់ប្រជាជនខ្មែរ និងមានមនុស្សជាច្រើនបានស្លាប់ ។ ចៅក្រមបានបន្តសំណួរដើម្បីឲ្យសាក្សីផ្តល់នូវការយល់ឃើញខ្លះៗទាក់ទងនឹង ខៀវ សំផន ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ខៀវ សំផន បានទទួលការគោរពយ៉ាងទូលំទូលាយពីប្រជាជន និងបានទទួលស្គាល់ថាជាមនុស្សមានភាពស្មោះត្រង់ ។ ភាពលេចធ្លោរបស់ ខៀវ សំផន បានកើតឡើងខណៈដែលសម្តេច ព្រះនរោត្តម សីហនុ ធ្វើជាប្រធានចលនាតស៊ូ ។ ខៀវ សំផន គោរពចំពោះមាគ៌ាបក្សកុម្មុយនីស្តកន្លងមក ហើយ ខៀវ សំផន ក៏បានលើកឡើងថា «យើងពុំអាចជំទាស់អំពីគោលនយោបាយ ដែលថ្នាក់ដឹកនាំដាក់ចុះមកបានទេ ដោយសារវាប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត ។ ចំណុចមួយស្តីអំពីការជម្លៀសនេះ ហ៊ូ យន់ បានលើកឡើងថា អ្វីដែលគណៈអចិន្ត្រៃយ៍ធ្វើនេះគឺខុសទាំងស្រុង ។ ហ៊ូ យន់ ដែលជាថ្នាក់ដឹកនាំជាន់ខ្ពស់ ធ្លាប់រៀនសូត្រជាមួយ ប៉ុល ពត នៅទីក្រុងប៉ារីស ហើយដែល ប៉ុល ពត ចាត់ទុកជាមនុស្សគួរឲ្យគោរព ប៉ុន្តែបែរជាត្រូវប្រហារជីវិតចោលនៅពេលប៉ុន្មានខែក្រោយក្នុងកាលៈទេសៈគួរឲ្យចម្លែក» ។ សាក្សីបានបន្តថា នៅពេល ខៀវ សំផន គ្រប់គ្រងកាសែត ខៀវ សំផន បានសរសេរអត្ថបទរិះគន់ដល់សម្តេច ព្រះនរោត្តម សីហនុ ហើយក្រោយមកមានប៉ូលិសចាប់សម្រាតខោអាវរបស់គាត់ ដែលធ្វើឲ្យ ខៀវ សំផន ខ្មាស់គេ ប៉ុន្តែ ខៀវ សំផន មិនបានបញ្ឈប់ការងារនោះទេ ហើយវាធ្វើឲ្យគាត់កាន់តែក្លាយជាមនុស្សគួរឲ្យចាប់អារម្មណ៍ថែមទៀត ។

អង្គជំនុំជម្រះបានបន្តសំណួរទាក់ទងនឹងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ។ សាក្សីបានពន្យល់ថា លក្ខន្តិកៈគឺគ្រាន់តែជាទ្រឹស្តី ប៉ុន្តែពុំមាននៅក្នុងការពិតទេ ។ នៅសម័យនោះ គណៈអចិន្ត្រៃយ៍ ជាអ្នកធ្វើការងារជាប្រចាំពុំមែនរដ្ឋសភាទេ ។ សាក្សីបានបន្តទៀតថា មន្ទីរស-២១ ជាគណៈកម្មាធិការខាងសន្តិសុខ ដែលមានសមាជិកមួយក្រុមតូច ហើយយើងឃើញថាចំនួនសមាជិកមានការកើនឡើងនៅពេល នួន ជា, ប៉ុល ពត និង សុន សេន ជាអ្នកគ្រប់គ្រងពុំមែនស្ថិតក្រោមគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នោះទេ ។ អង្គជំនុំជម្រះបានសួរសាក្សីពីទំនាក់ទំនងរវាង នួន ជា និង ខៀវ សំផន ។ សាក្សីបានរៀបរាប់ថា អ្វីដែល

ខ្លួនអាចនិយាយបាន គឺមានភស្តុតាងបង្ហាញថា ប៉ុល ពត គោរព ដល់ ខៀវ សំផន ប៉ុន្តែ សាក្សីពុំមានឯកសារណាមួយទេក្រៅពី ដឹងថា នួន ជា ត្រូវបានគាត់ទុកថាជាមនុស្សម្នាក់ពិសេស ។ ទោះជា យ៉ាងណា សាក្សីពុំមានយោបល់ចំពោះទំនាក់ទំនងរវាង នួន ជា និង ខៀវ សំផន ទេ ។ សាក្សី ក៏ពុំអាចបញ្ចេញយោបល់ណាមួយ ទាក់ទងនឹងតួនាទីផ្នែកយោធារបស់ នួន ជា បានឡើយ នៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែនៅក្រោយឆ្នាំ១៩៧៩ សាក្សី បានដឹងថា នួន ជា បានចេញសេចក្តីសម្រេចទាក់ទងនឹងយោធា ។

សាក្សីបានបំភ្លឺជូនអង្គជំនុំជម្រះថា ខៀវ សំផន ពេលនោះ មានទំនាក់ទំនងតិចតួចណាស់ ជាមួយសម្តេច ព្រះនរោត្តម សីហនុ ហើយការទាក់ទងជាមួយព្រះអង្គធ្វើតាមរយៈ អៀង សារី ។ ចៅក្រម ឡាវ៉ឺញ បានសួរបញ្ជាក់ពីតួនាទីជាឧបនាយករដ្ឋមន្ត្រី របស់ ខៀវ សំផន ដែលការពិភាក្សាអំពីតំណែងនេះ បានធ្វើ ឡើងនៅទីក្រុងប៉េកាំងរវាង ប៉ុល ពត,សម្តេច ព្រះនរោត្តម សីហនុ និង ជូ អេនឡាយ ។ សាក្សីជឿថា ខៀវ សំផន ពុំមានវត្តមាន នៅក្នុងការពិភាក្សានោះទេ ។ លោក ស្វេត គិតថា ប៉ុល ពត ទុកចិត្ត ខៀវ សំផន ណាស់ដោយសារ ខៀវ សំផន មានភាពស្មោះត្រង់ ចំពោះបុព្វហេតុ និងអនុវត្តបញ្ជា ។ តាមគំនិតរបស់សាក្សី តំណែង ជាឧបនាយករដ្ឋមន្ត្រី ពុំមែនជាតំណែងយុទ្ធសាស្រ្តនោះទេ ប៉ុន្តែ គ្រាន់តែជាតំណែង និមិត្តរូបប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ លោក ស្វេត បានបន្ថែមថា នៅក្នុងរូបភាពប្រគល់តំណែង នេះ គឺអាចទៅរួចថាជាយុទ្ធសាស្រ្តចំពោះសាធារណៈជន ដោយសារ ខៀវ សំផន ជាមនុស្សដែលមានភាពស្មោះត្រង់ ប៉ុន្តែ បើគិតអំពី ផ្នែកឥទ្ធិពលពីសំណាក់អ្នកដឹកនាំវិញ តំណែងនេះ ពុំមានប្រ-យោជន៍អ្វីទាល់តែសោះ ។ សាក្សីបានបញ្ចេញយោបល់ចំពោះ អត្តចរិករបស់ ខៀវ សំផន ថា ជាមនុស្សសុខចិត្តធ្វើជាអ្នកអនុវត្ត ជាជាងអ្នកដឹកនាំ និងជាមនុស្សស្រួលបត់បែនជាទីបំផុត ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាជាតិ វេង ហ៊ត់ បានចាប់ផ្តើម សំណួរទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងមនោគមវិជ្ជារបស់បក្សនេះ ។ ព្រះរាជអាជ្ញា បានលើកយក អត្ថន័យសៀវភៅ ដែលនិពន្ធដោយសាក្សីឈ្មោះ "ប៉ុល ពត ៖ ប្រវត្តិសុបិន្តអាក្រក់នៃប្រទេសកម្ពុជា" ដើម្បីឲ្យសាក្សីបញ្ចេញ យោបល់មួយចំនួន ។ ដំបូង លោក វេង ហ៊ត់ បានលើកយកពាក្យ "បដិវត្តដាច់ខាតបំផុតនៅក្នុងលោក" មកពិភាក្សា ។ ជាការឆ្លើយ តបសំណួរ សាក្សីបានបញ្ជាក់ថា បក្សកុម្មុយនីស្តនៅប្រទេសណា ក៏ដោយ ដូចជា ប្រទេសកូរ៉េខាងជើង ចិន ឬប្លុកសូវៀត មាន បំណងចង់ធ្វើដំណើរឲ្យបានឆាប់រហ័ស និងឈានទៅដល់រដ្ឋកុម្មុយ នីស្តដូចដែលលោក កាល់ម៉ាក្ស បានកំណត់ថា រដ្ឋទាំងអស់ត្រូវតែ មានសមភាពស្មើគ្នាទាំងស្រុង ។ សាក្សីបានបន្តលើកឡើងពីស្ថាន


ខៀវ សំផន កំពុងជូនដំណើរព្រះអង្គម្ចាស់ សុផានុវង្ស
អំឡុងពេលដំណើរទស្សនកិច្ចរបស់ព្រះអង្គនៅប្រទេសកម្ពុជ

ភាពនៅកម្ពុជាថា "នៅពេលដែលក្បាលម៉ាស៊ីនរដ្ឋធ្វើដំណើរ គឺចរិក លក្ខណៈកម្ពុជាប្រជាធិបតេយ្យត្រូវកម្រិតជាអប្បបរមា ដោយពុំ មានការយោគយល់ណាមួយ ចំពោះតថភាពពិត នៃសង្គមនោះ ឡើយ ទាក់ទងនឹងការបង្កើតឲ្យមានសមភាពទាំងស្រុង ស្តីពីទ្រព្យ សម្បត្តិ ។ នៅក្នុងន័យនេះ ប៉ុល ពត ដែលជាមេដឹកនាំបក្សកុម្មុយ នីស្តកម្ពុជា បានស្វែងរកហេតុផលដ៏ជ្រុលនិយមមួយ ហើយជា លទ្ធផល កម្ពុជាជួបគ្រោះមហន្តរាយយ៉ាងសម្បើមនេះ" ។ តំណាង សហព្រះរាជអាជ្ញា បានបន្តសំណួរទាក់ទងនឹងសេចក្តីសម្រេច របស់បក្សនៅខែឧសភា ឆ្នាំ១៩៧៥ ស្តីពីគោលដៅស្របច្បាប់

និងចាំបាច់នៅក្នុងការកម្មេចអ្វី ដែលនៅក្រោមបដិវត្ត ថាតើសេចក្តីសម្រេចនេះពាក់ព័ន្ធទៅនឹងទំនាក់ទំនងបក្សកុម្មុយនីស្តកម្ពុជា និងរណសិរ្សសម្ព័ន្ធមិត្តមុនៗយ៉ាងណាខ្លះ? សាក្សីបានជម្រាបថា សេចក្តីសម្រេចនៅក្នុងខែឧសភា មានន័យថា រណសិរ្សលែងមានសារប្រយោជន៍ជាចាំបាច់តទៅទៀតហើយ ។ សេចក្តីសម្រេចនោះ និយាយអំពីការចាត់ចែងរបៀបគ្រប់គ្រងបក្សកុម្មុយនីស្ដជាមួយរណសិរ្ស និងរបៀបបញ្ចប់បក្សកុម្មុយនីស្តវិញ ដូចដែលបានចាប់ផ្តើមនៅឆ្នាំ១៩៧៦ អំពីប្រព័ន្ធកម្ពុជាប្រជាធិបតេយ្យដ៏



…ះ របស់ប្រទេសឡាវ នៅព្រលានយន្តហោះពោធិ៍ចិនតុង
…ក្នុងរបបខ្មែរក្រហម (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

បរិសុទ្ធនេះ ។ សាក្សីបានបន្តទៀតថា « ជាការពិតអតីតសម្ព័ន្ធមិត្តគឺអ្នកសមាសភាពដែលមិនមែនកុម្មុយនីស្តដូចជារណៈសិរ្ស ។ សេចក្តីសម្រេចក្នុងខែឧសភា ផលវិបាកនៃសេចក្តីសម្រេចនេះគឺថាទំនាក់ទំនងនោះ មិនគួរបន្តទៀតដូចដែលមានពីមុនទេ ត្រូវតែផ្លាស់ប្តូរ ដោយអំណាចទាំងអស់ស្ថិតនៅក្នុងដៃរបស់សមាជិកស្នូលនៃបក្សកុម្មុយនីស្តកម្ពុជា ។ បញ្ហានេះ ត្រូវតែដោះស្រាយជាមួយរណសិរ្ស ដោយសារតែរណសិរ្សជាសមាសធាតុមិនមែនជាកុម្មុយនីស្ត ។ នេះជាសេចក្តីសម្រេចដើម្បីបង្កើតនូវរដ្ឋធម្មនុញ្ញដើម្បីប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញថ្មី ហើយលទ្ធភាពនៃរដ្ឋធម្មនុញ្ញនេះនាំឲ្យសម្តេច សីហនុ លាលែង ព្រះអង្គបញ្ចប់សមាសធាតុរណសិរ្ស ។ នេះជាអ្វីដែលកើតឡើងក្រោយសេចក្តីសម្រេចក្នុងខែឧសភា» ទាក់ទងអំពីភាពជាឯកជន សាក្សីបានបំភ្លឺថា ទម្រង់មួយពាក់ព័ន្ធនឹងទ្រព្យសម្បត្តិឯកជន ជាគំនិតខុសពីគំនិតរបស់អង្គការនិងបដិវត្តន៍ ។ ទ្រព្យសម្បត្តិឯកជនទោះបីជាខាងផ្នែកបញ្ញាស្មារតីក្តី ជាសម្ភារក្តី ជាទំនាស់មួយដ៏ខ្លាំងក្លា ដែលកើតចេញពីអ្នកនៅខាងក្រោមបដិវត្តន៍ ជាជាងអ្នកនៅខាងក្នុងបដិវត្ត ។ ដូច្នេះ បញ្ហាទាំងឡាយណា ដែលបង្ហាញឲ្យឃើញពីទស្សនៈទាក់ទងនឹងទ្រព្យសម្បត្តិឯកជន ឬទស្សនៈឯកជន ដែលបក្សចាត់ទុកថាជាការជំទាស់នឹងបដិវត្តន៍ ទោះបីជាកើតឡើងនៅថ្នាក់ខ្ពស់ក្តី នៅក្នុងស្រទាប់ប្រជាជនសាមញ្ញក្តី មិនត្រូវបានអនុញ្ញាតឡើយ ។ ដូច្នេះ អ្នកដែលមានទស្សនៈផ្សេង ទស្សនៈឯកជនដែលប្រឆាំងនឹងទស្សនៈសមូហភាពអាចប្រឈមនឹងការកម្មេច ។ មិនខុសពីការឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ សាក្សីនៅតែរក្សាចម្លើយដដែលតបនឹងតំណាងសហព្រះរាជអាជ្ញាថា ខ្លួនបានពិនិត្យឃើញមានការលុបបំបាត់ចោលនូវរចនាសម្ព័ន្ធតុលាការ ដែលនេះជាតថភាពមួយទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយហេតុថា គោលបំណងតែមួយគត់របស់តុលាការ គឺការវិនិច្ឆ័យក្តីដោយឯករាជ្យ ។ ដូច្នេះ ពុំចាំបាច់មានតុលាការទេ គំនិតឯករាជ្យគឺចេញពីបក្ស ហើយបក្សខ្លួនឯងជាអ្នកចេញសេចក្តីសម្រេច ។ បក្សចាត់ទុកតុលាការជាស្ថាប័នគ្មានសារសំខាន់សម្រាប់បក្សកុម្មុយនីស្តកម្ពុជា ។ សាក្សីបានបន្តទៀតថា វាជាការលំបាកណាស់ក្នុងការស្វែងរកពាក្យ«យុត្តិធម៌»នៅក្នុងសម័យនោះ ។ យើងឃើញមានការប្រើប្រាស់នូវប្រព័ន្ធមួយកាត់ទោសជាសមូហភាព ។ បុគ្គលណាដែលត្រូវសង្ស័យថាពុំមានភាពស្មោះត្រង់ បុគ្គលនោះ នឹងត្រូវកាត់ទោសនៅចំពោះមុខប្រជាជន និងប្រកាសឲ្យមេភូមិ ឬក៏សហករណ៍បានដឹងរួចបញ្ជូនដំណឹងទៅថ្នាក់ស្រុក ។ ក្នុងករណីខ្លះ នៅពេលរកឃើញថាពុំមានកំហុស អាចនឹងត្រូវដោះលែងមកវិញ ។ ប៉ុន្តែក្នុងករណី ដែលរកឃើញថាពុំអាចកែកំហុសបានភាគច្រើនត្រូវតែសម្លាប់ចោល ។ ករណីខ្លះអាចនឹងធ្វើសេចក្តីសម្រេចនៅថ្នាក់សហករណ៍ជាសមូហភាព ។ ប៉ុន្តែ ក្នុងករណីដែលបក្សចាត់ទុកថាធ្ងន់ធ្ងរ ត្រូវបញ្ជូនទៅមន្ទីរសន្តិបាល ឬ

កម្មន្ទីរស-២១ ដែលត្រូវសួរចម្លើយ និងបន្ទាប់មកប្រហារជីវិត ។ សាក្សីបានបន្ថែមទៀតថា «ខ្ញុំពិបាកនឹងជម្រាបថា នេះជាប្រព័ន្ធយុត្តិធម៌ណាស់ ។ វាគឺជាប្រព័ន្ធឆ្ពោះទៅរកការលុបបំបាត់ ឬកំកម្ទេចមនុស្សចោលទើបសមជាង ដោយសារមិនមានអ្វីអាចហៅឲ្យបានល្អជាងនេះទេ» ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ បានបន្តសំណួរពីសហភាគារបស់ខ្លួន ដោយផ្តោតសំខាន់លើការដកស្រង់យកអត្ថបទនៅក្នុងសៀវភៅនិពន្ធដោយសាក្សី ស្តីពីជនជាប់ចោទ ខៀវ សំផន ។ ព្រះរាជអាជ្ញាបានដកស្រង់ថា «ដោយមានភាពក្លាហាន ខៀវ សំផន បានដើរតាមគំរូរបស់ ហ៊ូ យន់ នៅរបបសង្គមរាស្ត្រនិយម ប៉ុន្តែគេចាត់ទុក ខៀវ សំផន ថាជាមន្ត្រីជាន់ខ្ពស់ ដែលមានជោគវាសនាល្អ បន្ទាប់មកការចាត់តាំងចេញពីគណៈក្រុងសម្ងាត់ ជាបញ្ញវន្តឲ្យទទួលបន្ទុកក្នុងការធ្វើសមានចិត្ត និងពង្រឹងជីវិតនយោបាយជាតួនាទីដែល ខៀវ សំផន ស័ក្តិសមនឹងការងារនេះ» ។ សាក្សីបានឆ្លើយតបនឹងការដកស្រង់ខាងលើថា ទំនាក់ទំនងបែបនោះ មាននៅក្នុងអំឡុងដើមឆ្នាំ១៩៦០ ។ ការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់ បានធ្វើឡើងខុសៗគ្នាតាមបណ្តាញរបស់សង្គមនីមួយៗ ដូចជារបបសង្គមរាស្ត្រនិយម និងរបបកម្ពុជាប្រជាធិបតេយ្យជាដើម ។ ដោយងាកចេញពីសំណួររបស់សហព្រះរាជអាជ្ញាបន្តិច សាក្សីបានបន្តទៀតថា ខៀវ សំផន ធ្លាប់ជាមនុស្សរឹងមាំ ហើយជាអ្នកប្រកាន់ទ្រឹស្តី ជាមនុស្សដែលធ្វើការប្រកាន់សីលធម៌ខ្ពស់ ហើយបន្តប្រកាន់នូវគោលការណ៍នេះដោយមិនចាំបាច់សួរសំណួរមកខ្លួនឯងច្រើនទេ ចំពោះអ្វីដែលគាត់ជឿជាក់ ។

សហព្រះរាជអាជ្ញាអន្តរជាតិ បានសួរទាក់ទងនឹងការសម្លាប់ជនបរទេស ដែលខ្មែរក្រហមបានចាប់ខ្លួនបន្តបន្ទាប់នៅក្នុងឆ្នាំ១៩៧០ ។ សាក្សីបានឆ្លើយថា ការចាប់ឈ្លើយសឹកបានចាប់ផ្តើមនៅខេត្តរតនៈគិរី បន្ទាប់ពីមានការបះបោរនៅសំឡូត និងមានការប្រយុទ្ធគ្នានៅខេត្តផ្សេងៗ ។ សាក្សីបានបន្តទៀតថា ព័ត៌មានដែលខ្លួនទទួលបាននៅពេលចាប់ខ្លួន ប្រសិនបើឈ្លើយសឹកគឺជាមនុស្សនៅមូលដ្ឋាន នឹងត្រូវដោះលែង ប៉ុន្តែ ប្រសិនពួកគេជាកងកម្លាំងប្រដាប់អាវុធរដ្ឋាភិបាលប្រឆាំងនឹងខ្មែរក្រហមភាគច្រើនត្រូវសម្លាប់ចោល ។

សាក្សីបានបញ្ជាក់ថា លក្ខខណ្ឌដែលមិនត្រូវជ្រើសរើសជាសមាជិកគណៈមជ្ឈិមអាចជាបុគ្គល ដែលធ្លាប់ទទួលការបណ្តុះបណ្តាលពីទីក្រុងហាណូយ ។ ព្រះរាជអាជ្ញាបានបន្តអានអត្ថបទដកស្រង់បន្ថែមទៀតថា «នៅឆ្នាំ១៩៧២ កងពលចម្បងរបស់វៀតណាមបានដកចេញពីកម្ពុជា ហើយក្រោយមកអះអាងថា ខ្មែរក្រហមបង្ខំឲ្យដកថយ» ។ ការណ៍នេះមិនពិតទេ វៀតណាមមិនសម្រេចចិត្តដកចេញដោយខ្លួនឯងទេ ដោយសារមេដឹកនាំខ្មែរជិតាស់ ពីព្រោះពួកគេត្រូវការពារក្រុងសៃហ្គន ហើយខ្មែរក្រហមយល់ថា ខ្លួនអាចគ្រប់គ្រងខ្លួនឯងបាន ។ សម្តេច ព្រះនរោត្តម សីហនុ បានជ្រាបជាមុនថា ខ្មែរក្រហមគ្រាន់តែត្រូវការព្រះអង្គដើម្បីបាំងមុខប៉ុណ្ណោះ ។ ព្រះអង្គឆ្ងល់យល់ថាប្រតិបត្តិការមកពីប៉េកាំងនោះ ជារនាំងបាំងមុខ តាមពិតព្រះអង្គពុំមានការត្រួតត្រាលើអ្វី ដែលកើតឡើងនៅកម្ពុជាទេ ។ តំណាងសហព្រះរាជអាជ្ញាបានដកស្រង់ថា «ខ្មែរក្រហមបានដឹងពីប្រជាប្រិយភាពរបស់ព្រះអង្គ ហើយបក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាក់នៅក្នុងការប្រជុំរបស់បក្ស គឺអ្នកទាំងនោះត្រូវគេថ្កោលទោសថាជាសក្តិភូមិ ។ ដូច្នេះ បក្សមិនបង្ហាញឲ្យមហាជនដឹងទេ ហើយអាចនឹងដឹងតែក្នុងជួរបក្សប៉ុណ្ណោះ» ។ សាក្សីបានជម្រាបថា ខ្មែរក្រហម និងថ្នាក់ដឹកនាំចង់ធ្វើឲ្យមានតុល្យភាពនៃរឿងពីរ ។ ទីមួយ ខ្មែរក្រហមចង់ឲ្យសម្តេច សីហនុ នៅសព្វព្រះហឫទ័យ សប្បាយរីករាយ កុំគិតឆ្ងល់យល់ពីអនាគតរបស់ព្រះអង្គ គឺថាទោះជាលំបាកយ៉ាងណាក្តី មិនពេញចិត្តយ៉ាងណាក្តី ទៅថ្ងៃអនាគត ព្រះអង្គនឹងត្រូវដឹកនាំខ្មែរក្រហម ។ម្យ៉ាងទៀត សម្តេច ព្រះនរោត្តម សីហនុ ទ្រង់មានប្រជាប្រិយភាព ចំពោះប្រជារាស្ត្រខ្មែរខ្លាំងណាស់ ។ ប៉ុន្តែហានិភ័យមួយ ដែលខ្មែរក្រហមមាននោះគឺថា ព្រះអង្គអាចនឹងយកអំណាចផ្តាច់មុខដោយការគាំទ្រពីប្រជារាស្ត្រកម្ពុជា ។

តំណាងសហព្រះរាជអាជ្ញា បានប្តូរប្រធានបទ ដោយមកពិភាក្សាពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញវិញ ។ សាក្សីបានជម្រាបថា ការទទួលបានព័ត៌មានពីប្រភពផ្សេងៗ មានលក្ខណៈស្របគ្នាថា មេដឹកនាំម្នាក់ៗ មានអំណាចក្នុងការអនុវត្តការជម្លៀសនៅតាមទីតាំងនីមួយៗក្នុងស្ថានភាពខុសៗគ្នា ។ នៅ

ភូមិភាគបូព៌ា ទំនងជាមានលក្ខណៈធូរស្រាលជាងភូមិភាគនិរតីរបស់ តាម៉ុក ។ សាក្សីបន្តថា នេះជាគំរូទាំងស្រុង ។ ភូមិភាគនីមួយៗមានគោលនយោបាយខុសគ្នាបន្តិចបន្តួច ។ បុគ្គលម្នាក់ៗជាកម្មាភិបាលជាន់ខ្ពស់ ក៏ដូចជាម្នាភិបាលយោធាថ្នាក់ក្រោមដែរមានផ្នត់គំនិតដឹកនាំ ឬក៏អនុវត្តខុសគ្នាបន្តិចបន្តួច ។ ចំណែកនៅក្នុងគោលនយោបាយវិញ គេអាចនឹងរកឃើញបន្តិចបន្តួចបាន ។ សាក្សីបានលើកឡើងអំពីការថ្លែងសុន្ទរកថារបស់ ខៀវ សំផន ស្ដីពីការជម្លៀសថា «ប្រជាជនដែលត្រូវជម្លៀសចេញ ត្រូវមកដោយដៃទទេ ។ ខៀវ សំផន បានបញ្ជាក់ថា វាមានភស្តុតាងនៃការពេញចិត្ត ហើយដោយសារតែអ្វី ដែលប្រជាជនយកមកតិចតួច គឺសម្រាប់ប្រើប្រាស់ក្នុងរយៈពេលឆាប់ ។ ដូច្នេះនៅពេលនោះមនុស្សទាំងអស់ នឹងស្មើភាពគ្នាដោយភាពអត់ដូចៗគ្នា ។ វាគឺជាវិធីសាស្ត្រមួយ ឬក៏កម្មវិធីមួយធ្វើឲ្យមនុស្សគ្មានឥវ៉ាន់ទាំងអស់គ្នាបានន័យថានៅពេលដែលយើងគ្មានទ្រព្យសម្បត្តិដូចគ្នា មនុស្សទាំងអស់នឹងស្មើគ្នាហើយ ។ ដូច្នេះការជូនដំណឹងក្នុងរយៈពេលឆាប់រហ័ស គឺប្រជាជនពុំអាចយកអ្វីជាប់ខ្លួនបានច្រើនទេ» ។

## ៤) ការសួរដេញដោលដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី បានតាំងសំណួរមួយចំនួនទាក់ទងនឹងការប្រជុំទិតៀន និងស្វ័យទិតៀន ដើម្បីឲ្យសាក្សីធ្វើការបកស្រាយ ។ សាក្សីបានជម្រាបថាតាមអ្វីដែលខ្លួនយល់ដឹង ប្រជុំទិតៀន និងស្វ័យទិតៀន កើតឡើងនៅក្នុងអង្គការចាត់តាំងជាផ្លូវការនៅក្នុងបក្សជាប្រព័ន្ធ សម្រាប់ប្រជាជនថ្មី ។ គេបញ្ចូលទៅជនបទមានវគ្គអប់រំរៀនសូត្រ ដែលជាការបណ្ដុះបណ្ដាលមនោគមន៍វិជ្ជា ឬក៏ជាការអប់រំឃោសនា ។ ប្រសិនបើនរណាបដិសេធ ឬប្រកែក ឧទាហរណ៍ ៖ មានបុគ្គលណាម្នាក់បេះផ្លែឈើដោយខ្លួនឯង ឬបុគ្គលនោះត្រូវតែចេះទិតៀនខ្លួនឯង ស្វ័យទិតៀនឲ្យបានគ្រប់គ្រាន់ ។ បើមិនដូច្នោះ អាចយកទៅដាក់គុក ឬក៏អាចនឹងសម្លាប់តែម្ដង ដោយសារតែប្រឆាំងនឹងវិន័យបក្ស ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានបញ្ជាក់ទៀតថា មនោគមន៍វិជ្ជាខ្មែរក្រហម ពិតជាមានតួនាទីសំខាន់ណាស់ ប៉ុន្តែអ្វីដែលជាបញ្ហាចំបង គឺកសិករនៅតាមមូលដ្ឋានមានភាពស្អប់ខ្ពើមអ្នកនៅទីក្រុង ហើយសាក្សីយល់ថានេះជាផលប៉ះពាល់មួយ ។ ខ្មែរក្រហមបានជ្រើសរើសយុវជន យុវនារី ទាហានក្មេងៗ ដែលចេញមកពីកសិករនៅតាមជនបទដាច់ស្រយាល និងមិនបានដឹងអំពីជីវិតរស់នៅក្នុងទីក្រុងទាល់តែសោះ ។ កសិករបដិវត្តចាត់ទុកអ្នកនៅទីក្រុងហាក់បីដូចជាជនមួយចម្លែកឃោរឃៅ ដែលត្រូវតែកម្ទេចចោល ។ មនោគមន៍វិជ្ជាខ្មែរក្រហម និងអារម្មណ៍ប្រឆាំងនឹងអ្នកទីក្រុង ហាក់ដូចជាដើរជាមួយគ្នា ។ សាក្សីបញ្ជាក់ថា នេះពុំមែនជាអ្វីចម្លែកទេសម្រាប់ប្រទេសកម្ពុជា វាកើតឡើងទូទាំងប្រវត្តិសាស្ត្រទៅហើយ ។ សាក្សីបន្ថែមថា ដោយសារមានកំហឹងនិងស្អប់ប្រជាជននៅទីក្រុង កងទ័ពខ្មែរក្រហមបានដើរលួចរបស់របរនៅពេលជម្លៀស និងធ្វើយ៉ាងណាបន្ទុំឲ្យប្រជាជនធ្វើដំណើរចេញពីទីក្រុងឲ្យបានឆាប់រហ័សបំផុត ដោយមិនគិតអំពីស្ថានភាពរបស់ប្រជាជនឡើយ បើទោះបីជាមានគក៏ ឬទារកទើបនឹងកើតក៏ដោយ ។ ករណីមួយចំនួន កងទ័ពខ្មែរក្រហមមានចិត្តអាណិតអាសូរប្រជាជនដែរ ដោយព្យាយាមជួយសម្រាលទុក្ខលំបាក ប៉ុន្តែករណីភាគច្រើន គេអនុវត្តតាមបញ្ជាក្នុងរបៀបមួយឃោរឃៅ ព្រមទាំងអាចឈានទៅដល់ការសម្លាប់ប្រជាជនណាដែលមិនធ្វើតាមបញ្ជាឲ្យបានឆាប់រហ័ស ។ អ្នកដែលចង់វិលត្រឡប់ចូលមកផ្ទះសម្បែងរបស់ខ្លួនត្រូវកងទ័ពខ្មែរក្រហមសម្លាប់ ដើម្បីគម្រាមកំហែងទៅដល់អ្នកដទៃកុំឲ្យមានការជំទាស់ ។ សាក្សី បានផ្ដល់យោបល់ចំពោះការជម្លៀសនេះថា នៅក្នុងកាលៈទេសៈធម្មតា ការជម្លៀសប្រជាជនរបៀបនេះ ត្រូវតែមានការរៀបចំប្រុងប្រយ័ត្នបំផុត ត្រូវតែមានទីកន្លែង មន្ទីរពេទ្យ ឬថ្នាំសង្កូវដើម្បីចែកជូននៅតាមផ្លូវ អាចមានមធ្យោបាយគមនាគមន៍ដឹកជញ្ជូន និងត្រូវមានអាហារសម្រាប់ផ្ដល់ឲ្យពួកគេនៅតាមផ្លូវ ។ ប៉ុន្តែការជម្លៀសនេះ ពុំមានអ្វីទាល់តែសោះ ក្រៅតែពីគោលបំណងជម្លៀសប្រជាជនឲ្យចេញពីទីក្រុងប៉ុណ្ណោះ ។ ទោះបីប្រជាជនដែលត្រូវជម្លៀសទាំងនោះមិនសប្បាយចិត្ត ក៏ខ្មែរក្រហមមិនបានពិចារណាទាល់តែសោះ ។ នេះជាចំណុចទូទៅមួយនៃការជម្លៀសប្រជាជនដោយមិនគិតអំពីការឈឺចាប់របស់មនុស្សជាតិ ។ ប្រជាជនទាំងនោះត្រូវតែដោះស្រាយ និងចាត់ចែងទៅតាមលទ្ធភាពរបស់ខ្លួនម្នាក់ៗ ។ សាក្សីបានបន្ថែមទៀតថា ប្រជា

ជននៅអ៊ឺរ៉ុបក្នុងសង្គ្រាមលោកលើកទី២ អាចទទួលបានការផ្គត់ផ្គង់អាហារក្នុងរយៈពេលខ្លី ដើម្បីព្យាយាមរកមធ្យោបាយណាមួយក្នុងការរស់រានមានជីវិត ។ មេធាវី សុវណ្ណារី បានសួរសាក្សីឲ្យបញ្ចេញយោបល់លើកម្រិតនៃការប៉ះទង្គិច ការឈឺចាប់របស់ប្រជាជនថ្មី និងប្រជាជនចាស់ ដែលកើតចេញពីមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ។ សាក្សីបានជម្រាបថា ខ្លួនពុំដឹងថាអាចនិយាយរៀបរាប់ពីការបាក់ស្បាតនេះ ដោយរបៀបណានោះទេ លុះត្រាតែអ្នកជំនាញខាងផ្នែកចិត្តសាស្ត្រ ។ ប៉ុន្តែ ជាការពិត វាជាបទពិសោធជូរចត់មួយ ។ បទពិសោធជូរចត់នេះមានពីរផ្នែក ។ ទីមួយសម្រាប់អ្នកដែលរស់នៅក្នុងបរិយាកាសតានតឹងលំបាកបែបនោះ និងទីពីរ ភាគច្រើននៃប្រជាជនកម្ពុជាដែល រស់នៅក្នុងស្ថានភាពនោះ បានដុតកំហឹងដល់បដិវត្តរបស់ខ្មែរក្រហម ។ សាក្សីក៏បានទទួលស្គាល់ថា ប្រជាជនពុំបានទទួលរបបអាហារគ្រប់គ្រាន់ទេ ។ ប្រជាជនភាគច្រើនទទួលការរឹតបន្តឹងចំពោះការអនុវត្តគោលនយោបាយខាងលើយ៉ាងតឹងរ៉ឹងបំផុតពីសំណាក់ខ្មែរក្រហម ។ ប៉ុល ពត និងថ្នាក់ដឹកនាំ ត្រូវតែទទួលខុសត្រូវ ដោយសារពួកគេអនុញ្ញាតឲ្យស្ថានភាពនេះកើតឡើង ហើយពុំបានចាត់វិធានការអ្វីដើម្បីបញ្ឈប់វា ។ សាក្សី ក៏បានបន្ថែមទៀតថា ជាការពិតប្រជាជនថ្មីដែលជាអ្នកទីក្រុងបានទទួលរបបអាហារតិចតួចបំផុត ដែលកើតឡើងយ៉ាងហោចណាស់២ឆ្នាំដំបូង បន្ទាប់មក ចាប់ពីឆ្នាំ១៩៧៨ ការបែងចែករវាងប្រជាជនថ្មី និងប្រជាជនចាស់ត្រូវបានលុបបំបាត់ចោល ។ ប៉ុន្តែ នៅដើមដំបូងប្រជាជនថ្មីមានស្ថានភាពរស់នៅពិបាកជាងប្រជាជនចាស់ ដែលវាមកពីមូលហេតុផ្សេងៗគ្នា ។ វាជាមានការដាក់ទណ្ឌកម្មដោយសារប្រជាជនថ្មីធ្លាប់រស់នៅទីក្រុងពុំធ្លាប់បានចូលរួមជាមួយបដិវត្តន៍ពីដំបូង និងម្យ៉ាងទៀត ដើម្បីជំរុញទឹកចិត្តប្រជាជនថ្មីឲ្យបង្ហាញពីភាពស្មោះត្រង់ជាមួយបដិវត្ត ។ មេធាវី បានបន្តសំណួរស្តីពីគោលនយោបាយនៃការបំបែកក្រុមគ្រួសារឲ្យនៅដាច់ដោយឡែកពីគ្នា ។ សាក្សីបានបញ្ជាក់ថា ក្រុមគ្រួសាររបស់មេដឹកនាំជាន់ខ្ពស់ទទួលបានការប្រព្រឹត្តពិសេស ។ ម្តាយរបស់ ខៀវ សំផន រស់នៅទីក្រុងភ្នំពេញ មានអ្នកជួយថែទាំ ដោយសារគាត់ចាស់ជរា ។ ប្រពន្ធ និងកូនរបស់ ខៀវ សំផន នៅភ្នំពេញ ប៉ុន្តែពួកគេមិននៅជាមួយគ្នាគ្រប់ពេលទាំងអស់ទេ ។ ម្តាយរបស់ នួន ជា តាមសាក្សីនៅទីក្រុងបាត់ដំបង បានឲ្យដឹងថាទទួលបានការយកចិត្តទុកដាក់ពិសេស ។ អ្នកដឹកនាំថ្នាក់ខ្ពស់របស់បក្ស និងសមាជិកទទួលបានការយកចិត្តទុកដាក់ពិសេស និងអាចរស់នៅជាមួយក្រុមគ្រួសារ ។ ដូច្នេះ លក្ខខណ្ឌចំពោះអ្នកកាន់អំណាច ទោះថ្នាក់មជ្ឈិម ឬថ្នាក់ក្រោមក៏ដោយ អាចរស់នៅជួបជុំគ្នា និងមានអាហារល្អប្រសើរជាងប្រជាជនធម្មតា ។

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គ្រីស្ទីន ម៉ាទីណូ បានសួរបន្តពីសហការីរបស់ខ្លួនទាក់ទងនឹងសៀវភៅរបស់សាក្សី ។ មេធាវីបានចោទសំណួរស្តីពីអវត្តមានចំពោះបទសម្ភាសន៍ជនរងគ្រោះ នៅក្នុងសៀវភៅដែលនិពន្ធដោយសាក្សី ។ សាក្សី ហ្វីលីព ស្សូត បានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនដឹងថាមានសៀវភៅជាច្រើន និយាយអំពីជនរងគ្រោះ និងមានឯកសារកត់ត្រាល្អណាស់ គឺថាពុំមានអ្វីដែលនិយាយពីផ្នត់គំនិតនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ក្នុងគោលបំណងខ្លួន សាក្សីបានសរសេរ និងសិក្សាស្រាវជ្រាវរកហេតុផលជាមូលដ្ឋានរបស់ ប៉ុល ពត និងអ្នកនៅជុំវិញមាន ខៀវ សំផន ឬ នួន ជា ថាតើមូលហេតុអ្វីទើបពួកគេធ្វើការងារនេះ ។ សាក្សីក៏បានលើកយកអ្វី ដែលជនរងគ្រោះបានសរសេរដែរ ។ មេធាវីបានសួរពីមូលហេតុដែលសាក្សីមិនអាចជួបសម្ភាសន៍ជាមួយ នួន ជា ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានជម្រាបថា ខ្លួនមានការលំបាកក្នុងការជួប ខៀវ សំផន, អៀង សារី និង នួន ជា ហើយបានព្យាយាមអស់រយៈពេល១៨ខែ ដើម្បីសុំជួប អៀង សារី និង ខៀវ សំផន។ ចំណែក នួន ជា នៅពេលនោះមិនបានអនុញ្ញាតឲ្យជួបទេ ។ ឆ្លើយតបនឹងសំណួររបស់មេធាវី សាក្សីបានបញ្ជាក់ថា ចំពោះមនុស្សដែលត្រូវដាក់ឲ្យទៅជាទាសករនៅក្នុងកម្រិតមួយ គឺថាយើងមើលថា ជាទាសករដោយសារជីវិតអ្នកទាំងនោះ ពុំមានអត្ថន័យក្នុងការរស់នៅ ។ អ្នកទាំងនោះពុំមានសិទ្ធិជ្រើសរើស មិនអាចទៅណាមកណាមិនអាចសម្រេចចិត្តថាត្រូវរស់នៅរបៀបម៉េច ឬមិនអាចសម្រេចថាត្រូវហូបអ្វី ហើយក៏ពុំអាចសម្រេចថាត្រូវរៀបការកូនឲ្យទៅអ្នកណា ។ ស្ថានភាពជាទាសករ បើយើងមើលចំណុចពិសេសរបស់កម្ពុជាប្រជាធិបតេយ្យ រដ្ឋជាទាសករនោះ អាចបញ្ជាក់បាន

អំពីអត្ថន័យរបស់របបនេះ ។

## ៥) ការសួរដេញដោលដោយមេធាវីការពារក្តី

### ក) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវី កុបប៉េ ការពារជនជាប់ចោទ នួន ជា បានចាប់ផ្តើមសំណួររបស់ខ្លួនមួយចំនួន ដើម្បី បញ្ជាក់ពីគុណវុឌ្ឍិរបស់អ្នកជំនាញ ហ្វីលីព ស្សត ឡើងវិញទាក់ទងនឹងប្រវត្តិការងារជាភ្នាក់ងារឆ្លើយឆ្លងសារព័ត៌មានបរទេស ។ សាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះថា គាត់មិនបានមកប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥ ទេ ។ សាក្សីបានរំឭកឡើងវិញអំពីការសរសេរសៀវភៅរបស់ខ្លួនថា គាត់បានចំណាយពេលធ្វើការពេញម៉ោងចាប់ពីឆ្នាំ១៩៩៩-២០០៤ ដើម្បីសរសេរសៀវភៅ ហើយលោកបានតាមដានហេតុការណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងជិតស្និតតាំងពីឆ្នាំ១៩៧០ នៅទីក្រុងប៉េកាំង ។ សាក្សីយល់ថា ប្រទេសចិនជាសម្ព័ន្ធដ៏ជិតស្និតជាមួយកម្ពុជាប្រជាធិបតេយ្យ ដូច្នេះហើយចិនជាអ្នកដឹងច្រើនអំពីអ្វីដែលកើតឡើងនៅក្នុងសម័យកាលនោះ ។ សាក្សីមកដល់ប្រទេសកម្ពុជាដំបូងនៅឆ្នាំ១៩៩១ បន្ទាប់ពីសម្តេចព្រះនរោត្តម សីហនុ យាងត្រឡប់មកពីក្រុងប៉េកាំងវិញ ។ សាក្សីបានបញ្ជាក់ថា ខ្លួនពុំចេះភាសាខ្មែរឡើយ ហើយពេលខ្លះមានការលំបាក ប៉ុន្តែនេះពុំមែនជាបញ្ហាសម្រាប់ការសម្ភាសន៍របស់លោកទេ ដោយសារ ខៀវ សំផន និង អៀង សារី អាចនិយាយភាសាបារាំងបានល្អ ។ មេធាវី កុបប៉េ បានសង្កត់ទៅលើការសួរដេញដោលទាក់ទងនឹងសៀវភៅរបស់សាក្សី ដែលមានលក្ខណៈប្លែកពីសៀវភៅរបស់លោក ប៊ែន ឃៀរនិន, ស៊ីវ ហេដឌ័រ និងដេវីដ ឆេនដល័រ ជាដើម ។ សាក្សីថា វាពុំមែនជាការលំបាកនោះទេ ។ យើងមិនចង់ឲ្យមានការខ្វែងគំនិតគ្នាក្នុងលំដាប់ជាបញ្ញវន្តនោះទេ ប៉ុន្តែទស្សនៈរបស់ ឃៀរនិន លោកពុំយល់ស្របនោះឡើយ ។ ប៉ុន្តែនៅក្នុងផ្នែកមួយចំនួនធំរបស់លោក ឆេនដល័រ បាននិយាយថា យើងមិនដឹងមានអ្វីកើតឡើង យើងមិនដឹងថា ប៉ុល ពត នៅឯណានៅពេលនោះ ហើយមិនដឹងថាគាត់ធ្វើអ្វីនោះទេ ។ សាក្សីបានបន្ថែមថា នៅក្នុងសៀវភៅរបស់គាត់វិញ សាក្សីបានជួបសម្ភាសន៍ជាមួយអតីតមេដឹកនាំខ្មែរក្រហម និងមន្ត្រីខ្មែរក្រហម ហើយចន្លោះខ្វះខាតហ្នឹងលោកបានបំពេញរួចរាល់ ។ យើងដឹងថា ប៉ុល



កងសិល្បៈខ្មែរក្រហមសម្តែងក្នុងអំឡុងដំណើរទស្សនកិច្ចរបស់គណៈប្រតិភូបរទេសនៅប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពត ជានរណា គិតអ្វី ធ្វើអ្វីនៅកន្លែងណា ។ យើងបានរកឃើញបែបនេះនៅពេលដែលយើងពិភាក្សា ។ សាក្សីបានរំឭកជូនមេធាវីទៀតថា សៀវភៅរបស់ខ្លួនពុំមែនជាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែជាជីវប្រវត្តិ និងដំណើរជីវិតរបស់ ប៉ុល ពត ។

មេធាវីបានសួរបញ្ជាក់យ៉ាងលម្អិតទៅលើអំណះអំណាងមួយចំនួន ដែលសាក្សីបានលើកឡើងនៅក្នុងសៀវភៅ ។ សាក្សីបានបញ្ជាក់ថា លោកសរសេរដោយសារផ្អែកលើបទសម្ភាសន៍ជាមួយកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាល និងអ្នកធ្លាប់មានទំនាក់ទំនងជាមួយ ប៉ុល ពត ។ សាក្សីថា តាមរយៈការយល់ឃើញផ្ទាល់ខ្លួន លោកអាចសន្និដ្ឋានថា នួន ជា ជាដៃគូរបស់ ប៉ុល ពត ឬអាចជាខ្លួនទីពីររបស់ ប៉ុល ពត ។

មេធាវី កូប៉េ បានបន្តការសួរដេញដោលទាក់ទងនឹងប្រភពនៃឯកសារ ដែលសាក្សីប្រើដើម្បីយោងដល់ការសរសេរនៅក្នុងសៀវភៅរបស់ខ្លួន ។ ចំពោះចំណុចទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅឧត្តុង្គ ក្នុងឆ្នាំ១៩៧៤ ដោយសារការអនុវត្តគោលនយោបាយរបស់បក្ស ។ សាក្សីបានបញ្ជាក់នូវប្រភពព័ត៌មានដែលខ្លួនទទួលបានពីសក្ខីកម្មរបស់ជនជាតិអាមេរិកឈ្មោះ ឌីអាក ដែលបាននិយាយយោងទៅលើសៀវភៅមួយ និងពីបុគ្គលម្នាក់ឈ្មោះ ភី ភួន ដែលបានផ្តល់ព័ត៌មានលម្អិតអំពីគោលនយោបាយក្នុងការសម្លាប់ទាហាន លន់ នល់ ដែលត្រូវបានចាប់ខ្លួន ។ លើសពីនេះ សាក្សីថា ខ្លួនបានដកស្រង់នូវប្រភពព័ត៌មានទទួលពីអ្នកភូមិទាក់ទងនឹងភាពស៊ីសង្វាក់គ្នាអំពីបញ្ហានេះ ។ ឆ្លើយតបនឹងសំណួររបស់មេធាវី សាក្សីបានជម្រាបជូនអង្គជំនុំជម្រះពាក់ព័ន្ធនឹងភាពខុសគ្នាជាមូលដ្ឋាន តាមទ្រឹស្តីមនោគមន៍វិជ្ជាកម្ពុជាប្រជាធិបតេយ្យ និងមនោគមន៍វិជ្ជាកុម្មុយនីស្តប្រទេសផ្សេង ។ សាក្សីបានជម្រាបថា ខៀវ សំផន បានពន្យល់ប្រាប់ខ្លួនថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាបញ្ហានៃការបំប្លែង ឬប្តូរចិត្តគំនិត ។ ខៀវ សំផន ថា ប៉ុល ពត និង នួន ជា មានប្រភពមកពីគហបតី ពុំមែនមកពីកសិករទេ ។ ពួកគាត់បំប្លែងខ្លួនទៅជាបដិវត្តកុម្មុយនីស្ត ដែលអ្នកផ្សេងត្រូវតែធ្វើដូចគាត់ ។ នេះជាកម្ពុជាប្រជាធិបតេយ្យ ដែលមិនមានស្តង់ដារដូចលទ្ធិកុម្មុយនីស្ត ម៉ាក្សស៊ីស នោះទេ ។ បើយើងត្រឡប់ក្រោយទៅមើលបដិវត្តបារាំងវិញ មានការផ្សាភ្ជាប់រវាងបញ្ញវន្ត កសិករ និងគហបតីរបស់បារាំង ។ បើយើងមើលម៉ូដែលរបស់ លេនីន ក៏ពុំមែនប្រាកដថា កម្ពុជាប្រជាធិបតេយ្យយកមកអនុវត្តដែរ ។

មេធាវី កុបប៉េ បានលើកយកអត្ថបទមួយនៅក្នុងសៀវភៅរបស់ ស៊ីវ ហេដឌ័រ ទាក់ទងនឹងការរៀបចំគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យថា “បន្ទាប់ពីឆ្នាំ១៩៧៥ អ្នកនាំពាក្យរបស់បក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាក់ដដែលៗថា បដិវត្តរបស់កម្ពុជា មិនមានធ្វើតាមគម្រូរបស់បរទេសណាមួយឡើយ ។ ដំហរទាំងអស់នេះ បានបញ្ជាក់អំពីគំនិតដ៏អស្ចារ្យបែបជាតិនិយមបរិសុទ្ធនិយម ហើយដែលថា គំនិតទាំងអស់នេះបានឆ្លុះបញ្ចាំងអំពីភាពច្បាស់លាស់” ។ ប៉ុន្តែ យ៉ាងណាក៏ដោយ ការសិក្សារបស់ ហេដឌ័រ បានធ្វើឲ្យយើងយល់ឃើញយ៉ាងច្បាស់ថា រយៈពេល ៤៥ឆ្នាំនៃប្រវត្តិសាស្ត្ររបស់ខ្លួន បក្សកុម្មុយនីស្តកម្ពុជា និងបក្សបន្តបន្ទាប់ធ្វើតាមគំរូរបស់វៀតណាម ទាំងកម្មវិធីពេលវេលា ក៏ដូចជាយោបល់វៀតណាមដែរ ។ មេធាវីបានបន្តដកស្រង់ទៀតថា “វាបង្កើតឲ្យមានជាមូលដ្ឋាននៃការយល់អំពីអាក្បកិរិយារបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងការអនុវត្តក៏ដូចជាការរៀបចំនូវផែនការគោលនយោបាយ ដូចដែលបានផ្តល់ដោយបក្សកុម្មុយនីស្តវៀតណាម ក៏ដូចជាបដិវត្តន៍នៅក្នុងតំបន់នានា” ។ សាក្សី ហ្វីលីព ស្ប៊ត បានឆ្លើយតបចំពោះការដកស្រង់នេះ ដោយបដិសេធថា ជាការមិនពិតទាំងស្រុងនោះទេ ។ នៅក្នុងការដកស្រង់ទីមួយនិយាយត្រឹមត្រូវ ដែលថា បក្សកុម្មុយនីស្តកម្ពុជា គឺជាបក្សកុម្មុយនីស្ត និងដឹកនាំដោយមនុស្សមួយក្រុមតូចប្រាកដមែន ។ សាក្សីបានបន្តថា ខ្លួនពុំយល់ស្របចំពោះការលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាយកលំនាំតាមបក្សកុម្មុយនីស្តវៀតណាមឡើយ ដោយសារវាឆ្លុះបញ្ចាំងពីវប្បធម៌ និងពុទ្ធសាសនា ដែលពុំអាចរកឃើញនៅប្រទេសផ្សេងក្រៅពីប្រទេសភូមា ។ សាក្សីបន្ថែមថា ជាការពិត តាមធម្មតាអាចមានគំនិតប្រហាក់ប្រហែលគ្នា ដោយសារប្រទេសទាំងពីរបានរៀនសូត្រជាមួយគ្នា ។ អ្នកបង្រៀនរបស់វៀតណាមបានជួយដល់កម្ពុជា នៅពេលដែលកម្ពុជា ចាប់ផ្តើមបក្សកុម្មុយនីស្តរបស់ខ្លួន ។ ប៉ុន្តែរហូតមកដល់សមាជនៅទសវត្សរ៍

ឆ្នាំ៦០ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើឡើងដោយពុំមានអ្នកចូលរួមពីខាងវៀតណាម ហើយក៏ពុំបានផ្តល់ព័ត៌មានទៅវៀតណាមដែរ ។ គោលនយោបាយធ្វើឡើង ដោយប្រទេសកម្ពុជានៅក្រោយឆ្នាំ១៩៧៥ មានលក្ខណៈខុសគ្នាស្រលះពីគោលនយោបាយរបស់វៀតណាម ។ សាក្សីបានបន្តទៀតថា បើនិយាយពីដំណាក់កាលមុនឆ្នាំ១៩៧៣ កម្ពុជា និងវៀតណាម មានលក្ខណៈប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែសាក្សីក៏បានកត់សម្គាល់បន្ថែមថា នៅពេលដែលនិយាយទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុង មេដឹកនាំ ចិន ម៉ៅ សេទុង និងមេដឹកនាំវៀតណាម បានពិភាក្សាដោយមានការយល់ស្របគ្នា ថាមិនអាចជម្លៀសប្រជាជនចេញពីទីក្រុងទេ ។ ផ្ទុយទៅវិញ ក្រោយមកបក្សកុម្មុយនីស្តកម្ពុជាបានធ្វើកិច្ចការនេះ ។

មេធាវីបានសួររកភស្តុតាងរឹងមាំ ដើម្បីបញ្ជាក់ថាពិតជាមានការប្រមូលផ្តុំទាហាន លន់ នល់ រួចសម្លាប់ចោលប្រាកដមែន ។ សាក្សីបានឆ្លើយតបថា ខ្លួនពុំអាចស្វែងរកឯកសារយោង ដើម្បីបង្ហាញមេធាវីបានទេ ដោយសារលោកពុំបានកត់ត្រាអំពីឯកសារនោះ ប៉ុន្តែសាក្សីផ្ទាល់បានចាំច្បាស់ថា ខ្លួនទទួលបានពីប្រភពមួយគួរឲ្យទុកចិត្ត ។ សាក្សីបានបញ្ជាក់ថា ជាគោលការណ៍អាចថាពុំមានឯកសារបញ្ជាក់ ដោយសារខ្លួនមិនបានឃើញឯកសារណាមួយ ដែលបង្គាប់បញ្ជាឲ្យទាហានខ្មែរក្រហមនៅតាមភូមិភាគនានាសម្លាប់មន្ត្រី ឬក៏ទាហាន លន់ នល់ នោះទេ ។ ក៏ប៉ុន្តែ អ្វីទាំងអស់នេះបានកើតឡើង ប្រហាក់ប្រហែលគ្នា នៅទូទាំងប្រទេសកម្ពុជាទាំងមូល ។ សាក្សីបន្តថា ដូច្នេះសាក្សីគិតថា នេះគឺជាភស្តុតាងបឋមដែលមានការយល់ដូចគ្នានៅក្នុងចំណោមទាហានទាំងអស់ ចំពោះអ្វីដែលខ្លួនត្រូវធ្វើ ។ សាក្សីថា ចំពោះឯកសារជាលាយលក្ខណ៍អក្សរ ឬបទបញ្ជាផ្ទាល់មាត់ប្រហែលជាមាន ប៉ុន្តែគ្រាន់តែខ្លួនពុំធ្លាប់បានឃើញ និងដឹង ។ អ្វីដែលសាក្សីអាចនិយាយបាន គឺថានៅគ្រប់ទីកន្លែង ហេតុការណ៍បែបនេះបានកើតឡើងដូចៗគ្នា ។ ដូច្នេះចង់បង្ហាញថា មានលក្ខណៈរួមគ្នាជាគោលនយោបាយដែលធ្វើឡើងនៅទូទាំងប្រទេស ។ សាក្សីបញ្ជាក់ទៀតថា លទ្ធភាពរបស់មេបញ្ជាការក្រុមណាមួយ ក្នុងការសម្លាប់ប្រជាជន ដោយពុំមានទទួលការណែនាំពិតជាអាចកើតមាន ។ ជាការពិត លទ្ធភាពរបស់បុគ្គលមួយ ហើយយើងមិនអាចយកការពន្យល់លក្ខណៈបុគ្គលមួយទៅគ្របដណ្តប់ទៅលើបែបបទនៃការអនុវត្តគោលនយោបាយនៅទូទាំងប្រទេស ដែលជាការយល់ឯកច្ឆន្ទក្នុងការកម្ចាត់បុកម្ទេចមន្ត្រី ទាហាន និងមន្ត្រីជាន់ខ្ពស់ លន់ នល់ នោះទេ ។

## ១) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីអន្តរជាតិ អង់តា ហ្គីសេ ការពារក្តីជនជាប់ចោទ ខៀវ សំផន បានបន្តសំណួរពីសហភាគា របស់ខ្លួនដោយបញ្ជាក់ឡើងវិញពាក់ព័ន្ធនឹងបទពិសោធរបស់សាក្សីក្នុងការនិពន្ធសៀវភៅ ស្តីពីប្រវត្តិរបស់ ប៉ុល ពត ។ សាក្សីបានបញ្ជាក់ថា នៅក្នុងការសម្ភាសន៍បុគ្គលមួយចំនួនដែលពាក់ព័ន្ធ បើទោះបីជានៅក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ មានបុគ្គលខ្លះ ដែលចូលចិត្ត ប៉ុល ពត បានផ្តល់ចម្លើយដែលមានភាពលម្អៀងក៏ដោយ បទសម្ភាសន៍ទាំងអស់មិនត្រូវបានប្រើប្រាស់ទាំងស្រុងនៅក្នុងសៀវភៅរបស់សាក្សីនោះទេ ។ ការជ្រើសរើសយកព័ត៌មានមកប្រើប្រាស់នៅក្នុងសៀវភៅរបស់សាក្សី បានធ្វើដោយមានការត្រួតពិនិត្យហ្មត់ចត់ និងវាយតម្លៃពីភាពស៊ីសង្វាក់គ្នាជាមួយឯកសារផ្សេងៗទៀត ។ មេធាវីបានសួរឡើងវិញ អំពីការប្រមូលយកនូវព័ត៌មានរបស់សាក្សីទាក់ទងនឹង ខៀវ សំផន ។ សាក្សីធ្លាប់សម្ភាសន៍ ខៀវ សំផន ដោយផ្ទាល់ប្រហែល៥ ឬ៦លើក ដោយផ្អែកលើការសិក្សាស្រាវជ្រាវអំពីប្រវត្តិ ខៀវ សំផន ជាមុននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សាក្សីក៏ធ្លាប់បានសម្ភាសន៍ សួង ស៊ីគឿន និង ពីង សាយ អំពីប្រវត្តិរបស់ ខៀវ សំផន ក៏ដូចជាធ្លាប់បានសិក្សាពីនិក្ខេបបទរបស់ ខៀវ សំផន ដែរ ។ មេធាវីបានលើកយក អត្ថបទដកស្រង់ចេញពីសៀវភៅរបស់សាក្សី ដែលសរសេរពាក់ព័ន្ធនិក្ខេបបទរបស់ ខៀវ សំផន ស្តីពីរបបស្វ័យឧបត្ថម្ភ ។ សាក្សី ហ៊ីលីព ស្សូត បានបញ្ជាក់ថា ខៀវ សំផន បានសរសេរអំពីរបបស្វ័យឧបត្ថម្ភសម្រាប់របបសង្គមរាស្ត្រនិយម ដឹកនាំដោយសម្តេច ព្រះនរោត្តម សីហនុ ប៉ុន្តែការអនុវត្តបានធ្វើដោយឧបករណ៍បច្ចេកវិទ្យាក្នុងការកសាងប្រទេស ។ ផ្ទុយទៅវិញ ការអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ធ្វើឡើងដោយប្រើកម្លាំងមនុស្ស ដែលជាកត្តាខុសប្លែកពីនិក្ខេបបទរបស់ ខៀវ សំផន ។

សាក្សីបានបញ្ជាក់ជូនអង្គជំនុំជម្រះថា នៅមុនឆ្នាំ១៩៦៧

បន្ទាប់ពី ខៀវ សំផន, ហូ យន់ និង ហ៊ូ នឹម បានចុះទៅជនបទ ខៀវ សំផន ធ្លាប់បានសរសេរកាសែតរិះគន់ដល់របបសង្គមរាស្ត្រនិយម ដែលសាក្សីយល់ថាគឺជាភាពក្លាហានបំផុត ។ លោក ស្វេត បានបន្តទៀតថា ខៀវ សំផន មានទំនាក់ទំនងជិតស្និតជាមួយ អៀង សារី ដែលជាស្ថាបនិកបក្សកុម្មុយនីស្តក្នុងអំឡុងឆ្នាំ១៩៦០ ។ មេធាវី ការពារក្តីបានលើកឡើងអំពីសក្ខីកម្មរបស់ មាស វឿន ដែលថា ខៀវ សំផន ត្រូវបានប្រកាសស្វែងរកដើម្បីកាត់ក្បាល ។ ដូច្នេះ វាបង្ហាញពីរបបហឹង្សាមួយ ។ សាក្សីបានឆ្លើយតបថា នៅក្នុងអំឡុងពេលនោះ ជាធម្មតាអ្នកដែលប្រឆាំងនឹងត្រូវចាប់ខ្លួន ។ មេធាវីបានសួរបញ្ជាក់សាក្សីទាក់ទងនឹងអត្ថចរិកមួយចំនួនរបស់ ប៉ុល ពត ដោយ ផ្អែកលើអត្ថបទសំណេររបស់អ្នកប្រវត្តិសាស្ត្រ ដេវីដ ឆេនដល័រ ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានជួប ប៉ុល ពត នៅប៉េកាំងក្នុងឆ្នាំ១៩៧៧ ឃើញថា ប៉ុល ពត គឺជាបុគ្គលប្រកបទៅដោយភាពដឹកនាំ និងមានភាពញញឹមរាក់ទាក់ ដែលធ្វើឲ្យអ្នកដទៃធ្វើតាមការណែនាំរបស់គាត់ ។ មេធាវី អង់តា ហ្គីសសេ បានតាំងសំណួរមួយចំនួនទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយដកស្រង់ចេញពីសៀវភៅរបស់សាក្សីថា “នួន ជា និង ខៀវ សំផន ទទួលបន្ទុកពិនិត្យតាមប៉ុស្តិ៍ត្រួតពិនិត្យ នៅភូមិភាគឧត្តរ និងនៅខេត្តតាកែវ” ។ លោក ស្វេត បានពន្យល់ថា ខ្លួនទទួលបានប្រភពព័ត៌មាននេះពី ភី ភួន ជាបុគ្គលដែលមានទំនាក់ទំនងជិតស្និតនឹង ប៉ុល ពត ។ សាក្សីបានបន្ថែមថា ខ្លួនក៏បានទទួលព័ត៌មានពី សួង ស៊ីគឿន និងឯកសារមួយចំនួនទៀតដែលមាននៅក្នុងបណ្ណសារដ្ឋានវៀតណាមដែរ ។ ទាក់ទងនឹងមន្ទីរ៨៧០ សាក្សីបានជម្រាប ជូនអង្គជំនុំជម្រះថា លោកពុំបានសិក្សាឲ្យស៊ីជម្រៅជាងអង្គហេតុផ្សេងៗទៀតឡើយ ដោយសារមន្ទីរនេះជាអង្គភាពសម្ងាត់មួយ ដូច្នេះពិបាកស្វែងរកឯកសារ ។ លោក ហ្វីលីព ស្វេត ជឿជាក់ថា ខៀវ សំផន ជាប្រធានមន្ទីរ៨៧០ ដែលមានតួនាទីសំខាន់ ពុំមែនមានតែឈ្មោះនោះឡើយ បើយោងលើឯកសារនៅក្នុងបណ្ណសារដ្ឋាននៅប្រទេសវៀតណាម ។ ពាក់ព័ន្ធនឹងគោលនយោបាយបង្អត់អាហារប្រជាជន សាក្សីបានបញ្ជាក់ថា ខ្មែរក្រហមពុំមាននយោបាយបង្អត់អាហារប្រជាជនឡើយ ប៉ុន្តែដោយសារកម្មាភិបាលថ្នាក់ក្រោម ដែលទទួលបន្ទុកអនុវត្តនយោបាយរបស់ថ្នាក់លើមានចំណេះដឹងទាប ដែលជាមូលហេតុនាំឲ្យមានការខុសឆ្គង ។

មេធាវីជាតិ គង់ សំអុន បានចាប់ផ្តើមសំណួរទាក់ទងនឹងឈ្មោះ ភី ភួន ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំផ្សេងៗក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥ ។ សាក្សីបានបញ្ជាក់ថា ភី ភួន ជាជនជាតិភាគតិច ដូច្នេះ ក្នុងអំឡុងពេលនោះ ភី ភួន ទទួលបានការទុកចិត្តពីថ្នាក់ដឹកនាំ ។ សាក្សីបន្តទៀតថា ទោះបីជា ភី ភួន មិនបានចូលរួមប្រជុំដោយផ្ទាល់ ប៉ុន្តែ ភី ភួន អាចស្ថិតនៅក្បែរកិច្ចប្រជុំ ដូច្នេះគាត់មានលទ្ធភាពស្តាប់ឮការប្រជុំទាំងនោះ មិនតែប៉ុណ្ណោះតួនាទីរបស់ ភី ភួន ក្នុងពេលនោះហាក់ដូចជាលេខាផ្ទាល់របស់ ប៉ុល ពត ដែរ ។ មេធាវីបានផ្តោតសំណួរមួយចំនួនទាក់ទងនឹងទំហំការងាររបស់ ខៀវ សំផន ដែលមានឋានៈជាប្រធានគណៈប្រធានរដ្ឋ ។ សាក្សីបានបញ្ជាក់ថា ខៀវ សំផន បានចូលរួមក្នុងកិច្ចប្រជុំ និងមានឯកសារជាច្រើនបញ្ជាក់ថា ខៀវ សំផន បានចូលរួមធ្វើសេចក្តីសម្រេចផ្សេងៗ ប៉ុន្តែពុំមានឯកសារណាមួយ ដែលបង្ហាញថា ខៀវ សំផន ចេញសេចក្តីសម្រេចតែឯងឡើយ ។ មេធាវីបានបន្តសំណួរដោយលើកយកឯកសារកំណត់ហេតុនៃកិច្ចប្រជុំការងារមូលដ្ឋាន នៅថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ។ របៀបវារៈនៅក្នុងកិច្ចប្រជុំនោះមានបញ្ហាបោះឆ្នោត នៅថ្ងៃ២០ ខែមីនា ឆ្នាំ១៩៧៦ និងសភាពការណ៍នៅឧត្តរ ១០៦ និង ១០៣ ។ នៅក្នុងឯកសារនោះ បានរៀបរាប់អំពីការរាយការណ៍របស់សមមិត្ត ហែម (ខៀវ សំផន) ស្តីពីគោលការណ៍បោះឆ្នោត សំណូមពរនៃការបោះឆ្នោត វិធីបោះឆ្នោត លក្ខណៈផ្សេងៗដើម្បីឈរឈ្មោះជាតំណាង និងវិធីនៃការអប់រំ និងឃោសនា ។ សាក្សីបានទទួលស្គាល់ថា យើងដឹងថា ខៀវ សំផន ទទួលខុសត្រូវលើការបោះឆ្នោត ដោយសារមានឯកសារជាច្រើននិយាយពីបញ្ហានេះ ដោយសារ ខៀវ សំផន ទទួលខុសត្រូវចំពោះទំនាក់ទំនងជាមួយសម្តេច សីហនុ អំពីការងារណៈសិរ្ស ។ សាក្សីបានបញ្ជាក់ថា ការបោះឆ្នោតគឺជាផ្នែកមួយឲ្យគេទទួលស្គាល់ការបង្កើតកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យអ្នកខាងក្រៅយល់ថា នេះជាស្ថាប័នធម្មតា ដែលជាទូទៅកើតមាននៅគ្រប់រដ្ឋ ដែលមានសភាតំណាងប្រជាជន ។

# សវនាការស្តាប់សក្ខីកម្មសាក្សី អៀង ផាន

## ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្ម អៀង ផាន អតីតប្រធានកងពលតូច ២២១ របស់របបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការសួរដេញដោលសាក្សីរូបនេះបានប្រព្រឹត្តទៅជិតមួយថ្ងៃពេញ ដោយមានប្រជាជនកម្ពុជាប្រមាណ ៤០០នាក់ មកពីខេត្តស្វាយរៀង និងកំពង់ឆ្នាំងបានចូលរួមតាមដាន ដោយផ្ទាល់នៅបន្ទប់សវនាការ ។ ដោយឡែក ជនជាប់ចោទ នួន ជា បានលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដោយសម្រេចចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ដែលត្រូវបានរៀបចំ ទុកក្នុងបន្ទប់រង់ចាំនៅក្រោមសាលសវនាការ ។



អៀង ផាន
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចំពោះមុខអ្នកចូលរួម និងភាគីនៃរឿងក្តីប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានប្រាប់ អៀង ផាន អំពីសិទ្ធិរបស់គាត់ក្នុងការបដិសេធមិនឆ្លើយតបសំណួរ ឬការស្នើឲ្យធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់បន្ទុកលើខ្លួនឯង ។ បានន័យថា តាមរយៈចម្លើយ ឬអំណះអំណាងនោះ អាចធ្វើឲ្យគាត់ទទួលរងការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ ។ បន្ថែមលើនេះ អង្គជំនុំជម្រះបានផ្តល់មេធាវីមួយរូប ឈ្មោះ ម៉ម រិទ្ធា ជូន អៀង ផាន ដើម្បីប្រឹក្សាយោបល់មុននឹងគាត់ឆ្លើយតបសំណួរណាមួយដែលអាចដាក់បន្ទុកលើខ្លួនគាត់ ។ ប៉ុន្តែ គាត់មានករណីកិច្ចឆ្លើយតបគ្រប់សំណួរទាំងអស់ដែលសួរ ដោយចៅក្រម និងភាគីផ្សេងៗ លើកលែងតែចម្លើយនៃសំណួរទាំងនោះនាំឲ្យដាក់បន្ទុកមកលើខ្លួនគាត់ប៉ុណ្ណោះ ។

ដោយសារតែសាក្សី អៀង ផាន បានបម្រើការងារជាយោធាខ្មែរក្រហមចាប់តាំងពីគាត់បានចូលរួមបដិវត្តក្នុងឆ្នាំ១៩៧០ ដូច្នេះក្នុងការសួរដេញដោលសាក្សីរូបនេះ ភាគីទាំងអស់បានផ្តោតសំខាន់អំពីការរៀបចំរចនាសម្ព័ន្ធរបស់យោធាខ្មែរក្រហម ប្រព័ន្ធទំនាក់ទំនងការងារនៅក្នុងជួរកងទ័ព ព្រមទាំងការសម្រិតសម្រាំង និងការបោសសម្អាតខ្មាំងនៅក្នុងជួរកងទ័ពខ្មែរក្រហមជាដើម ។

### ១) ប្រវត្តិសាវតាររបស់ អៀង ផាន

អៀង ផាន មានអាយុ ៦០ឆ្នាំ បច្ចុប្បន្នជាយោធារស់នៅភូមិបេង ឃុំអន្លង់វិល ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ អៀងដូ ម្តាយឈ្មោះ អួង មិត្ត ប្រពន្ធឈ្មោះ ទង់ អន មានកូនចំនួន៥នាក់ ។ ផាន បានចូលរួមជាមួយចលនាបដិវត្តខ្មែរក្រហមក្នុងឆ្នាំ១៩៧០ បន្ទាប់ពីមានការទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីអំណាច ។ គាត់ត្រូវបានដំឡើងឋានៈជាបន្តបន្ទាប់នៅក្នុងជួរយោធាខ្មែរក្រហម ដោយចាប់ផ្តើមពីប្រធានពួកដែលគ្រប់គ្រងគ្នា ៣នាក់ រហូតក្លាយទៅជាប្រធានកងពលតូចដែលត្រូវបានបញ្ជូន

ទៅប្រយុទ្ធជាមួយវៀតណាមនៅភូមិភាគបូព៌ា ។ គាត់បានបញ្ជាក់ថា មូលហេតុដែលជានះត្រូវដំឡើងយ៉ាងចាប់រហ័ស និងជាបន្តបន្ទាប់ដោយសារ ទី១) វណ្ណៈភាពល្អ ពីព្រោះខ្លួនមានវណ្ណៈជាកសិករកណ្តាលថ្នាក់ក្រោម ទី២) ខ្លួនបំពេញការងារបានល្អ និងត្រឹមត្រូវ និងទី៣) ខ្លួនមានភាពក្លាហានក្នុងការបំពេញការងារ ។

នៅមុនឆ្នាំ១៩៧៥ ដាន ធ្លាប់បានប្រយុទ្ធជាមួយទាហាន លន់ នល់ ជាច្រើនលើក ។ ក្នុងឆ្នាំ ១៩៧៣-១៩៧៤ កងទ័ពរបស់ដាន ប្រយុទ្ធជាមួយទាហាន លន់ នល់ នៅខេត្តតាកែវ កំពង់ស្ពឺ និងក្រុងព្រះសីហនុ ។ នៅឆ្នាំ១៩៧៥ ដាន បានដឹកនាំកម្លាំងពិសេសវាយឆ្មក់ចូលក្នុងទីក្រុងភ្នំពេញតាមផ្លូវពោធិ៍ចិនតុង ។ ពេលនោះគាត់ដឹកនាំទ័ពវាយចូលពីក្រោយទាហាន លន់ នល់ ហើយចូលទៅដល់ព្រលានយន្តហោះពោធិ៍ចិនតុង ។ ពេលចូលទៅដល់ព្រលានយន្តហោះ ទាហានខ្មែរក្រហមបានបាញ់រះចំឃ្លាំងគ្រាប់យន្តហោះ ហើយបានផ្ទុះមួយគ្រាប់ ដែលបណ្តាលឲ្យទាហាន លន់ នល់ មានការភ័យស្លន់ស្លោ និងសុំចុះចាញ់ ។ នៅពេលនោះក្រុមរបស់គាត់បានប្រមូលគ្រឿងសព្វាវុធ និងគ្រាប់រំសេវផ្សេងៗពីទាហាន លន់ នល់ រួចចាប់បញ្ជូនខ្លួនទាហានទាំងនោះទៅសមរភូមិក្រោយ ។ បន្ទាប់ពីវាយបែកទីក្រុងភ្នំពេញបានប៉ុន្មានខែ គាត់ត្រូវបានបញ្ជូនទៅស្រុកអង្គរបុរី ខេត្តតាកែវ ។ នៅទីនោះ ដាន មានតួនាទីជាអ្នកដឹកនាំកម្លាំងការពារព្រំដែននៅជាប់វៀតណាម និងចូលរួមបង្កបង្កើនផលជាមួយកសិករនៅក្នុងតំបន់នោះ ។ នៅចុងឆ្នាំ១៩៧៧ ដាន បានចូលរួមប្រជុំជាមួយ ឈិត ជឿន ហៅ ម៉ុក ប្រធានភូមិភាគនិរតី អំពីផែនការបង្កើន និងបញ្ជូនកងទ័ពទៅការពារព្រំដែននៅខេត្តស្វាយរៀងក្នុងភូមិភាគបូព៌ា បន្ទាប់ពីមេភូមិភាគនេះត្រូវបានចោទថាក្បត់ ។ នៅឆ្នាំ១៩៧៨ ដាន ត្រូវបានបញ្ជូនទៅភូមិភាគបូព៌ា ហើយបានដឹកនាំកម្លាំងវាយទប់ទល់ជាមួយកង-ទ័ពវៀតណាមដែលកំពុងវាយរុលចូលមកដល់ខេត្តស្វាយរៀង ។ ប៉ុន្តែក្នុងពេលនោះ កម្លាំងរបស់ខ្លួនពុំអាចទប់ទល់បានឡើយ ហើយកងទ័ពវៀតណាមបានវាយដេញជាបន្តបន្ទាប់រហូតដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួល


ព្រះសង្ឃនិមន្តចូលរួមតាមដានសវនាការនៅសាលាក្តីខ្មែរក្រហម (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

រលំនៅឆ្នាំ១៩៧៩ ដាន នៅតែបន្តដឹកនាំកម្លាំង តស៊ូប្រយុទ្ធប្រឆាំងជាមួយកម្លាំងរបស់រដ្ឋាភិបាលកម្ពុជា រហូតដល់មានការធ្វើសមាហរណកម្មនៅទសវត្សរ៍ឆ្នាំ៩០ ហើយបច្ចុប្បន្នគាត់បានបន្តបម្រើការងារជាយោធានៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ។

### ២) រចនាសម្ព័ន្ធយោធាខ្មែរក្រហម

ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា អៀងដានបញ្ជាក់ថា យោធាខ្មែរក្រហមត្រូវបានរៀបចំជា ពួក ក្រុម អនុសេនាតូច អនុសេនាធំ វរៈសេនាតូច វរៈសេនាធំ កងពលតូច និងកងពលធំ ។ ក្នុងមួយពួក មានគ្នា៣នាក់ មួយក្រុមមានគ្នា១២នាក់ មួយអនុសេនាតូចមានគ្នា៣៦នាក់ និងមួយអនុសេនាធំមានគ្នា ជាងមួយរយនាក់ ។ បីក្រុមបង្កើតបានមួយអនុសេនាតូច បីកងអនុសេនាតូចបង្កើតបានមួយកងអនុសេនាធំ បួនកងអនុសេនាធំបង្កើតបានមួយកងវរៈសេនាតូច បួនកងវរៈសេនាតូចបង្កើតបានមួយកងវរៈសេនាធំ បួនកងវរៈសេនាធំបង្កើតបានមួយកងពលតូច ហើយប្រាំកងពលតូចបង្កើតបានមួយកងពលធំ ដែលមួយកងពលតូចសម្រាប់ធ្វើអន្តរាគមន៍ និងបួនកងពលទៀតសម្រាប់ថ្មើរជើង ។ ឆ្លើយតបនឹងសំណួររបស់ មេធាវី សុន អរុណ សាក្សីបញ្ជាក់ថា ការរៀបចំរចនាសម្ព័ន្ធយោធារបស់ខ្មែរក្រហមយកលំនាំតាមប្រទេសចិន ដែលការរៀបចំនេះមានលក្ខណៈខុសគ្នាជាមួយរចនាសម្ព័ន្ធយោធារបស់របប លន់ នល់ ដែលយកគំរូតាមសហរដ្ឋអាមេរិក ។



### ៣) ប្រព័ន្ធទំនាក់ទំនងការងារ

ទាក់ទងនឹងប្រព័ន្ធទំនាក់ទំនងការងារនៅក្នុងផ្នែកយោធា អៀងដាន បានបញ្ជាក់ថា មុនឆ្នាំ១៩៧៥ ខ្លួនទទួលបញ្ជាពី សំ ប៊ិត ដែលជាប្រធានកងពលតូចលេខ២ ប្រចាំនៅភូមិភាគនិរតី ។ ជារៀងរាល់ខែ ប្រធានកងពលបានកោះហៅប្រធានកងវរៈសេនាធំទាំងអស់ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន មកប្រជុំណែនាំ និងដាក់ការងារឲ្យអនុវត្ត ។ បន្ទាប់ពីប្រជុំជាមួយប្រធានកងពលរួចហើយ ប្រធានកងវរៈសេនាធំទាំងនោះ កោះហៅអ្នកនៅក្រោមបង្គាប់របស់ខ្លួនមកប្រជុំដើម្បីដាក់ផែនការបន្ត ។ ដាន បញ្ជាក់បន្ថែមថា ពេលខ្លះខ្លួនទទួលផែនការពីថ្នាក់លើតាមរយៈសារទូរលេខដែលផ្ញើដោយ វ៉ែន និង សុន សេន ។ បន្ទាប់ពីទទួលបានសារទូរលេខទាំងនោះ គាត់កោះហៅអ្នកនៅក្រោមបង្គាប់មកប្រជុំ ដើម្បីដាក់ និងណែនាំអនុវត្តផែនការ ។ ក្នុងការប្រជុំណែនាំនេះពុំមានការចែកជាឯកសារឡើយ គ្រាន់តែណែនាំដោយផ្ទាល់មាត់ប៉ុណ្ណោះ ។ ដូច្នេះ អ្នកចូលរួមត្រូវខិតខំស្តាប់ និងកត់ត្រាដើម្បីយកទៅអនុវត្ត ។ គាត់ពន្យល់ថា មូលហេតុដែលគាត់មិនចែកជាឯកសារ ហើយត្រូវកោះប្រជុំ និងណែនាំដោយផ្ទាល់មាត់នោះ ព្រោះដើម្បីការពារកុំឲ្យមានការលួចព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យា ។

អៀង ដាន បញ្ជាក់ទៀតថា ក្នុងអំឡុងពេលដែលខ្លួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ វ៉ែន នៅភូមិភាគបូព៌ា វ៉ែន បានមកទីក្រុងភ្នំពេញជាញឹកញាប់មួយឬពីរសប្តាហ៍ម្តង ដើម្បីប្រជុំជាមួយមេដឹកនាំធំៗដូចជា ប៉ុល ពត និង សុន សេន ។ កិច្ចប្រជុំទាំងនោះភាគច្រើននិយាយអំពីសភាពការណ៍ នៅតាមព្រំដែន និងយុទ្ធសាស្ត្រដើម្បីទប់ទល់ និងវាយសម្រុកទៅលើកងទ័ពវៀតណាមវិញ ។ ពេលត្រឡប់មកវិញ វ៉ែន តែងតែកោះហៅមេបញ្ជាការ

កងពលទាំងអស់មកជួបប្រជុំ និងប្រាប់បន្តនូវអ្វីដែលគាត់បានប្រជុំជាមួយមេដឹកនាំទាំងនោះ ។

## ៤) ការប្រជុំបង្កើតកងទ័ពដើម្បីការពារនៅភូមិភាគបូព៌ា

អៀង ផាន បញ្ជាក់ថា នៅចុងឆ្នាំ១៩៧៧ ខ្លួនបានចូលរួមកិច្ចប្រជុំមួយ ដែលត្រូវបានរៀបចំ ធ្វើនៅផ្ទះ តាម៉ុក ក្នុងខេត្តតាកែវ ។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងរៀបចំកម្លាំងបន្ថែម ដើម្បីបញ្ជូនទៅការពារនៅភូមិភាគបូព៌ាប្រឆាំងនឹងការវាយរុលរបស់វៀតណាម ។ បន្ទាប់ពីមានកិច្ចប្រជុំនេះ កងវរសេនាធំរបស់ខ្លួន និងកងវរសេនាធំមួយចំនួនទៀត ត្រូវបានបញ្ជូនទៅភូមិភាគបូព៌ា ដើម្បីទៅប្រយុទ្ធជាមួយកងទ័ពវៀតណាម ។ ផាន បានបញ្ជាក់បន្ថែមថា នៅពេលកងវរសេនាធំទាំងនោះទៅដល់ខេត្តស្វាយរៀង បក្សបានរៀបចំជាកងពលធំមួយដាក់ឲ្យស្ថិតនៅក្រោមការដឹកនាំរបស់ វ៉ែន ដែលត្រូវជាកូនប្រសាររបស់ តាម៉ុក ។ នៅក្នុងកងពលធំនេះមាន៥កងពលតូច រួមមានកងពលតូច២២១ (ជាកងពលអន្តរាគមន៍ដែលដឹកនាំដោយ អៀង ផាន ផ្ទាល់) កងពលតូច៣០៧ កងពលតូច៣៤០ កងពលតូច៨០៤ ។ ទោះបីជាយ៉ាងណា កងពលទាំងនេះពុំអាចទប់ទល់បានជាមួយកងទ័ពរបស់វៀតណាមឡើយ ហើយកងទ័ពវៀតណាមបានវាយរុលមករហូតដល់ដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ ។

ឆ្លើយតបនឹងសំណួររបស់លោក សុន អរុណ ពាក់ព័ន្ធនឹងវត្តមានរបស់ ឈូក រីន (ជាសាក្សីម្នាក់ ដែលអះអាងថាខ្លួនបានដឹងអំពីកិច្ចប្រជុំនេះដែរ ហើយបានផ្តល់សក្ខីកម្មដាក់បន្ទុកលើជនជាប់ចោទ នួន ជា យ៉ាងច្រើនពាក់ព័ន្ធនឹងការសម្រេចបោសសម្អាតកម្មាភិបាលនៅភូមិភាគបូព៌ា) ផាន បញ្ជាក់ថា គាត់ពុំបានឃើញវត្តមានរបស់ ឈូក រីន នៅក្នុងកិច្ចប្រជុំនេះឡើយ ព្រោះសមាសភាពចូលរួមប្រជុំមានឋានៈចាប់ពីប្រធានកងពលឡើង ។ ដូច្នេះ ឈូក រីន ដែលមានឋានៈត្រឹមតែប្រធានកងវរសេនាធំ ពុំមានសិទ្ធិចូលរួមប្រជុំឡើយ ។ កិច្ចប្រជុំនេះត្រូវបានដឹកនាំ និងធ្វើជាអធិបតីដោយ ឈិត ជឿន ហៅ ម៉ុក ចំណែកមេដឹកនាំផ្សេងៗទៀតដូចជា ប៉ុល ពត, សុន សេន ពុំមានវត្តមាននៅក្នុងកិច្ចប្រជុំនេះឡើយ ។

## ៥) ការបោសសម្អាត និងការសម្រិតសម្រាំងនៅក្នុងជួរកងទ័ពខ្មែរក្រហម

នៅពេលតំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវន្ត សួរថា តើធ្វើដូចម្តេចទើបដឹង ឬអាចកំណត់ បានថានៅក្នុងជួរកងទ័ពខ្មែរក្រហមនៅមាន ឬអ្នកធ្លាប់មានជាប់និន្នាការ ឬមានទំនាក់ទំនងជាមួយទាហាននៃរបប លន់ នល់? អៀង ផាន បញ្ជាក់ថា ដឹងតាមរយៈការធ្វើប្រវត្តិរូប ។ ក្នុងការធ្វើប្រវត្តិរូបនេះ ពុំមានអ្នកហ៊ានកុហក ឬបន្លំបោកប្រាស់ឡើយ ព្រោះបន្ទាប់ពីធ្វើប្រវត្តិរូបរួច បក្សនឹងចាត់តាំងឲ្យអ្នកផ្សេងទៅពិនិត្យតាមដានដល់ស្រុកភូមិកំណើត ដើម្បីផ្ទៀងផ្ទាត់អំពីភាពត្រឹមត្រូវនៃប្រវត្តិរូបនោះ ។ ដាក់



តាម៉ុក (ទីពីររាប់ពីឆ្វេង) ថតជាមួយមិត្តភ័ក្រ្តជនជាតិចិននៅព្រំដែនក

ស្តែងដូចរូបគាត់ផ្ទាល់ បន្ទាប់ពីគាត់បានធ្វើប្រវត្តិរូបរួចមានអ្នកទៅពិនិត្យតាមដានដល់ភូមកំណើតរបស់ខ្លួនថែមទៀត ។ ដូច្នេះ ក្នុងការធ្វើប្រវត្តិរូបនេះ ពុំមានអ្នកហ៊ានលាក់បាំងប្រវត្តិពិតរបស់ខ្លួនឡើយ ។ ផាន អះអាងថា ការតម្រូវឲ្យធ្វើប្រវត្តិរូបជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលតម្រូវឲ្យអ្នកចូលបម្រើកងទ័ពត្រូវធ្វើប្រវត្តិរូប ។ ប្រវត្តិរូបទាំងនោះត្រូវបញ្ជូនទៅប្រធានកងពល ហើយប្រធានកងពលបញ្ជូនបន្តទៅថ្នាក់លើ ។ ផាន បានបញ្ជាក់បន្ថែមថា នៅសម័យសង្គ្រាម បុគ្គលដែលចូលរួមក្នុងចលនាបដិវត្ត ទោះបីមានប្រវត្តិរូបល្អ ឬមិនល្អ ត្រូវបានរក្សាទុកជា

កម្លាំងរបស់បក្សមួយអន្ទើសិន ។ ប៉ុន្តែរហូតដល់ ឆ្នាំ១៩៧៧ និង១៩៧៨ បក្សបានធ្វើការសម្រិតសម្រាំងបុគ្គល ដែលមានសមាសភាពមិនល្អ ឬធ្លាប់មានទំនាក់ទំនងជាមួយទាហាន លន់ នល់ ចេញពីជួរកងទ័ព ដោយបញ្ជូនបុគ្គលទាំងនោះ ទៅធ្វើការនៅតាមកសិដ្ឋានចិញ្ចឹមមាន់ ជ្រូក ដាំកប្បាស ឬវាយថ្មជាដើម ។ គួរបញ្ជាក់ថា ពាក់ព័ន្ធនឹងការសម្រិតសម្រាំងបុគ្គល ដែលមានសមាសភាពមិនល្អនៅក្នុងជួរកងទ័ពនេះ តំណាងសហព្រះរាជអាជ្ញាបានសួរផ្តោតសំខាន់ចំពោះការបោសសម្អាតយោធា និងកម្មាភិបាលនៅ



ម្ពុជា-ថៃ នាចុងទសវត្សរ៍៨០ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិភាគបូព៌ាដែលត្រូវបានធ្វើមុនពេល ផាន ដឹកនាំកម្លាំងរបស់គាត់ទៅភូមិភាគនេះ ។ ប៉ុន្តែ ផាន បានបញ្ជាក់ជាច្រើនលើកច្រើនសារថាគាត់ពុំបានដឹងអំពីការបោសសម្អាតនេះឡើយ ។

### បញ្ហាផ្សេងៗ

បន្ទាប់ពីសវនាការស្តាប់សក្ខីកម្មសាក្សី អៀង ផាន ចប់សព្វគ្រប់ អង្គជំនុំជម្រះបានផ្តល់ឱកាសជូនភាគីទាំងអស់លើកឡើងអំពីសំណើ និងជំហររបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និងភាគីផ្សេងៗទៀត ។ ចាប់ផ្តើមដំបូង លោក ពេជ អង្គ ជា សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវសំណើរបស់ខ្លួនពីរចំណុចគឺ ៖

ទី១) ស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងទុក្ខសោក ដែលជនរងគ្រោះបានទទួលរងផលប៉ះពាល់ពីអង្គហេតុទាំងមូលដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺ ពុំមែនថ្លែងត្រឹមតែផលប៉ះពាល់ និងសេចក្តីទុក្ខសោកដែលកើតចេញពីអង្គហេតុដែលត្រូវយកមកជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ប៉ុណ្ណោះទេ ដោយសុំឲ្យថ្លែងពីសេចក្តីទុក្ខសោកទាំងអស់ដែលជនរងគ្រោះបានទទួលរងនៅក្នុងរបបខ្មែរក្រហមទាំងមូល ។ ការធ្វើដូច្នេះ អាចឲ្យប្រជាជនកម្ពុជាទាំងអស់ និងសហគមន៍អន្តរជាតិបានដឹងអំពីរឿងរ៉ាវពិតដែលបានកើតនៅក្នុងរបបនេះ និងរួមចំណែកដល់ការផ្សះផ្សាជាតិ ។

ទី២) សុំអង្គជំនុំជម្រះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលទើបតែផ្តល់សក្ខីកម្ម និងធ្វើសេចក្តីថ្លែងទុក្ខរួចចេញពីសាលសវនាការសិនមុននឹងអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើអត្ថាធិប្បាយចំពោះការថ្លែងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ការធ្វើដូច្នេះដើម្បីជៀសវាងមិនឲ្យមានការប៉ះពាល់ដល់ផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ មានន័យថា បើអនុញ្ញាតឲ្យភាគីធ្វើអត្ថាធិប្បាយនៅចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ដែលទើបតែធ្វើសេចក្តីថ្លែងទុក្ខចប់នោះអាចធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីកាន់តែឈឺចាប់ខ្លាំងឡើង ។

ចំណែកតំណាងសហព្រះរាជអាជ្ញា យឹត វ៉ែន័រ ពុំបានជំទាស់ចំពោះការលើកឡើងរបស់សហ មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។ បន្ថែមលើនេះគាត់បានលើកឡើងអំពីសំណើទាំង ១០ចំណុចរបស់ខ្លួន ជូនអង្គជំនុំជម្រះដើម្បីពិចារណា និងសម្រេច ។ តំណាងសហព្រះរាជអាជ្ញាបានលើកឡើងថា ៖

ទី១) ដើមបណ្តឹងរដ្ឋប្បវេណីគប្បីតែទទួលសំណួរគ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងរឿងក្តី ។

ទី២) ដើមបណ្តឹងរដ្ឋប្បវេណីដែលមកផ្តល់សក្ខីកម្មនៅក្នុងសវនាការជាជនរងគ្រោះជាក់ស្តែង ហើយគាត់បានផ្តល់ភស្តុតាងជាក់ស្តែងតាមរយៈការថ្លែងអំពីផលប៉ះពាល់ និងការឈឺចាប់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ។

ទី៣) ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននៅក្នុងរឿងក្តី ឌុច

ជាសមាជិក ឬសាច់ញាតិរបស់ជនរងគ្រោះ ។

ទី៤) ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើសុំឲ្យមកផ្តល់សក្ខីកម្ម សុទ្ធសឹងតែជាជនរងគ្រោះ ដោយសារការជម្លៀសដោយបង្ខំ ។ ដូច្នេះ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវនឹងចំណុចស្នូលនៃអង្គហេតុដែលកំពុងជំនុំជម្រះសេចក្តី ។

ទី៥) ប្រសិនបើក្រុមមេធាវីការពារក្តីមានបំណងធ្វើអត្ថាធិប្បាយទៅលើសេចក្តីថ្លែងទុក្ខសោករបស់ ដើមបណ្តឹងរដ្ឋប្បវេណីពុំសមស្របចំពោះការអនុវត្តទៅតាមផ្លូវច្បាប់ឡើយ ។

ទី៦) សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានតម្លៃជាភស្តុតាងនៅក្នុងសំណុំរឿង ។

ចិត្តទុកដាក់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដូចដើមបណ្តឹងរដ្ឋប្បវេណីមុនៗដែរ ។

ទី១០) បញ្ហាស្រួចស្រាល់នឹងត្រូវដោះស្រាយ ហើយសហព្រះរាជអាជ្ញានឹងសួរសំណួរឲ្យបានទូលំទូលាយ ។

មេធាវីការពារក្តីជនជាប់ចោទ នួន ជា លោក វ៉ិចទ័រ កុបប៉េ បានយល់ស្របជំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា ហើយពុំបានបន្ថែមអ្វីច្រើនទៀតឡើយ ។ ដោយឡែក ក្រុមមេធាវីអន្តរជាតិ អាកទួរ វ៉ែកគែន បានលើកឡើងថា ខ្លួនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលមានការអនុវត្ត ដោយគ្រាន់តែកោះហៅមនុស្សឲ្យមកថ្លែងសេចក្តីទុក្ខសោក និងផលប៉ះពាល់ដោយពុំបាន



ខៀវ សំផន (ស្តាំ) ពេលទទួលគណៈប្រតិភូឡាវដឹកនាំដោយព្រះអង្គម្ចាស់ សុផានុវង្ស ឬព្រះអង្គម្ចាស់ក្រហមក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ អ្នកដែលចូលរួមជូនដំណើរព្រះអង្គម្ចាស់នៅព្រលានយន្តហោះមាន អៀង សារី (ខាងក្រោយ ខៀវ សំផន) និង សាឡុត បាន ហៅ សូ ហុង និងកម្មាភិបាលផ្សេងទៀត (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទី៧) ដើមបណ្តឹងរដ្ឋប្បវេណីដែលមានបំណងសួរជនជាប់ចោទ នឹងត្រូវបានស្នើឲ្យផ្តល់បញ្ជីសំណួរជាមុនសិន ។ ដូច្នេះក្នុងនាមខ្លួនជាភាគីគប្បីបានពិនិត្យសំណួរទាំងនោះដែរ ។

ទី៨) តំណាងសហព្រះរាជអាជ្ញានឹងបន្តអនុវត្តតាមនីតិវិធី និងពេលវេលាដែលអង្គជំនុំជម្រះបានសម្រេចទាក់ទងនឹងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ។

ទី៩) ទាក់ទងនឹងភារកិច្ចរបស់តុលាការក្នុងការស្វែងរកការពិត តំណាងសហព្រះរាជអាជ្ញានឹងជំរុញឲ្យតុលាការយកសួរនាំអំពីអង្គហេតុ ឬបទពិសោធដែលជននោះបានឆ្លងកាត់ ។ ដូច្នេះការធ្វើបែបនេះពុំត្រឹមត្រូវឡើយ ព្រោះអាចខុសទៅនឹងគោលការណ៍ច្បាប់ ។ មេធាវីបានបញ្ជាក់បន្ថែមថា “...នេះខ្ញុំគិតថាវាជារូបភាពនៃការផ្សះផ្សាជាតិ ចំពោះអ្នកខ្លះគេមិនគិតបែបនេះទេ ចំពោះខ្ញុំ ខ្ញុំគិតថាដូចជាមិន មានសារៈសំខាន់អីទេនៅពេលដែលយើងធ្វើសវនាការបែបនេះ យើងមិនមែនធ្វើដើម្បីភាពចាំបាច់ក្នុងការផ្សះផ្សាជាតិកម្ពុជាទេ គឺយើងធ្វើសវនាការ ដើម្បីកាត់ក្តី...” ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ព្រំ ស៊ូ

## ថ្ងៃទី២១-២២ ខែឧសភា ឆ្នាំ២០១៣

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្ម សាក្សីឈ្មោះ ព្រំ ស៊ូ ដើម្បីស្តាប់សក្ខីកម្មទាក់ទងនឹងប្រព័ន្ធទំនាក់ទំនងរដ្ឋបាលថ្នាក់មូលដ្ឋាន និងថ្នាក់មជ្ឈិមក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សី ព្រំ ស៊ូ ជាអតីតកម្មាភិបាលខ្មែរក្រហមក្នុងមន្ទីរពាណិជ្ជកម្មនៅតំបន់១០៣ ក្រោយមកតំបន់១០៣ត្រូវបានប្រែក្លាយជាតំបន់ស្វយ័ត ។ ភូមិសាស្ត្រ នៃតំបន់១០៣ គ្របដណ្តប់លើខេត្តព្រះវិហារទាំងមូល និងផ្នែកខ្លះនៃខេត្តស្ទឹងត្រែង ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់មជ្ឈិមដោយផ្ទាល់តែម្តង ។ សវនាការស្តាប់សក្ខីកម្មនេះ ធ្វើឡើងនៅពេលព្រឹក រីឯពេលរសៀល អង្គជំនុំជម្រះបានបើកសវនាការផ្សេងដាច់ដោយឡែកមួយទៀត ដើម្បីស្តាប់សក្ខីកម្មសាក្សី ហ្វីលីព ហ្វ៊ីរល្យាន-ហ្គោលប្រែស ដែលជាសាក្សីផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន តាមរយៈប្រព័ន្ធអ៊ីនធឺណែតពីប្រទេសបារាំង ។ សវនាការសួរដេញដោលសាក្សី ព្រំ ស៊ូ បានបន្តរហូតដល់ព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ ។

ក្នុងអំឡុងពេលសវនាការ សាក្សី ព្រំ ស៊ូ បានបញ្ជាក់ថា ប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញ ទៅខេត្តកំពង់ធំ បានទទួលអាហារគ្រប់គ្រាន់ដោយមានការផ្គត់ផ្គង់អង្ករ និងអំបិលពីសំណាក់មន្ទីរពាណិជ្ជកម្មតំបន់ មុនពេលអ្នកទាំងនោះត្រូវបានបញ្ជូនទៅតាមសហករណ៍ផ្សេងៗ ។ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា សាក្សី ព្រំ ស៊ូ បានអះអាងថា ខ្លួនធ្លាប់ជួបក្នុងអំឡុងពេលនៃពិធីតែងតាំង កង ចាប ឲ្យកាន់តំណែងជាប្រធានភូមិភាគថ្មី ក្រោមអធិបតីភាពរបស់ នួន ជា នៅក្នុងមន្ទីរតំបន់ក្នុងខេត្តព្រះវិហារ ។ រីឯជនជាប់ ចោទ ខៀវ សំផន ពុំធ្លាប់បានជួបដោយផ្ទាល់ទេ ប៉ុន្តែធ្លាប់ដឹងថា ខៀវ សំផន ជាបញ្ញវន្តម្នាក់មកពី ប្រទេសបារាំង ។

ជនជាប់ចោទ ខៀវ សំផន បានបង្ហាញវត្តមាននៅក្នុងសវនាការស្តាប់សក្ខីកម្មសាក្សី ព្រំ ស៊ូ ប៉ុន្តែជនជាប់ចោទ នួន ជា ពុំបានចូលរួមស្តាប់សវនាការនេះដោយផ្ទាល់ទេ ដោយសារមានបញ្ហាសុខភាពពិបាកអង្គុយ ហេតុនេះអង្គជំនុំជម្រះបានអនុញ្ញាតឲ្យ នួន ជា ចូលរួមតាមដាននីតិវិធីសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការតាមរយៈប្រព័ន្ធវីដេអូ ។

នីតិវិធីក្នុងការសួរដេញដោលសាក្សី ព្រំ ស៊ូ បានចាប់ផ្តើមដោយសហព្រះរាជអាជ្ញា បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយ គឺមេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម ។ ការសួរដេញដោលបានចំណាយពេល២ព្រឹក (ថ្ងៃទី២១ និង២២ ខែឧសភា ឆ្នាំ២០១៣) ដោយមានការចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ប្រជាជន សិស្ស និស្សិត និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អំពីកិច្ចដំណើរការនីតិវិធីប្រមាណ ៦០០នាក់មកពីរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តកណ្តាល ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ។



ព្រំ ស៊ូ
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ១) ប្រវត្តិសាវតាររបស់សាក្សី ព្រំ ស៊ូ

សាក្សី ព្រំ ស៊ូ កើតនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩៥០ នៅភូមិរលួស ឃុំស្វាយចេក ស្រុកថ្មពួក ខេត្តបាត់ដំបង ហើយសព្វថ្ងៃមានទីលំនៅខេត្តសៀមរាប ។ បច្ចុប្បន្នជាមន្ត្រីចូលនិវត្តន៍ ។ សាក្សីមានឪពុក ឈ្មោះ ឆុង ឈុន, ម្តាយឈ្មោះ ហួត មន និងមានភរិយាឈ្មោះ រីម សំអាង និងមានកូន៤នាក់ ។

## ៧) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

មុនពេលប្រគល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីចោទសំណួរលើសាក្សី អង្គជំនុំជម្រះបានជូនដំណឹងសាក្សីអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សីដែលមាននៅក្នុងអំឡុងពេលនៃសវនាការ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវ័ន្ត ត្រូវបានផ្តល់ឱកាសដើម្បីសាកសួរសាក្សី ។ ផ្តើមដំបូង សាក្សីត្រូវបានស្នើឲ្យរៀបរាប់អំពីការចូលធ្វើបដិវត្តន៍នៅមុនឆ្នាំ១៩៧៥ ដោយតំណាងសហ ព្រះរាជអាជ្ញាប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដើម្បីធ្វើការបញ្ជាក់បន្ថែម ។ សាក្សី ព្រំ ស៊ូ បានរៀបរាប់ថា នៅក្នុងឆ្នាំ១៩៧១ ខ្លួនត្រូវបានចាត់តាំងដោយអង្គការឲ្យធ្វើការឃោសនាអប់រំនៅក្នុង មូលដ្ឋាននៅស្រុករវៀង ក្នុងខេត្តព្រះវិហារ និងនៅក្នុងឃុំដាច់ស្រយាលមួយចំនួន ក្នុងខេត្តកំពង់ធំ ។ សាក្សីបានពន្យល់ថា អង្គការ សំដៅលើក្រុមដឹកនាំដែលនៅពីលើគ្រប់ខ័ណ្ឌអង្គការតំបន់១០៣ ក្នុងនោះរួមមានអង្គការមជ្ឈិម អង្គការភូមិភាគ និងអង្គការតំបន់ជាដើម ។ នៅឆ្នាំ១៩៧១ ក្នុងតំបន់១០៣មានការបង្កើតជាសហគម ក្រោយមកប្រែក្លាយជាសហករណ៍នៅក្នុងឆ្នាំ១៩៧៣ តាមបញ្ជារបស់គណៈតំបន់ដែលមានឈ្មោះ ហង្ស ជាអនុប្រធានតំបន់នៅពេលនោះ ។ សាក្សី ព្រំ ស៊ូ បានបន្ថែមថា តំបន់១០៣ ជាតំបន់ដែលគ្របដណ្តប់លើភូមិសាស្ត្រខេត្តព្រះវិហារទាំងមូល និងស្រុកមួយចំនួននៃខេត្តស្ទឹងត្រែង មានដូចជា ស្រុកថាឡាបរិវ៉ាត់ ស្រុកសៀមបូក និងស្រុកព្រះនង្គ័ល ។ តំបន់១០៣មានស្រុកសរុបទាំងអស់ចំនួន១៣ និង ជាតំបន់ស្វយ័តដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់ពីសំណាក់ថ្នាក់មជ្ឈិមតែម្តង ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហ-ព្រះរាជអាជ្ញាទាក់ទងនឹងមន្ទីរពាណិជ្ជកម្មនៃតំបន់១០៣ សាក្សី ព្រំ ស៊ូ បានបញ្ជាក់ថា នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរនេះមានភារកិច្ចទទួលខុសត្រូវលើ ការផ្គត់ផ្គង់ស្បៀងអាហារ ថ្នាំពេទ្យ និងសំលៀកបំពាក់សម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់នោះ ។ បន្ទាប់មក នៅក្នុងឆ្នាំ១៩៧៥ បន្ទាប់ពីទីក្រុងភ្នំពេញត្រូវបានខ្មែរក្រហមដណ្តើមយកបាន ប្រជាជនជាច្រើននាក់ត្រូវបានជម្លៀសមកកំពង់ធំតាមរយៈកប៉ាល់ ប៉ុន្តែខ្លួនពុំចាំអំពីកាលបរិច្ឆេទនៃការទៅដល់នៃប្រជាជនដែលត្រូវបានជម្លៀសទាំងនោះទេ ។ សាក្សី ព្រំ ស៊ូ បានបន្តថា នៅពេលមានការជម្លៀសប្រជាជនទៅខេត្តកំពង់ធំ ខ្លួនត្រូវបានចាត់តាំងមកទទួលប្រជាជនទាំងនោះដោយផ្ទាល់ ដែលមានចំនួនសរុបប្រហែលបីពាន់នាក់ ។ នៅពេលនោះខ្លួនបាននាំយកស្បៀងអាហារពីមន្ទីរពាណិជ្ជកម្មនៃតំបន់១០៣ក្នុងខេត្តព្រះវិហារ ដើម្បីផ្គត់ផ្គង់ប្រជាជនដែលទើបនឹងទៅដល់ខេត្តកំពង់ធំ ។ អាហារទាំងនោះរួមមាន អង្ករ អំបិល ជាដើម ។ បន្ទាប់មក ប្រជាជនទាំងអស់នោះត្រូវបានដឹកជញ្ជូនយកទៅតាមសហករណ៍ ។ ត្រង់ចំណុចនេះ សាក្សី ព្រំ ស៊ូ បានបង្ហាញអំពីការ



កម្មាភិបាលជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនៅព្រលានយន្តហោះទីក្រុងភ្នំ
ខៀវ សំផន, នួន ជា, អៀង សារី, វន វេត, សុន សេន, ម៉ី

យល់ឃើញផ្ទាល់ខ្លួនចំពោះមូលហេតុដែលនាំឲ្យមានការជម្លៀសប្រជាជនថា បើតាមគំនិតរបស់ខ្លួន ការជម្លៀសធ្វើឡើងដោយសារការខ្វះខាតស្បៀងអាហារ និងការភ័យខ្លាចអំពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។

ឆ្លើយតបនឹងសំណួរ ដែលសួរអំពីតួនាទីរបស់ខ្លួនក្នុងតំបន់ ១០៣ សាក្សី ព្រំ ស៊ូ បានអះអាងថា ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនមានភារកិច្ចត្រឹមតែជាអ្នកគ្រប់គ្រងឃ្លាំងប្រមូលសម្ភារ ដែលដឹកជញ្ជូនមកពីភ្នំពេញ ដើម្បីចែកចាយបន្ត

ទៅតាមស្រុកនីមួយៗ នៅក្នុងតំបន់តែប៉ុណ្ណោះ ។ អ្នកដែលទទួលបន្ទុកទាក់ទងទៅថ្នាក់មជ្ឈិមដើម្បីស្នើសុំសម្ភារ ឈ្មោះ ប៉ង់ និង ឈ្មោះ គី ។ រីឯប្រធានមន្ទីរ ពាណិជ្ជកម្មតំបន់១០៣ ឈ្មោះ កៀន ហើយឈ្មោះ រិទ្ធ ជាអនុប្រធាន ។ ចម្ងាយពីមន្ទីរពាណិជ្ជកម្មទៅមន្ទីរតំបន់ គឺប្រហែល១៥គីឡូ ។ ការប្រជុំសន្និបាតរវាងមន្ទីរទាំងពីរនេះធ្វើឡើងក្នុងអំឡុងពេលបីខែម្តង ដោយមានការចូលរួមពីគណៈស្រុក និងផ្នែកយោធាដែរ ។ ខ្លឹមសារប្រជុំនៃកិច្ចប្រជុំផ្តោតសំខាន់លើការផលិតស្រូវឲ្យបានពី៣ទៅ៧តោនក្នុងមួយហិចតា ។



ពេញ ពេលជូនដំណើរគណៈប្រតិភូចិនត្រលប់ទៅវិញ ។ ពីស្តាំទៅឆ្វេង ៖ ប្រាង, ចេន អន, អៀង ធីរិទ្ធ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

សាក្សីបានបន្ថែមថា ការិយាល័យតំបន់១០៣មួយ ត្រូវបានបង្កើតឡើងមានទីតាំងនៅទីក្រុងភ្នំពេញ នៅជិតមាត់ទន្លេ ហើយអ្នកដែលត្រូវបានបញ្ជូនទៅធ្វើការនៅការិយាល័យនោះ ក្រោយមកសុទ្ធតែត្រូវបានចាប់ខ្លួន និងសម្លាប់លើកលែងតែបងថ្លៃរបស់ ខៀវ សំផន ម្នាក់ប៉ុណ្ណោះដែលរួចរស់ជីវិត ។ បងថ្លៃរបស់ ខៀវ សំផន ដែលនៅរួចជីវិតនោះមានឈ្មោះ ឈន ត្រូវបានដោះលែងឲ្យចេញពីគុកនៅឆ្នាំ១៩៧៩ ។

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវ័ន្ត បានបញ្ចប់ការសួរដេញដោល អង្គជំនុំជម្រះប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ ដើម្បីបន្តការសួរដេញដោលសាក្សី ។

តំណាងសហព្រះរាជអាជ្ញា ឌេល លីសាក់ បានស្នើឲ្យសាក្សីធ្វើការបញ្ជាក់លម្អិតអំពីឈ្មោះ កង ចាប ហៅ សែ ថាតើឈ្មោះនេះមានតួនាទីជាអ្វី ។ សាក្សី ព្រុំ ស៊ូ បានពន្យល់រៀបរាប់ថា កង ចាប ហៅ សែ គឺជាប្រធានភូមិភាគឧត្តរថ្មី ដែលមានវិសាលភាពគ្របដណ្តប់លើតំបន់១០៣, ១០៤ និង១០៦ ដែលតំបន់ទាំងបីនេះគ្របដណ្តប់លើខេត្តសៀមរាប ខេត្តព្រះវិហារ ផ្នែកខ្លះនៃខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង ។ ការតែងតាំង កង ចាប ធ្វើជាប្រធានភូមិភាគ បានធ្វើឡើងក្រោមអធិបតីរបស់ នួន ជា ហើយនៅក្នុងពិធី តែងតាំងនេះ នួន ជា បានលើកឡើងអំពីភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ និងខ្មាំងស៊ីរូងផ្ទៃក្នុង និងបានជំរុញឲ្យអ្នកចូលរួមខិតខំបង្កបង្កើនផលពី៣ទៅ៧តោនក្នុងមួយហិចតា ដោយសារនៅតំបន់នោះផលិតស្រូវបានតិចតួចនៅឡើយ ។ សាក្សីបានបន្តថា បន្ទាប់ពីមានពិធីតែងតាំងនោះហើយ ឈ្មោះ ហង្ស និងអ្នកដទៃផ្សេងទៀតក្នុងតំបន់១០៣ ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខស-២១នៅដើមឆ្នាំ១៩៧៨ ។ បន្ទាប់ពីបញ្ជូនមកដល់ស-២១ហើយ ហង្ស បានសរសេរសំបុត្រមួយច្បាប់នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៨ ដើម្បីស្នើឲ្យអង្គការដោះលែងខ្លួន និងបញ្ជាក់ថាខ្លួនពុំមែនជាជនក្បត់ទេ ។ អត្ថន័យនៅក្នុងសំបុត្រនោះបានសរសេរថា ៖

"បង និងបក្សជាទីស្នេហា និងមេដឹកនាំជាទីស្នេហា ។ ខ្ញុំស្នើសុំឲ្យបងៗ និងបក្សជាទីស្នេហា រកយុត្តិធម៌សម្រាប់ខ្ញុំ ។ ខ្ញុំមិនដែលធ្លាប់គិត ឬក៏បន្តិចបន្តួចទាល់តែសោះថាក្បត់បក្ស ។ ខ្ញុំមិនដែលចូលរួមការពិភាក្សាជាមួយនឹងខ្សែក្បត់នោះទេ ។ បក្សបានពិនិត្យប្រវត្តិរូបរបស់ខ្ញុំ ហើយមើលឃើញថាខ្ញុំមិនមែនជាជនក្បត់នោះទេ ។ ដូច្នេះសុំឲ្យបក្សទុកជីវិតឲ្យខ្ញុំផង ។ (.....)ក្នុងអំឡុងពេលនៃការប្រជុំលើកទី១របស់ភូមិភាគ៨០១ បងទី២ បានមកធ្វើជាគណៈធិបតីប្រជុំ ។ នៅក្នុងកិច្ចប្រជុំនោះ មានការលើកឡើងអំពីការបាត់ខ្សែមួយម៉ឺនខ្សែ ដោយពេលនោះ ខ្ញុំមានការព្រួយបារម្ភណាស់ ។ ក្នុងពេលបណ្តុះបណ្តាលនោះ បងបាននិយាយ

អំពីគោលគំនិតមួយចំនួន បងបាននិយាយថា ហេតុអ្វីបានជាម៉ាស៊ីនកិនស្រូវតែងតែខូចជាញឹកញាប់ ។ ហើយនៅពេលដែលនិយាយដូច្នោះ គឺថាបងបានសំឡឹងមើលខ្ញុំ ។ ក៏ប៉ុន្តែទោះបីជាខ្ញុំមានការភ័យខ្លាចក៏ដោយ ខ្ញុំមិនដែលធ្លាប់គិតថា ខ្ញុំនឹងត្រូវបានបក្សចាប់ខ្លួនដោយចោទប្រកាន់ខ្ញុំថាក្បត់នោះទេ» ។

### ៣) ការសួរដេញដោលសាក្សីដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបានបញ្ចប់ការសាកសួរដេញដោលរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចោទសួរសាក្សី ព្រំ ស៊ូ ។ មេធាវីជាតិ នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក ពេជ អង្គ ចាប់ផ្តើមសំណួរដំបូង ផ្តោតសំខាន់លើការលើកឡើងរបស់សាក្សីទាក់ទងនឹងការជម្លៀសប្រជាជនទៅខេត្តកំពង់ធំ ថាតើប្រជាជនដែលត្រូវបានជម្លៀសទៅទីនោះ ទទួលបានអាហារហូបចុកគ្រប់គ្រាន់ដែរឬយ៉ាងណា? សាក្សី ព្រំ ស៊ូ បានបញ្ជាក់ឡើងវិញថា ប្រជាជន ដែលត្រូវជម្លៀសមានទាំង ក្មេង ចាស់ ប្រុស ស្រី ប៉ុន្តែពុំមានការខ្វះខាតអ្វីទេ ។ អ្នកទាំងនោះពុំត្រូវបានចាត់ទុកជាខ្មាំងទេ ហើយលក្ខខណ្ឌការងារក៏ដូចគ្នាទៅនឹងប្រជាជនមូលដ្ឋានដែរ ។

ឆ្លើយតបនឹងសំណួររបស់មេធាវី ពេជ អង្គ ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងតំបន់ស្វយ័ត និងគណៈមជ្ឈិម សាក្សី ព្រំ ស៊ូ ពន្យល់ថា នៅមុនពេលភូមិភាគឧត្តរថ្មីត្រូវបានបង្កើតឡើង តំបន់១០៣ និងតំបន់១០៤ ដែលស្ថិតនៅខាងឧត្តរ និងឦសាន មានដូចជា ខេត្តព្រះវិហារ ស្ទឹងត្រែង រតនគិរី ជាតំបន់ស្វយ័ត ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងគណៈមជ្ឈិម ដែលខុសពីតំបន់ផ្សេងៗទៀត ដែលចាំបាច់ត្រូវទាក់ទងទៅគណៈភូមិភាគជាមុន ទើបគណៈភូមិភាគទាក់ទងបន្តទៅគណៈមជ្ឈិម ។ ប៉ុន្តែ ក្រោយពីភូមិភាគឧត្តរថ្មីត្រូវបានបង្កើតឡើង គណៈតំបន់១០៣ត្រូវទាក់ទងទៅគណៈភូមិភាគ ដោយឈប់ទាក់ទងទៅគណៈមជ្ឈិមដោយផ្ទាល់ដូចមុនទៀតហើយ ។

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បេនី យេ បានបន្តពីសហការីរបស់ខ្លួនដើម្បីចោទ សួរសាក្សី ។ មេធាវី បេនី យេ សួរទាក់ទងនឹងប្រជាជនដែលត្រូវបានជម្លៀសទៅតំបន់ ១០៣ ក្រោយមកត្រូវបានបញ្ជូនត្រឡប់ទៅទីក្រុងភ្នំពេញវិញដែរឬយ៉ាងណា? សាក្សី ព្រំ ស៊ូ បានបញ្ជាក់នៅត្រង់ចំណុច នេះថា ប្រជាជនដែលជម្លៀសពីទីក្រុងភ្នំពេញទៅតំបន់១០៣ ពុំត្រូវបានបញ្ជូនត្រឡប់ទៅទីក្រុងភ្នំពេញវិញទេ នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែក្រោយការដួលរលំនៃរបបនេះ ប្រជាជនដែលត្រូវបានជម្លៀសទៅទីនោះទាំងអស់បានធ្វើដំណើរត្រឡប់ទៅស្រុកកំណើត និងទីក្រុងភ្នំពេញវិញ ។

ឆ្លើយតបនឹងសំណួររបស់មេធាវីពាក់ព័ន្ធនឹងការបញ្ជូននិស្សិតខ្មែរមកពីបរទេសទៅតំបន់១០៣ សាក្សី ព្រំ ស៊ូ បានបរិយាយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អនុធន និស្សិតចាំបាច់ត្រូវទៅរៀនសូត្រ នៅតាមជនបទ ដោយលត់ដំខ្លួនតាមរយៈការធ្វើស្រែចម្ការ ប៉ុន្តែក្រោយមកអ្នកខ្លះត្រូវបានបញ្ជូនត្រឡប់ទៅទីក្រុងភ្នំពេញវិញ ។

### ៤) ការសួរដេញដោលសាក្សីដោយមេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម

#### ក) មេធាវីការពារក្តី ខៀវ សំផន

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន លោក អាកទួរ វ៉េកកែន ដែលមានសញ្ជាតិបារាំង ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាជូន ដើម្បីចោទសួរសាក្សីទាក់ទងនឹងរចនាសម្ព័ន្ធគ្រប់គ្រងនៅតំបន់ ១០៣ ។ ចាប់ផ្តើមដំបូង មេធាវី វ៉េកកែន បានចោទសួរទាក់ទងនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងនៅតំបន់១០៣ និងការដាក់តំបន់នេះឲ្យស្ថិតនៅក្រោមភូមិភាគឧត្តរថ្មី ។ សាក្សី ព្រំ ស៊ូ បានបញ្ជាក់ថា ពិតជា មានការផ្លាស់ប្តូរអ្នកគ្រប់គ្រង និងមានការបង្កើតភូមិភាគឧត្តរថ្មីពិតប្រាកដមែន ។ សាក្សីបន្ថែមថា នៅពេលនោះមានការផ្លាស់ប្តូរប្រធានភូមិភាគជាញឹកញាប់ ។ ដំបូង កង ចាប ហៅ សែ ត្រូវបានតែងតាំងជាប្រធានភូមិភាគឧត្តរថ្មីមុនគេបង្អស់ បន្ទាប់មកតំណែងជាប្រធានភូមិភាគនេះត្រូវបានប្រគល់ទៅឲ្យឈ្មោះ សឿង ។ រីឯ តំណែងប្រធានតំបន់១០៣ ដែលមានឈ្មោះ តា ឃឹម ជាអ្នកកាន់កាប់ ក៏ត្រូវផ្លាស់ប្តូរទៅឲ្យឈ្មោះ ស្វាយ វឿន ជាអ្នកកាន់កាប់ជំនួសវិញ ។ គួរកត់សម្គាល់ថា ឈ្មោះ ស្វាយ វឿន នេះ ក៏ធ្លាប់បានចូល

រួមផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការពីថ្ងៃទី៣ ដល់ទី៩ ខែតុលា ឆ្នាំ២០១២ ដែរ ដោយនៅពេលនោះ ស្វាយ វឿន នេះ បានប្រើឈ្មោះដូវការថា មាស វឿន។ បន្ទាប់ពី ស្វាយ វឿន ចូលមកកាប់តំណែងនេះរួចមក ខ្លួនត្រូវបានផ្តល់ភារកិច្ចថ្មីទទួលបន្ទុកបង្កបង្កើនផលពី៣តោនទៅ៧តោន ហើយ ស្វាយ វឿន បានប្រាប់ខ្លួនឲ្យខិតខំធ្វើការ ដោយសារបុគ្គលដែលមានឈ្មោះនៅក្នុងបញ្ជីរបស់អង្គការ ត្រូវបានអង្គការលើកលែងទោសឲ្យអស់ហើយ ។ ស្វាយ វឿន បានកាន់ដំណែងជាប្រធានតំបន់១០៣ រហូតដល់ពេលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ។ សាក្សីបានបញ្ជាក់ថាមានអ្នកទោសខ្លះត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ ហើយការដោះលែងនេះធ្វើឡើងនៅមុនឆ្នាំ១៩៧៩ នៅមុនពេលវៀតណាម វាយចូលមកក្នុងប្រទេសកម្ពុជា ។ សាក្សីបានបន្តថាចំពោះការសម្រេចដោះលែងអ្នកទោសនៅពេលនោះ ខ្លួនពុំបានដឹងថា តើអង្គការជាអ្នកសម្រេចដោះលែង ឬ ស្វាយ វឿន ខ្លួនឯងផ្ទាល់ជាអ្នកបញ្ជាឲ្យដោះលែងទេ ។ ប៉ុន្តែខ្លួនពិតជាឃើញអ្នកទោសត្រូវបានដោះលែងប្រាកដមែន ។

មេធាវីជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន លោក គង់ សំអុន បានបន្តពីសហការីអន្តរជាតិរបស់ខ្លួនដើម្បីសួរដេញដោលសាក្សី ។ មេធាវី គង់ សំអុន បានបន្តសួរទាក់ទងនឹងថ្នាក់ដឹកនាំសំខាន់ៗនៅតំបន់១០៣ ដើម្បីឲ្យសាក្សីបញ្ជាក់សារជាថ្មី ។ សាក្សី ព្រុំ ស៊ូ បានពន្យល់ថា ការគ្រប់គ្រងនៅតំបន់១០៣ ត្រូវបានបែងចែកជា៣ដំណាក់កាល ។ ដំណាក់កាលទី១ តំបន់១០៣ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ម៉ាន ដែលជាប្រធានតំបន់ ។ នៅដំណាក់កាលទី២ បន្ទាប់ពី ម៉ាន ស្លាប់ទៅ ហង្ស ត្រូវបានតែងតាំងជាប្រធានតំបន់១០៣ ។ ដំណាក់កាលទី៣ បន្ទាប់ពី ហង្ស ត្រូវបានចាប់ខ្លួន ឈ្មោះ ឃឹម បានកាន់ដំណែងជាប្រធានតំបន់១០៣នេះ ។ ចុងក្រោយអង្គុស នៅមុនពេលរបបខ្មែរក្រហមដួលរលំឈ្មោះ ស្វាយ វឿន ត្រូវបានតែងតាំងឲ្យចូលកាន់ដំណែងជំនួស ឃឹម បន្ទាប់ពី ឃឹម ត្រូវបានអង្គការចាប់ខ្លួន ។

### ១) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា លោក វិចទ័រ កុបប៉េ បានចាប់ផ្តើមសំណួរដំបូង ដោយផ្តោតសំខាន់លើទំនាក់ទំនងរវាងសាក្សី និងកម្មាភិបាលនៅក្នុងតំបន់១០៣ទាំងមូល ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី ព្រុំ ស៊ូ បានរៀបរាប់ថា



ក្រុមការងារមជ្ឈមណ្ឌលឯកសារចុះផ្សព្វផ្សាយពីដំណើរការវិវត្តន៍តុលាការខ្មែរក្រហម នៅសាកលវិទ្យាល័យកម្ពុជា
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្លួនស្គាល់កម្មាភិបាលតែមួយចំនួនប៉ុណ្ណោះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងការចាប់ខ្លួនអតីតទាហាននៃរដ្ឋការ លន់ នល់ សាក្សីបញ្ជាក់ថា ទាហានរដ្ឋការ លន់ នល់ ពុំមានការចាប់ខ្លួនទេ គ្រាន់តែត្រូវបញ្ជូនទៅធ្វើការនៅតាមសហករណ៍ លើកលែងតែទាហានមួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែខ្លួនពុំបានដឹងច្បាស់លាស់នោះទេ ។

បន្ទាប់មក មេធាវី កុបប៉េ បានបន្តសួរទាក់ទងនឹងការលើកឡើងរបស់សាក្សីដែលអះអាងថា នួន ជា មានវត្តមាន និងធ្វើជាអធិបតីនៅក្នុងពិធីតែងតាំង កង ចាប ឲ្យធ្វើជាប្រធានភូមិភាគឧត្តរ ។ មេធាវី កុបប៉េ បានសួរសាក្សីថា *"តើលោកដឹងថាអ្នកដែលមកតាំងតែង កង ចាប គឺជា នួន ជា ដោយរបៀបណា? និងថាតើលោកស្គាល់ នួន ជា ចាប់តាំងពីពេលណា?"* សាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងតាមរយៈអន្តរក្សរបស់ នួន ជា ឈ្មោះ ឡេ និងឈ្មោះ សុន (ស្ត្រី) ដែលជាសមាជិកសភាប្រចាំនៅខេត្តព្រះវិហារ ប៉ុន្តែ ខ្លួនពុំធ្លាប់ជួប នួន ជា ដោយផ្ទាល់នៅមុនពេល នួន ជា មកតែងតាំង កង ចាប ទេ ។ មេធាវី កុបប៉េ បានសួរទៀតថា នៅពេលនោះ ឈ្មោះ ឡេ បានចូលប្រជុំដែរឬទេ ។ សាក្សីបានបញ្ជាក់ថា ឡេ ពុំបានចូលប្រជុំទេ ។ មេធាវីហាក់បីដូចជាចង់សួរឈ្វេចសាក្សីអំពីមូលហេតុដែលនាំឲ្យសាក្សីដឹងថា នួន ជា ជាអ្នកចូលរួមតែងតាំង កង ចាប ដោយមេធាវីសួរដេញបន្ថែមថា បើឈ្មោះ ឡេ ពុំបានចូលប្រជុំទេ ហេតុអ្វីបានជាលោកសាក្សីដឹងថាអ្នកដែលចូលរួមមកធ្វើជាអធិបតីនៅពេលនោះជា នួន ជា ។ សាក្សីបានពន្យល់អំពីមូលហេតុដែលនាំឲ្យខ្លួនស្គាល់ថា ដោយសារខ្លួនធ្លាប់ស្គាល់តាមរយៈអ្នកពីខាងក្រៅ និងតាមរយៈវិទ្យុដែលផ្សាយពីមុនថា នួន ជា ជាប្រធានសភារបស់កម្ពុជាប្រជាធិបតេយ្យ ។ មេធាវីសួរទៀតថា តើនៅក្នុងពេលប្រជុំនោះ នួន ជា បានធ្វើការណែនាំខ្លួនដែរឬទេ និងថា តើអ្នកចូលរួមនៅពេលនោះហៅ នួន ជា យ៉ាងដូចម្តេច ។ សាក្សី ព្រំ ស៊ូ បានអះអាងថា ខ្លួនពុំចាំទេ គ្រាន់តែដឹងថាអ្នកចូលរួមហៅថា បងធំទី២ ។ អ្នកដែលចូលរួមនៅក្នុងកិច្ចប្រជុំនៅពេលនោះមានប្រមាណ៥០នាក់ដូចជា នួន ជា, កង ចាប និង ហង្ស ជាដើម ។ នៅពេលនោះ ហង្ស ជាអ្នកទទួលខុសត្រូវចំពោះកិច្ចប្រជុំនោះ ។ បន្ទាប់ពីកិច្ចប្រជុំនោះ នួន ជា បានធ្វើដំណើរទស្សនកិច្ចនៅក្នុងការដ្ឋានរបស់សាក្សី ប៉ុន្តែនៅពេលនោះសាក្សីពុំបាននិយាយជាមួយ នួន ជា ដោយផ្ទាល់ទេ ព្រោះខ្លួនកំពុងនៅវាលស្រែ ។ សាក្សីបានបញ្ជាក់ថា ខ្លួនចំណាំបានអំពីសំឡេងរបស់ នួន ជា ដែលបាននិយាយទៅកាន់អ្នកចូលរួម ដែលមានសំលេងដូចជាអ្នកមកពីខេត្តបាត់ដំបង ។

ឆ្លើយតបចំពោះសំណួររបស់មេធាវី កុបប៉េ ដែលសួរអំពីការប្រជុំសម្ងាត់រវាង នួន ជា, កង ចាប, តា ឃឹម និង តា សារឿន ដែលក្រោយមកនាំឲ្យមានការចាប់ខ្លួន ហង្ស សាក្សី ព្រំ ស៊ូ បានបញ្ជាក់ថា ខ្លួនពុំបានដឹងប្រាកដទេ គ្រាន់តែជាការស្មាន និងការវិភាគផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ មេធាវីបានសួរទៀតថាតើធ្វើដូចម្តេចទើបសាក្សីដឹងថា នួន ជា ស្ថិតនៅក្នុងកិច្ចប្រជុំសម្ងាត់នោះ ។ សាក្សីបានបញ្ជាក់ថា នោះជាការស្មានរបស់ខ្លួនតែប៉ុណ្ណោះ ។ បន្ទាប់មក មេធាវី កុបប៉េ បានសួរសំណួរជាច្រើនចង់បង្ហាញថា សាក្សីលើកឡើងអំពីវត្តមានរបស់ នួន ជា នៅក្នុងកិច្ចប្រជុំតែងតាំង កង ចាប ជាការស្មាន និងវិភាគផ្ទាល់ខ្លួនរបស់សាក្សី ដែលពុំអាចយកមកធ្វើជាភស្តុតាងដើម្បីដាក់បន្ទុកលើ នួន ជា បានឡើយ ។ ប៉ុន្តែការសួរសំណួរដដែលៗរបស់មេធាវី កុបប៉េ បានធ្វើឲ្យអង្គជំនុំជម្រះស្នើឲ្យមានការផ្លាស់ប្តូរសំណួរផ្សេង ពីព្រោះសាក្សីបានបញ្ជាក់ហើយថា ការលើកឡើងអំពីវត្តមានរបស់ នួន ជា នៅក្នុងកិច្ចប្រជុំសម្ងាត់គ្រាន់ជាការស្មាន និងការវិភាគផ្ទាល់ខ្លួន ។ ដូច្នេះ មេធាវីពុំចាំបាច់សួរសំណួរដែលមានលក្ខណៈច្រំដែលលើចំណុចតែមួយនោះទេ ។ បន្ទាប់ពីការកត់សម្គាល់របស់ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន មេធាវីការពារក្តី នួន ជា បានបញ្ចប់ការសួរសំណួររបស់ខ្លួន និងលើកឡើងថា ខ្លួនមានសេចក្តីរីករាយ ដោយសារតែអង្គជំនុំជម្រះ បានទទួលស្គាល់ថា ចម្លើយរបស់សាក្សីស្តីពីកិច្ចប្រជុំសម្ងាត់ គ្រាន់តែជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់សាក្សី ។

សវនាការស្តាប់សក្ខីកម្មសាក្សី ព្រំ ស៊ូ បានបញ្ចប់នៅព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ បន្ទាប់មកនៅពេលរសៀលថ្ងៃដដែល អង្គជំនុំជម្រះបានបើកសវនាការស្តាប់សក្ខីកម្មសាក្សីមួយរូបទៀត ដែលនឹងផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ខៀវ សំផន តាមរយៈប្រព័ន្ធអ៊ីនធឺណែតពីប្រទេសបារាំង ។

# ពន្យល់ពាក្យសំខាន់

ជនរងគ្រោះ : សំដៅទៅលើរូបបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្មដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ដើមបណ្តឹងរដ្ឋប្បវេណី : សំដៅទៅលើជនរងគ្រោះដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រម ស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។

ជនជាប់ចោទ : សំដៅទៅលើបុគ្គល ដែលត្រូវចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។

ភាគី : សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

អង្គជំនុំជម្រះវិសាមញ្ញ : សំដៅទៅលើតុលាការពិសេស នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលបង្កើតឡើងដោយច្បាប់ស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុង


មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : dccam@online.com.kh

គេហទំព័រ : www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*John D. and Catherine T. MacArthur Foundation and British Embassy-Cambodia.*


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យច័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



សារមន្ទីរប្រល័យពូជសាសន៍ជើងឯក ក្នុងអំឡុងពេល
ប្រារព្ធពិធីទិវានៃការចងចាំថ្ងៃ២០ ខែឧសភា ឆ្នាំ២០១២
(រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែមិថុនា ឆ្នាំ២០១៣